រាជបណ្ឌិតសភាកម្ពុជា

ROYAL ACADEMY OF CAMBODIA

# ការអោយតំលៃខ្លួនឯងនិងគុណភាពសិក្សា

## សិក្សាករណី គរុនិស្សិតកំរិតឧត្តមផ្នែកវិទ្យាសាស្ត្រ
## និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ

SELF-ESTEEM AND STUDY QUALITY
CASE STUDY OF HIGHER EDUCATION TEACHER TRAINEES IN
SCIENCE AND MATHEMATICS AT NATIONAL INSTITUTE OF EDUCATION

សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

Thesis of Master's Degree

និស្សិត : សន ចាន់ថៃ

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី៣

មុខជំនាញ : វិទ្យាសាស្ត្រអប់រំ

សាស្ត្រាចារ្យដឹកនាំ : បណ្ឌិត អ៊ឹម ភុច

ការពារ ខែ ធ្នូ ឆ្នាំ ២០០៤

## រាជបណ្ឌិតសភាកម្ពុជា

ROYAL ACADEMY OF CAMBODIA

# ការអោយតំលៃខ្លួនឯងនិងគុណភាពសិក្សា

## សិក្សាករណី គរុនិស្សិតកំរិតឧត្តមផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ

SELF-ESTEEM AND STUDY QUALITY
CASE STUDY OF HIGHER EDUCATION TEACHER TRAINEES IN
SCIENCE AND MATHEMATICS AT NATIONAL INSTITUTE OF EDUCATION

សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

Thesis of Master's Degree

ព្រះរាជាណាចក្រកម្ពុជា
បណ្ណាល័យ
លេខ .054.07.
រាជបណ្ឌិតសភាកម្ពុជា

និស្សិត : សន ចាន់ថៃ

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី៣

មុខជំនាញ : វិទ្យាសាស្ត្រអប់រំ

គណៈមេប្រយោគ

បណ្ឌិត អ៊ឹម កុច

បណ្ឌិត នេត បារ៉ុម

បណ្ឌិត ចាន់ រដ្ឋសុធា

បណ្ឌិត នូ ចាន់សុភី

បណ្ឌិត ជេត ជាលី

ការពារ ខែ ធ្នូ ឆ្នាំ ២០០៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**រាជបណ្ឌិតសភាកម្ពុជា**

## លិខិតបញ្ជាក់

ខ្ញុំ **បណ្ឌិត អ៊ុំ ក្រុច** ជាប្រធានមុខវិជ្ជាវិទ្យាសាស្ត្រអប់រំ និងជាសាស្ត្រាចារ្យណែនាំការស្រាវជ្រាវរបស់និស្សិត **សន ចាន់ថៃ** លើប្រធានបទ "ការអោយតំលៃខ្លួនឯង និង គុណភាពសិក្សា : សិក្សាករណី គរុនិស្សិតកម្រិតឧត្តមសិក្សាផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ" សូមបញ្ជាក់ថា :

គណៈមេប្រយោគបានវាយតម្លៃលើសារណានេះក្នុងនិទ្ទេស *ល្អណាស់ និងមានលក្ខណៈវិទ្យាសាស្ត្រ* ដោយអាចយកទៅផ្សព្វផ្សាយជាសាធារណៈ ដើម្បីជាគុណប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវលើផ្នែកវិទ្យាសាស្ត្រអប់រំ ។

ខ្លួនខ្ញុំផ្ទាល់ ក្រោយពីបានពិនិត្យជាលើកចុងក្រោយលើអត្ថបទសារណា ទាំងអក្ខរាវិរុទ្ធ និង ខ្លឹមសាររួចមក ខ្ញុំមានយោបល់ស្របទៅនឹងសេចក្តីសន្និដ្ឋានរបស់គណៈមេប្រយោគ ព្រមទាំងសូមបញ្ជាក់ថា សារណានេះពិតជាមានលក្ខណៈវិទ្យាសាស្ត្រ ហើយនិស្សិត **សន ចាន់ថៃ** ពិតជាស័ក្តិសមនឹងទទួលបានសញ្ញាប័ត្របរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រអប់រំពិតប្រាកដមែន ។

ភ្នំពេញ ,ថ្ងៃទី ខែ មករា ឆ្នាំ ២០០៥

**សាស្ត្រាចារ្យណែនាំ និងជា**

**ប្រធានមុខវិជ្ជាវិទ្យាសាស្ត្រអប់រំ**

បណ្ឌិត. អ៊ុំ-ក្រុច

# ឧទ្ទិសកថា

ខ្ញុំបាទសូមឧទ្ទិសស្នាដៃនេះជូនដល់វិញ្ញាណក្ខន្ធលោកឪពុក **សូ សន** ដែលបានទទួលមរណភាពក្នុងដំណាក់កាលពាក់កណ្តាលនៃការស្រាវជ្រាវនេះ និងសូមឧទ្ទិសដល់វិញ្ញាណក្ខន្ធបុព្វបុរសខ្មែរស្នេហាជាតិដែលបានធ្វើពលិកម្ម ដើម្បីរក្សាទឹកដីកម្ពុជា សូមអោយវិញ្ញាណក្ខន្ធរបស់លោកសម្រេចបាននូវសុខតិភពកុំបីឃ្លៀងឃ្លាតប្រែទៅជាប្រការអ្វីឡើយ ហើយក៏សូមឧទ្ទិសស្នាដៃនេះអោយនៅឋិតថេរចីរកាលជារៀងរហូត ដើម្បីជាប្រយោជន៏សំរាប់អ្នកអប់រំ អ្នកស្រាវជ្រាវ និងប្រជាពលរដ្ឋខ្មែរដែលស្នេហាចំណេះដឹង ។

# សេចក្តីថ្លែងអំណរគុណ

ការស្រាវជ្រាវលើប្រធានបទ "ការអោយតំលៃខ្លួនឯង និងគុណភាពសិក្សា ករណីសិក្សា : គរុនិស្សិតកម្រិតឧត្តមផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ" ត្រូវបានទទួលការឧបត្ថម្ភ ការណែនាំ និងការទទួលបានវិភាគទានគំនិតពីសំណាក់មនុស្ស និងស្ថាប័នមួយចំនួន ដើម្បីជួយអោយស្នាដៃស្រាវជ្រាវនេះលេចចេញជារូបរាងឡើង ។ បើពុំមានជំនួយជាសម្ភារៈ ស្មារតី និងការណែនាំដ៏ថ្លៃថ្លាពីលោក លោកស្រីទាំងនោះទេ ការស្រាវជ្រាវនេះពិតជាមិនអាចចេញជាលទ្ធផលបានឡើយ ។ ដូច្នេះ ដើម្បីរំឭកដល់គុណដ៏សប្បុរសនេះ ខ្ញុំបាទ **សន ចាន់ថៃ** សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ លោក លោកស្រី ដែលបានចូលរួមចំណែកដល់ការស្រាវជ្រាវនេះ ដូចដែលមានឈ្មោះខាងក្រោម :

- លោកបណ្ឌិត **អ៊ុំ កុច** សាស្ត្រាចារ្យណែនាំ និងជាសាស្ត្រាចារ្យបង្រៀនឯកទេសវិទ្យាសាស្ត្រអប់រំ ដែលបានផ្តល់ការលើកទឹកចិត្ត និងគំនិតណែនាំល្អៗ ព្រមទាំងបានផ្តល់នូវឯកសារផ្សេងៗ ដើម្បីអោយស្នាដៃស្រាវជ្រាវនេះមានលក្ខណៈវិទ្យាសាស្ត្រ ។
- លោកបណ្ឌិត **នេត បារ៉ុម** លោកបណ្ឌិត **ចាន់ វឌ្ឍសុផា** លោកបណ្ឌិត **ឌូ ចាន់សុភី** និង លោកបណ្ឌិត **ផេត ផាលី** សាស្ត្រាចារ្យបង្រៀនឯកទេសវិទ្យាសាស្ត្រអប់រំ ដែលបានផ្តល់វិភាគទានគំនិតដ៏ថ្លៃថ្លាសំរាប់ជាប្រទីប ដើម្បីមើលពីចក្ខុវិស័យ និងជាចក្ខុទស្សន៍ពីរឿងរ៉ាវអប់រំ ព្រមទាំងបានជួយរិះគន់កែលំអក្នុងន័យ ស្ថាបនា ដើម្បីអោយស្នាដៃស្រាវជ្រាវនេះកាន់តែល្អប្រសើរឡើង ។
- លោក បណ្ឌិត **សុខ សំណាង** ប្រធានរាជបណ្ឌិសភាកម្ពុជា និងលោកបណ្ឌិត **ឆយ យីហាង** សាស្ត្រាចារ្យនៃរាជបណ្ឌិតសភាកម្ពុជាដែលបានបង្ហាត់អំពីវិធីសាស្ត្រស្រាវជ្រាវ និងវិធីសរសេរនិក្ខេបបទ ។
- លោកសាស្ត្រាចារ្យ និងបណ្ឌិតផ្សេងទៀតដែលបានផ្តល់នូវទស្សនាទានគំនិត និងចែករំលែកចំណេះដឹង និងបទពិសោធន៍ល្អៗក្នុងកម្មវិធីសិក្ខាសាលា ដែលនេះអាចចាត់ទុកថាជាជំនួយស្មារតីក្នុងការជួយផ្តល់នូវចំណេះដឹងកាន់តែទូលាយសំរាប់ការស្រាវជ្រាវ ។
- ស្ថាប័ន **រាជបណ្ឌិតសភាកម្ពុជា** សំរាប់ការផ្តល់អាហារូបករណ៍ដល់ការសិក្សា និងការស្រាវជ្រាវនេះ ។

- សាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ ដែលបានផ្តល់ភាពងាយស្រួលក្នុងការប្រមូលទិន្នន័យស្រាវជ្រាវនេះ ។

- គរុនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំដែលបានផ្តល់ចំលើយចំពោះកម្រងសំ- ណួរ និងការធ្វើសម្ភាសន៍ក្នុងការស្រាវជ្រាវនេះ ។

- លោក **កេង ហាក់** ដែលត្រូវជាឪពុកមា និងលោកស្រី **សាង ញ៉ី** ដែលជាម្តាយមីងចំពោះការផ្តល់លទ្ធ-ភាពក្នុងការស្នាក់នៅមួយរយៈពេលសិក្សាកន្លងមក ។ ជាពិសេសសបំផុតនោះ សូមថ្លែងអំណរគុណដល់អ្នកម្តាយមានគុណ **សាង តិមតាង** ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ទំនុកបំរុងអោយមានការអប់រំជារៀងរហូតមក ។ នៅទីបញ្ចប់ សូមថ្លែងអំណរគុណដល់បង ប្អូនប្រុសស្រី មិត្តភ័ក្តិ និងមនុស្សផ្សេងទៀតដែលបានចូលរួមចំណែកជួយដោយផ្ទាល់ និងមិនផ្ទាល់ រហូតដល់ស្នាដៃស្រាវជ្រាវនេះលេចចេញជារូបរាងឡើង ។

## SUMMARY

Cambodia had gone civil war for almost 3 decades. After the cease of chronic internal conflict and strife, the effects of war influenced on both the social infrastructure and human mental health. The war has resulted in the Cambodian people to lose their self-esteem and self-confidence. In schools, many of Cambodian present students do not have hard-work to obtain the very good scores, but they, in return, are lack of capacity, and hesitate to make a quick decision and feel unclear about their life destiny. They must often hold plagiarism and cheat in every exam session or ask someone to help them for their goal achievement, while they had unconfident abilities.

Wherease, Self-Esteem plays vital roles in pushing students to work hard and to improve their confidence and accomplishment in work and study. Students who have high self-esteem are able to learn and grow with ease. They are not afraid to achieve, they interact well with others. Thus, depending upon the above main points, it is significant to conduct research on "Self-Esteem and Study Quality: Case Study of Higher Education Teacher Trainees in Science and Mathematics at National Institute of Education."

The aim of the study was to find out the factors which influenced on the self-esteem of higher education teacher trainees. In the same time, we would like to know the relation between self-esteem and students' achievement. It was also to discover level of self-esteem and its relevant factors. The study selected 77 teacher trainees in science and mathematics including 54 males and 23 females ranging in age from 20 to 28 as participants. They were asked to fulfill the questionnaires. Self-esteem was measured by psychological test, and other questionnaires by 5 Likert-Scale. The findings showed that higher education teacher trainees in science and mathematics had above average of self-esteem. Self-esteem had positive correlation with study achievement, and study satisfaction had very high positive correlation with study accomplishment. Nevertheless, the age negatively correlated with self-esteem for graduated students' level. The implication of whole thesis was focused on as follows:

**Chapter 1 : Introduction of the Research**

- A- Context of Study
- B- Statement of Problem and Research Questions
- C- Objectives of Research
- D- Conceptual Framework
- E- Scientific Hypotheses
- F- Scope of Research

**Chapter 2 : Literature Review**

- A- The Term of Personality
- B- The Term of Self-Esteem
- C- Personal Characteristics and Self-Esteem
- D- Self-Esteem and Study Satisfaction
- E- The Term of Study Quality
- F- Self-Esteem and Study Accomplishment
- G- Study Satisfaction and Study Accomplishment

**Chapter 3 : Method of Research**

- A- Target Group
- B- Measurement
- C- Procedures

**Chapter 4 : Results of Research**

A- Research findings from Descriptive Statistics

a- Personal Characteristics

b- Self-Esteem

c- Professional Satisfaction

d- Study Satisfaction

e- Study Accomplishment

f- Interviews

B- Research findings from Regression

a- Relation between Personal Characteristics and Self-Esteem

b- Relation between Self-Esteem and Study Accomplishment

c- Relation between Self-Esteem and Study Satisfaction

d- Relation between Study Satisfaction and Study Accomplishment

**Chapter 5 : Discussion**

A- Factors which improve and cripple Self-Esteem

a- Family and Self-Esteem

b- School and Self-Esteem

c- Society and Self-Esteem

d- Personal Individual and Self-Esteem

B- Personal Characteristics and Self-Esteem

C- Self-Esteem and Study Accomplishment

D- Self-Esteem and Study Satisfaction

E- Study Satisfaction and Study Accomplishment

**Conclusion**

Self-Esteem is very important for all individuals. It is the essential foundation for a wider array of physical strength and mental health. It provides leaders, educators and students with tough struggle and motivation to achieve their goals and happiness. From this study, the growth of self-esteem did not rely on the age of 20 to 27. Yet, the factors in education in family and in schools, and the social world and cultural environment contribute the growth of self-esteem. Reasonable instructions, comfort, love, acceptance and support of family help the children improve self-esteem and self-concept in them. The rational and fair evaluation of teachers, school environment, materials for teaching and learning, the curriculum and the students' participation, and rewards assist students to develop self-esteem at schools. The social regime, social life, culture, traditional norm, stereotype, corruption and religiosity also influence on self-esteem in people. In order to build people's self-esteem and self-belief or self-worth, they have to pay great attention to the impact factors relevant to increase self-esteem such as justice, success in study and logical rewards... After studying the "Self-Esteem and Study Quality : Case Study of Higher Education Teacher Trainees at National Institute of Education", I considered that Self-Esteem plays very fundamental roles for motivating students to improve their learning and capacity ; and in order to upgrade education quality, they have to heed to improve students' self-esteem in advance. Thus, in the future, we will concentrate on the field of "Emotional Intellectual Leaders" which is necessary demand for improving Cambodian leaders. It might be the subject for the doctoral degree dissertation.

**Recommendations**

**Bibliography**

# សេចក្តីសង្ខេប

ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមស៊ីវិលជិតបីទសវត្សរ៍ ។ បន្ទាប់ពីមានការបញ្ចប់ជំលោះ និងការបាក់បែកផ្ទៃក្នុង លទ្ធផលនៃសង្គ្រាម មានឥទ្ធិពលទាំងទៅលើហេដ្ឋារចនាសម្ព័ន្ធសង្គម និងសុខភាពផ្លូវចិត្តរបស់មនុស្ស ។ សង្គ្រាមបាននាំឱ្យប្រជាពលរដ្ឋខ្មែរបាត់បង់នូវការជឿជាក់លើខ្លួនឯង និងការអោយតំលៃលើខ្លួនឯង ។ នៅតាមសាលារៀន សិស្ស និស្សិតជាច្រើនពុំបានខិតខំធ្វើការរៀនសូត្រ ដើម្បីទទួលបានពិន្ទុសិក្សាល្អឡើយ ប៉ុន្តែផ្ទុយទៅវិញ ពួកគេបែជាខ្វះសមត្ថភាព និងមានចិត្តស្ទាក់ស្ទើរក្នុងការសម្រេចចិត្តធ្វើអ្វីមួយអោយបានឆាប់រហ័ស និងមានអារម្មណ៍មិនប្រាកដអំពីជោគវាសនាជីវិតរបស់ខ្លួន ។ នៅពេលមានការប្រលងប្រជែងម្តងៗ សិស្ស និស្សិតភាគច្រើនតែងតែលួចចំលង ឬពឹងពាក់មនុស្សខាងក្រៅអោយជួយពួកគេ ដើម្បីសំរេចគោលបំណងរបស់ខ្លួន នៅខណៈពេលដែលពួកគេពុំទាន់មានសមត្ថភាពច្បាស់លាស់ ។ រីឯការឱ្យតំលៃខ្លួនឯងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយជំរុញអោយសិស្ស និស្សិតមានការតស៊ូយ៉ាងស្វិតស្វាញ និងជួយអោយពួកគេមានការជឿជាក់លើខ្លួនឯង ដើម្បីសំរេចសមិទ្ធផលក្នុងការងារ និងក្នុងការសិក្សា ។ សិស្ស និស្សិតដែលមានការឱ្យតំលៃខ្លួនឯងខ្ពស់អាចរីកចំរើន និងរៀនបានដោយងាយស្រួល និងទទួលបានលទ្ធផលល្អ ។ ពួកគេមិនខ្លាចពីការសម្រេចជោគជ័យ និងមិនរាថយចំពោះបរាជ័យឡើយ ហើយពួកគេថែមទាំងមានទំនាក់ទំនងល្អជាមួយអ្នកដទៃផ្សេងទៀត ។ ដូច្នេះ យោងទៅលើចំណុចសំខាន់ៗខាងលើ វាមានសារៈសំខាន់ណាស់ ក្នុងការធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ "ការអោយតំលៃខ្លួនឯង និងគុណភាពសិក្សា : ករណីសិក្សា គរុនិស្សិតកម្រិតឧត្តមផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ" ។

គោលបំណងសំខាន់នៃការស្រាវជ្រាវនេះ គឺដើម្បីរកអោយឃើញកត្តានានាដែលជះឥទ្ធិពលដល់ការអោយតំលៃខ្លួនឯងរបស់គរុនិស្សិត ។ ជាមួយគ្នានេះផងដែរ យើងក៏ចង់ដឹងផងដែរ អំពីទំនាក់ទំនងរវាងការអោយតំលៃខ្លួនឯងជាមួយនឹងសមិទ្ធផលសិក្សារបស់គរុនិស្សិត ។ ការស្រាវជ្រាវនេះក៏មានគោលបំណងរកអោយឃើញអំពីកម្រិតនៃការអោយតំលៃខ្លួនឯង និងកត្តាដែលមានទំនាក់ទំនងទៅនឹងការឱ្យតំលៃខ្លួនឯងផងដែរ ។

ការស្រាវជ្រាវនេះបានជ្រើសរើសគរុនិស្សិតកម្រិតឧត្តមផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យាចំនួន ៧៧ នាក់ (ប្រុស ៥៤ ស្រី ២៣) ជាក្រុមគោលដៅស្រាវជ្រាវ ។ ពួគេត្រូវបានស្នើរឱ្យបំពេញកម្រងសំណួរស្រាវជ្រាវ ។ កម្រងសំណួរនៃការអោយតំលៃខ្លួនឯងត្រូវបានធ្វើការវាស់វែងតាមរយៈការធ្វើតែសចិត្តវិទ្យា ហើយ

កម្រងសំណួរផ្សេងទៀតដែលទាក់ទងទៅនឹងសមត្ថភាពវិទ្យាសាស្ត្រ និងការពេញចិត្តនឹងការសិក្សា ត្រូវបានធ្វើការវាស់វែង តាមរយៈការកំណត់តម្លៃស្កេលប្រាំកម្រិត (5 Likert-Scale) ។

លទ្ធផលស្រាវជ្រាវបានបង្ហាញថា គរុនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យាមានការអោយតំលៃខ្លួនឯងកម្រិតលើមធ្យម ហើយការអោយតំលៃខ្លួនឯងមានទំនាក់ទំនងវិជ្ជមានជាមួយសមិទ្ធផលសិក្សា ។ ការស្រាវជ្រាវក៏បានរកឃើញថា ការពេញចិត្តនឹងការសិក្សាមានទំនាក់ទំនងវិជ្ជមានខ្ពស់បំផុតជាមួយសមិទ្ធផលសិក្សា ហើយការឱ្យតំលៃខ្លួនឯងមានទំនាក់ទំនងវិជ្ជមានតិចតួចជាមួយការពេញចិត្តនឹងការសិក្សា ប៉ុន្តែកត្តាអាយុវ័យមានទំនាក់ទំនងអវិជ្ជមានជាមួយការអោយតំលៃខ្លួនឯងទៅវិញ ។ ការអនុវត្តនៃការស្រាវជ្រាវនេះនឹងផ្តោតទាំងស្រុងទៅលើចំណុចសំខាន់ៗដូចខាងក្រោម :

**ជំពូកទី១ : សេចក្តីផ្តើមនៃការស្រាវជ្រាវ**

១.១ - បរិបទនៃការស្រាវជ្រាវ

១.២ - បញ្ហានៃការស្រាវជ្រាវ

១.៣ - គោលបំណងនៃការស្រាវជ្រាវ

១.៤ - ប្រព័ន្ធគំនិត

១.៥ - សម្មតិកម្មវិទ្យាសាស្ត្រ

១.៦ - ដែនកំណត់នៃការស្រាវជ្រាវ

**ជំពូកទី២ : មូលដ្ឋានទ្រឹស្តី**

២.១ - បញ្ញត្តិនៃបុគ្គលិកលក្ខណៈ

២.២ - បញ្ញត្តិនៃការអោយតំលៃខ្លួនឯង

២.៣ - លក្ខណៈពិសេសផ្ទាល់ខ្លួន និង ការអោយតំលៃខ្លួនឯង

២.៤ - ការអោយតំលៃខ្លួនឯង និង ការពេញចិត្តនឹងការសិក្សា

២.៥ - បញ្ញត្តិគុណភាពសិក្សា

២.៦ - ការអោយតំលៃខ្លួនឯង និង សមិទ្ធផលសិក្សា

២.៧ - ការពេញចិត្តនឹងការសិក្សា និង សមិទ្ធផលសិក្សា

**ជំពូកទី៣ : វិធីស្រាវជ្រាវ**

៣.១ - មុខសញ្ញាដែលត្រូវចូលរួម

៣.២ - ការវាស់វែងលទ្ធផលស្រាវជ្រាវ

- អថេរឯករាជ្យ
- អថេរមិនឯករាជ្យ

៣.៤ - លំនាំស្រាវជ្រាវ

**ជំពូកទី៤ : លទ្ធផលស្រាវជ្រាវ**

៤.១ - លទ្ធលផលស្រាវជ្រាវតាមរយៈស្ថិតិពិពណនា

៤.១.ក- លក្ខណៈពិសេសផ្ទាល់ខ្លួន

៤.១.ខ- ការអោយតំលៃខ្លួនឯង

៤.១.គ- ការពេញចិត្តលើមុខជំនាញឯកទេស

៤.១.ឃ- ការពេញចិត្តនឹងការសិក្សា

៤.១.ង- សមិទ្ធផលសិក្សា

៤.១.ច- បទសម្ភាសន៍

៤.២ - លទ្ធផលស្រាវជ្រាវតាមរយៈមេគុណទំនាក់ទំនង

៤.២.ក- ទំនាក់ទំនងលក្ខណៈពិសេសផ្ទាល់ខ្លួន និង ការអោយតំលៃខ្លួនឯង

៤.២.ខ- ទំនាក់ទំនងការអោយតំលៃខ្លួនឯង និង សមិទ្ធផលសិក្សា

៤.២.គ- ទំនាក់ទំនងការអោយតំលៃខ្លួនឯង និង ការពេញចិត្តនឹងការសិក្សា

៤.២.ឃ- ទំនាក់ទំនងការពេញចិត្តនឹងការសិក្សា និង សមិទ្ធផលសិក្សា

**ជំពូកទី៥ : ការពិភាក្សា**

៥.១ - កត្តាដែលជះឥទ្ធិពលដល់ការរីកចំរើន និងរាំងស្ទះដល់ការអោយតំលៃខ្លួនឯង

៥.១.ក- ស្ថានភាពគ្រួសារ និង ការអោយតំលៃខ្លួនឯង

៥.១.ខ- ស្ថានភាពអប់រំនៅសាលារៀន និង ការអោយតំលៃខ្លួនឯង

៥.១.គ- ស្ថានភាពមជ្ឈដ្ឋាន និង ការអោយតំលៃខ្លួនឯង

៥.១.ឃ- កត្តាផ្ទាល់ខ្លួន និង ការអោយតំលៃខ្លួនឯង

២.២- លក្ខណៈពិសេសផ្ទាល់ខ្លួន និងការអោយតំលៃខ្លួនឯង

២.៣- ការអោយតំលៃខ្លួនឯង និង សមិទ្ធផលសិក្សា

២.៤- ការអោយតំលៃខ្លួនឯង និង ការពេញចិត្តនឹងការសិក្សា

២.៥- ការពេញចិត្តនឹងការសិក្សា និង សមិទ្ធផលសិក្សា

**សេចក្តីសន្និដ្ឋាន**

លទ្ធផលស្រាវជ្រាវនេះមានលក្ខណៈគួរអោយចាប់អារម្មណ៍ និងមានសារៈសំខាន់ក្នុងការជួយអភិវឌ្ឍការអោយតំលៃខ្លួនឯងរបស់សិស្សនិងនិស្សិត ព្រមទាំងជាកត្តាជួយជំរុញអោយការសិក្សារបស់សិស្ស និងនិស្សិតគ្រប់រូបទទួលបានលទ្ធផលល្អ ។ ដូច្នេះការសិក្សាស្រាវជ្រាវនេះនាំទៅដល់ការធ្វើសន្និដ្ឋានដូចតទៅ :

- ការអោយតំលៃខ្លួនឯងមានសារៈសំខាន់ខ្លាំងណាស់សំរាប់បុគ្គលម្នាក់ៗ ។ វាជាមូលដ្ឋានគ្រឹះក្នុងការបង្កើតបាននូវកំលាំងចិត្ត និងជំរុញឱ្យបុគ្គលម្នាក់ៗដែលតែងតែជួបឧបសគ្គមានការតស៊ូយ៉ាងស្វិតស្វាញនឹងការងារ ។ ម្យ៉ាងវិញទៀត មនុស្សដែលមានការឱ្យតំលៃខ្លួនឯងខ្ពស់ តែងតែមានកំលាំងចិត្ត និងសុខភាពផ្លូវចិត្តល្អ ។ តាមរយៈការស្រាវជ្រាវនេះ លទ្ធផលបានបង្ហាញថា ការរីកចំរើននៃការអោយតំលៃខ្លួនឯងមិនអាស្រ័យទៅលើអាយុទេ សំរាប់និស្សិតឧត្តមសិក្សា ប៉ុន្តែកត្តាអប់រំនៅក្នុងគ្រួសារ សាលារៀន និងកត្តាមជ្ឈដ្ឋានមានឥទ្ធិពលដល់ការអោយតំលៃខ្លួនឯងរបស់មនុស្ស ។ បរិយាកាសគ្រួសារ ដូចជាការផ្តល់ហេតុផលក្នុងការអប់រំរបស់ឪពុកម្តាយ ការផ្តល់សេចក្តីស្រលាញ់ និងការផ្តល់បាននូវសុខមាលភាពផ្លូវចិត្ត ការថែរក្សា ការប្រើភាសាវិជ្ជមាន និងរបៀបអប់រំដោយមានការពន្យល់អំពីហេតុផលរបស់ឪពុកម្តាយ ជួយអោយបុត្រធីតាមានការរីកលូតលាស់ការអោយតំលៃខ្លួនឯងបានល្អ និងជួយឱ្យគេអភិវឌ្ឍខ្លួនឯងទៅជាមនុស្សពេញលេញ និងស្វិតស្វាញ តស៊ូក្នុងការងារដែលជាហេតុជួយអោយគេទទួលបានជោគជ័យនៅថ្ងៃអនាគត ។

- ការអោយតំលៃខ្លួនឯងខ្ពស់ជាល័ក្ខខ័ណ្ឌដ៏សំខាន់សំរាប់សំគាល់នូវការអភិវឌ្ឍដល់និស្សិត មន្ត្រីអប់រំ និងអ្នកគ្រប់គ្រងឱ្យបំពេញការងាររបស់ខ្លួនដោយភាពម្ចាស់ការ និងមានស្មារតីទទួលខុសត្រូវខ្ពស់ តាមរយៈការអប់រំ ។ ដូច្នេះនិស្សិតដែលជាអនាគតអ្នកអប់រំ និងជាមន្ត្រីគ្រប់គ្រង ត្រូវតែមានការឱ្យតំលៃខ្លួនឯងខ្ពស់ ព្រោះវាជាមូលដ្ឋានគ្រឹះនៃកំលាំងចិត្ត ក្នុងការតស៊ូយ៉ាងស្វិតស្វាញនឹងការងាររហូតទទួលបានលទ្ធផលសិក្សាបានល្អប្រសើរ ។ សិស្ស និស្សិតកាន់តែមានការអោយតំលៃខ្លួនឯងខ្ពស់ គុណភាពសិក្សារបស់គេកាន់តែប្រសើរឡើង ។ បរិយាកាសសាលារៀន បន្ទប់រៀន និងសម្ភារៈសិក្សាមានឥទ្ធិពលយ៉ាងខ្លាំងដល់កំលាំងចិត្តក្នុងការសិក្សារបស់និស្សិត ។ ជាមួយគ្នានេះដែរ កម្មវិធីសិក្សាបង្កប់ខ្លឹមសារពីងាយទៅលំបាក វិធីសាស្ត្របង្រៀនដែលផ្តល់ឱកាសអោយមានការចូលរួមរបស់និស្សិត និងការផ្តល់ឱកាសឱ្យនិស្សិតបញ្ចេញសមត្ថភាព និងការវាយតម្លៃដែលមានការបញ្ជាក់អំពីមូលវិចារណ៍ហេតុផល ជាល័ក្ខខ័ណ្ឌចាំបាច់ សំរាប់ជួយអភិវឌ្ឍការឱ្យតំលៃ

ខ្លួនឯងរបស់សិស្ស និស្សិតនៅក្នុងការអប់រំនៅតាមសាលារៀន ។ ជាមួយគ្នានេះដែរ ការវាយតំលៃសមិទ្ធផលសិក្សារបស់សិស្ស និស្សិត ដោយមានការចូលរួមពីគណកម្មាការខាងក្រៅ ប្រកបដោយតម្លាភាព មានឥទ្ធិពលយ៉ាងខ្លាំងដល់ការជឿជាក់លើសមត្ថភាពខ្លួនរបស់សិស្ស និងនិស្សិត ។

- ឥទ្ធិពលគ្រប់គ្រងនៃរបបសង្គម សាសនា និងវប្បធម៌ប្រពៃណីរស់នៅ ក្នុងសង្គមក៏មានឥទ្ធិពលដល់កាអោយតំលៃខ្លួនឯងរបស់មនុស្សដែរ ។ មនុស្សដែលរស់នៅក្នុងស្ថានភាពសង្គមមានការគាំទ្រច្រើនមានការអភិវឌ្ឍការអោយតំលៃខ្លួនឯងខ្ពស់ ។

- និស្សិតដែលមានការអោយតំលៃខ្លួនឯងខ្ពស់នឹងទទួលបានសមិទ្ធផលសិក្សាបានល្អ និងមានកំលាំងចិត្តចង់សិក្សា ព្រមទាំងមានឆន្ទៈមោះមុតមិនរួញរានឹងឧបសគ្គ ហើយនៅទីបញ្ចប់ ពួកគេនឹងអាចសំរេចគោលបំណងដែលគេបានគ្រោងទុកនៅក្នុងជីវិតរបស់គេ ព្រោះគេជាមនុស្សមានការប្តេជ្ញាចិត្តខ្ពស់ មិនរាថយចំពោះបរាជ័យ ។ ការអោយតំលៃខ្លួនឯងត្រូវបានអភិវឌ្ឍព្រមគ្នាទាំងនៅក្នុងបរិយាកាសគ្រួសារ សាលារៀន និងបរិយាកាសសង្គមទាំងមូល ។ នៅពេលមនុស្សទទួលបានការអប់រំក្នុងគ្រួសារ និងសាលារៀន ដែលបង្កប់នូវខ្លឹមសារការអោយតំលៃខ្លួនឯង មនុស្សនោះនឹងមានអារម្មណ៍ជឿជាក់លើខ្លួនឯងកាន់តែខ្លាំង ហើយបរិយាកាសល្អក្នុងសង្គមក៏ជាការរួមចំណែកដ៏សំខាន់ក្នុងការអភិវឌ្ឍការអោយតំលៃខ្លួនឯងរបស់មនុស្សដែរ ។ ដូច្នេះ ដើម្បីអភិវឌ្ឍសង្គមក្តី ឬសេដ្ឋកិច្ចសង្គមទាំងមូលក្តី គេត្រូវតែអភិវឌ្ឍធនធានមនុស្សដែលប្រកបដោយការអោយតំលៃខ្លួនឯងជាមុនសិន ហើយការអភិវឌ្ឍធនធានមនុស្សទាមទារនូវល័ក្ខខ័ណ្ឌបីសំខាន់ : ជីវភាពប្រ-សើរឡើង ការអោយតំលៃខ្លួនឯងឬកិត្តិយស និងសេរីភាពក្នុងការជ្រើសរើស ។ ការស្រាវជ្រាវផ្តល់ជាមតិថាយើងត្រូវតែយកចិត្តទុកដាក់ដល់ការអភិវឌ្ឍការអោយតំលៃខ្លួនឯងរបស់សិស្ស និស្សិតនៅតាមផ្ទះ និងនៅតាមសាលារៀនជាមុនសិន ដើម្បីឈានទៅរកការអភិវឌ្ឍសង្គម ឬសេដ្ឋកិច្ចរបស់សង្គម ពោលគឺយើងត្រូវអភិវឌ្ឍសមត្ថភាពសិក្សារបស់សិស្ស និងនិស្សិត ដើម្បីអភិវឌ្ឍការអោយតំលៃខ្លួនឯងអោយបានខ្ពស់ ។ ដូច្នេះ ដើម្បីស្តារជំនឿផ្លូវចិត្ត និងជួយអោយប្រជាពលរដ្ឋខ្មែរមានការទុកចិត្តគ្នា គេត្រូវយកចិត្តទុកដាក់ដល់កត្តាដែលមានឥទ្ធិពលដល់ការឱ្យតំលៃខ្លួនឯង និងយុទ្ធសាស្ត្រអភិវឌ្ឍការអោយតំលៃខ្លួនឯង ។

បន្ទាប់ពីធ្វើការសិក្សាស្រាវជ្រាវអំពី *ការឱ្យតំលៃខ្លួនឯង និងគុណភាពសិក្សា : សិក្សាករណី គរុនិស្សិតកម្រិតឧត្តមសិក្សាផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ* អ្នកស្រាវជ្រាវយល់ឃើញថា ការអោយតំលៃខ្លួនឯងដើរតួនាទីស្នូល ក្នុងការជួយអោយសិស្ស និងនិស្សិតមានកំឡាំងចិត្តក្នុងការសិក្សា និង មានសមត្ថភាពកាន់តែល្អប្រសើរឡើង ។ ដូច្នេះ ប្រសិនបើមានឱកាស អ្នកស្រាវជ្រាវនឹងបន្តសិក្សាស្រាវ

ជ្រាវតទៅទៀត ស្ដីអំពីប្រធានបទទាក់ទងនឹងវិស័យ "ចិត្តរំភើបប្រកបដោយបញ្ញាញាណរបស់អ្នកដឹកនាំ "Emotional Intellectual Leaders" សំរាប់ការសិក្សាស្រាវជ្រាវនៅថ្ងៃអនាគត ។

**អនុសាសន៍**

**គន្ថនិទ្ទេស**

**ឧបសម្ព័ន្ធ**

# ពាក្យបំព្រួញ

| | |
|---|---|
| ដ-ឯ-ម | ដូចឯកសារដើម (op.cit) |
| -ដ- | ដដែល (ibid) |
| ល.រ | លេខរៀង |
| វ.ជ.អ | វិទ្យាស្ថានជាតិអប់រំ |
| DV | Dependent Variable ( អថេរមិនឯករាជ្យ) |
| Ibid., | Ibidem (ដដែល) |
| IV | Independent Variable ( អថេរឯករាជ្យ) |
| op.cit., | opere citato (ដូចឯកសារដើម) |
| SD | Standard Deviation (លំងាកស្តង់ដា) |
| SE | Standard Error ( លំអៀងស្តង់ដា) |
| $\overline{X}$ | Mean ( មធ្យម) |
| r | Regression ( មេគុណសហទំនាក់ទំនង) |
| P. | Page ( ទំព័រ) |
| JICA | Japan International Cooperation Agency ( ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន) |
| UNICEF យូនីសេហ្វ | United Nation Children's Emergency Fund ( មូលនិធិអង្គការសហប្រជាជាតិសំរាប់សង្គ្រោះកុមារ) |

# បញ្ជីរូបភាព


| ល.រ រូបភាព | ខ្លឹមសាររូបភាព | ទំព័រ |
|---|---|---|
| ១ | ប្រព័ន្ធគំនិតនៃការស្រាវជ្រាវ | ៦ |
| ២ | ដ្យាក្រាមស្តីពីចំនួនប្រេកង់អ្នកចូលរួម | ៦៤ |
| ៣ | ការពេញចិត្តលើមុខជំនាញឯកទេស | ៧០ |
| ៤ | ទំនាក់ទំនងអាយុ និងការអោយតំលៃខ្លួនឯង | ៧៨ |
| ៥ | ការអោយតំលៃខ្លួនឯង និងសមិទ្ធផលសិក្សា | ៨០ |
| ៦ | ការអោយតំលៃខ្លួនឯង និងពិន្ទុសិក្សានិស្សិតជីវវិទ្យា | ៨១ |
| ៧ | ការអោយតំលៃខ្លួនឯង និងពិន្ទុសិក្សានិស្សិតគីមីវិទ្យា | ៨២ |
| ៨ | ការអោយតំលៃខ្លួនឯង និងពិន្ទុសិក្សានិស្សិតគណិតវិទ្យា | ៨៣ |
| ៩ | ការអោយតំលៃខ្លួនឯង និងពិន្ទុសិក្សានិស្សិតរូបវិទ្យា | ៨៣ |
| ១០ | ការពេញចិត្តនឹងការសិក្សា និងសមិទ្ធផលសិក្សា | ៨៥ |
| ១១ | កត្តាដែលមានឥទ្ធិពលដល់ការអោយតំលៃខ្លួនឯង | ៨៦ |
| ១២ | រូបភាពក្នុងឧបសម្ព័ន្ធ | ១៣៣ |

# បញ្ជីតារាង


| ល.រ តារាង | ខ្លឹមសារតារាង | ទំព័រ |
|---|---|---|
| ១ | មុខសញ្ញាក្នុងការស្រាវជ្រាវ | ៥៥ |
| ២ | ចំនួនក្រុមគោលដៅស្រាវជ្រាវ | ៦៣ |
| ៣ | មធ្យម និងលំងាកស្តង់ដារបស់អាយុអ្នកចូលរួម | ៦៤ |
| ៤ | មុខរបរអាណាព្យាបាលរបស់អ្នកចូលរួមបំពេញកម្រងសំណួរ | ៦៥ |
| ៥ | ប្រភេទនៃចំនួនអ្នកចូលរួម និងកម្រិតអប់រំនៃមុខជំនាញ | ៦៥ |
| ៦ | ពិន្ទុនៃការអោយតំលៃខ្លួនឯងរបស់អ្នកចូលរួម | ៦៦ |
| ៧ | កត្តាភេទ និងការអោយតំលៃខ្លួនឯង | ៦៦ |
| ៨ | ការអោយតំលៃខ្លួនឯង និងពិន្ទុសិក្សា | ៦៧ |
| ៩ | ការប្រៀបធៀបកម្រិតអាយុ និងការអោយតំលៃខ្លួនឯង | ៦៩ |
| ១០ | កម្រិតនៃការអោយតំលៃខ្លួនឯងរបស់និស្សិត | ៦៩ |
| ១១ | ការពេញចិត្តចំពោះមុខជំនាញរបស់និស្សិត | ៧២ |
| ១២ | កម្រិតសមត្ថភាពដែលនិស្សិតទទួលបាន | ៧៤ |
| ១៣ | លទ្ធផលរួមនៃទំនាក់ទំនងអថេរ | ៧៥ |
| ១៤ | មេគុណទំនាក់ទំនងរវាងអថេរឯករាជ្យ និងមិនឯករាជ្យ | ៧៧ |
| ១៥ | ទំនាក់ទំនងវិទ្យាសាស្ត្រនិងគណិតវិទ្យាជាមួយការអោយតំលៃខ្លួនឯង | ៨៤ |
| ១៦ | តារាងកម្រងសំណួរក្នុងឧបសម្ព័ន្ធ | ១២៦ |

# មាតិកា

ទំព័រ


ឧទ្ទិសកថា ........ I

សេចក្តីថ្លែងអំណរគុណ ........ II

សេចក្តីសង្ខេប ........ IV

ពាក្យបម្រួញ ........ XII

បញ្ជីរូបភាព ........ XIII

បញ្ជីតារាង ........ XIV

មាតិកា ........ XV

លំនាំដើម ........ ១

ជំពូកទី ១ សេចក្តីផ្តើម ........ ២

១.១- បរិបទនៃការស្រាវជ្រាវ ........ ២

១.២- បញ្ហានៃការស្រាវជ្រាវ ........ ៤

១.៣- គោលបំណងនៃការស្រាវជ្រាវ ........ ៥

១.៤- ប្រព័ន្ធគំនិត ........ ៥

១.៥- សម្មតិកម្មវិទ្យាសាស្ត្រ ........ ៦

១.៦- ដែនកំណត់នៃការស្រាវជ្រាវ ........ ៧

ជំពូកទី ២ មូលដ្ឋានទ្រឹស្តី ........ ៨

២.១- បញ្ញត្តិបុគ្គលិកលក្ខណៈ ........ ៨

២.១.ក- និយមន័យបុគ្គលិកលក្ខណៈ ........ ៨

២.១.ខ- ទ្រឹស្តីបុគ្គលិកលក្ខណៈ ........ ១០

២.១.គ- កត្តាដែលជះឥទ្ធិពលដល់ការអភិវឌ្ឍបុគ្គលិកលក្ខណៈ ........ ១៣

២.២- បញ្ញត្តិនៃការអោយតំលៃខ្លួនឯង ........ ១៤

២.២.ក - និយមន័យការអោយតំលៃខ្លួនឯង ........ ១៤

២.២.ខ- ធម្មជាតិនៃការអោយតំលៃខ្លួនឯង ..........១៩
២.២.គ- ឫសគល់ និងប្រវត្តិនៃការអោយតំលៃខ្លួនឯង ..........២១
២.២.គ.១- ឫសគល់នៃការអោយតំលៃខ្លួនឯង ..........២១
២.២.គ.២- ប្រវត្តិនៃការអោយតំលៃខ្លួនឯង ..........២៤
២.២.ឃ- ប្រភេទនៃការអោយតំលៃខ្លួនឯង ..........២៦
២.២.ឃ.១- អាំងឌីកាទ័រការអោយតំលៃខ្លួនឯងកម្រិតទាប ..........២៦
២.២.ឃ.២- អាំងឌីកាទ័រការអោយតំលៃខ្លួនឯងកម្រិតខ្ពស់ ..........២៧
២.២.ង- កត្តាដែលជះឥទ្ធិពលដល់ការអោយតំលៃខ្លួនឯង ..........២៨
២.២.ង.១- កត្តាគ្រួសារ ..........២៨
២.២.ង.២- កត្តាមជ្ឈដ្ឋាន ..........៣១
២.២.ង.៣- កត្តាសាលារៀន ..........៣២
២.២.ង.៤- កត្តាតំណពូជ ..........៣៤
២.២.ច- ការអភិវឌ្ឍការអោយតំលៃខ្លួនឯង..........៣៤
២.២.ច.១- ការកសាងការអោយតំលៃខ្លួនឯងពីសំណាក់គ្រួសារ ..........៣៥
២.២.ច.២- ការកសាងការអោយតំលៃខ្លួនឯងពីសំណាក់សាលារៀន ..........៤០
២.២.ច.៣- ការកសាងការអោយតំលៃខ្លួនឯងដោយខ្លួនឯង ..........៤១
២.២.ច.៤- ការកសាងការអោយតំលៃខ្លួនឯងពីសំណាក់មជ្ឈដ្ឋាន ..........៤២
២.៣- លក្ខណៈពិសេសផ្ទាល់ខ្លួន និងការអោយតំលៃខ្លួនឯង ..........៤៣
២.៣.ក- ការអប់រំ និងការអោយតំលៃខ្លួនឯង ..........៤៣
២.៣.ខ- ភេទ និងការអោយតំលៃខ្លួនឯង ..........៤៤
២.៣.គ- អាយុវ័យ និងការអោយតំលៃខ្លួនឯង ..........៤៥
២.៤- ការអោយតំលៃខ្លួនឯង និងការពេញចិត្តនឹងការសិក្សា ..........៤៦
២.៥- បញ្ញត្តិនៃគុណភាពសិក្សា ..........៤៧
២.៦- ការពេញចិត្តនឹងការសិក្សា និងសមិទ្ធផលសិក្សា ..........៥០

២.៧- ការអោយតំលៃខ្លួនឯង និងសមិទ្ធផលសិក្សា ..... ៥១

**ជំពូកទី ៣ វិធីស្រាវជ្រាវ** ..... ៥៥

៣.១- មុខសញ្ញាដែលត្រូវចូលរួម ..... ៥៥

៣.២- ការវាស់វែងលទ្ធផលស្រាវជ្រាវ ..... ៥៧

៣.២.ក- អថេរឯករាជ្យ ..... ៥៧

៣.២.ខ- អថេរមិនឯករាជ្យ ..... ៥៩

៣.៣- លំនាំស្រាវជ្រាវ ..... ៦០

**ជំពូកទី ៤ លទ្ធផលនៃការស្រាវជ្រាវ** ..... ៦៣

៤.១- ទិដ្ឋភាពទូទៅនៃលទ្ធផលស្រាវជ្រាវតាមស្ថិតិពិពណ៌នា ..... ៦៣

៤.១.ក- លក្ខណៈពិសេសផ្ទាល់ខ្លួន ..... ៦៣

៤.១.ខ- ការអោយតំលៃខ្លួនឯង ..... ៦៦

៤.១.គ- ការពេញចិត្តលើមុខជំនាញឯកទេស ..... ៧០

៤.១.ឃ-ការពេញចិត្តលើមុខវិជ្ជាសិក្សា ..... ៧០

៤.១.ង- សមិទ្ធផលសិក្សា ..... ៧៣

៤.១.ច- លទ្ធផលសម្ភាសន៍ ..... ៧៥

៤.២- មេគុណទំនាក់ទំនងរវាងអថេរ ..... ៧៧

៤.២.ក- លក្ខណៈពិសេសផ្ទាល់ខ្លួន និងការអោយតំលៃខ្លួនឯង ..... ៧៨

៤.២.ខ- ទំនាក់ទំនងការអោយតំលៃខ្លួនឯង និងសមិទ្ធផលសិក្សា ..... ៨០

៤.២.គ- ទំនាក់ទំនងការអោយតំលៃខ្លួនឯង និងការពេញចិត្តនឹងការសិក្សា ..... ៨៥

៤.២.ឃ- ទំនាក់ទំនងការពេញចិត្តនឹងការសិក្សា និងសមិទ្ធផលសិក្សា ..... ៨៥

៤.៣- កត្តាដែលមានឥទ្ធិពលលើការអោយតំលៃខ្លួនឯង ..... ៨៦

៤.៣.ក- វិធីអប់រំក្នុងគ្រួសារ និងការអោយតំលៃខ្លួនឯង ..... ៨៧

៤.៣.ខ- វិធីអប់រំនៅសាលារៀន និងការអោយតំលៃខ្លួនឯង ..... ៨៧

៤.៣.គ- ឥទ្ធិពលមជ្ឈដ្ឋាន និងការអោយតំលៃខ្លួនឯង ..... ៨៨

៤.៣.ឃ- ឥទ្ធិពលការអោយតំលៃផ្ទាល់ខ្លួន និងការអោយតំលៃខ្លួនឯង ..............៨៨
៤.៣.ង- ការផ្ទៀងផ្ទាត់លទ្ធផលស្រាវជ្រាវជាមួយសម្មតិកម្មស្រាវជ្រាវ ............៨៩
**ជំពូកទី ៥ ការពិភាក្សា** ........................................................................................៩១
៥.១- កត្តាដែលនាំអោយរីកចំរើន និងរាំងស្ទះដល់ការអោយតំលៃខ្លួនឯង..... ៩១
៥.១.ក- ស្ថានភាពអប់រំក្នុងគ្រួសារជាមួយការអោយតំលៃខ្លួនឯង .......................៩២
៥.១.ខ- ស្ថានភាពអប់រំនៅសាលារៀនជាមួយការអោយតំលៃខ្លួនឯង ................៩៦
៥.១.គ- ស្ថានភាពមជ្ឈដ្ឋានជាមួយការអោយតំលៃខ្លួនឯង ............................ ៩៩
៥.១.ឃ- កត្តាផ្ទាល់ខ្លួនជាមួយការអោយតំលៃខ្លួនឯង ........................................ ១០៣
៥.២- ទំនាក់ទំនងលក្ខណៈពិសេសផ្ទាល់ខ្លួន និងការអោយតំលៃខ្លួនឯង ...... ១០៦
៥.៣- ទំនាក់ទំនងការអោយតំលៃខ្លួនឯង និងសមិទ្ធផលសិក្សា ...................... ១១០
៥.៤- ទំនាក់ទំនងការអោយតំលៃខ្លួនឯង និងការពេញចិត្តនឹងការសិក្សា.......១១៣
៥.៥- ទំនាក់ទំនងការពេញចិត្តនឹងការសិក្សា និងសមិទ្ធផលសិក្សា ...............១១៤
**សេចក្ដីសន្និដ្ឋាន**..........................................................................................................១១៨
**អនុសាសន៍**.....................................................................................................................១២០
**គន្ថនិទ្ទេស**.......................................................................................................................១២២
**ឧបសម្ព័ន្ធ** .......................................................................................................................១២៦

# ជំនាំដើម

សារណាស្តីអំពី "ការអោយតំលៃខ្លួនឯង និងគុណភាពសិក្សា : សិក្សាករណី គរុនិស្សិតកម្រិតឧត្តម ផ្នែកវិទ្យាសាស្ត្រនិងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ" បានរៀបចំធ្វើការស្រាវជ្រាវឡើងក្រោមការណែនាំ ដោយផ្ទាល់ពីលោកបណ្ឌិត **អ៊ឹម កុច** សាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រអប់រំនៅរាជបណ្ឌិតសភាកម្ពុជា និងមាន ការជួយទិទៀនកែលំអ ពីលោកសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រអប់រំនៃរាជបណ្ឌិតសភាកម្ពុជា ដែលរួមមាន លោក បណ្ឌិត **នេត បារ៉ុម** លោកបណ្ឌិត **ចាន់ រដ្ឋសុជា** លោកបណ្ឌិត **ទូ ចាន់សុភី** និងលោកបណ្ឌិត **ជេត ជាលី** ដើម្បីអោយស្នាដៃសារណានេះមានលក្ខណៈវិទ្យាសាស្ត្រ ។ សារណានេះធ្វើឡើងក្នុងគោលបំណងបញ្ចប់ថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី៣ ផ្នែកវិទ្យាសាស្ត្រអប់រំនៅរាជបណ្ឌិតសភាកម្ពុជា ។

សារណានេះត្រូវបានរៀបចំចប់ជាស្ថាពរ នៅខែ ធ្នូ ឆ្នាំ ២០០៤ ។ ខ្ញុំបាទសង្ឃឹមថា សារណានេះ ពិតជាមានប្រយោជន៍ក្នុងការចូលរួមចំណែករំលែកនូវចំណេះដឹងខាងវិស័យអប់រំ ជាពិសេស ក្នុងគោលបំណង លើកជាអនុសាសន៍ស្តីអំពីយុទ្ធសាស្ត្រអប់រំ ដើម្បីជួយអភិវឌ្ឍការអោយតំលៃខ្លួនឯងដល់សិស្ស និស្សិត ក៏ដូច ជាការងារបណ្តុះបណ្តាលគ្រូបង្រៀន ព្រមទាំងមន្ត្រីគ្រប់គ្រងអប់រំអោយកាន់តែមានប្រសិទ្ធភាព និងគុណ-ភាព ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ សារណានេះអាចនឹងមានចំណុចខ្វះខាត និងកំហុសឆ្គងជៀសមិនរួច ឡើយចំពោះផ្នែកខ្លឹមសារ ។

ក្នុងនាមជាអ្នកស្រាវជ្រាវវិទ្យាសាស្ត្រ ខ្ញុំបាទសូមរង់ចាំដោយសោមនស្សរីករាយក្នុងការទិទៀន និង រិះគន់កែលំអ ក្នុងន័យស្ថាបនាគ្រប់ពេលវេលាពីសំណាក់ សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងប្រិយមិត្តអ្នកអានទាំងឡាយដោយក្តីរីករាយ ។ ខ្ញុំបាទនឹងទទួលយកនូវរាល់គំនិតទិទៀនកែលំអទាំងឡាយ ដើម្បីជំរុញអោយស្នាដៃសិក្សាស្រាវជ្រាវនេះរឹតតែកាន់មានសុក្រិតភាពថែមឡើង ។

ជាថ្មីម្តងទៀត ខ្ញុំសូមអំពាវនាវអោយអ្នកស្រាវជ្រាវ និងបញ្ញាជនខ្មែរទាំងអស់មេត្តាចូលរួមចំណែក ចែករំលែកនូវអត្ថបទស្រាវជ្រាវជាភាសាជាតិអោយបានច្រើន សំរាប់ជាប្រទីបបំភ្លឺចំណេះដឹងដល់ពលរដ្ឋខ្មែរ ទាំងអស់ និងសូមអំពាវនាវផងដែរដល់មាតា បិតា សាស្ត្រាចារ្យ គ្រូបង្រៀន អ្នកដឹកនាំ ត្រូវយកចិត្តទុកដាក់ លើវិធីអប់រំកូន សិស្ស និស្សិត និងពលរដ្ឋខ្មែរអោយមានការអោយតំលៃខ្លួនឯងខ្ពស់ ក្នុងគោលបំណងប្រ កួតប្រជែងបញ្ញាញាណ និងការអភិវឌ្ឍសង្គមជាតិ ។

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ - បរិបទនៃការស្រាវជ្រាវ

ពិភពលោកកំពុងរីកចំរើនយ៉ាងខ្លាំងឥតឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃ ។ សម្ភារៈទំនើបៗ ឧបករណ៍ផ្នែកៗដែលពុំមានពីមុនមកត្រូវបានកកើតឡើង ។ មនុស្សដែលធ្លាប់តែនៅឆ្ងាយពីគ្នាពុំដែលបានដឹង និងស្គាល់គ្នានោះ ត្រូវបានខិតជិតគ្នា និងស្គាល់គ្នាកាន់តែច្បាស់ឡើងតាមរយៈប្រព័ន្ធបច្ចេកវិទ្យាផ្សព្វផ្សាយទំនើបដូចជាទូរទស្សន៍ ទូរស័ព្ទ និងអ៊ីនធឺណែតជាដើម ។ អាគារ ក្រុមហ៊ុន គ្រឹះស្ថាន សហគ្រាសធំៗដែលជាកំឡាំងស្នូលសំរាប់អភិវឌ្ឍប្រទេសជាតិត្រូវបានកសាងឡើង ។ ការរីកចំរើននូវសម្ភារៈសំបូរបែបរបស់ពិភពលោកនេះត្រូវបានកកើតឡើងដោយសារស្នាដៃច្នៃប្រឌិតរបស់មនុស្ស ។ អ្នកដែលមានសមត្ថភាពផលិតនូវសម្ភារៈទំនើបទាំងនេះបានពិតជាមនុស្សដែលមានចំណេះដឹងផ្នែកវិទ្យាសាស្រ្ត មានកម្លាំងចិត្តមុតមាំសកម្មប្រយុទ្ធសហការគ្នា ព្រមទាំងព្យាយាមតស៊ូដោយជឿជាក់លើសមត្ថភាពខ្លួន ។ ចំណេះដឹងក្តី សម្ភារៈទំនើបក្តីសុទ្ធតែមានប្រភពចេញពីមនុស្សដែលបានទទួលការអប់រំប្រកបដោយគុណភាព ព្រមទាំងមានការអោយតំលៃខ្លួនឯងខ្ពស់ ។

នៅក្នុងសម័យសាកលភាវូបនីយកម្ម (សម័យបច្ចេកវិទ្យាព័ត៌មាន) គេអភិវឌ្ឍសេដ្ឋកិច្ចប្រទេសជាតិដោយពឹងផ្អែកលើចំណេះដឹងរបស់មនុស្សដែលមានការអោយតំលៃខ្លួនឯង ស្របតាមវប្បធម៌របស់ជាតិខ្លួនក្នុងនោះប្រទេសកម្ពុជាក៏មានវិធី និងយុទ្ធសាស្រ្តរបស់ខ្លួនក្នុងការកសាងប្រទេសជាតិដែរ ។ វប្បធម៌ និងការអប់រំដើរតួនាទីស្នូលក្នុងការបណ្តុះបណ្តាលធនធានមនុស្សអោយប្រកបដោយការជឿជាក់លើខ្លួនឯង ។ មើលឃើញពីហេតុផលនេះ លោក ចន វ៉េខនសេឡូស (John Vaconscellos) បានអំពាវនាវអោយរដ្ឋាភិបាលរបស់គាត់ត្រួតពិនិត្យលើការអប់រំ ដែលត្រូវតែជួយជំរុញមនុស្សអោយធ្វើសកម្មភាពប្រកបដោយការទទួលខុសត្រូវ តាមរយៈការអោយតំលៃលើខ្លួនឯងនេះ[១] ។ វិបុលភាព និងគុណធម៌សង្គមត្រូវបានកើតមានឡើងក្រោមស្នាដៃរបស់មនុស្សដែលមានការអោយតំលៃខ្លួនឯងខ្ពស់នេះឯង ។

នៅពេលបច្ចុប្បន្ន ប្រជាពលរដ្ឋខ្មែរកំពុងធ្វើការអភិវឌ្ឍប្រទេសជាតិខ្លួនឡើងវិញ ព្រមទាំងបាននឹងកំពុងធ្វើសមាហរណកម្មចូលទៅក្នុងតំបន់អាស៊ាន និងពិភពលោក ។ ដើម្បីអាចកសាង និងប្រកួតប្រជែងកំលាំងបញ្ញាញាណជាមួយនឹងអ្នកដទៃបាន គេចាំបាច់ត្រូវការកសាងធនធានមនុស្សប្រកបដោយគុណភាព និងការជឿជាក់លើខ្លួនឯងជាមុនសិន ដោយសំឡឹងមើលចក្ខុវិស័យពីការកសាងប្រជាជាតិកំពុងអភិវឌ្ឍអោយប្រែ

---

[១] សូមមើល http: //joi.ito.com/archives/1999/02/28/self_esteem_and_the_information_age.html

ក្លាយទៅជាប្រជាជាតិអភិវឌ្ឍ ។ ការសម្រេចគោលដៅនេះបាន គឺអាស្រ័យលើការអប់រំចាប់ពីកុមារមតេយ្យរហូតដល់ឧត្តមសិក្សាដែលត្រូវតែទទួលបាននូវអាទិភាពខ្ពស់នាំមុខគេ [២] ។

តាមទម្លាប់កន្លងមក ប្រជាពលរដ្ឋកម្ពុជាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសាសនា ទំនៀមទំលាប់ និងវប្បធម៌រៀនសូត្រមួយតាមរយៈការទន្ទេញអោយចាំនូវចំណេះដឹងនានាដោយពុំចាំបាច់គិតពិចារណា រិះគន់ស្លាបនាឡើយ [៣] ។ ម្យ៉ាងវិញទៀត គ្រួសារភាគច្រើនពុំមានការអប់រំកូនបន្ថែមឡើយ ។ ក្រោមឥទ្ធិពលសាកលភាវូបនីយកម្ម ការអប់រំរបស់ប្រទេសកម្ពុជាបានមកដល់ចំណុចរបត់ក្នុងការប្រែប្រួលតាមទស្សនៈអប់រំរបស់បរទេស ដោយផ្អែកលើមូលដ្ឋានរបៀបអប់រំរបស់ខ្លួនដែលមានពីមុនមកយកមកកែច្នៃអប់រំតាមរបៀបថ្មីមួយដែលធ្វើយ៉ាងណាអោយសិស្ស និស្សិតម្នាក់ៗមានការចូលរួមយ៉ាងសកម្មដោយស្មារតីម្ចាស់ការខ្ពស់ ។

ដោយហេតុប្រទេសកម្ពុជាឆ្លងកាត់សង្គ្រាមរ៉ាំរ៉ៃជិត ៣០ ឆ្នាំ ទាំងធនធានមនុស្ស ទាំងហេដ្ឋារចនាសម្ព័ន្ធសង្គមត្រូវទទួលរងវិនាសន៍ខ្ទិចខ្ទី ហើយសង្គ្រាមនិងវិនាសកម្មរ៉ាំរ៉ៃក្នុងទសវត្សរ៍ចុងក្រោយនេះបានធ្វើអោយប្រជារាស្ត្រកម្ពុជាបាត់បង់អស់ជំនឿទំនុកចិត្ត ក្ដីសង្ឃឹមរបស់ខ្លួនចំពោះអនាគត និងសុភមង្គលរបស់ប្រទេសជាតិ [៤] ។ ទាំងអស់នេះសុទ្ធតែជាឫសគល់ដែលនាំឱ្យការអោយតំលៃខ្លួនឯងរបស់មនុស្សមានកម្រិតទាប ។

សាលារៀន វិទ្យាស្ថានអប់រំ និងសាកលវិទ្យាល័យមានតួនាទីបណ្តុះបណ្តាលសិស្ស និស្សិតអោយយល់ដឹងអំពីអរិយធម៌ដ៏ស្ញប់ស្ញែងរបស់ខ្លួន តាមរយៈការផ្ដល់សេរីភាពអោយសិស្សវិភាគរកហេតុផល ព្រមទាំងជួយបណ្តុះ និងសាបព្រោះការអោយតំលៃខ្លួនឯងរបស់សិស្ស និងនិស្សិតឡើងវិញ ។ ការយកចិត្តទុកដាក់ជាចំបងលើការអោយតំលៃខ្លួនឯងនេះគឺជាគន្លឹះដ៏មានសារៈសំខាន់ សំរាប់បណ្តុះពលរដ្ឋអោយមានជំនឿក្នុងការកសាងប្រទេសជាតិ និងអាចប្រកួតប្រជែងជាមួយបរទេសក្នុងពេលបច្ចុប្បន្ន ។ ការដែលអាចប្រកួតប្រជែងជាមួយគេបាន លុះណាតែមនុស្សមានសមត្ថភាព និងមានការជឿជាក់លើខ្លួនឯង ។ ការជឿជាក់លើខ្លួនឯងមានសារៈសំខាន់ណាស់ ក្នុងការបណ្តុះបណ្តាលធនធានមនុស្សអោយក្លាយទៅជាអ្នកដឹកនាំដែលមានស្មារតីទទួលខុសត្រូវខ្ពស់ ។ កាលណានិយាយពីអ្នកដឹកនាំគឺសំដៅទៅដល់មនុស្សគ្រប់រូបដែលជាអ្នកដឹកនាំខ្លួនឯងដោយភាព

---

[២] ស៊ន សំណាង : បទពិសោធន៍ក្នុងការអភិវឌ្ឍប្រទេសមាឡេស៊ី ក្នុងសិក្ខាសាលា ខែធ្នូ ឆ្នាំ ២០០៣

[៣] Elizabeth Fiona King , To what extent does culture affect teacher education and practice in Cambodia? , Theses of education , University of London , 2003, p.2

[៤] កៅ គីមហ៊ួន និង ស សុកន្ត័ផ័យ : សន្តិភាពផ្លូវចិត្ត "ដើម្បីសន្តិភាពពិតមួយស្ថិតស្ថេរយូរអង្វែង" ភ្នំពេញ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ១៩៩៦ ទំព័រ.៣៥

ម្ចាស់ការមិនបណ្តោយអោយអណ្តែតត្រសែតទៅតាមការអូសទាញរបស់មិត្តភ័ក្តិដែលជាក្រុមពាលាអាវ៉ាសែ ម៉្យាវិញទៀត មេដឹកនាំដែលរាប់បញ្ចូលទាំងមេគ្រួសារ ទាំងប្រធានក្រុមពិភាក្សា គ្រូបង្រៀន នាយកសាលា និងមនុស្សដទៃទៀតចាំបាច់ត្រូវតែជាមនុស្សស្គាល់ចំណុចខ្លាំងរបស់ខ្លួនព្រមទាំងមានស្មារតីទទួលខុសត្រូវខ្ពស់ និងសកម្មប្រយុទ្ធទៀតផង ។ មនុស្សអាចសម្រេចគោលដៅនេះបាន លុះណាតែមនុស្សនោះមានសមត្ថភាព និងមានការអោយតំលៃលើខ្លួនឯងខ្ពស់ ។

## ១.២- បញ្ហានៃការស្រាវជ្រាវ

ដោយសង្កេតឃើញជាក់ស្តែងថា សិស្សនិងនិស្សិតនៅតាមសាលារៀននៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នមានការជឿជាក់លើខ្លួនឯងទាប ខ្វះទំនុកចិត្តលើខ្លួនឯង ខ្វះជំនឿលើខ្លួនឯង មិនជឿជាក់លើសមត្ថភាពខ្លួន ស្ទាក់ស្ទើរក្នុងការសំរេចចិត្តធ្វើអ្វីមួយអោយបានឆាប់រហ័ស និងមានអារម្មណ៍មិនប្រាកដអំពីជោគវាសនារបស់ខ្លួន ទើបនៅពេលមានការប្រលងប្រជែងម្តងៗ មិនថាតែការប្រលងកម្រិតថ្នាក់ជាតិ និងក្នុងសាលានោះទេ សិស្ស និងនិស្សិតភាគច្រើនតែងតែពឹងពាក់អោយគេឯងជួយរត់ការសូកលុយ ដើម្បីអោយខ្លួនសម្រេចគោលបំណង រឺប្រលងជាប់នៅក្នុងពេលដែលខ្លួនពុំទាន់មានសមត្ថភាពច្បាស់លាស់ ។ បញ្ហាមួយទៀតនោះគឺថា សិស្ស និស្សិតភាគច្រើនបានលួចលាក់យកសំណៅឯកសារមេរៀន ( ប្រ៊ីយ៉ុង) លាក់ទុកជាប់នឹងខ្លួន ដើម្បីបើកចំលងក្នុងពេលដោះស្រាយវិញ្ញាសា និងក្នុងប្រភេទប្រលងផ្សេងៗទៀត ឬពឹងពាក់មនុស្សខាងក្រៅឱ្យរត់យកឯកសារ ឬចំលើយវិញ្ញាសាចូលក្នុងបន្ទប់ប្រលង ។

ម៉្យាងវិញទៀត ពួកគេពុំបានខិតខំត្រិះរិះពិចារណា ដើម្បីដោះស្រាយបញ្ហាដោយខ្លួនឯងនោះឡើយ ។ បញ្ហាទាំងអស់នេះគឺកើតឡើងដោយសារការខ្វះជំនឿទុកចិត្តលើខ្លួនឯង ។ គេអាចកាត់បន្ថយ និងឈានទៅរកការលប់បំបាត់បញ្ហាទាំងនេះបាន អាស្រ័យដោយមានការអប់រំប្រកបដោយគុណភាពទាំងនៅក្នុងថ្នាក់រៀនទាំងនៅក្នុងគ្រួសារ ព្រមជាមួយនឹងការកាត់បន្ថយចំណុចអសកម្មមួយចំនួនរបស់សង្គម ។ ដោយមើលឃើញនូវបញ្ហា និងសារៈសំខាន់នៃការអោយតំលៃខ្លួនឯង អ្នកស្រាវជ្រាវបានចោទជាចំណោទបញ្ហាស្រាវជ្រាវមួយចំនួន ដើម្បីធ្វើការសិក្សាស្រាវជ្រាវពីកត្តាដែលមានសារៈសំខាន់ទាំងនោះសំរាប់លើកស្ទួយការអប់រំ ពិសេសទៅលើការអោយតំលៃខ្លួនឯងរបស់គរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំ ដូចមានសំណួរខាងក្រោម :

១- តើមនុស្សមានការអោយតំលៃខ្លួនឯងខ្ពស់មានលក្ខណៈសំគាល់យ៉ាងណាខ្លះ ?

២- តើការអោយតំលៃខ្លួនឯងរីកលូតលាស់ឡើងអាស្រ័យនឹងកត្តាអ្វីខ្លះ ?

៣- តើនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំមានការអោយតំលៃខ្លួនឯងក៏រិតណា ?

៤- តើការអោយតំលៃខ្លួនឯងរបស់និស្សិតអាស្រ័យនឹងកត្តាអ្វីខ្លះ ?

៥- តើនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំទទួលបានលទ្ធផលល្អកម្រិតណា ?

ដំណោះស្រាយនៅក្នុងចំណោទបញ្ហានៃការស្រាវជ្រាវទាំងនេះនឹងត្រូវបង្ហាញនៅក្នុងស្នាដៃនេះទាំងមូល ។

## ១.៣ – គោលបំណងនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាខាងលើ ការស្រាវជ្រាវនេះមានគោលបំណងដូចខាងក្រោម :

- រកអោយឃើញបណ្តាកត្តាដែលជះឥទ្ធិពលទៅលើការអោយតំលៃលើខ្លួនឯង និងកត្តាដែលធ្វើអោយមានការរាំងស្ទះដល់ការរីកចំរើននៃអោយតំលៃខ្លួនឯងរបស់សិស្ស និងនិស្សិត ។

- រកអោយឃើញកំរិតនៃការអោយតំលៃខ្លួនឯងរបស់និស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ ។

- រកអោយឃើញនូវបណ្តាកត្តាដែលមានទំនាក់ទំនងជាមួយការអោយតំលៃខ្លួនឯង ។

- ផ្អែកលើលទ្ធផលខាងលើ ការស្រាវជ្រាវនេះនឹងឈានទៅដល់ការលើកជាអនុសាសន៍ស្តីអំពីយុទ្ធសាស្ត្រអប់រំ ដើម្បីជួយអភិវឌ្ឍការអោយតំលៃខ្លួនឯងរបស់សិស្ស និងនិស្សិតក្នុងគោលបំណងជំរុញការបណ្តុះបណ្តាលគ្រូបង្រៀន ក៏ដូចជាមន្ត្រីគ្រប់គ្រងអប់រំអោយកាន់តែមានប្រសិទ្ធភាព និងគុណភាព ។

## ១.៤ – ប្រព័ន្ធគំនិត

ដើម្បីបង្ហាញប្រព័ន្ធគំនិតអោយមានលក្ខណៈងាយយល់ ការស្រាវជ្រាវនេះបានរៀបចំបង្កើតប្រព័ន្ធគំនិតជាដ្យាក្រាមមួយ ដើម្បីឆ្លើយតបទៅនឹងគោលបំណង និងបញ្ហានៃការស្រាវជ្រាវ ។ រូបភាពនៃប្រព័ន្ធគំនិតនេះនឹងបង្ហាញពីកត្តានានាដែលមានទំនាក់ទំនងរវាងគ្នានឹងគ្នា ដោយរួមមានកត្តាឱ្យតំលៃខ្លួនឯង កត្តាសមត្ថភាពវិទ្យាសាស្ត្រ កត្តាលក្ខណៈពិសេសផ្ទាល់ខ្លួន និងកត្តាពេញចិត្តនឹងការសិក្សារបស់និស្សិតកម្រិតឧត្តមផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ ។ ជាមួយនេះដែរ សមាសធាតុដែលសន្មតថាមានឥទ្ធិពលដល់ការឱ្យតំលៃខ្លួនឯងក៏ត្រូវបញ្ចូលនៅក្នុងប្រព័ន្ធនេះដែរ ។

នៅក្នុងការស្រាវជ្រាវនេះ ការអោយតំលៃខ្លួនឯងដែលសំដៅទៅលើអារម្មណ៍ ឥរិយាបថ ជំនឿការជឿជាក់លើខ្លួនឯង និងការពេញចិត្តលើខ្លួនឯង ហើយនិងកត្តាលក្ខណៈពិសេសផ្ទាល់ខ្លួនសំដៅទៅលើអាយុភេទ និងកម្រិតអប់រំរបស់និស្សិតគឺជាអថេរឯករាជ្យ ។ រីឯការពេញចិត្តនឹងការសិក្សា និងសមិទ្ធផលសិក្សារបស់គរុនិស្សិតជាអថេរមិនឯករាជ្យ ។




*រូបភាពទី១ : ប្រព័ន្ធគំនិតនៃការស្រាវជ្រាវ*

## ១.៥ - សម្មតិកម្មវិទ្យាសាស្ត្រ

ដើម្បីឆ្លើយតបទៅនឹងបញ្ហា និងវត្ថុបំណងក្នុងបរិបទនៃប្រធានបទនេះ ការស្រាវជ្រាវបានសន្មតនូវសម្មតិកម្មមួយចំនួនដូចខាងក្រោម :

១- និស្សិតនឹងមានការអោយតំលៃខ្លួនឯងកម្រិតខ្ពស់ ហើយរបៀបអប់រំនៅក្នុងគ្រួសារ និងសាលារៀនជះឥទ្ធិពលដល់ការរីកចំរើននៃការអោយតំលៃខ្លួនឯង ។

២- ការអោយតំលៃខ្លួនឯងមានទំនាក់ទំនងវិជ្ជមានជាមួយសមិទ្ធផលសិក្សា ។

៣- កត្តាលក្ខណៈពិសេសផ្ទាល់ខ្លួន ( អាយុ ភេទ អប់រំ) មានឥទ្ធិពលដល់ការអោយតំលៃខ្លួនឯង ។

៤- ការអោយតំលៃខ្លួនឯងមានទំនាក់ទំនងវិជ្ជមានជាមួយការពេញចិត្តនឹងការសិក្សា ។

៥- ការពេញចិត្តនឹងការសិក្សាមានទំនាក់ទំនងវិជ្ជមានជាមួយសមិទ្ធផលសិក្សា ។

ដើម្បីសំរេចបានទូវសម្មតិកម្មខាងលើ ការស្រាវជ្រាវនេះបានខិតខំស្វែងរកទ្រឹស្តីដែលមានទំនាក់ទំនងទៅបង្ហាញនៅក្នុងជំពូកបន្ទាប់ ។

## ១.៦- វិដែនកំណត់នៃការស្រាវជ្រាវ

ទំហំនៃការស្រាវជ្រាវនេះធ្វើឡើងទៅលើឯកសារទ្រឹស្តី ដែលទាក់ទងទៅនឹងការអោយតំលៃខ្លួនឯង (self-esteem) និងគុណភាពសិក្សា ។ ការបង្កើតកម្រងសំណួរស្រាវជ្រាវធ្វើតែទៅលើគរុនិស្សិតផ្នែកវិទ្យា-សាស្ត្រ និងគណិតវិទ្យានៃវិទ្យាស្ថានជាតិអប់រំ (វជអ) តែប៉ុណ្ណោះ ។ អ្នកចូលរួមក្នុងការស្រាវជ្រាវមានចំនួន ៧៧នាក់ ដែលសុទ្ធតែជានិស្សិតបរិញ្ញាបត្រ័បូក ១ ដែលនឹងត្រូវទៅបំរើវិស័យអប់រំតាមបណ្តាខេត្តក្រុងនៃព្រះរាជាណាចក្រកម្ពុជា ។ កម្រងសំនួរនៃការឱ្យតំលៃខ្លួនឯងត្រូវបានដកស្រង់ពីសំណួរតាមអ៊ីនធឺណេត ដោយយកមកកែច្នៃអោយសមស្របតាមស្ថានភាពជាក់ស្តែង ហើយត្រូវយកមកធ្វើតែសតាមចិត្តវិទ្យា ដើម្បីស្វែងរកការអោយតំលៃខ្លួនឯងរបស់គរុនិស្សិតម្នាក់ៗ ។ រីឯកម្រងសំណួរទាក់ទងនឹងសមត្ថភាពវិទ្យាសាស្ត្រ និងការពេញចិត្តនឹងការសិក្សាត្រូវបានធ្វើឡើង ដោយផ្អែកលើការធ្វើតែសវាយតំលៃលើមុខវិជ្ជាសិក្សាជាក់ស្តែងដែលសាស្ត្រាចារ្យខ្មែរ និងជំនាញការជប៉ុនបានឯកភាពយកមកប្រើនៅក្នុងវគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ ។ ការស្រាវជ្រាវនេះត្រូវបានធ្វើការវាស់វែងតែទៅលើអថេរការពេញចិត្តនឹងការសិក្សា អថេរការឱ្យតំលៃខ្លួនឯង អថេរលក្ខណៈពិសេសផ្ទាល់ខ្លួន និងអថេរសមិទ្ធផលសិក្សាប៉ុណ្ណោះ ។ ការស្រាវជ្រាវនេះអាចមានលក្ខណៈស៊ីជំរៅអំពីអារម្មណ៍ផ្ទាល់ខ្លួនរបស់គរុនិស្សិត និងមានលក្ខណៈច្បាស់លាស់ ដោយកម្រងសំណួរសុទ្ធតែបង្ហាញពីអ្វីដែលនិស្សិតបានជួបប្រទះ និងបានទទួលយក តាមរយៈការអនុវត្តកម្មវិធីបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ ។ ការស្រាវជ្រាវអំពីការឱ្យតំលៃខ្លួនឯង និងគុណភាពសិក្សានេះអាចជាមូលដ្ឋានគ្រឹះខាងទ្រឹស្តី និងគោលការណ៍អនុវត្តក្នុងការបណ្តុះបណ្តាលគ្រូ ក៏ដូចជាបណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងផ្សេងទៀតអោយមានស្មារតីម្ចាស់ការក្នុងការបំពេញភារកិច្ចខ្លួនដោយការទទួលខុសត្រូវខ្ពស់ ។ ការស្រាវជ្រាវនេះបានប្រើ-ប្រាស់សំណួរបែបបរិមាណវិស័យផង និងសំណួរបែបគុណវិស័យផង ដើម្បីស្វែងរកអោយឃើញពីការឱ្យតំលៃខ្លួនឯង និងសមត្ថភាពសិក្សារបស់គរុនិស្សិតអោយកាន់តែស៊ីជំរៅ ។

# ជំពូកទី២
# មូលដ្ឋានទ្រឹស្តី

ស្នាដៃស្រាវជ្រាវនេះបានផ្តោតទៅលើទ្រឹស្តីនិយាយអំពីការអោយតំលៃខ្លួនឯង និងគុណភាពសិក្សា ។ ទ្រឹស្តីដែលទាក់ទងនឹងបញ្ញត្តិការអោយតំលៃខ្លួនឯង និងគុណភាពសិក្សាសមត្ថភាពវិទ្យាសាស្ត្រត្រូវលើកយកមកប្រៀបធៀប ដោយផ្អែកលើឯកសារនៃស្នាដៃស្រាវជ្រាវរបស់បរទេសដែលបានធ្វើពីមុន ។ ដោយមូលហេតុការអោយតំលៃខ្លួនឯងជាសមាសធាតុមួយនៃបុគ្គលិកលក្ខណៈ ដូច្នេះបញ្ញត្តិនៃបុគ្គលិកលក្ខណៈនឹងត្រូវលើកយកមកបកស្រាយពន្យល់សំរាប់ជាមូលដ្ឋានទ្រឹស្តីនៃការស្រាវជ្រាវនេះដែរ ។

## ២.១- បញ្ញត្តិបុគ្គលិកលក្ខណៈ

### ២.១.ក - និយមន័យបុគ្គលិកលក្ខណៈ

ពាក្យបុគ្គលិកលក្ខណៈមានប្រភពចេញពីពាក្យ ឡាតាំង Persona ដែលមានន័យដើមថា "របាំងមុខ" ។ មនុស្សនាំមុខគេដែលផ្តោតការយកចិត្តទុកដាក់លើបញ្ញត្តិនេះគឺលោក Gordon Allport [5] ដោយបានប្រមូលនិយមន័យនានារបស់ពាក្យនេះជាច្រើនចូលទៅក្នុងបញ្ជី ។ លោក Allport បានបញ្ជាក់ន័យពាក្យបុគ្គលិកលក្ខណៈដោយផ្អែកលើចំណាត់ថ្នាក់៣ប្រភេទដូចខាងក្រោមៈ

- ប្រភេទទី១ៈ លោក Allport បញ្ជាក់ន័យរបស់ពាក្យនេះដោយផ្អែកលើគោលវិធីឥទ្ធិពលខាងក្រៅថា បុគ្គលិកលក្ខណៈត្រូវបានគេមើលឃើញថាជាគុណសម្បត្តិជាក់លាក់របស់បុគ្គលនៅពេលគេធ្វើការសង្កេត។ និយមន័យនេះពុំបានមើលអោយស៊ីជំរៅខាងក្នុងរបស់មនុស្សបានទេ ដោយគេមើលតែភិនភាគខាងក្រៅដែលជាហេតុនាំអោយគេធ្វើការប៉ាន់ប្រមាណអំពីអាកប្បកិរិយារបស់មនុស្សមានភាពទូលាយ ។ ពាក្យនេះមានប្រភពចេញពីរបាំងមុខដែលពាក់ដោយតួសំដែងសិល្បៈជនជាតិរ៉ូម៉ាំងតាមរយៈល្ខោនក្រិចបុរាណ ដោយមើលឃើញតែផ្ទៃមុខដែលគេពាក់ ឬរូបរាងខាងក្រៅរបស់តួសំដែង ដោយគេពុំបានដឹងលក្ខណៈជាក់ស្តែងថា តួអង្គនោះមានអារម្មណ៍ និងសភាពលក្ខណៈបែបណាឡើយ ។

- ប្រភេទទី២ៈ លោក Allport និយាយសំដៅទៅលើរចនាសម្ព័ន្ធខាងក្នុង ដោយមើលឃើញថាបុគ្គលិកលក្ខណៈពុំមែនជារបាំងមុខពិតប្រាកដនោះទេ ប៉ុន្តែវាជារចនាសម្ព័ន្ធសរីរចិត្តវិទ្យា (Phiso-psycho logical Structure) ។ បុគ្គលិកលក្ខណៈជាសមាសភាគផ្សេងៗគ្នានៃចរិតលក្ខណៈខាងក្នុង ដោយគាត់បាន

---

[5] សូមមើល Jess Feist, Theories of Personality, Holt, Rinehart & Winston Inc, 1990 p. 7-13 និង Raghda I. Saba, Lecture of Introduction to Personality Theories, 1999, p.1-5

បញ្ជាក់ថា បុគ្គលិកលក្ខណៈជាការប្រមូលផ្តុំកម្លាំងថាមពល (dynamic organization) ដែលមាននៅក្នុងប្រព័ន្ធសរីរចិត្តសាស្ត្ររបស់មនុស្សដែលកំណត់ទៅលើការគិត កាយវិការ និងឥរិយាបថរបស់មនុស្ស ។

- ប្រភេទទី៣ : លោក Allport អោយនិយមន័យនៃពាក្យបុគ្គលិកលក្ខណៈដោយផ្អែកទៅលើទស្សនៈវិជ្ជមានថា បុគ្គលិកលក្ខណៈអាចត្រូវគេធ្វើការវាស់វែងបានតាមរយៈការធ្វើតែសចិត្តវិទ្យា ។ ដូច្នេះគេអាចអោយនិយមន័យពាក្យនេះបាន តាមរយៈការអោយពិន្ទុដែលគេធ្វើតែសបុគ្គលិកលក្ខណៈ ឬតាមរបាយការណ៍របស់អ្នកសង្កេតដែលមានការហ្វឹកហ្វឺន ។ ទោះជាយ៉ាងណាក៏ដោយ ក៏ពុំទាន់មាននិយមន័យណាមួយដែលអាចទទួលយកបានចំពោះអ្នកទ្រឹស្តីបុគ្គលិកលក្ខណៈផ្សេងទៀតឡើយ ។ ចិត្តវិទូផ្នែកបុគ្គលិកលក្ខណៈទំនើបបានកំណត់និយមន័យបុគ្គលិកលក្ខណៈ អាស្រ័យទៅលើគោលបំណងស្រាវជ្រាវ និងការអង្កេតដ៏ជាក់លាក់របស់គេ ។

លោក Maddi (1976) និងលោក Mischel (1976) បានអោយនិយមន័យថា បុគ្គលិកលក្ខណៈរួមមានរចនាបទផ្សេងគ្នា និងមិនមានការប្រែប្រួលដែលទាក់ទងគ្នាស្តីពីការគិត អាកប្បកិរិយា និងការឆ្លើយតបទិដ្ឋភាពផ្លូវចិត្តដែលបញ្ជាក់ពីការចុះសំរុងរបស់មនុស្សចំពោះកាលៈទេសៈជុំវិញ[៦] ។ តាមន័យទូទៅ លោក Jess Feist បានបញ្ជាក់ថា បុគ្គលិកលក្ខណៈសំដៅទៅលើចរិកលក្ខណៈ (characteristics) អារម្មណ៍ និងលក្ខណៈអចិន្ត្រៃយ៍ (permanent trait) របស់បុគ្គលម្នាក់ៗដែលមានបង្កប់នូវភាពនឹងនរ មិនប្រែប្រួលនៃអាកប្បកិរិយារបស់បុគ្គលនោះ[៧] ។ នេះបានសេចក្តីថា បុគ្គលិកលក្ខណៈមានការរួមផ្សំរវាងលក្ខណៈប្រែប្រួលផង (ដូចជាការគិត ការយល់ដឹង ទស្សនៈបំណិន) និងលក្ខណៈមិនប្រែប្រួលផង (ដូចជា លក្ខណៈបុគ្គលឆាប់ខឹង ឆេវឆាវ ងាយអូសទាញ។ល។) ។

លោក John W. Santrock បានអោយនិយមន័យថា បុគ្គលិកលក្ខណៈជាអាកប្បកិរិយា ចិត្តរំភើប និងការគិតផ្សេងពីគ្នាដែលមិនប្រែប្រួលដែលបុគ្គលអាចប្រព្រឹត្ត ដើម្បីដោះស្រាយ រឺសម្របទៅតាមមជ្ឈដ្ឋានខាងក្រៅ[៨] ។ និយាយជារួម មនុស្សតែងមានបុគ្គលិកលក្ខណៈពិសេសផ្ទាល់ខ្លួនឯងម្នាក់ៗដែលធ្វើឱ្យមនុស្សម្នាក់ខុសប្លែកពីមនុស្សម្នាក់ទៀត តែទោះជាយ៉ាងណា គេតែងមើលឃើញពីលក្ខណៈពិសេសមិនចេះប្រែប្រួល (trait) និងលក្ខណៈដែលប្រែប្រួល (state) នៅក្នុងបុគ្គលិកលក្ខណៈរបស់មនុស្សដែលគេអាចសំគាល់

---

[៦] Camile B. Wortman ; Elizabeth F. Loftus, Psychology, New York, Alfred A.Knopf,1988, p. 345

[៧] Jess Feist, Theories of Personality.,op.cit., p7

[៨] John W. Santrock, Psychology, USA, Brown & Benchmark, 1994, p.402.

ការសំដែងអាកប្បកិរិយារបស់មនុស្សបាន ។ បុគ្គលិកលក្ខណៈត្រូវបានក្រុមអ្នកប្រាជ្ញខាងបុគ្គលិកលក្ខណៈ ខិតខំស្រាវជ្រាវ និងបានរកឃើញទ្រឹស្តីផ្សេងៗគ្នា ។

### ២.១.២ - ទ្រឹស្តីបុគ្គលិកលក្ខណៈ

ទ្រឹស្តីបុគ្គលិកលក្ខណៈជាប្រព័ន្ធនៃការប៉ាន់ប្រមាណ គំនិត និងគោលការណ៍ដែលលើកឡើង ដើម្បីពន្យល់អំពីបុគ្គលិកលក្ខណៈ [៩] ។ មនុស្សបានមើលឃើញស្ថានភាពដូចគ្នាក្នុងរបៀបផ្សេងពីគ្នាស្តីអំពីមនុស្ស ។ ការគិត និងការប៉ាន់ស្មានក្នុងទិដ្ឋភាពផ្សេងគ្នានេះនាំអោយមនុស្សមើលឃើញបុគ្គលិកលក្ខណៈផ្សេងពីគ្នាដែលនេះជាហេតុនាំអោយមានទស្សនៈទ្រឹស្តីអំពីបុគ្គលិកលក្ខណៈមានច្រើនប្រភេទ ។ ទោះជាមានទ្រឹស្តីបុគ្គលិក-លក្ខណៈច្រើនយ៉ាងនេះក៏ដោយ តែទ្រឹស្តីដែលមានឥទ្ធិពល និងពេញនិយមមានដូចខាងក្រោម :

- **ទ្រឹស្តីចិត្តវិភាគ** (Psychoanalytic Theory) ទ្រឹស្តីចិត្តវិភាគនេះត្រូវបានបង្កើតឡើងមុនគេបង្អស់ដោយលោក Sigmund Freud ។ តាមទ្រឹស្តីនេះ បុគ្គលិកលក្ខណៈលេចឡើងអាស្រ័យទៅលើកំលាំងចិត្ត វិចលករផ្លូវភេទ និងសភាវគតិ ។ បុគ្គលិកលក្ខណៈជាអញ្ញាណ (unconsciousness) ដែលបានកប់ជ្រៅដោយគេមិនបានដឹង បណ្តាលមកពីចិត្តរំភើប (emotion) អវិជ្ជមានកាលពីកុមារភាព [១០] ។

មនុស្សធ្វើសកម្មភាពអាស្រ័យដោយសារកំលាំងជំរុញដែលមានប្រភពពីចំណង់ផ្លូវភេទកាលពីកុមារភាព ។ បទពិសោធន៍ពីកុមារភាពដំបូងជាមួយឪពុកម្តាយបានដក់ជាប់ និងអាចកំណត់រូបរាងបុគ្គលិកលក្ខណៈរបស់មនុស្សទាំងមូល ។ វត្ថុនានាដែលកើតឡើងពីស្មាដៃមនុស្សពឹងផ្អែកទាំងស្រុងលើយន្តកម្មផ្លូវចិត្តដែលប្រទាញប្រទង់គ្នារវាងកំលាំងសភាវគតិ (សេចក្តីត្រេកត្រអាល ការសប្បាយរីករាយ ចំណង់ផ្លូវភេទ សេចក្តីស្នេហា ការលោភលន់) ជាមួយនឹងនិយាមសង្គម និងតម្រូវការរបស់សង្គម(តំលៃយល់ដឹងខាងសីលធម ចំណេះដឹង) ។ ចំណង់ និងសភាវគតិរបស់មនុស្សមានតាំងពីកំណើតដោយចាក់ឫសយ៉ាងជ្រៅ និងរក្សាកប់ទុកតាំងពីកុមារភាព ។ តាមយន្តការនេះ សកម្មភាពបច្ចុប្បន្នកើតឡើងដោយសារអញ្ញាណដែលត្រូវគេសន្មតថាអតីតកាលកំណត់ឱ្យមានបច្ចុប្បន្នកាល ។ ទ្រឹស្តីចិត្តវិភាគបានផ្តោតយ៉ាងខ្លាំងទៅលើមូលដ្ឋាននៃចលករផ្លូវភេទ ។ លោក Freud បានបញ្ជាក់ថា មនុស្សធ្វើសកម្មភាពនានាដោយសារឥទ្ធិពលនៃកំលាំងអញ្ញាណជំរុញដែល បណ្តាលមកពីតម្រូវការផ្លូវភេទ (ការប៉ះពាល់សេចក្តីថ្នាក់ថ្នមរបស់ម្តាយចំពោះកុមារមុនអាយុប្រាំឆ្នាំ) ដែលកុមារមិនបានទទួលបណ្តាលអោយមានវិបត្តិផ្លូវចិត្តដែលកប់នៅក្នុងអញ្ញាណ ។ ទ្រឹស្តីនេះបង្ហាញឱ្យឃើញ

---

[៩] Dennis Coon, Essentials of Psychology, exploration and application, Soy Inc, 1994, p.452

[១០] John W. Santrock, Psychology, op.cit. , p.402

ថា ថាមពលផ្លូវភេទមានឥទ្ធិពលដល់ទង្វើរបស់មនុស្ស ។ មនុស្សធ្វើអ្វីៗដោយសារមកពីចំណង់ផ្លូវភេទដែល គេប្រៀបដូចជាសត្វពស់ ។ ជាធម្មតា សត្វពស់ពុំចេះនៅកន្លែងកណ្តាលវាលល្ហល្ហេវទេ ។ នៅពេលមនុស្សយក សត្វពស់មកដាក់កណ្តាលវាល សត្វនេះនៅបានតែមួយរយៈពេលខ្លី បន្ទាប់មកវានឹងលូនទៅរកធម្មជាតិដើម វាវិញគឺព្រៃក្រប៉ូត ឬទីងងឹត ។ ធម្មជាតិរបស់សត្វនេះគឺកន្លែងកៀនកោះ ស៊ុបទ្រុប ។ ពេលវាលូនចេញមក ខាងក្រៅគ្រាន់តែមួយអន្លើ ដើម្បីរកចំណី ហើយទីបំផុត វានឹងវិលទៅរកសភាពដើមវាវិញ រីឯមនុស្សកើត ចេញពីកាម (ផ្លូវភេទ) ការសម្តែងចេញមកខាងក្រៅ ការទំនាក់ទំនង ការធ្វើការងារគឺកើតចេញពីយន្តកម្ម ជំនួសឱ្យសភាវគតិផ្លូវភេទប៉ុណ្ណោះ ទីបំផុតមនុស្សនឹងរត់ទៅរកធម្មជាតិដើមរបស់ខ្លួនគឺចំណង់ផ្លូវភេទនោះឯង វិញ ។ ជំលោះផ្នែកខាងក្នុង និងការប្រកួតប្រជែងរវាងអញ្ញាណ និងញាណនាំឱ្យកកើតឡើងបានជាអំពើរបស់ មនុស្សដែលត្រូវបានស្តែងឱ្យឃើញពីបុគ្គលិកលក្ខណៈ ។ លោក Sigmund Freud (១៩១៧) បញ្ជាក់ថា សភាវគតិដែលកប់ជ្រៅដែលមិនបានដឹងមានឥទ្ធិពលលើរបៀបនៃការគិតដល់អារម្មណ៍ និងការសំដែងចេញ ជាសកម្មភាពរបស់មនុស្ស ។ កំលាំងសភាវគតិ កំលាំងជំរុញដែលបណ្តាលមកពីតម្រូវការផ្លូវភេទតែងតែមាន ជំលោះជាមួយតម្រូវការរបស់សង្គម [១១] ។ ផ្អែកលើទ្រឹស្តីនេះ ការអោយតំលៃខ្លួនឯងរបស់មនុស្សម្នាក់ៗអាច កើតចេញពីហេតុផលអតីតភាពរបស់ខ្លួន និងកើតចេញពីបទពិសោធន៍ដែលជះឥទ្ធិពលមក លើរូបគេតាំងតែពី គេនៅកុមារភាពមកម្លេះ ជាពិសេស ទំនាក់ទំនងរវាងកុមារជាមួយម្តាយ និងកុមារជាមួយកុមារដទៃ។ល។

- ទ្រឹស្តីអាកប្បកិរិយានិយម (Behaviorism Theory)

មនុស្សបង្កើតទ្រឹស្តីនេះមុនគេគឺលោក Skinner និងលោក Watson ។ លោក Skinner បានសន្និ-ដ្ឋានថា បុគ្គលិកលក្ខណៈជាអាកប្បកិរិយារបស់មនុស្សដែលត្រូវកំណត់ដោយមជ្ឈដ្ឋានខាងក្រៅ [១២] ។ មជ្ឈ-ដ្ឋានខាងក្រៅខ្លួន និងឥទ្ធិពលនៃល័ក្ខខ័ណ្ឌ (គ្រឿងលើកទឹកចិត្ត និងទណ្ឌកម្ម) ដើរតួនាទីដ៏សំខាន់ដល់បុគ្គលិក លក្ខណៈ ព្រោះមនុស្សធ្វើសកម្មភាពផ្សេងៗពឹងផ្អែកទៅលើមជ្ឈដ្ឋានដែលគេកំពុងតែរស់នៅ ។ ល័ក្ខខ័ណ្ឌនៃ កត្តាខាងក្រៅខ្លួនតម្រូវឱ្យមនុស្សខិតខំប្រឹងប្រែង ឬមិនប្រឹងប្រែងធ្វើសកម្មភាពបែបណាមួយ ។ មនុស្សធ្វើ សកម្មភាពមកពីចលករខាងក្នុងខ្លួនរបស់គេ និងចលករខាងក្រៅខ្លួន ។ ទាសករខិតខំធ្វើសកម្មភាពមកពីការ ដាក់ទណ្ឌកម្ម ដែលជាឥទ្ធិពលខាងក្រៅ រីឯការខិតខំប្រឹងប្រែងរៀនសូត្ររបស់សិស្សមកពីចលករចង់សិក្សា របស់គេ និងការទទួលបានរង្វាន់ដែលជាកត្តាខាងក្រៅខ្លួន ។ ទស្សនៈអាកប្បកិរិយានិយមបញ្ជាក់ថា មនុស្ស

---

[១១] John W. Santrock, Psychology, op.cit., p.7

[១២] Ibid. , p 411

ជួបរឿងរ៉ាវ និងព្រឹត្តការណ៍បច្ចុប្បន្ននៅក្នុងមជ្ឈដ្ឋាន គេនឹងធ្វើសកម្មភាព ដើម្បីឆ្លើយតបដោយស្របតាមតម្រូវការរបស់គេ ។ ដូច្នេះអាកប្បកិរិយារបស់មនុស្សដែលសំដែងមកខាងក្រៅតាមរយៈប្រតិកម្មឆ្លើយតបទៅនឹងអ្វីដែលគេជួបប្រទះនឹងកត្តាមជ្ឈដ្ឋានខាងក្រៅ ។ តាមទស្សនៈនេះ ការឱ្យតំលៃខ្លួនឯងរបស់មនុស្សមានឥទ្ធិពលពីមជ្ឈដ្ឋានដែលគេកំពុងរស់នៅ ដូចជាឪពុកម្តាយ សាលារៀន ទំនាក់ទំនងសង្គម និងពីកត្តាផ្ទាល់ខ្លួនរបស់គេផងដែរ ។

- **ទ្រឹស្តីមនុស្សនិយម** (Humanistic Theory)

លោក អាប្រាហាម ម៉ាស្លូ (Abraham Maslow) បានចាត់ទុកទ្រឹស្តីនេះជារលកចលករទីបីនៃទ្រឹស្តីបុគ្គលិកលក្ខណៈ បន្ទាប់ពីទ្រឹស្តីចិត្តវិភាគ និងអាកប្បកិរិយានិយម ។ លោក Carl Roger (1961) និងលោក Maslow (1971) បានបញ្ជាក់ថា ទ្រឹស្តីមនុស្សនិយមផ្តោតទៅលើសេរីភាព សមត្ថភាពរបស់មនុស្សសំរាប់ការរីកលូតលាស់ដោយអាស្រ័យលើគុណភាពវិជ្ជមានរបស់មនុស្ស [១៣] ។ ការរីកលូតលាស់របស់មនុស្ស និងការសំដែងសកម្មភាពគឺអាស្រ័យលើបទពិសោធន៍ និងសមត្ថភាពឯកជនរបស់មនុស្ស ។ បទពិសោធន៍ផ្ទាល់ខ្លួនឯងនេះមានឥទ្ធិពលដល់ការអភិវឌ្ឍបុគ្គលិកលក្ខណៈ ។ ទង្វើដែលមនុស្សធ្វើគឺដោយសារកត្តាផ្ទាល់ខ្លួនគេ វាពុំមែនមកពីកត្តាខាងក្រៅ ឬកត្តាអញ្ញណណាឡើយ ដោយមានការវិវាទជាមួយទ្រឹស្តីចិត្តវិភាគ និងអាកប្បកិរិយានិយម ។ ទស្សនៈមនុស្សនិយមក៏បានច្រានចោលទស្សនៈប្រពៃណីនិយម ដែលបានធ្វើការប្រៀបធៀបមនុស្សទៅនឹងបន្ទះឈើដែលស្ថិតនៅលើផ្ទៃទឹកសមុទ្រ និងប្រៀបធៀបទឹកសមុទ្រទៅនឹងសង្គមមនុស្សដែលគេរស់នៅ ។ នៅពេលខ្យល់បក់មក បន្ទះឈើនឹងរំជើបរំជួលទៅតាមទឹករលកសមុទ្រដែលនាំសំដៅទៅទីកន្លែងណាមួយ ។ ដូចគ្នានេះដែរ មនុស្សទៅជាបែបណាមួយគឺដោយសាររលកសង្គម ឬកត្តាមជ្ឈដ្ឋាននាំទៅបែបនោះ ។ ទោះជាយ៉ាងនេះក៏ដោយ តាមទ្រឹស្តីមនុស្សនិយមបង្ហាញអោយឃើញថា មនុស្សជាម្ចាស់វាសនាគ្រប់គ្រងលើខ្លួនឯង មានសមត្ថភាពអាចប្រឈមទៅនឹងបញ្ហា និងមានលទ្ធភាពទ្រទ្រង់ដោយខ្លួនឯង មិនមែនទទន់ជ្រាយ ទទួលរងឥទ្ធិពលមជ្ឈដ្ឋាន និងសង្គមទាំងស្រុងឡើយ ព្រោះមនុស្សវិញទេដែលជាអ្នកធ្វើអំពើដែលនាំអោយសង្គមទៅបែបណានោះ ។

លោក John W. Santrock បានអះអាងថា មនុស្សមានសមត្ថភាពដោយខ្លួនឯងក្នុងការដោះស្រាយបញ្ហា និងមានសមត្ថភាពគ្រប់គ្រងជីវិតខ្លួនឯង ព្រមទាំងសម្រេចបានអ្វីមួយដោយសារខ្លួនចង់បាន ។ ជាមួយនេះ មនុស្សមានសមត្ថភាពយល់ដឹងពីខ្លួនឯង និងពីពិភពលោក ។ របៀបដែលយើងយល់ជ្រាបពីខ្លួន

---

[១៣] John W. Santrock, Psychology, op.cit., p.415

យើង និងមជ្ឈដ្ឋានជុំវិញខ្លួនយើងគឺជាធាតុដ៏សំខាន់នៃបុគ្គលិកលក្ខណៈ[១៤] ។ តាមទស្សនៈមនុស្សនិយមមនុស្សប្រៀបបានទៅនឹងពេជ្រដែលមិនទាន់ច្នៃ លុះដល់ពេលធ្វើការកែច្នៃហើយ នោះតំលៃរបស់វាកាន់តែខ្ពស់ ស្រដៀងគ្នានេះដែរ មនុស្សមានតំលៃខ្លួនស្រាប់ពីធម្មជាតិ លុះបានកែច្នៃហើយ គេនឹងប្រសើរកាន់តែខ្លាំងឡើង ។ អាកប្បកិរិយាដែលមនុស្សសំដែងឡើងគឺដោយសារតែមនុស្សខ្លួនឯងផ្ទាល់ ពុំមែនដោយកំលាំងអាទិទេព ឬ កំលាំងអញ្ញាណណាឡើយ ។

រួមសេចក្តីមក ទ្រឹស្តីបុគ្គលិកលក្ខណៈផ្តោតទៅលើវិសាលភាពនៃបុគ្គលិកលក្ខណៈដែលនាំទៅដល់ការកើតចេញជាអាកប្បកិរិយារបស់មនុស្សក្នុងហេតុផលផ្សេងគ្នា ។ ទ្រឹស្តីមនុស្សនិយមអះអាងថា បុគ្គលិកលក្ខណៈកើតចេញពីការខិតខំប្រឹងប្រែង និងកើតពីការអោយតំលៃខ្លួនឯងផ្ទាល់របស់មនុស្ស ។ ទ្រឹស្តីចិត្តវិភាគបញ្ជាក់ថា បុគ្គលិកលក្ខណៈកើតចេញពីជម្លោះរវាងចំណង់ផ្លូវភេទជាក់លាក់ ភាពកំរោលខាងក្នុង សេចក្តីសប្បាយរីករាយជាមួយនឹងសំពាធសង្គមដែលតំណាងអោយចរិយាធម៌ រីឯទ្រឹស្តីអាកប្បកិរិយានិយមបញ្ជាក់ថា បុគ្គលិកលក្ខណៈកើតចេញពីចំណង់ខាងក្នុង និងខាងក្រៅ ដើម្បីឆ្លើយតបទៅនឹងមជ្ឈដ្ឋានខាងក្រៅខ្លួន ។

### ២.១.គ - កត្តាដែលជះឥទ្ធិពលដល់ការអភិវឌ្ឍបុគ្គលិកលក្ខណៈ

តាមចិត្តវិទ្យា មានទស្សនៈពីរប្រភេទដែលគេមើលឃើញពីរឿងរ៉ាវ ឬភាវៈនានាកកើតឡើង ឬ ដំណើរការឡើង ដោយមិនត្រឹមតែនិយាយអំពីលំនាំប្រវត្តិសាស្រ្តប៉ុណ្ណោះទេ តែថែមទាំងពីគំនិតរបស់មនុស្ស និងការអភិវឌ្ឍរបស់គេថែមទៀត ។ គំនិតទាំងពីរនេះមានលក្ខណៈផ្ទុយគ្នាទាំងស្រុង ។

ក្រុមទីមួយគឺគោលទ្រឹស្តី Mechanism របស់លោក Sigmund Freud និងមួយទៀតគឺគោលទ្រឹស្តី Teleology របស់លោក Carl Jung ។ ទ្រឹស្តី Mechanism បញ្ជាក់ថា រឿងរ៉ាវកើតឡើងដោយសារហេតុ និង ផល ។ រឿងមួយកើតឈានទៅដល់កើតរឿងមួយទៀត ដែលអាចឈានទៅនឹងកើតរឿងមួយផ្សេងទៀតជាបន្តបន្ទាប់ ដែលគេអាចនិយាយបានថាអតីតកាលកំណត់បច្ចុប្បន្នកាល ។ រីឯទស្សនៈទ្រឹស្តី Teleology បញ្ជាក់ថា ដោយសារតែមនុស្សមានគំនិតគិតពីអនាគតតាមរយៈគោលបំណង តម្លៃ និង អត្ថន័យ ។ល។ដែលទាក់ទងទៅនឹងឆន្ទៈ និងសេរីភាពរបស់គេ និងដោយសារមនុស្សធ្វើអ្វីៗសុទ្ធតែមានគោលបំណង និងយល់ថាខ្លួនគេនឹងមានតម្លៃ និងមានន័យសំរាប់ពេលអនាគត ទើបនាំអោយគេធ្វើសកម្មភាពនានាដែលអាចអោយគេធ្វើការសង្កេតបុគ្គលិកលក្ខណៈបាន ។

---

[១៤] John W. Santrock, Psychology, op.cit., p.415

យោងតាមទស្សនៈរបស់លោក Freud ការអភិវឌ្ឍបុគ្គលិកលក្ខណៈពេលបច្ចុប្បន្នគឺមានឫសគល់តាំងពីដើមវ័យកុមារភាពរបស់មនុស្សមកម្លេះ ។ អាកប្បកិរិយា ឥរិយាបថ និងចិត្តគំនិតដែលមនុស្សមានរហូតមកដល់ពេលបច្ចុប្បន្ននេះមានប្រភពពីរឿងរ៉ាវ និងបទពិសោធន៍នានាដែលគេបានដក់ជាប់យ៉ាងជ្រៅពីអតីតកាល ។ លើសពីនេះទៅទៀត រឿងរ៉ាវដែលដំណើរការឡើងគឺដោយសារកំលាំងសភាវគតិដែលជាកត្តារុញច្រានឱ្យមនុស្សធ្វើសកម្មភាពនាពេលបច្ចុប្បន្ន ។ កត្តាសភាវគតិរបស់មនុស្សនេះមានតាំងពីកំណើតមកម្លេះ ដូច្នេះមនុស្សធ្វើសកម្មភាព និងមានអាកប្បកិរិយាដូចសព្វថ្ងៃគឺជាការទទួលមតិកផ្លូវចិត្តតាំងពីតូចតរៀងមក ។ បុគ្គលិកលក្ខណៈរបស់មនុស្សមានប្រភពកើតចេញពីអតីតកាល ។

តាមទស្សនៈ Teleology បានបង្ហាញអោយឃើញថា មនុស្សធ្វើសកម្មភាព ដោយសារគោលបំណង តំលៃ និងតម្រូវការផ្នែកផ្លូវចិត្តរបស់គេសំរាប់ថ្ងៃអនាគត តាមសេរីភាពនៃឆន្ទៈរបស់គេ ។ សិស្សដែលធ្វើសកម្មភាពទៅកើតគឺកើតឡើង ដោយសារគេមើលឃើញពីតម្លៃរបស់គេនៅថ្ងៃអនាគត ។ អ្នកជំនួញខិតខំធ្វើការរកស៊ីនាពេលបច្ចុប្បន្នទំនងមកពីគេមានគោលបំណងចង់ក្លាយជាអ្នកមានទ្រព្យសំរាប់ថ្ងៃអនាគតរបស់គេ ។ ដោយសារមនុស្សរស់នៅត្រូវមានគោលបំណងសំរាប់បំពេញមហិច្ឆតា និងតម្រូវការរបស់ខ្លួន ដូច្នេះហើយមនុស្សខិតខំធ្វើសកម្មភាពឡើង ។ មនុស្សមានសកម្មភាពផ្សេងគ្នាបណ្តាលមកពីបុគ្គលិកលក្ខណៈរបស់គេដែលកើតចេញពីការមើលឃើញពីគោលបំណងរបស់ខ្លួននៅថ្ងៃអនាគត ។

ទោះជាមានទស្សនៈស្តីពីការអភិវឌ្ឍបុគ្គលិកលក្ខណៈផ្សេងគ្នាក៏ដោយ តែកត្តាដែលត្រូវបានគេមើលឃើញថាមានការជះឥទ្ធិពលដល់បុគ្គលិកលក្ខណៈរបស់មនុស្សរួមមាន កត្តាតំណពូជ កត្តាមជ្ឈដ្ឋានសង្គម កត្តាសកម្មភាពផ្ទាល់ខ្លួន និងកត្តាអប់រំ [១៥] ។

## ២.២ — បញ្ញត្តិនៃការអោយតំលៃខ្លួនឯង

### ២.២.ក-និយមន័យការអោយតំលៃខ្លួនឯង

បញ្ញត្តិនៃការអោយតំលៃខ្លួនកើតចេញពីពាក្យ ខ្លួន + ការអោយតំលៃ ។

- **ខ្លួន (អាត្មន)** : ( Self )

បញ្ញត្តិនៃពាក្យខ្លួនត្រូវបានក្រុមអ្នកប្រាជ្ញ វិទ្យាសាស្ត្រទំនើប អ្នកស្រាវជ្រាវ អ្នកបង្កើតទ្រឹស្តីសាសនាជាច្រើនខិតខំស្វែងយល់អំពីអត្តសញ្ញាណរបស់វា ដោយបានយល់ឃើញក្នុងសភាពប្រហាក់ប្រហែលគ្នា លើកលែងតែក្រុមអ្នកសាសនានិយមដែលជឿលើអាទិទេព ។ មនុស្សម្នាក់ៗតែងតែមានអត្តសញ្ញាណគ្រប់គ្នាដែល

[១៥] សូមមើល ចាន់ រដ្ឋសុជា : ការអភិវឌ្ឍនៃបុគ្គលិកលក្ខណៈរបស់មនុស្ស ក្នុងអត្ថបទមេរៀន ឆ្នាំ ២០០៣

យកខ្លួនជាគ្រឿងសំគាល់ ដើម្បីដឹងថាខ្លួនជាមនុស្សបែបណាមួយ ។ ពាក្យខ្លួននេះប្រៀបបានស្រមោលអន្ទោលតាមប្រាណ ។ យើងយល់ពីខ្លួនគឺដោយសារខ្លួនយើង មិនមែនដោយសារអ្នកផ្សេងឡើយ ។ ការយល់ពីខ្លួននេះគឺមិនមានការលំបាកអ្វីឡើយ ប៉ុន្តែការបកស្រាយពីខ្លួនមានសញ្ញាណ និងហេតុផលផ្សេងៗពីគ្នា យោងទៅតាមមុខងារនៃការស្រាវជ្រាវ និងគោលបំណងរបស់គេ ។

តាមទស្សនវិជ្ជាព្រះពុទ្ធសាសនា ពាក្យខ្លួន (អាត្ម័ន) មានពីរប្រភេទ ។ ប្រភេទទីមួយ ខ្លួនសំដៅទៅលើសរីរាង្គវិញ្ញាណខាងក្រៅដែលគេមើលឃើញ និងប៉ះពាល់បាន ពោលគឺអង្គប្រាណរបស់មនុស្ស ។ ខ្លួននេះជាភ្នាក់ងារនៃបុគ្គលិកលក្ខណៈដែលគេអាចសំគាល់បានថាជាអត្តសញ្ញាណផ្នែករាងកាយ ។ រីឯន័យទីពីរ ពាក្យខ្លួនសំដៅទៅលើការគិត អារម្មណ៍ វិញ្ញាណដែលកើតចេញពីតណ្ហាដោយមានប្រភពចេញពីរំញោចខាងក្រៅដែលព្រះពុទ្ធបានធ្វើសមាធិស្រាវជ្រាវរកឃើញនូវទស្សនៈដ៏អស្ចារ្យស្តីអំពីមនុស្ស ។ តាមន័យនេះ គេអាចចាត់ទុកថាជាខ្លួនបាននោះ លុះណាតែមានភ្នាក់ងារខាងក្រៅដែលតំណាងដោយសរីរាង្គកាយ (សំបកខ្លួន) និងភ្នាក់ងារខាងក្នុងដែលតំណាងដោយញាណអរូបី ការគិត និងអារម្មណ៍ [១៦] ។

ស្រដៀងគ្នានេះដែរ ចិត្តវិទូមនុស្សនិយមបានកត់សំគាល់ឃើញថា ពាក្យខ្លួននេះជាឯកត្តាជាប់ទាក់ទងគ្នា និងមិនមានការប្រែប្រួលនៃការកកើតបានបុគ្គលិកលក្ខណៈ ។ សញ្ញាណដំបូងនៃពាក្យខ្លួននេះត្រូវបានគេមើលឃើញឃ្លាមួយសរសេរថា ស្គាល់ខ្លួនអ្នក ( Know Thyself ) ដែលត្រូវបានគេចារនៅលើជញ្ជាំងសិលាចារិកតាំងពីនៅសម័យក្រិចបុរាណ ប៉ុន្តែក្រោយមក ពាក្យខ្លួននេះត្រូវបានចិត្តវិទូ William James ធ្វើការវិភាគវែកញែកយ៉ាងល់អិត ដោយផ្អែកលើសមាសធាតុចំនួនបីដែលរួមមាន The material me សំដៅលើរាងកាយដែលមានផ្នែកនៃសរីរាង្គផ្សេងៗនៅជាប់ជាមួយ The social me សំដៅទៅលើការយល់ដឹងពីខ្លួនស្តីពីកិត្យានុភាពរបស់ខ្លួន ដោយកែវភ្នែករបស់អ្នកដទៃដែលមើលឃើញថាខ្លួនមានសមាសធាតុបែបណាមួយ និង The spiritual me សំដៅទៅលើការត្រួតពិនិត្យពីគំនិត និងអារម្មណ៍ [១៧] ។ ដូច្នេះបញ្ញត្តិខ្លួននេះកកើតចេញពីសរីរាង្គកាយ ពីព្រលឹងវិញ្ញាណ និងការមើលឃើញខ្លួនពីសំណាក់មនុស្សដទៃ ។

សម្តេចសង្ឃជួនណាតបានសរសេរថា ខ្លួន (បាឡីថា អត្ត ឯសំស្ក្រឹតថា អាត្ម័ន) គឺជាសិពាង្គរាងកាយចិត្ត [១៨] ។ តាមន័យនេះមនុស្សយើងដែលគេអាចចាត់ថាខ្លួនបាន លុះណាតែមានទាំងសរីរាង្គកាយដែលយើង

[១៦] សូមមើល David J. Kalupahana, A History of Buddhist Philosophy Continuities and Discontinuities, USA, University of Hawaii Press, 1992, p. 5 , 70 , 111

[១៧] Zimbado, Psychology & Life , USA, Scott Forman & Company, 1985, p. 401

[១៨] ជួន ណាត : វចនានុក្រមខ្មែរ ភាគទី១ និងទី២ ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ១៩៦៧ -៦៨ ទំព័រ ១១៤ - ១៧២៧

មើលឃើញ និងប៉ះពាល់បាន ព្រមទាំងចិត្តគំនិតដែលយើងមើលមិនឃើញ ។ នៅក្នុងវចនានុក្រមភាសាអង់គ្លេស គេបានសរសេរថា ខ្លួនជាធម្មជាតិ និងបុគ្គលិកលក្ខណៈរបស់មនុស្ស [១៩] ។ ខ្លួននេះត្រូវគេមើលឃើញថាជាលក្ខណៈពុំមានប្រែប្រួល ( real self ) និងមានលក្ខណៈមួយអន្លើ ( ideal self ) ដែលសំដៅទៅលើអារម្មណ៍ ចិត្តគំនិត និងចិត្តរំភើប ។

ជាទូទៅ បញ្ញត្តិខ្លួនជាការស្គាល់ថាខ្លួនអ្នកជាអ្នកណា ហើយពាក្យខ្លួននេះគឺអ្វីដែលធ្វើអោយអ្នកមានលក្ខណៈខុសផ្លែកពីមនុស្សផ្សេងទៀត ។ ពាក្យខ្លួននេះមិនសំដៅតែសំបករូបរាងខាងក្រៅ ឬ ទ្រង់ទ្រាយខាងក្រៅដូចសំបកសាកសពឥតវិញ្ញាណប៉ុណ្ណោះទេ តែថែមទាំងមានសភាពជាក់លាក់ផ្នែកខាងក្នុងដែលគេអាចចាត់ទុកអ្នកថាជាមនុស្សមួយពេញលេញពិតប្រាកដ ។ ក្នុងន័យនេះ ដើម្បីយល់ពីលក្ខណៈដែលអាចសំគាល់បានថាជាខ្លួននោះ គេត្រូវតែយល់ដឹងពីសមាសធាតុរបស់វាដូចខាងក្រោម :

ការយល់ដឹងពីទម្រង់សាច់ ឈាម និងឆ្អឹងដែលគេអោយឈ្មោះថាអង្គប្រាណ

ការយល់ដឹងពីលំនាំដែលធ្វើអោយខ្លួនឯងធ្វើសកម្មភាព និងយល់ដឹងពីការគិតនៃគំនិតរបស់ខ្លួន

ការយល់ដឹងពីការអភិវឌ្ឍពីខ្ញុំជាអ្វី ទៅជាខ្ញុំជាអ្វីមួយទៀត តែស្ថិតនៅតែជាមនុស្សដដែល

ការយល់ដឹងពីការដែលនាំអោយខ្លួនឯងមានសកម្មភាព និងពិចារណាពីគំនិតខ្លួនឯង

ការយល់ដឹងពីខ្លួនឯងជាមនុស្សដែលកើតពីសមាសធាតុអារម្មណ៍ ទេពកោសល្យ តួនាទី សុខភាព គោលបំណង និងលទ្ធភាព [២០] ។ ការយល់ដឹងពីសមាសធាតុនេះជួយអោយមនុស្សស្គាល់ និងយល់អំពីខ្លួនឯង ហើយ មនុស្សកាន់តែធំធាត់ឡើង គេកាន់តែយល់ និងស្គាល់ពីខ្លួនគេកាន់តែប្រសើរ និងបានល់អិតឡើង ។

យោងតាមរបកកំហើញរបស់អ្នកស្ថាបនិកសាសនា និងអ្នកប្រាជ្ញទំនើប ពួកគេមើលឃើញក្នុងហេតុផលប្រហាក់ប្រហែលគ្នាស្ដីអំពីខ្លួន លើកលែងតែ សាសនវិទូដែលយកអាទិទេពជាធំដែលចាត់ទុកថាខ្លួនជាការកើតឡើងដោយស្នាដៃអាទិទេព ដែលការនេះវាផ្ទុយស្រឡះពីព្រះសមណគោតម ក៏ដូចជាចិត្តវិទូមនុស្សនិយមដែលបញ្ជាក់ថា ខ្លួននេះកកើតឡើងដោយសារមានសរីរាង្គកាយជាគ្រឿងសំគាល់ខាងក្រៅរបស់មនុស្ស និងចិត្តគំនិតខាងក្នុងដែលមានអារម្មណ៍ គោលបំណង និងការគិតជាដើម ។

---

[១៩] Collins, Australian School Dictionary, Harper collins Publisher, 1992, p.634

[២០] K.Fillip. J., Foundation of Education, key reading, Sydney UTS, 1992.

- **ការអោយតំលៃ** ( Esteem )

ការអោយតំលៃជាការលើកតំលៃ ជាសេចក្តីគោរពខ្ពស់ ទស្សនៈពេញចិត្ត ឬ ចូលចិត្ត ។

យោងតាមការផ្សំន័យនៃពាក្យទាំងពីរ គេអាចអោយន័យការឱ្យតំលៃខ្លួនឯងថា ជាការលើកតម្កើង ការគោរព ការពេញចិត្ត ឬចូលចិត្ត និងការអោយតំលៃអំពីខ្លួនឯង ។ ទោះជាយ៉ាងនេះក៏ដោយ ការអោយតំលៃខ្លួនជាបញ្ញត្តិដែលត្រូវបានគេបកស្រាយផ្សេងៗគ្នាយ៉ាងទូលំទូលាយទៅតាមគោលបំណងរបស់គេ ដោយអាស្រ័យទៅលើចំណេះដឹង ជំនឿ និងបរិបទវប្បធម៌របស់ជនជាតិនីមួយៗ ប៉ុន្តែពាក្យនេះត្រូវបានគេចាប់ផ្តើមសំគាល់យ៉ាងផុសផុលនៅក្នុងការសិក្សាស្រាវជ្រាវចិត្តវិទ្យាគ្លីនីក ។ ការអោយតំលៃខ្លួនឯងជាលក្ខណៈពិសេសដាច់ដោយឡែកនៃបុគ្គលិកលក្ខណៈរបស់មនុស្ស ។ ជាធម្មតា ពាក្យនេះច្រើនត្រូវបានគេយកមកប្រើនៅក្នុងចំណោមពួកអ្នកទ្រឹស្តីមនុស្សនិយម ដូចជា លោក Willaim James, Alfred Adler, Erich From, Abraham Maslow និង Carl Roger ជាដើម ក្នុងគោលបំណងស្វែងយល់ពីបញ្ញត្តិផ្ទាល់ខ្លួនរបស់មនុស្ស ។

បញ្ញត្តិនៃការអោយតំលៃខ្លួនឯងច្រើនទាក់ទងទៅនឹងបញ្ញត្តិផ្សេងៗទៀត ដូចជាបញ្ញត្តិ self- worth, self-concept, self-efificacy, self-confindence, self-awareness, self-respect. self-... ។

តាមអ្នកប្រាជ្ញរបស់អង្គការយូនីសែហ្វបានបញ្ជាក់ថា ការអោយតំលៃខ្លួនឯងគឺជាបទពិសោធន៍ខាងសមត្ថភាពដែលអាចបំពេញបាននូវការប្រកួតប្រជែងក្នុងជីវិត និងអារម្មណ៍ និងភាពស័ក្តិសមទទួលបាននូវសុភមង្គល [២១] ។ លោក Abraham Maslow បានបញ្ជាក់ថា ការអោយតំលៃខ្លួនឯងជាអារម្មណ៍នៃការជឿជាក់ និងការលើកតំលៃខ្លួនឯងផ្ទាល់របស់បុគ្គលម្នាក់ៗ [២២] ។ មនុស្សដែលអាចចាត់ទុកថាខ្លួនមានតំលៃគឺអាស្រ័យលើខ្លួនឯងផង និងការអោយតំលៃពីអ្នកដទៃផង ទើបគេអាចមើលឃើញថាខ្លួនគេមានលក្ខណៈគ្រប់-គ្រាន់ក្នុងតំលៃជាមនុស្សមួយពេលលេញ ។ លោក Coppersmith (1967) បានអោយនិយមន័យថា ការអោយតំលៃខ្លួនឯងជាការវិនិច្ឆ័យផ្ទាល់ខ្លួនពីតំលៃដែលបញ្ជាក់ពីឥរិយាបថ ដែលបុគ្គលបានប្រកាន់ខ្ជាប់ចំពោះខ្លួនឯង [២៣] ។ ការអោយតំលៃខ្លួនឯងនេះគឺស្ថិតនៅលើបុគ្គលម្នាក់ៗដែលខ្លួនកំពុងស្ថិតក្នុងស្ថានភាព ឬព្រឹត្តការណ៍ណាមួយដែលគេបានរស់នៅ ។ ការដែលមនុស្សហ៊ានសំដែង ឬបញ្ចេញសមត្ថភាពក្នុងទីសាធារណៈគឺដោយសារបុគ្គលនោះជឿជាក់លើខ្លួនឯង និងអោយតំលៃលើខ្លួនឯង ទើបនាំអោយគេអាចសំដែងអាកប្បកិរិ-យាចេញមក ។ តាមទស្សនៈ Teleology របស់លោក Jung យើងឃើញថា រឿងដែលយើងអាចបោះជុំ

---

[21] Unicef P²D Guide : Self – Awareness , P.9
[22] Jess Feist, Theories of Personality, op.cit, p. 7-9
[23] Karalynn Bodnovich, The Relationship between Preschoolers Academic Self-Esteem and The Quality of Their Child Care Center, 2002 on line: http:www// etd. wvu. edu.

ហ៊ានទៅមុខបាន និងអាចឈានទៅមុខបន្តទៅទៀតគឺអាស្រ័យដោយគំនិតគិតពីអនាគតរបស់យើង និងអាស្រ័យដោយសារតំលៃ គោលបំណង អត្ថន័យ ។ល។ ដោយពឹងផ្អែកលើឆន្ទៈ និងបញ្ញត្តិនៃគោលការណ៍ណែនាំចំពោះពិភពលោក ។

ការឱ្យតំលៃខ្លួនឯងត្រូវបានគេគិតថា វាមានកម្រិតខ្ពស់ ឬទាបអាស្រ័យលើមនុស្សម្នាក់ៗ ។ លោក Rosenberg (1979) ដែលជាអ្នកបង្កើតមាត្រដ្ឋាន (scale) សំរាប់វាស់ការឱ្យតំលៃខ្លួនឯងរបស់មនុស្សពេញវ័យនោះបានបង្ហាញថា ការអោយតំលៃខ្លួនឯងថាជាលក្ខណៈដាច់ដោយឡែករបស់បុគ្គលិកលក្ខណៈ ដែលមិនមានការផ្លាស់ប្តូរ និងមានលក្ខណៈសាកល ព្រមទាំងវាស់វែងបាននៅខណៈពេលណាមួយ [២៤] ។ ការអោយតំលៃខ្លួនឯងអាចគេសង្កេតបានតាមរយៈការអនុវត្តសមត្ថភាពបញ្ចេញមកខាងក្រៅ ។ លោក Brow (1993) បានបង្ហាញថា ការអោយតំលៃខ្លួនឯងជាការតម្រង់ទិសវិជ្ជមាន និងអវិជ្ជមានទូទៅដែលសំដៅលើខ្លួនឯង (self) និងផ្អែកលើលំនាំវិនិច្ឆ័យ ដែលបុគ្គលត្រួតពិនិត្យការអនុវត្តការងារ សមត្ថភាព ការសន្និដ្ឋានដោយយោងទៅលើស្តង់ដា និងការអោយតំលៃលើខ្លួនឯង ហើយឈានទៅរកការធ្វើការសម្រេចចិត្តទៅលើការអោយតំលៃខ្លួនឯងនោះ [២៥] ។

ការអោយតំលៃខ្លួនឯងរបស់មនុស្សម្នាក់ៗមានសណ្ឋានផ្សេងៗគ្នា អ្នកខ្លះជឿជាក់លើខ្លួន ដោយមើលឃើញពីតំលៃគុណធម៌ សមត្ថភាព រូបសម្បត្តិ ចំណេះដឹង ឬបទពិសោធន៍ផ្ទាល់ខ្លួនទើបនាំអោយគេអាចចុះចូលក្នុងសង្គម ទាក់ទងជាមួយបុគ្គលផ្សេងនៅក្នុងមជ្ឈដ្ឋានដែលគេកំពុងរស់នៅ ។ ទាំងនេះគឺដោយសារ គេមានជំនឿលើខ្លួនគេ ។ ការអោយតំលៃខ្លួនឯង មានឥទ្ធិពលដល់ជីវិតរស់នៅប្រចាំថ្ងៃ របស់មនុស្សគ្រប់រូប ដោយជួយអោយគេអាចសំរេចបានជោគជ័យ មានសុភមង្គល និងសំរេចគោលដៅរបស់គេ នៅពេលណាបុគ្គលនោះមានការជឿជាក់ និងការអោយតំលៃខ្លួនឯង ពោលគឺការស្គាល់ខ្លួនឯងអោយបានច្បាស់ ។ លោក Walter បញ្ជាក់ថា ការអោយតំលៃលើខ្លួនឯងជាអារម្មណ៍ដែលមានសមត្ថភាពអាចលៃលកដោះស្រាយទៅនឹងការប្រកួតប្រជែងជាមូលដ្ឋានរបស់ជីវិត និងតំលៃនៃការនាំអោយមានសុភមង្គល [២៦] ។ សិស្សដែលមានការជឿជាក់លើខ្លួនឯង ច្រើនតែជាមនុស្សដែលមានជំនឿលើការសិក្សា ជឿលើសមត្ថភាព និងមានគោលបំណងច្បាស់លាស់សំរាប់ទ្រទ្រង់ជីវិតរបស់គេ ។ ការអោយតំលៃខ្លួនឯងមានឫសគល់ពីកត្តាជាច្រើន និងមានកំរិតផ្សេងគ្នាដែរ ។ ចលកររបស់សិស្សក្នុងការសិក្សាគឺអាស្រ័យដោយខ្លួនគេមានជំនឿលើខ្លួនឯងលើការសិ-

---

[24] Wade & Tavris, Psychology, Harper & Row Publish, Inc, 1990.

[25] profile: The Relationship Between Gender and Self-esteem with Body Image, on line: http:// 216.239.57.104/ Search? q = cache. GTI 24 a I6 DM5:www.

[26] Ibid., p. on line

ក្សា និងមានកត្តាជុំវិញពីខាងក្រៅ តែកត្តាខ្លួនឯងនេះជាកត្តាសំខាន់ និងកំណត់លើកត្តាផ្សេងៗទៀត ។ ការឱ្យតំលៃខ្លួនឯងនេះជាតំរូវការរបស់មនុស្សខ្ពង់ខ្ពស់ដែលនឹងក្លាយទៅជាកំពូលមនុស្ស ប្រសិនបើមនុស្សនោះសំរេចបានតម្រូវការទាំងនេះពេញបរិបូរណ៍ ។

សរុបសេចក្ដីមក ការអោយតំលៃខ្លួនឯងជាអារម្មណ៍ដែលមើលឃើញពីតំលៃរបស់ខ្លួនឯង ។ ការឱ្យតំលៃខ្លួនឯងជាការវាយតំលៃពីសមាសធាតុពីខាងក្រៅផង និងការយល់ឃើញចេញពីធម្មជាតិដើមរបស់ខ្លួនឯងផង ដើម្បីកំណត់តំលៃ ស្គាល់តំលៃ និងពេញចិត្តលើខ្លួនឯង ។

### ២.២.១ - ធម្មជាតិនៃការអោយតំលៃខ្លួនឯង

ការអោយតំលៃខ្លួនឯងជាលក្ខណៈសំគាល់អំពីប្រភេទបុគ្គលិកលក្ខណៈរបស់មនុស្ស ។ មនុស្សមានអត្តសញ្ញាណរៀងខ្លួន ដើម្បីជាគ្រឿងសំគាល់ភេទ ភិនភាគ និងតំលៃរបស់ខ្លួន ។ មនុស្សមានសមត្ថភាពក្នុងការវិនិច្ឆ័យអំពីអត្តសញ្ញាណរបស់ខ្លួន និងអាចវាស់វែងពីតំលៃរបស់គេ ដើម្បីស្គាល់ខ្លួនឯងមានលក្ខណៈបែបណាមួយ និងក៏អាចធ្វើការសំរេចចិត្តអំពីការពេញចិត្ត ឬចូលចិត្តលើខ្លួនឯងក្នុងករិណីណាមួយផងដែរ ។ មនុស្សមានសម្បត្តិផ្ទាល់ខ្លួនរបស់គេ ដូចជា រូបសម្បត្តិ ពិណសំបុរ ទ្រព្យទ្រាយ សមត្ថភាព សីលធម៌ បញ្ញាញាណ ការគិត សកម្មភាពការងារ និងការទំនាក់ទំនង ។ សមាសធាតុនេះមានសារៈសំខាន់ណាស់ក្នុងការជួយមនុស្សអោយមើលឃើញពីតំលៃខ្លួនឯង ។ ប្រសិនបើមនុស្សមិនពេញចិត្តផ្នែកណាមួយ ឬអោយតំលៃខ្លួនឯងទាបលើចំណុចណាមួយក្នុងចំណោមសមាធាតុខាងលើ នោះគេនឹងមានបញ្ហា ឬអាចបណ្ដាលអោយមានការឈឺចាប់ខាងផ្លូវចិត្តដែលនាំឱ្យគេមើលឃើញពីតំលៃខ្លួនឯងទាប រឺនាំអោយគេក្លាយជាមនុស្សមិនមានសមត្ថភាពគ្រប់គ្រងលើខ្លួនឯង និងគ្រប់គ្រងលើអ្នកដទៃ ។ កង្វះខាតខាងការអោយតំលៃខ្លួនឯងអាចនាំអោយគេមានការខ្វះខាតខាងសមត្ថភាព ខាងការទំនាក់ទំនង និងមិនមានការតស៊ូនៅក្នុងឆាកជីវិត ។ ប៉ុន្តែ ប្រសិនបើមនុស្សមានការអោយតំលៃខ្លួនគ្រប់គ្រាន់វិញ គេអាចក្លាយជាមនុស្សមានសមត្ថភាព និងមានភាពរុងរឿង ព្រោះគេមានកំឡាំងចិត្តខ្លាំង មានសុខភាពផ្លូវចិត្តល្អ មានគំនិតសុទិដ្ឋិនិយម ព្រមទាំងមានការតស៊ូស្វិតស្វាញនឹងការងារ ។ ធម្មជាតិនៃការអោយតំលៃខ្លួនឯងកើតពីកត្តាខ្លួនឯងផង និងកត្តាខាងក្រៅផង តែកត្តាខ្លួនឯងផ្ទាល់ជាកត្តាស្នូល ។ ឧទាហរណ៍ ព្រះពុទ្ធបរមគ្រូបានឈានដល់កំពូលមនុស្សដោយសារព្រះអង្គជឿជាក់លើខ្លួនឯង និងមានការអោយតំលៃខ្លួនឯងខ្ពស់ ។ ការឱ្យតំលៃខ្លួនឯងរបស់ព្រះពុទ្ធពុំមានបុគ្គលណាម្នាក់អាចប្រៀបប្រដូចបានឡើយ និងបាននាំអោយព្រះអង្គឈានដល់អរិយបុគ្គលសំរាប់ជាគំរូមនុស្សទូទៅ ។ សមិទ្ធផលនេះរឹតតែនាំអោយមនុស្សជាច្រើនជឿថា ព្រះអង្គស័ក្ដិសមទទួលបានការគោរព និងការអោយតំលៃដែលកើតពីស្ថា

ដៃរបស់ព្រះអង្គ ។ តើកត្តាអ្វីដែលនាំអោយព្រះអង្គមានការជឿជាក់ និងអោយតំលៃខ្លួនឯងនេះ ?

លោកស្រី Dunn បានបញ្ជាក់ថា ធម្មជាតិនៃការអោយតំលៃខ្លួនឯងទាក់ទងទៅនឹងវិសាលភាពដែលមនុស្សមើលឃើញពីខ្លួនឯងក្នុងលក្ខណៈហេតុ និងផល ។ អ្នកស្រីបានបញ្ជាក់ថា ការយល់ដឹងពីបុព្វហេតុគឺជាការបង្ហាញដ៏មានសារសំខាន់អំពីអារម្មណ៍របស់ខ្លួន ហើយខ្លឹមសារនៃការជឿជាក់លើខ្លួនឯងគឺជាអារម្មណ៍មានហេតុផលលើអ្វីមួយ និងអាចជះឥទ្ធិពលលើអ្វីមួយផ្សេងទៀត [២៧] ។ ធម្មជាតិនៃការអោយតំលៃខ្លួនឯងកើតចេញពីការគិតគូ និងអោយតំលៃខ្លួនឯងផ្ទាល់ផង និងអាចកើតចេញពីសមាសធាតុជុំវិញខ្លួនរបស់មនុស្សផងដែរ ។ លោក Matthew & លោក Patrick (2000) បានបញ្ជាក់ថា ប្រសិនបើកាលៈទេសៈខាងក្រៅកំណត់លើការអោយតំលៃខ្លួនឯង មនុស្សដែលស្ថិតក្នុងស្ថានភាពខាងលើនោះកាន់តែបង្កើនការអោយតំលៃខ្លួនឯងកាន់តែប្រសើរ ហើយមនុស្សនោះនឹងធ្វើអោយកាលៈទេសៈរបស់គេបានប្រសើរវិញដែរ [២៨] ។ ជាធម្មតា គេមិនអាចធ្វើអោយកាលៈទេសៈនោះប្រែប្រួលបានទេ ព្រោះអ្វីៗទាំងនោះគ្រាន់តែនៅជុំវិញប៉ុណ្ណោះ ។ ការនេះប្រៀបបានដូចជាខ្លួនយើងកំពុងឆ្លុះកញ្ចក់ រីឯការវិនិច្ឆ័យលើខ្លួនយើងបែបណាមួយនៅចំពោះមុខកញ្ចក់នោះគឺអាស្រ័យដោយសារការគិតរបស់យើង ព្រោះកញ្ចក់គ្រាន់តែជាឧបករណ៍សំរាប់ឆ្លុះប៉ុណ្ណោះ ប៉ុន្តែប្រសិនបើឧបករណ៍នោះជាមនុស្សវិញ នោះអាចបណ្តាលអោយគេមានការប្រែប្រួលការគិត ។ ប្រសិនបើការអោយតំលៃខ្លួនកំណត់កត្តាកាលៈទេសៈ នោះកាលៈទេសៈនឹងជះឥទ្ធិពលដល់ការអោយតំលៃខ្លួនឯងបានកាន់តែប្រសើរឡើងវិញថែមទៀត ។ កត្តាដែលកំណត់លើកាឱ្យតំលៃខ្លួនរបស់អ្នកគឺកើតពីការគិតរបស់អ្នក ទោះជាកាលៈទេសៈ និងការអោយតំលៃខ្លួនឯងមានទំនាក់ទំនងនឹងគ្នាក៏ដោយ ។ បើអ្នកមើលទៅលើវត្ថុអ្វីមួយ វាអាស្រ័យលើការគិតរបស់អ្នកថាតើអ្នកអោយតំលៃ ឬក៏អត់ ។ វត្ថុនៅជុំវិញខ្លួនមនុស្សគឺនៅដដែល តែចិត្តរបស់មនុស្សទេមានការប្រែប្រួល ។ ទាក់ទងទៅនឹងហេតុផលរវាងការអោយតំលៃខ្លួនឯង និងកាលៈទេសៈការស្រាវជ្រាវជាច្រើនបានបង្ហាញថា របៀបចិញ្ចឹមកូនរបស់ឪពុកម្តាយនៅក្នុងកំឡុងពេលអាយុ ៣ ឬ ៤ ឆ្នាំដំបូងមានឥទ្ធិពលដល់ការចាប់ផ្តើមការអោយតំលៃខ្លួនឯងរបស់កុមារ ។

ធាតុសំខាន់បីយ៉ាងដែលមានទំនាក់ទំនងនឹងការអោយតំលៃខ្លួនឯង ។ ធាតុទាំងបីនេះមានភាពផ្សេងពីគ្នា តែវាមានអន្តរទំនាក់ទំនងនឹងគ្នាក្នុងការជួអោយគេយល់ដឹង និងលើកតម្កើងការអោយតំលៃខ្លួនឯងរបស់មនុស្ស ។

---

[27] Lilian G. Katz, Distinction Between Self-Esteem and Narcissism: Implications for Practice, 1993 on line: http:// ericeece.org/pubs/books/selfe.html.

[28] Matthew Mckay, Ph.D , Patrick Fanning, Self-Esteem, United States of America, New Harbinger Publications, 2000. p.2

- ការត្រួតពិនិត្យការយល់ដឹងខាងក្នុង ( internal locus control ) កត្តានេះត្រូវបានបញ្ជាក់ពីការយល់ដឹងខាងក្នុងរបស់មនុស្សអំពីបុព្វហេតុ និងទិសដៅឆ្ពោះទៅរកការទទួលខុសត្រូវ ។ នៅពេលសមាសធាតុនេះកើនច្រើនឡើង មនុស្សកាន់តែមានអារម្មណ៍ពេញចិត្តពីជោគវាសនាដែលស្ថិតក្នុងកណ្ដាប់ដៃរបស់គេ ។ កត្តានេះកើតចេញពីការទទួលស្គាល់ថា សកម្មភាពរបស់មនុស្សបណ្ដាលអោយមានផលវិបាក និងមើលឃើញពីទំនាក់ទំនងហេតុនិងផលដែលទាក់ទងទៅនឹងការជោគជ័យ និងបរាជ័យ ព្រមទាំងការប្រើប្រាស់សកម្មភាពប្រកបដោយការទទួលខុសត្រូវ ។

- ការយល់ដឹងពីការទទួលយក និងការទទួលស្គាល់ខ្លួនឯង (sense of acceptance and belonging) កត្តានេះបង្ហាញថា យើងមានអារម្មណ៍ចង់បាន អារម្មណ៍ទទួលស្គាល់ និងពេញចិត្តខ្លួនឯងកម្រិតណា ។ ពេលដែលយើងទទួលយកតំលៃខ្លួនឯងកាន់តែខ្លាំងឡើង យើងអាចធ្វើសកម្មភាពពេញលេញ និងបង្ហាញខ្លួនយើងជាមួយអ្នកដទៃក្នុងទីសាធារណៈផ្សេងៗ ។ កត្តានេះកើតចេញពីឥរិយាបថ បទពិសោធន៍ សុវត្ថិភាពផ្លូវចិត្ត និងសមត្ថភាពបែងចែកសកម្មភាពអនុវត្តន៍របស់យើង ។ ការយល់ដឹងពីការទទួលយក និងកម្មសិទ្ធិគឺជាការទទួលស្គាល់ខ្លួនឯង ។

- ការយល់ដឹងខាងសមត្ថភាពផ្ទាល់ខ្លួន (sense of competence ) កត្តានេះទាក់ទងទៅនឹងភាពពិសិដ្ឋ និងប្រសិទ្ធភាពរបស់ខ្លួន ព្រមទាំងភាពពូកែចំណានខាងអ្វីមួយក្នុងកម្រិតបែបណាមួយដែលយើងបានគិតនោះ ។ ប្រសិនបើយើងបញ្ជាក់ថា ខ្លួនយើងមានការរីកចំរើន ឬ ជោគជ័យនោះ យើងនឹងកាន់តែជឿជាក់លើខ្លួនយើងកាន់តែខ្លាំង ហើយយើងមានទំនោរប្រថុយពីអនាគត ។ កត្តានេះកើតចេញពីកោសល្យ សមិទ្ធផល និងការទទួលស្គាល់ទេពកោសល្យពីអ្នកដទៃ និងការឆ្លើយតបក្នុងន័យស្ថាបនា [២៩] ។

## ២.២.គ - ឫសគល់ និងប្រវត្តិនៃការអោយតំលៃខ្លួនឯង

### ២.២.គ.១ - ឫសគល់នៃការអោយតំលៃខ្លួនឯង

ដូចចរិតលក្ខណៈផ្សេងៗទៀតនៃបុគ្គលិកលក្ខណៈ ការអោយតំលៃខ្លួនឯងមានឫសគល់របស់វាតាំងពីដំណាក់កាលដំបូងនៃជីវិតរបស់មនុស្សមកម្លេះ ។ លោក Bruce Narromore និង លោក Bill Counts បានបញ្ជាក់ថា ប្រសិនបើមនុស្សយើងត្រូវបានឪពុកម្ដាយ មិត្តសំឡាញ់ និងមនុស្សនៅជិតខាងផ្ដល់ចំលើយតបវិជ្ជមាន នោះមនុស្សយើងនឹងអភិវឌ្ឍនូវការវាយតំលៃខ្លួនឯងកាន់តែវិជ្ជមានឡើងខ្ពស់(high self-evaluation) ប៉ុន្តែប្រសិនបើមនុស្សសំខាន់ៗទាំងអស់នោះបែរជាផ្ដល់នូវអារម្មណ៍ និងទឹកមុខអវិជ្ជមានដល់យើងវិញ នោះ

[29] សូមមើល http://www.calstatela.edu /faculty/jshindl/cm/self-esteem.htm.

មនុស្សយើងនឹងបញ្ច្រាបបាននូវការវាយតំលៃទាំងនេះចូលទៅក្នុងបញ្ញត្តិខ្លួនរបស់យើង ហើយយើងនឹងរៀនស្អប់ពីខ្លួនឯង [៣០] ។ ជាការពិតណាស់ ការអោយតំលៃខ្លួនឯងកើតចេញពីរបៀបដែលឪពុកម្តាយយកចិត្តទុកដាក់ និងប្រព្រឹត្តមកលើរូបយើង ហើយឫសគល់នៃការអោយតំលៃខ្លួនឯងរបស់មនុស្សគឺមានចាប់ពីដំណាក់កាលដំបូង នៅពេលកុមារទទួលបាននូវផាសុខភាព និងសេចក្តីថ្នាក់ថ្នម ។ កុមារត្រូវការយកចិត្តទុកដាក់ផ្នែករាងកាយ និងផ្នែកភាសាវិជ្ជមានពីសំណាក់ឪពុកម្តាយរបស់ពួកគេ ហើយពេលពួកគេចំរើនវ័យបន្តិចមកពួកគេទាមទានូវសមាសមាសធាតុជាច្រើនថែមទៀត ដូចជាសេចក្តីស្រលាញ់ ការយកចិត្តទុកដាក់ ការអោយតំលៃ ដើម្បីអោយផ្លូវចិត្តរបស់គេមានតុល្យភាព ។ មូលដ្ឋាននេះហើយដែលនាំអោយបង្កប់នូវការឱ្យតំលៃរបស់មនុស្សយើង ព្រោះជំរៅនៃសេចក្តីស្រលាញ់របស់ម្តាយបានកប់យ៉ាងជ្រៅនៅក្នុងទឹកចិត្តរបស់កូនជារៀងរហូតមកដោយពួកគេមិនអាចបំភ្លេចបាន [៣១] ។

លោក Pratica ពោលថា ប្រសិនបើកុមាររស់នៅជាមួយការពេញចិត្ត កុមារនឹងរៀនស្រលាញ់ខ្លួនគេ បើកុមាររស់នៅជាមួយការលើកទឹកចិត្ត នោះពួកវានឹងរៀនពីការជឿជាក់ ហើយប្រសិនបើកុមាររស់នៅជាមួយនឹងការសសើរ ពួកវានឹងរៀនពីជំនឿទុកចិត្តលើខ្លួនឯង ប៉ុន្តែប្រសិនបើកុមាររស់នៅជាមួយការចំអកឡកលើយពីអ្នកផ្សេងវិញ នោះពួកវានឹងរៀនពីភាពអៀនខ្មាស់ [៣២] ។ លុះដល់កុមារឈានដល់វ័យជំទង់ ឥរិយាបថទាំងអស់នេះត្រូវបានចាក់ឫស និងស្ថាបនាបានយ៉ាងរឹងមាំនៅក្នុងបុគ្គលិកលក្ខណៈ ហើយនាំអោយពួកវាកាន់តែលំបាកយ៉ាងខ្លាំងក្នុងការផ្លាស់ប្តូរនូវបទពិសោធន៍ទាំងនេះ ។ ឫសគល់នៃការអោយតំលៃខ្លួនឯងបានចាក់ឫស និងស្ថាបនាយ៉ាងមាំនៅក្នុងដើមវ័យកុមារ ហើយបទពិសោធន៍ក្រោយមករបស់យើងនៅតែជះឥទ្ធិពលដល់អារម្មណ៍ចំពោះខ្លួនយើងទៀត ។

លើសពីនេះទៅទៀត របៀបដែលយើងមើលឃើញខ្លួនរបស់យើងអាចមានការប្រែប្រួល ។ កាលនៅក្នុងវ័យកុមារ ប្រសិនបើយើងរស់នៅជាមួយការរិះគន់ យើងនឹងរៀនពីរបៀបថ្កោលទោស។ លុះដល់យើងចំរើនវ័យ ប្រសិនបើយើងរស់នៅជាមួយការរិះគន់ឥតឈប់ឈរទៀតនោះ រូបភាពចិត្តខ្លួនឯង (self-emage) នឹងមានការលំបាកក្នុងការធ្វើអ្វីមួយអោយបានល្អប្រសើរ ។ នៅក្នុងដំណាក់កាលវ័យនេះ បើមិត្តសំឡាញ់ ឬអ្នកដទៃលើកទឹកចិត្ត និងលើកតម្កើងខ្លួនយើងថែមទៀត នោះយើងនឹងមានអារម្មណ៍អោយតំលៃ

[30] Bruce Narramor and Bill Counts, Freedom From Guilt, Califonia, Harvest House, 1974, p.39-41
[31] Profile : Roots of Self esteem , p. www.rice-lewisclinic.com/aricles/roots.html
[32] Patricia Kramer, Self-esteem Library, Discovering the Real You, New York, The Rosen Publishing Group Inc, 1991.p.7-10

ខ្លួនឯងខ្ពស់បន្ថែមទៀត ៣៣ ។ ជាមួយគ្នានេះដែរ បញ្ហាផ្ទាល់ខ្លួនក៏មានឥទ្ធិពល និងជាដើមហេតុនាំអោយមនុស្សយើងមើលឃើញដល់រូភាពចិត្តខ្លួនឯង ។ មនុស្សយល់ថា ខ្លួនគេជាម្ចាស់នៃសេចក្តីស្រលាញ់ ម្ចាស់ទ្រព្យធន អំណាច ការគ្រប់គ្រងលើខ្លួនឯង និងកិត្យានុភាពដែលជួយឱ្យខ្លួនគិតថា ខ្លួនឯងទេដែលសំរេចបាននូវរបស់ទាំងឡាយដែលគេចង់បាន ។ មូលដ្ឋានមើលពីតំលៃខ្លួនឯងផ្ទាល់នេះ នាំអោយមនុស្សឈានទៅដល់ការគិតគូពីខ្លួនឯង ។ នៅពេលមនុស្សមើលឃើញពីតំលៃខ្លួនឯងហើយ គេនឹងមើលឃើញពីតំលៃនៃកិរិយាមាយាទប្រចាំថ្ងៃរបស់គេ ហើយគេនឹងគិតពីតំលៃផ្ទាល់របស់គេជាប្រចាំ ដែលប្រព័ន្ធគំនិតពីខ្លួននេះបានបញ្ជ្រាបចូលទៅក្នុងចិត្តគំនិតរបស់គេឥតឈប់ឈរ ដែលទាំងនេះជាឫសគល់នៃការអោយតំលៃខ្លួនឯង ។

ក្រៅពីនេះ ទំនៀមទំលាប់ ប្រពៃណី និងសាសនាមានឥទ្ធិពលដល់បញ្ញត្តិផ្ទាល់ខ្លួនរបស់មនុស្សយើងផងដែរ ។ មនុស្សមួយចំនួនបានប្រកាន់យកបរិយាកាសជំនឿសាសនា និងប្រពៃណីសង្គមដែលជំរុញ និងលើកតម្កើងការលូតលាស់ការអោយតំលៃខ្លួន និងបត់បែនតាមកាលៈទេសៈ ។ ជំនឿអាចជួយពង្រឹងការអោយតំលៃខ្លួនយើង ។ មនុស្សដែលមានជំនឿលើសាសនាជឿលើព្រះអាទិទេពយល់ថា រូបភាពចិត្តគំនិតការអោយតំលៃខ្លួនឯងមានឫសគល់ចេញពីសច្ចភាពនៃសេចក្តីស្រលាញ់របស់ព្រះចំពោះពួកគេ ។ តំលៃរបស់មនុស្សមិនប្រែប្រួលទេ តែអារម្មណ៍របស់មនុស្សទេដែលប្រែប្រួល ។ មនុស្សបានមើលឃើញពីការទាន់ខ្សោយអំពីខ្លួនឯង ដូចនេះ មនុស្សត្រូវពឹងពាក់ទៅលើជំនឿផ្សេងដែលជំរុញដល់ចិត្តរបស់គេអោយកំរើកចំពោះព្រឹត្តការណ៍ផ្សេងៗ ។ នៅពេលណាគេបួងសួងសូមព្រះជាម្ចាស់អោយជួយ និងប្រទានពរដល់ពួកគេ នៅពេលនោះដំណើរការរីកលូតលាស់ខាងផ្នែកផ្លូវចិត្តលើខ្លួនឯងនឹងចាប់ផ្តើមកកើតមានឡើង ។

ទោះជាយ៉ាងណាក៏ដោយ ជាទូទៅ គុណសម្បត្តិដ៏មានសារៈសំខាន់ចំនួន ៤ ដែលបង្កើតនូវមូលដ្ឋានសំរាប់ការអោយតំលៃខ្លួនឯង ដែលរួមមាន សមត្ថភាពខាងការអនុវត្តការងារ លទ្ធភាពនៃលក្ខណៈផ្ទាល់ខ្លួនភាពទាក់ទាញខាងរាងកាយ និងគុណសម្បត្តិល្អខាងសីលធម ៣៤ ។ ពីព្រោះនៅពេលណាមនុស្សជឿជាក់ថាខ្លួនឯងមានសមត្ថភាពគ្រប់គ្រាន់ មានតំលៃខាសីលធមខ្ពស់ និងមានរូបរាងកាយផ្ទាល់ខ្លួនចុះចូលក្នុងសង្គមបាន នោះគេនឹងមានអារម្មណជឿជាក់លើខ្លួនគេ និងមានកាអោយតំលៃខ្លួនឯង ។ ការអោយតំលៃលើខ្លួនឯងមានឫសគល់ពីលក្ខណៈជាក់លាក់ដែលមិនប្រែប្រួលនៃបុគ្គលិកលក្ខណៈ ទម្លាប់ និងឥរិយាបថ ។ ដូច្នេះសមត្ថភាពគ្រប់គ្រាន់ តំលៃខាងរូបរាងកាយ សីលធមផ្ទាល់ខ្លួន និងជំនឿជាសរសរស្តម្ភក្នុងការជួយអោយ

---

33 Bruce Narramor and Bill Counts, Freedom From Guilt, op.cit., p.39-40

34 សូមមើល Constantine Sedikides , Marilynn B.Brewer, Individual Self, Relational Self , Collective Self , USA, UK, Taylor and Francis Group, 2001.p 75.

មនុស្សកាន់តែមើលឃើញពីតំលៃ និងពេញចិត្តលើខ្លួនគេ ព្រមទាំងមានមោទនភាពពីខ្លួនគេថែមទៀត ។

**២.២.ត.២ - ប្រវត្តិនៃការអោយតំលៃខ្លួនឯង**

មនុស្សជាច្រើនាក់ណាស់ដោយរួមមានអ្នកសាសនានិយម អ្នកស្រាវជ្រាវទំនើបបាននាំគ្នាសន្មតអំពីប្រវត្តិនៃការអោយតំលៃខ្លួនឯងក្នុងទិដ្ឋភាព និងការវិនិច្ឆ័យផ្សេងពីគ្នាតាមបរិបទសម័យកាលរបស់គេ ។

+ ក្រុមអ្នកស្រាវជ្រាវទំនើប : ក្រុមអ្នកស្រាវជ្រាវពិសេសពួកចិត្តវិទូបានអះអាងបញ្ជាក់ថា ចលនានៃការអោយតំលៃខ្លួនឯងមានប្រវត្តិដើមរបស់វានៅក្នុងចិត្តវិទ្យាគ្លីនិកក្នុងពេលថ្មីៗ ពិសេសនៅក្នុងទ្រឹស្តីបុគ្គលិកលក្ខណៈរបស់មនុស្ស ។ ក្រុមមនុស្សទាំងនោះរួមមាន លោក William James, Alfred Adler, Erich Fromm, Abraham Maslow, Carl Roger និងអ្នកស្រាវជ្រាវជំនាន់ក្រោយៗទៀត ។ ផ្អែកលើទស្សនៈបែបវិទ្យាសាស្ត្រនេះ គេបានមើលឃើញថា លោក William James ជាជនទីមួយដែលបានបង្កើបពាក្យខ្លួន(អាត្មា)នេះឡើងនៅក្នុងឆ្នាំ១៨៩០ ។ បច្ចុប្បន្ន មនុស្សជាច្រើនបានសិក្សាស្រាវជ្រាវពីការអោយតំលៃខ្លួនឯងនៅក្នុងវិស័យអប់រំ និងបានរកឃើញពីកម្រិតនៃការអោយតំលៃខ្លួនឯង ព្រមទាំងពីបុព្វហេតុដែលមនុស្សមានការអោយតំលៃលើខ្លួនឯង ។ នេះជាប្រវត្តិនាំអោយមានការចាប់អារម្មណ៍ និងយកចិត្តទុកដាក់កាន់តែខ្លាំងឡើងរហូតមកដល់បច្ចុប្បន្នក៏នៅមានការប្រើពាក្យខ្លួននេះក្នុងវិស័យផ្សេងៗទៀត ពិសេសនៅពេលដែលមុខវិជ្ជាចិត្តវិទ្យាមានការរីកចំរើនយ៉ាងខ្លាំង ព្រោះប្រធានបទចិត្តវិទ្យាគឺការសិក្សាអំពីបាតុភូតចិត្តរបស់មនុស្ស ពិសេសអំពីបុគ្គលិកលក្ខណៈរបស់មនុស្ស ។ ជាមួយគ្នានេះដែរ កម្មវត្ថុរបស់ចិត្តវិទ្យាផ្តោតលើមនុស្ស ដើម្បីស្គាល់មនុស្សមួយខុសពីមនុស្សមួយទៀតបែបណានោះ ដែលនេះជាហេតុនាំអោយខិតចូលកាន់តែជ្រៅទៅលើសភាពលក្ខណៈរបស់មនុស្ស (state) និងលក្ខណៈមិនចេះប្រែប្រួលរបស់មនុស្ស (traits) ដែលជាសមាសធាតុនៃបុគ្គលិកលក្ខណៈរបស់មនុស្ស ។ និយាយជារួម នៅពេលមនុស្សធ្វើការអង្កេតស្រាវជ្រាវពីបាតុភូតចិត្តតាមបែបវិទ្យាសាស្ត្រ នៅពេលនោះគេខំស្វែងយល់ពីខ្លួនមនុស្សហើយ ។ បើផ្អែលើទ្រឹស្តីវិទូមនុស្សនិយមបានមើលឃើញថា មនុស្សខិតខំស្វែងយល់អំពីខ្លួនឯងដោយខិតខំបំបែកខ្លួន និងរកគំនិតបដិវត្តន៍ឱ្យចេញផុតពីគំនិតរបស់អាទិទេព ដែលនេះជាសញ្ញាដំបូងបង្អស់ដែលមនុស្សយកចិត្តទុកដាក់អំពីតំលៃការអោយតំលៃខ្លួនឯងរបស់មនុស្សផ្ទាល់ ។ មនុស្សខ្លួនឯងប្រៀបបានទៅនឹងពេជ្រដែលគេអាចច្នៃទៅមានតំលៃ ។ ទ្រឹស្តីវិទូដែលមានគំនិតឱ្យដាច់ចេញពីគំនិតស្ថិតក្រោមឥទ្ធិពលអាទិទេពមានអារីស្តូត ដាវិន និងចិត្តវិទូទំនើបផ្សេងទៀតជាច្រើន ។ ដូច្នេះប្រវត្តិនៃការអោយតំលៃខ្លួនឯងមានប្រភពចេញពីក្រុម អ្នកចិត្តវិទូក្នុងសតវត្សរ៍វិទ្យាសាស្ត្រទំនើបនេះ ពោលគឺនៅពេលមានការសិក្សាចិត្តវិទ្យា នៅពេលនោះមានការសិក្សាអំពីការអោយតំលៃខ្លួនមនុស្ស ។

+ ក្រុមអ្នកសាសនានិយម : ក្រុមមនុស្សប្រកាន់សាសនាផ្សេងៗបានយល់ឃើញពីប្រវត្តិនៃការអោយតំលៃខ្លួនឯងនេះដែរ ប៉ុន្តែក្នុងទិដ្ឋភាពផ្សេងពីក្រុមអ្នកស្រាវជ្រាវទំនើប ។ តាមប្រវត្តិសាសនា គេអាចវិភាគឃើញថា ប្រវត្តិនៃការអោយតំលៃខ្លួនឯងមានតាំងពីយូរយាណាស់មក ដោយគេធ្វើការវិភាគលើប្រវត្តិរបស់អ្នកបង្កើតសាសនាមកម្លេះ ។

- គ្រីសសាសនា : ក្រុមអ្នកកាន់សាសនាគ្រីសបានក្រឡេកទៅក្រោយមើលពីប្រវត្តិអតីតកាលរបស់ពូជមនុស្សដែលមាននៅលើផែនដីដំបូងដែលដំណាងដោយអាដាម និងនាងអ៊ីវ ។ គេយល់ឃើញថាពីដំបូង អាដាមដែលជាការឆ្នៃយល់របស់ព្រះជាម្ចាស់នោះ បានយល់ដឹងពីមនុស្សដទៃនៅជុំវិញខ្លួន អាដាមមិនមែនយល់ដឹងពីខ្លួនឯងមុនឡើយ ។ តាមសាសនាគ្រីស សរសេរថា ដំបូងមានតែអាដាមម្នាក់ឯងប៉ុណ្ណោះ លុះក្រោយមកមានរូបនាងអ៊ីវមួយផ្សេងទៀតដែលកើតចេញពីផ្នែកនៃរាងកាយរបស់អាដាម ។ អាដាមយល់ច្បាស់ថា នាងអ៊ីវជាឆ្អឹងនៃឆ្អឹងរបស់គាត់ និងជាសាច់នៃសាច់របស់គាត់ ប៉ុន្តែក្នុងន័យនេះ អាដាមខ្លួនឯងមិនដឹងថា ខ្លួនឯងមានប្រភពពីណាមកឡើយ ។ តើអ្នកណាជាបុព្វបុរសរបស់ខ្លួន ? នៅពេលព្រះជាម្ចាស់ស្តីបន្ទោសចំពោះកំហុសរបស់អ្នកទាំងពីរ អាដាមបានបន្ទោសទៅលើនាងអ៊ីវ និងព្រះជាម្ចាស់ រីឯនាងអ៊ីវបានស្តីបន្ទោសទៅលើសត្វពស់ដែលតំណាងដោយភាវៈអាក្រក់ និងភាពល្ងង់ខ្លៅ ។ ការយល់ដឹងរបស់គេបានកើតចេញពីការយល់ឃើញពីហេតុផលល្ងង់ខ្លៅផ្សេងៗគ្នា ។ ផ្លែផ្កានៃចំណេះដឹងពីអំពើល្អ និងអំពើអាក្រក់បានបង្កើតអោយមានខ្លួនដែលមានអំពើបាបដោយមានលេចឡើងនូវបញ្ញត្តិការស្រលាញ់ខ្លួន ការអោយតំលៃខ្លួនឯង ការទទួលយកតំលៃខ្លួន ការអាណិតខ្លួន និងបញ្ញត្តិពីខ្លួនផ្សេងៗទៀត ។ ដូច្នេះ គេចាត់ទុកថា បញ្ញត្តិខ្លួនជាច្រើននៅពេលបច្ចុប្បន្នគឺមានឫសគល់ចេញពីអំពើបាបរបស់អាដាម និងនាងអ៊ីវ ។ លុះសតវត្សរ៍ក្រោយៗមក មនុស្សបានបន្តសិក្សាពីសាខាចំណេះដឹងអំពើល្អ និងអំពើអាក្រក់ដែលបានរាលដាលជាមែកធាងនៃគតិបណ្ឌិត ហើយបានលេចចេញជាមែកធាងនៃទស្សនវិជ្ជាដែលមានលក្ខណៈវិទ្យាសាស្ត្រ និងបច្ចុប្បន្នជាបរមត្ថវិជ្ជានៃចិត្តវិទ្យានាពេលបច្ចុប្បន្ននេះ ។

- ព្រះពុទ្ធសាសនា : ទ្រឹស្តីនៅក្នុងព្រះពុទ្ធសាសនាជាទ្រឹស្តីសិក្សាអំពីមនុស្ស សិក្សាអំពីតំលៃសីលធិមរបស់មនុស្ស ។ បញ្ញត្តិពីពាក្យខ្លួននៅក្នុងសាសនានេះមានច្រើន ហើយត្រូវបានបន្តមកដល់សព្វថ្ងៃនេះទៀត ។ ពាក្យទាំងនេះដូចជាពាក្យជួយខ្លួនជាមុន ខ្លួនទីពឹងខ្លួន ការយកឈ្នះលើខ្លួនឯងជាមហាជោគជ័យលើអ្វីៗទាំងអស់ ។ល។ នៅប្រទេសកម្ពុជា ជនជាតិខ្មែរបានដក់ជាប់នូវជំនឿព្រះពុទ្ធសាសនាថា ការថ្លៃថ្នូរថោកទាប បរិសុទ្ធិ និងមិនបរិសុទ្ធិកើតមកពីខ្លួន មានខ្លួនជាទីសម្គាល់ មិនមែនកើតឡើងដោយស្នាដៃទេវតាណា

ឡើយ ។ សូម្បីព្រះពុទ្ធជាគ្រូដើមក៏បានទទួលការថ្លៃថ្នូរ បរិសុទ្ធិព្រោះអំពើផ្ទាល់ខ្លួនរបស់ព្រះអង្គដែរ [៣៥] ។ ពាក្យទាំងនេះត្រូវបានព្រះពុទ្ធពិសោធយ៉ាងល្អិតល្អន់ហើយ ទើបព្រះអង្គបង្កើតជាឱកាសកម្មសំរាប់បម្រើមនុស្សជំនាន់ក្រោយរហូតមកដល់សព្វថ្ងៃនេះ ដើម្បីស្វែងយល់អំពីមនុស្ស ។ បញ្ញត្តិខ្លួន (អាត្មន) ត្រូវបានប្រើប្រាស់ជាមុខងារពីរបែប គឺមុខងារជាបុគ្គលិកលក្ខណៈដែលគេអាចបញ្ជាក់បានតាមរូបរាងកាយ និងជីវជាមុខងារគំនិតដែលកើតពីតណ្ហា ។ ពាក្យខ្លួន ឬអាត្មនធ្វើអោយព្រះអង្គ មានការចូលរួមនៅក្នុងការវិភាគស៊ីជំរៅស្តីពីចិត្តវិទ្យាមនុស្ស [៣៦] ។ ផ្អែកលើទ្រឹស្តី និងបញ្ញត្តិនេះ គេមើលឃើញថា បញ្ញត្តិខ្លួននេះត្រូវបានយកមកប្រើតាំងពីសម័យព្រះពុទ្ធព្រះអង្គមកម្លេះ ទោះជានៅសម័យនោះ នូវពុំទាន់មានការពិសោធលក្ខណៈវិទ្យាសាស្ត្រដូចសព្វថ្ងៃក៏ដោយ ។

**២.២..ឃ - ប្រភេទនៃការអោយតំលៃខ្លួនឯង**

មនុស្សគ្រប់រូបពិតជាមានការវិនិច្ឆ័យលើការអោយតំលៃលើខ្លួនឯង និងគិតពីតំលៃផ្ទាល់ខ្លួនខ្លាំងជាងអ្នកដទៃ ហើយមនុស្សម្នាក់ៗតែងតែលំអៀងក្នុងការអោយតំលៃលើខ្លួនឯងដែរ ។ មនុស្សទទួលស្គាល់ និងអោយតំលៃខ្លួនឯងមានលក្ខណៈផ្សេងពីគ្នា ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។ មនុស្សដែលមានការអោយតំលៃខ្លួនឯងក្នុងកម្រិតខ្ពស់ក្នុងវិស័យមួយមិនប្រាកដថា មនុស្សនោះមានការអោយតំលៃខ្លួនឯងខ្ពស់ជាងក្នុងវិស័យមួយទៀតឡើយ ដោយតែងតែមិនវាយតំលៃខ្លួនឯងខ្ពស់រហូតគ្រប់ស្ថានភាព និងពេលវេលានោះទេ ។ យោងតាមទ្រឹស្តីតម្រូវការរបស់លោកម៉ាស្លូ និងអ្នកឯកទេសខាងការអោយតំលៃខ្លួនឯង គេមើលឃើញថា ការអោយតំលៃខ្លួនឯងមានពីរកំរិត ។

**២.២.ឃ.១- ការអោយតំលៃខ្លួនឯងកម្រិតទាប :** តម្រូវការលំដាប់ទាបជាតំរូវការបានមកពីការគោរពរបស់អ្នកដទៃ តម្រូវការខាងតួនាទី កេរ្តិ៍ឈ្មោះ ភាពជោគជ័យ ភាពល្បីល្បាញ ការយកចិត្តទុកដាក់ ការទទួលស្គាល់ សេចក្តីថ្លៃថ្នូរ និងកិត្យានុភាព ។ មនុស្សដែលពុំមានសមត្ថភាព គ្មានសីលធម៌ គ្មានការទាក់ទាញមានការឱ្យតំលៃខ្លួនឯងទាប [៣៧] ។ ការឱ្យតំលៃខ្លួនឯងកម្រិតទាបកើតចេញពីការវាយតំលៃរបស់អ្នកដទៃ ហើយការឱ្យតំលៃខ្លួនបែបនេះជាអារម្មណ៍ស្ទាក់ស្ទើរ និងជឿងឆ្ងល់អំពីការទទួលស្គាល់តំលៃរបស់ខ្លួនព្រមទាំងមានអារម្មណ៍អន្លង់អន្លោច ក្រៀមក្រំ និងកំសត់ ។ អារម្មណ៍បែបនេះអាចនាំអោយថាមពលកំលាំង

---

[35] ពុទ្ធសាសនា២៥០០ ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ២000 ទំព័រ ១៥៧

[36] David J. Kalupahana, A History of Buddhist Philosophy Continuities and Discontinuities, USA, University of Hawaii Press, 1992., p.5.31,70, 111

[37] Constantine Sedikides , Marilynn B.Brewer, Individual Self, Relational Self , Collective Self, op.cit., p75

ចិត្តចុះខ្សោយ ហើយបង្ករឱ្យការខិតខំប្រឹងប្រែងចុះទាប [៣៨] ។ ប្រសិនបើមនុស្សមានអារម្មណ៍ដូចជាបាត់បង់សមត្ថភាពណាមួយក្នុងការលៃលកដោះស្រាយបញ្ហាជីវិត ម្តងខ្សោយម្តងខ្លាំង និងមានអារម្មណ៍គិតពីខ្លួនឯងមិនគ្រប់គ្រាន់ មានអារម្មណ៍ថាខ្លួនអន់ ហើយតែងតែអោយតំលៃខ្លួនឯងទាប ពេលនោះមនុស្សនោះត្រូវបានគេគិតថាជាមនុស្សដែលមានការអោយតំលៃខ្លួនឯងកម្រិតទាប ។ តាមគោលការណ៍ណែនាំស្តីពីការអោយតំលៃខ្លួនឯងរបស់អង្គការយូនីសេហ្វបានអោយដឹងថា មនុស្សដែលមានការអោយតំលៃខ្លួនឯងទាបជាមនុស្សដែលមានអាកប្បកិរិយាបង្ករការទាស់ទែង និងប្រើកំលាំងជាជាងការដោះស្រាយដោយសន្តិវិធី ។ លើសនេះទៅទៀត មនុស្សបែបនេះចូលចិត្តគេចចេញពីការទទួលខុសត្រូវនូវអ្វីដែលខ្លួនគេបានប្រព្រឹត្ត ។ មនុស្សមានការអោយតំលៃខ្លួនឯងទាបជាមនុស្សមិនចូលចិត្តធ្វើការងារជាក្រុមទេ ដោយចេះតែមានអារម្មណ៍ចេះតែចង់គេចវេស ប៉ុន្តែចូលចិត្តមើលបំណាំ និងស្វែងរកកំហុសអ្នកដទៃ ។ បុគ្គលប្រភេទនេះច្រើនមានអារម្មណ៍មិនសូវមានសុវត្ថភាពខាងផ្លូវចិត្ត និងមានអារម្មណ៍មិនសប្បាយរីករាយ ដោយចូលចិត្តស្តីបន្ទោសគេឯង ហើយជាមនុស្សចូលចិត្តគិតតែពីប្រយោជន៍ខ្លួនឯងប៉ុណ្ណោះ ។ ចរិតច្រឡោងខាង ក្រអឺតក្រទម និងមានកំលាំងចិត្តខ្សោយជាអាកប្បកិរិយារបស់មនុស្សមានការអោយតំលៃខ្លួនឯងទាប ។ ជារឿយៗ មនុស្សមានការអោយតំលៃខ្លួនឯងទាបច្រើនតែបរាជ័យ ដោយមានអារម្មណ៍ចង់តែពឹងឱ្យគេជួយ និងត្រូវការមានគ្នីគ្នានៅជាមួយ ។ មនុស្សប្រភេទនេះមិនចង់មានការទំនាក់ទំនងក្នុងសង្គមទេ ហើយពួកគេពិបាកបកស្រាយពន្យល់អំពីអាកប្ប-កិរិយារបស់ខ្លួនអោយបានត្រឹមត្រូវ ហើយជាមនុស្សច្រើនបោះបង់ចោលបេសកម្មរបស់ខ្លួននៅពាក់កណ្តាលទីដោយជាញឹកញាប់មនុស្សបែបនេះកម្រឈានទៅដល់ការសំរេចគោលដៅក្នុងជីវិតរបស់គេណាស់ [៣៩] ។ សរុបសេចក្តីមក ការអោយតំលៃខ្លួនឯងទាបជាការគិត និងអារម្មណ៍មិនសូវមានសុវត្ថភាព តូចតែ្ជរ គ្មានកំឡាំងចិត្ត គ្មានការទទួលខុសត្រូវ អារម្មណ៍គិតតែពីចាប់កំហុស គំនិតច្រលោងខាង មិនចុះសំរុងជាមួយអ្នកដទៃ និងមានគំនិតក្រអឺតក្រទម ព្រមទាំងជាអារម្មណ៍ដែលចង់តែអោយគេយកចិត្តទុកដាក់ចំពោះខ្លួន ដោយគ្មានភាពឯករាជ្យ ។

**២.២.ឃ.២- ការអោយតំលៃខ្លួនឯងកម្រិតខ្ពស់ :** តម្រូវការនេះទាក់ទងទៅនឹងតម្រូវការចំពោះការគោរពខ្លួនឯងដោយរួមមានជំនឿជឿជាក់ សមត្ថភាព សមិទ្ធផល ភាពម្ចាស់ការ ឯករាជ្យភាព និងសេរីភាព ។ មនុស្សដែលមានការឱ្យតំលៃខ្លួនឯងខ្ពស់មានអារម្មណ៍ថា ខ្លួនឯងមានតំលៃអាចសម្រេចបានសមិទ្ធផល និងមានបំណងក្នុងជីវិតច្បាស់លាស់ ។ មនុស្សដែលសម្រេចបានការជោគជ័យជួយឱ្យខ្លួនគេមើល

[38] Lilian G. Katz, Distinction between self-esteem and narcissism, implication for practice, op.cit., p. on line

[39] Unicef $P^2$ D Guide : Self - Awareness , op.cit., p.9

ឃើញពីរបៀបដែលអ្នកដទៃមើលមកខ្លួនគេ និងមានវិធីទំនាក់ទំនងជាមួយអ្នកដទៃក្នុងសង្គម ដឹងពីភាពខ្លាំង និងភាពខ្សោយរបស់ខ្លួន មានគំនិតឯករាជ្យ និងមានសមត្ថភាពហ៊ានប្រឈមមុខនឹងការដោះស្រាយបញ្ហា និងឧបសគ្គនានា ។ នៅពេលមនុស្សមានការអោយតំលៃខ្លួនឯងកម្រិតខ្ពស់ហើយ មនុស្សនោះតែងតែមានការជឿជាក់ មានការសម្រេចចិត្តបានលឿន និងចេះបង្ហាញអោយអ្នដទៃយល់ពីគំនិត និងតម្រូវការរបស់ខ្លួនឯងបែបណាមួយ ។ មនុស្សដែលមានការឱ្យតំលៃខ្លួនឯងខ្ពស់ច្រើនមានអាកប្បកិរិយាហ៊ានទទួលខុសត្រូវ និងជាសមាជិកគំរូក្នុងក្រុម ។ មនុស្សប្រភេទនេះជាមនុស្សមានឥរិយាបថប្រកបដោយសុភវិនិច្ឆ័យ និងមានចិត្តទទួលយកគំនិតអ្នកដទៃ (ចរិតអ្នកប្រជាធិបតេយ្យ) ។ គេអាចមើលឃើញផងដែរថា មនុស្សមានការឱ្យតំលៃខ្លួនឯងខ្ពស់ច្រើនតែមានចិត្តទូលាយ ប្រាកដនិយម និងជាមនុស្សមានកំឡាំងចិត្តខ្លាំង ហើយមានចរិតយុត្តិធម៌ មានគំនិតចេះជួយអាណិតអាសូរ និងចេះបង្ហាញចិត្តត្រេកអរ ។ មនុស្សដែលមានការឱ្យតំលៃខ្លួនឯងខ្ពស់ច្រើនមានគំនិតសុទិដ្ឋិនិយម ហើយជាអ្នកមានគំនិតបង្កើតថ្មី និងចេះគ្រប់គ្រងស្ថានភាព ដោយបង្ករអោយស្ថានភាពនោះកើតឡើងដោយសំរួលជាជាងតបតទៅនឹងព្រឹត្តការណ៍នោះ [៤០] ។ ឥរិយាបថ និងអាកប្បកិរិយាខាងលើទាំងនេះ ជាការបង្ហាញអោយឃើញពីលក្ខណៈពិសេសរបស់មនុស្សមានការអោយតំលៃខ្លួនឯងកម្រិតខ្ពស់ ។ មនុស្សដែលមានការអោយតំលៃខ្លួនឯងខ្ពស់ច្រើនទទួលបានជោគជ័យ មានសក្តានុពល និងទទួលបានសុភមង្គលក្នុងជីវិត ។

### ២.២.៦- កត្តាដែលជះឥទ្ធិពលដល់ការអោយតំលៃខ្លួនឯង

ដោយសារតែការអោយតំលៃខ្លួនឯងជាលក្ខណៈពិសេសដាច់ដោយឡែករបស់បុគ្គលិកលក្ខណៈរបស់មនុស្ស ហើយបុគ្គលិកលក្ខណៈទទួលឥទ្ធិពលពីកត្តាមជ្ឈដ្ឋានផ្សេងៗ ដូច្នេះការអោយតំលៃខ្លួនឯងក៏មានការទទួលឥទ្ធិពលខាងក្រៅដោយខានពុំបានឡើយ ។ កត្តាដែលមានឥទ្ធិពលលើការឱ្យតំលៃខ្លួនឯងនេះ រួមមានកត្តាគ្រួសារ សាសនា សង្គម កត្តាផ្ទាល់ខ្លួន និងសាលារៀន (អប់រំ) ជាដើម ។

២.២.៦.១ - *កត្តាគ្រួសារ* : គ្រួសារមានឥទ្ធិពលដល់ការបណ្តុះនូវឥរិយាបថនៃការឱ្យតំលៃខ្លួនឯង ។ ការស្រាវជ្រាវជាច្រើនបានសន្និដ្ឋានថា ការគាំទ្ររបស់គ្រួសារមានឥទ្ធិពលយ៉ាងចំបងដល់ការឱ្យតំលៃខ្លួនឯង ។ លោក Yabiku, Nunley និងលោក Axinn (1999) បានសន្និដ្ឋានថា កុមារមានការឱ្យតំលៃខ្លួនឯងកាន់តែខ្ពស់ឡើង នៅពេលណាឪពុកម្តាយរបស់វាមានការស្រលាញ់ ការគាំទ្រ ទំនុកបម្រុង និងមានទំនាក់ទំនងកាន់តែជ្រាលជ្រៅជាមួយជីវិតរបស់ពួកវា ។ ស្រដៀងគ្នានេះដែរ លោក Nunley

---

[40] Unicef P² D Guide : Self – Awareness , op.cit., p.9

(1996)បានបញ្ជាក់ថា កុមារមានការឱ្យតំលៃខ្លួនឯងខ្ពស់ ដោយថាក្រុម ពួកគេមានឪពុកម្តាយមានការចេះដឹង និង ទទួលយកនូវគំនិតថ្មី ចេះជំរុញលើកតម្កើងកូនខ្លួនឯងអោយចេះបង្កើតនូវទស្សនៈផ្ទាល់ខ្លួនឯង ព្រមទាំងចេះផ្តល់ការគាំទ្រដល់កូនដែលពួកវាត្រូវការ ដើម្បីបង្ហាញគំនិត និងទស្សនៈរបស់ពួកវា [៤១] ។

លោក អ៊ឹម កុច បានបង្ហាញពីការអប់រំកូនក្នុងគ្រួសារថា គ្រួសារដើរតួទីមួយដ៏ល្អរបស់កូននៅក្នុងគ្រួសារ ព្រោះថាការអប់រំផ្នែកសីលធម៌ល្អ ទំលាប់ល្អ គំរូល្អ និងទឹកចិត្តចង់រៀន គ្រួសារមានឥទ្ធិពលណាស់ ។ បើតាមការបញ្ជាក់របស់គាត់ គ្រួសារមានបីប្រភេទដែលរួមមានគ្រួសារផ្តាច់ការ គ្រួសារមានការអនុញ្ញាត និងគ្រួសារមានការពន្យល់ហេតុផល [៤២] ។ គ្រួសារបីប្រភេទនេះមានឥទ្ធិពលដល់ការរីកលូតលាស់នៃការឱ្យតំលៃខ្លួនឯងផ្សេងគ្នាដែរ ។ លោក អ៊ឹម កុច បានសន្និដ្ឋានថា ដើម្បីឱ្យកូនមានភាពម្ចាស់ការ ឱ្យតំលៃខ្លួនខ្ពស់មកលើខ្លួនឯង មានសុខភាពផ្លូវចិត្តល្អ គួរមាតាបិតាប្រើប្រាស់របៀបគ្រប់គ្រងកូនតាមប្រភេទពន្យល់ហេតុផលនៃបំណងល្អរបស់ឪពុកម្តាយ ដើម្បីអោយកូនបានយល់ និងឯកភាពទទួលយកធ្វើតាមទាំងរីករាយ [៤៣] ។

លោក Baumrind (1967) បានបញ្ជាក់ថា កូនដែលស្ថិតក្នុងគ្រួសារផ្តាច់ការនឹងក្លាយទៅជាមនុស្សអោយតំលៃខ្លួនទាប មានអារម្មណ៍ភ័យខ្លាច និងមិនចាប់អារម្មណ៍ក្នុងការរៀនសូត្រ ។ ចំពោះគ្រួសារដែលមានការអនុញ្ញាត ការផ្តល់សេរីភាពជ្រុលបណ្តាលអោយកូនក្លាយទៅជាមនុស្សមានះ និងកំរោលឃោឃៅខ្វះទាំងសមត្ថភាពសំរេចចិត្តអោយបានត្រឹមត្រូវ និងភាពម្ចាស់ការ ។ លោក Baumrind បានបញ្ជាក់ថា កុមារស្ថិតក្នុងគ្រួសារពន្យល់ហេតុផលនឹងមានការពឹងពាក់ខ្ពស់លើសមត្ថភាព ព្រមទាំងមានអារម្មណ៍រីករាយក្នុងជីវិតខ្លួនថែមទៀតផង ។

លោក Cooppersmith (1967)បានបញ្ជាក់ពីកម្រិតនៃការឱ្យតំលៃខ្លួនរបស់កុមារទាក់ទងគ្រួសារថា ក្មេងដែលមានការអោយតំលៃខ្លួនឯងទាបមានប្រភពចេញពីផ្ទះដែលមានការបង្ហាញ និងផ្តល់នូវសេចក្តីស្រលាញ់តិចតួចដល់ពួកគេ ។ កុមារដែលមានការអោយតំលៃខ្លួនឯងទាបជាញឹកញាប់ត្រូវបានគេព្រងើយកន្តើយ និងមានការដាក់គំរិតព្រំដែន និងការដាក់វិន័យច្រើន ព្រមទាំងមានការពិភាក្សាតិចតួច ប៉ុន្តែពួកគេបែរជាមានការទទួលទណ្ឌកម្មលើរាងកាយចំពោះការរំខានដល់ឪពុកម្តាយ ។ កុមារដែលមានការអោយតំលៃខ្លួនឯងកំរិតមធ្យមមានទំនាក់ទំនងទៅនឹងការស្រលាញ់ មានវិន័យច្រើន និងធ្វើការសម្រេចចិត្តរួមគ្នា ប៉ុន្តែ

---

[41] Rochelle L. James, The Correlation Between Adolescent Self-esteem, Religiosity and Perceive Family Support ,p. http:/// clearing house .mwsc.edu/manuscrips/247.asp.

[42] អ៊ឹម កុច : របៀបអប់រំកូនក្នុងគ្រួសារ ក្នុងទស្សនាវដ្តីគ្រូបង្រៀន លេខ១៨ ឆ្នាំ ២០០៤ ទំព័រ ១៥

[43] -ដ-ទំព័រ ១៦

មានសិទ្ធិបុគ្គលតិចតួច និងមានការការពារតិចតួច រីឯកុមារដែលមានការអោយតំលៃខ្លួនឯងកម្រិតខ្ពស់ត្រូវបានគេមើលឃើញចំពោះកុមារណាដែលមានឪពុកម្តាយផ្តល់នូវសេចក្តីស្រលាញ់ រួមជាមួយនឹងការដាក់វិន័យដែលមានលក្ខណៈសមហេតុសមផល ដោយវិន័យទាំងនោះត្រូវបានគេយកមកអនុវត្តយ៉ាងប្រយ័ត្នប្រយែង និងជាបន្តបន្ទាប់ ។ សិទ្ធិឯកជនត្រូវបានអនុញ្ញាត ហើយឯករាជ្យភាពត្រូវបានគេជំរុញឡើង ៤៤ ។

លើសពីនេះទៅទៀត ការស្រាវជ្រាវជាច្រើនផ្សេងទៀតបានបង្ហាញថា គ្រួសារមានឥទ្ធិពលដល់ការអោយតំលៃខ្លួនឯង សំរាប់កុមារ ជំទង់ និងមនុស្សពេញវ័យ ។ លោក Copper លោក Holman និងលោក Brain Waite (1983) បានបង្ហាញថា កុមារដែលមានឪពុកម្តាយដែលពុំមានការគាំទ្រមានការអោយតំលៃលើខ្លួនឯងទាបបំផុត ។ នៅក្នុងការសិក្សាស្រាវជ្រាវរបស់លោក James ស្តីពីទំនាក់ទំនងរវាងការអោយតំលៃខ្លួនឯង និងការគាំទ្ររបស់គ្រួសារបានបង្ហាញលើការសន្និដ្ឋានរបស់លោក Nunley (1996) ថា កុមារដែលមានប្រភពចេញពីគ្រួសារដែលមានវិធីទំនាក់ទំនងខ្សោយ ឬគ្រួសារដែលមិនមានដំណើរការល្អទៃតែងតែមានការអោយតំលៃខ្លួនឯងទាប និងមានបញ្ហា ដោយបង្កើតបាននូវអត្តសញ្ញាណផ្ទាល់ខ្លួនរបស់គេ ។ លោក Niolon(1999)ដែលធ្វើការសិក្សាលើគ្រួសារដែលមានដំណើរការប្រព្រឹត្តទៅមិនបានល្អបានបញ្ជាក់ថា ដោយសារគ្រួសារដែលមានតំណើរការមិនល្អបានបង្កើននូវភាពតានតឹង និងជំលោះ ទើបកុមារស្ថិតក្នុងគ្រួសារប្រភេទបែបនេះមានការអោយតំលៃខ្លួនឯងទាប និងមានការប្រថុយគ្រោះថ្នាក់ឈឺចាប់ពីការធ្លាក់ទឹកចិត្ត ។ តាមរយៈការស្រាវជ្រាវរបស់លោក Hopper លោកHolman និងលោក Brainwaite (1983) ក៏បានបង្ហាញច្បាស់ថា គ្រួសារដែលប្រើវិធីអប់រំក្នុងគ្រួសារបានត្រឹមត្រូវពីកុមារភាព នោះកុមារដែលនឹងចំរើនពេញវ័យឡើងនឹងមានការអោយតំលៃខ្លួនឯងខ្ពស់ ប៉ុន្តែកុមារដែលមានគ្រួសារមិនមានការគាំទ្រ ពួកគេមានការអោយតំលៃលើខ្លួនឯងទាបបំផុត ។ លោក James សន្និដ្ឋានថា អារម្មណ៍ថាខ្លួនមានសុវត្ថិភាព ស្នេហភាពជួយបង្ករអោយកុមារមានការយល់ដឹងពីខ្លួនឯងជាលក្ខណៈវិជ្ជមាន ( positive self-perception) ជាមួយគ្នានេះដែរ ជំទង់ដែលមានអារម្មណ៍សុទិដ្ឋិនិយមបានយល់ជ្រាបពីការគាំទ្ររបស់គ្រួសារ និងការអោយតំលៃខ្លួនឯងវិជ្ជមាន ។ ផ្ទុយទៅវិញ ជំទង់ដែលមានអារម្មណ៍ទុទិដ្ឋិនិយមវិញយល់ជ្រាបពីការទទួលគាំទ្រពីគ្រួសារ និងការអោយតំលៃខ្លួនឯងអវិជ្ជមាន ៤៥ ។ ដូចនេះ របៀបឬវិធីអប់រំនៅក្នុងគ្រួសារដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍការអោយតំលៃខ្លួនឯង ហើយទឹកចិត្តម្តាយបានដក់ជាប់ជ្រៅនៅក្នុងផ្លូវចិត្តរបស់មនុស្សគ្រប់រូបដែលសមដូចលោកប្រធានាធិបតីសហរដ្ឋអាមេរិក អាប្រាហាំ លីនខុន បានថ្លែងនៅពេលរូបលោកជាប់ជា

---

[44] Zimbado, Psychology & Life, opcit., p.59-60

[45] Rochelle L. James, The Correlation Between Adolescent Self-esteem, Religiosity and Perceive Family Support , op.cit. on line: http:/// clearing house .mwsc.edu/manuscrips/247.asp.

ប្រធានាបតីថា អ្វីដែលគាត់មានរហូតមកដល់ពេលនេះ និងទៅអនាគត គឺសុទ្ធតែជារបស់ដែលបានមកពីម្ដាយរបស់គាត់ ។ នេះគឺជាជំរៅថាមពលអប់រំរបស់ម្ដាយដែលដក់ជាប់មកលើផ្លូវចិត្តរបស់កូនគ្រប់គ្នា ហើយមតិកនៃសេចក្ដីស្រលាញ់នេះពិតជាមានឥទ្ធិពលដល់ការអោយតំលៃខ្លួនឯងរបស់មនុស្សគ្រប់រូប ។

២.២.១.២ - កត្តាមជ្ឈដ្ឋាន : ការអោយតំលៃខ្លួនឯងពឹងផ្អែកទៅលើកត្តាជាច្រើននៅជុំវិញខ្លួនយើង ហើយមនុស្សរស់នៅជាមួយកត្តាទាំងនេះជារៀងរាល់ថ្ងៃ ។ មជ្ឈដ្ឋានខាងក្រៅរួមមានអ្នកជិតខាង មិត្តភក្តិ ប្រពន្ធ័ផ្សព្វផ្សាយ វប្បធម ទំនៀមទំលាប់ និងសាសនា ដែលសមាសធាតុទាំងនេះជះឥទ្ធិពលដល់ការអោយតំលៃខ្លួនឯង ។ ការអោយតំលៃខ្លួនកើតឡើងដោយសារលទ្ធផលនៃបទពិសោធន៍របស់យើងជាច្រើនឆ្នាំ ពិសេសពេលដែលយើងរស់នៅតាំងពីវ័យកុមារភាព ។ កែវភ្នែកដែលយើងបានឃើញ ហើយត្រចៀកដែលយើងបានឮគ្រប់ពេលវេលាអំពីរឿងអាក្រក់ និងរឿងល្អលាយឡំគ្នាចំរុះបែបបានថតយកព្រឹត្តកាណ៍ទាំងនោះចូលក្នុងខួរក្បាលរបស់យើង ។ ការទទួលបានព្រឹត្តិការណ៍ទាំងនោះបន្តិចម្ដងៗបានស្ថាបនា និងកសាងឡើងវិញឥតឈប់ឈរនូវអ្វីដែលគេបានជួបប្រទះនៅក្នុងមជ្ឈដ្ឋានទាំងនោះ ។ លោក Patricia Kramer (1991) បានបញ្ជាក់ថា មនុស្ស និងវត្ថុនៅជុំវិញខ្លួនរបស់អ្នកជះឥទ្ធិពលដល់រូបអ្នកអោយមានអារម្មណ៍បែបណាមួយអំពីខ្លួនរបស់អ្នក រីឯបរិយាកាសជុំវិញខ្លួនរបស់អ្នកបានកំណត់ថា អ្នកនឹងក្លាយជាមនុស្សបែបណាមួយ ហើយសាសនាមានឥទ្ធិពលដល់បុគ្គលិកលក្ខណៈរបស់មនុស្ស ដោយវាជះឥទ្ធិពលដល់រូបភាពចិត្ត (Self-image) របស់អ្នក [៤៦] ។ ការអោយតំលៃខ្លួនឯងក៏ពឹងផ្អែកជាមូលដ្ឋានទៅលើទំនាក់ទំនងអន្តរបុគ្គល របៀបទំនាក់ទំនងក្នុងសង្គម ។ លោក Contantine និងលោក Marilyn បានបញ្ជាក់ថា ការអោយតំលៃខ្លួនឯងកើនឡើងឆ្លើយតបទៅនឹងការទទួលស្គាល់សង្គម ហើយការអោយតំលៃខ្លួនឯងធ្លាក់ចុះឆ្លើយតបទៅនឹងការបដិសេធសង្គម [៤៧] ។ នៅពេលមនុស្សយើងធ្វើរឿងរ៉ាវអ្វីមួយដែលត្រូវសង្គមទទួលស្គាល់ យើងនឹងមានទឹកចិត្តកាន់តែខ្លាំង និងកាន់តែឱ្យតំលៃខ្លួនយើង ប៉ុន្តែនៅពេលអ្វីមួយដែលយើងធ្វើនោះត្រូវបានសង្គមឱ្យតំលៃតិចឬមិនទទួលស្គាល់វិញ នោះមនុស្សយើងនឹងថមថយកំលាំងចិត្ត និងរសាយចិត្តលែងចង់ធ្វើ រីឯការមើលឃើញពីតំលៃខ្លួនឯងក៏ថមថយដែរ ។

លោក Mecca និង សហការីរបស់លោក (១៩៨៩) ក៏ដូចជាលោក Maruk (1995) បានអះអាងស្រដៀងគ្នាថា អត្តសញ្ញាណសង្គម និងបរិបទសង្គមមានទំនាក់ទំនងជាមួយការអោយតំលៃលើខ្លួនឯង ហេតុ

---

[46] Patricia Kramer, Self-esteem Library, Discovering the Real You, op.cit, p.7-9

[47] Constantine Sedikides , Marilynn B.Brewer, Individual Self, Relational Self , Collective Self, op.cit., p.74

ដូចនេះហើយមានការស្រាវជ្រាវថ្មីៗជាច្រើន បានធ្វើការយកចិត្តទុកដាក់ទៅលើទំនាក់ទំនងសាសនាជាមួយការអោយតំលៃលើខ្លួនឯង រីឯការស្រាវជ្រាវខ្លះបានអះអាងថា សាសនាមានឥទ្ធិពលតិចតួច ហើយខ្លះទៀតថាមានឥទ្ធិពលខ្លាំងដល់ការអោយតំលៃខ្លួនឯង ។ ទោះជាយ៉ាងណាក៏ដោយ សាសនាដែលដក់ជាប់ក្នុងចិត្តគំនិតមនុស្សគ្រប់រូបពិតជាមានឥទ្ធិពលដល់ការអោយតំលៃខ្លួនឯងរបស់មនុស្ស ទោះតិចក្តីឬច្រើនក្តី ។ សាសនាបានជ្រាបចូលក្នុងខួរក្បាលរបស់មនុស្សតាំងពីមនុស្សដឹងក្តីមកម្លេះ ។ ទោះជាការអោយតំលៃខ្លួនឯងមិនមានឥទ្ធិពលដល់សាសនាក៏ដោយ តែសាសនា និងជំនឿព្រលឹងវិញ្ញាណ ព្រមទាំងទំនៀមទំលាប់ពិតជាសមាសធាតុដ៏មានសក្តានុពលដល់ការកំណត់អត្តសញ្ញាណផ្ទាល់ខ្លួនរបស់មនុស្សគ្រប់រូប ។ លោក Habib បានរកឃើញថា និស្សិតសាកលវិទ្យាល័យដែលមានជំនឿស៊ុបមានការអោយតំលៃខ្លួនឯងកាន់តែខ្ពស់ បើប្រៀបធៀបជាមួយសិស្ស និស្សិតដែលមានជំនឿសាសនាមិនស៊ុប[៤៨] ។

ឥទ្ធិពលសង្គម វប្បធម៌រស់នៅក៏មានឥទ្ធិពលដល់ការអោយតំលៃខ្លួនដែរ ។ លោក Lilian G. Katz បានសន្និដ្ឋានថា ពលរដ្ឋរបស់លោកខាងលិចមានការអោយតំលៃខ្លួនឯងជាលក្ខណៈបុគ្គល (individual independent self-esteem) ខណៈពេលពលរដ្ឋលោកខាងកើតតំណាងអោយប្រទេសអាស៊ីមានការអោយតំលៃខ្លួនឯងមានលក្ខណៈអន្តរឯករាជ្យ (inter-independent self-esteem) ។ នេះក៏ដោយសារតែរបៀបរស់នៅរចនាសម្ព័ន្ធសង្គម វិធីសាស្រ្តចិញ្ចឹមកូនក្នុងគ្រួសារតែងតែមានឥទ្ធិពលដល់ការឱ្យតំលៃខ្លួនឯងរបស់មនុស្សក្នុងសង្គមនោះ ។ ដូច្នេះ ឥទ្ធិពលសង្គមរបស់ប្រទេសកម្ពុជាពិតជាបានដើរតួនាទីក្នុងការរួមចំណែកអភិវឌ្ឍការឱ្យតំលៃខ្លួនឯងរបស់មនុស្ស ហើយឥទ្ធិពលនេះបានដើរតួនាទីជាប្រចាំថ្ងៃ ។

២.២.១.៣ - *កត្តាសាលារៀន:* សាលារៀនមិនគ្រាន់តែជាទីកន្លែងបណ្តុះបណ្តាលមនុស្សអោយមានចំណេះដឹងប៉ុណ្ណោះទេ តែជីវិតនៅក្នុងសាលារៀនមានឥទ្ធិពលខ្លាំងណាស់ដល់បញ្ញត្តិផ្ទាល់ខ្លួនរបស់សិស្ស ដូចជាបណ្តុះបានរូបភាពចិត្ត បណ្តុះការអោយតំលៃខ្លួនឯង និងជួយអោយសិស្សមានការជឿជាក់លើខ្លួនឯង និងមានជំនឿលើខ្លួនឯង ។ នៅពេលសាលាបណ្តុះបានការអោយតំលៃលើខ្លួនឯង សិស្សកាន់តែទទួលបានជោគជ័យនៅក្នុងសាលារៀន ។ ជាមួយគ្នានេះ ការអោយតំលៃផ្ទាល់ខ្លួនរបស់សិស្សមានឥទ្ធិពលត្រលប់ទៅលើសាលារៀនវិញដែលស័ក្តិសមដូចលោក Marsh (1990) អះអាងថា សិស្សដែលមានការអោយតំលៃលើខ្លួនឯងកាន់តែខ្ពស់ទំនងជានាំអោយសិស្សនោះកាន់តែទទួលបានជោគជ័យនៅក្នុងសាលារៀន ។

[48] Rochelle L. James, The Correlation Between Adolescent Self-esteem, Religiosity and Perceive Family Support ,op.cit., online : http:/// clearing house .mwsc.edu/manuscrips/247.asp.

ប្រហែលគ្នានេះដែរ លោក Cansley & Tyler (1989) លោក Matcalfe (1981) និងលោក Reynolds (1980) បានបង្ហាញថា ការអោយតំលៃខ្លួនឯងកាន់តែខ្ពស់មានទំនាក់ទំនងទៅនឹងឥរិយាបថនៃការពេញចិត្ត និងចូលចិត្តសាលារៀនកាន់តែខ្លាំងឡើង ហើយមានអាកប្បកិរិយាកាន់តែវិជ្ជមានឡើងនៅក្នុងថ្នាក់រៀន ព្រមទាំងមានប្រជាប្រិយភាពជាមួយសិស្សដទៃទៀតកាន់តែខ្លាំងឡើងនៅក្នុងសាលារៀន [៤៩] ។ សមត្ថភាព និងចំណេះដឹងអាចជួយអោយមនុស្សមានការអោយតំលៃលើខ្លួនឯង ។ លោក Lilian G. Katz បានផ្តល់ដំបូន្មានថា អ្នកអប់រំត្រូវតែគិតឡើងវិញពីយុទ្ធសាស្ត្រដែលត្រូវយកមកប្រើក្នុងពេលបច្ចុប្បន្ន ដើម្បីជំរុញអោយការអោយតំលៃខ្លួនឯងរបស់សិស្សចំរើនឡើង ។ គាត់ក៏បានជំរុញអោយអ្នកអប់រំទាំងឡាយអោយគិតពិចារណាអំពីអ្វីដែលជាកត្តាមានឥទ្ធិពលដល់អារម្មណ៍របស់សិស្សក្នុងការអោយតំលៃខ្លួនឯង [៥០] ។ គេគួរតែរៀបចំគោលបំណងកម្មវិធីសិក្សារបស់សាលា ដើម្បីអោយកុមារមានអារម្មណ៍ល្អក្នុងការជំរុញអោយមានបញ្ញត្តិផ្ទាល់ខ្លួនឯងខ្ពស់ ។ សៀវភៅដែលអោយកុមារអាន និងឧបករណ៍ផ្តល់អោយកុមារលេងអាចជួយអោយសិស្សមានអារម្មណ៍ល្អអំពីខ្លួនគេ ។ ការប្រើប្រាស់ពាក្យសំដីសសើរលើកទឹកចិត្តដោយសមហេតុផលរបស់គ្រូ ដូចជា ( គ្រូចូលចិត្តការងាររបស់អ្នក អ្នកជាមនុស្សពិសេស គ្រូពេញចិត្តពិន្ទុសិក្សាល្អរបស់អ្នក) ជួយបណ្តុះបាននូវការអោយតំលៃខ្លួនឯងរបស់សិស្សកាន់តែខ្លាំងឡើង ។ ខ្លឹមសារកម្មវិធីសិក្សាស្តីអំពីវប្បធម៌ អរិយធម៌ស្នប់ស្នែង និងមោទនភាពរបស់ជាតិអាចជួយជំរុញបណ្តុះចិត្តសិស្សអោយមានអារម្មណ៍មោទនភាព ។ ការសសើរដោយការបង្ហាញគំរោងស្នាដៃរបស់សិស្ស ការផ្តល់សម្ភារៈសំរាប់លេងក៏ជាការជួយអោយសិស្សមើលឃើញថា ពួកគេជាមនុស្សល្អ និងមានតំលៃដែលទាំងនេះជាឫសគល់ជួយអោយគេមានការអោយតំលៃខ្លួនឯងខ្លាំងថែមទៀត ។

សាលារៀនជាទីកន្លែងដែលជួយអោយសិស្សបានអភិវឌ្ឍសមត្ថភាពដែលអាចឈានដល់ការកំណត់ពីខ្លួនឯង និងជាទីកន្លែងទំនាក់ទំនងជាមួយមិត្តភ័ក្តិរបស់គេកាន់តែរីកដុះដាលល្អឡើង ហើយក៏ជាទីកន្លែងដែលសមាជិកសហគមដើរតួក្នុងរយៈកាលការអភិវឌ្ឍកាន់តែខ្ពស់ឡើង ។ ដូច្នេះ ការកសាងការអោយតំលៃខ្លួនឯង សមត្ថភាពអន្តរបុគ្គល ការដោះស្រាយបញ្ហា និងភាពជាអ្នកដឹកនាំមានសារៈសំខាន់ណាស់ក្នុងភាពត្រឹមត្រូវ ក៏ដូចជាការពង្រីកភាពជោគជ័យក្នុងការសិក្សា [៥១] ។ តាមការស្រាវជ្រាវរបស់លោក Hoge , Smit និងលោក Hanson (1990) បានរកឃើញថា ការពេញចិត្ត ការចូលចិត្តរបស់សិស្សជាមួយសាលារៀន ការ

---

49 Rot Hok, Foundation of Education, in lecture paper, p.111

50 Lilian G. Katz, Distinction Between Self-Esteem and Narcissism: Implications for Practice, op.cit., p.1-2

51 Woolfolk, Educational Psychology,op.cit, p.112

យល់ដឹង (sense) ពីការចាប់អារម្មណ៍ពីមិត្តរួមថ្នាក់ ពីការយកចិត្តទុកដាក់ ការវាយតំលៃ និងការឆ្លើយតប របស់គ្រូបង្រៀនមានឥទ្ធិពលដល់ការអោយតំលៃខ្លួនឯងរបស់សិស្ស ។ ដូច្នេះ សាលារៀន ពិសេសគ្រូបង្រៀន មានតួនាទីសំខាន់ណាស់ក្នុងការបង្កើតបរិយាកាស សំរាប់បណ្តុះបានការអោយតំលៃខ្លួនឯងរបស់សិស្ស និង ជួយឱ្យសិស្សមានអារម្មណ៍យល់ដឹងអំពីខ្លួនគេក្នុងកម្រិតណាមួយ ដែលគ្រូកំពុងដើរតួជាគំរូដល់អារម្មណ៍ ឥរិ-យាបថ និងអាកប្បកិរិយារបស់ពួកគេ រីឯខ្លឹមសារមេរៀន និងសម្ភារៈសិក្សាក៏ជះឥទ្ធិពលដល់ការអោយតំលៃ ខ្លួនឯងរបស់សិស្សដែរ ។

២.២.១.៤ - កត្តាតំណពូជ : រូបសម្បត្តិ ពណ៌សំបុរ ទ្រង់ទ្រាយមាឌ កំពស់បានទទួលពី បុព្វបុរសរបស់យើង ។ រូបសម្បត្តិជួយអោយមនុស្សមានការអោយតំលៃខ្លួនឯង ។ គេអាចធ្វើការទំនាក់ទំនង ជាសាធារណៈនៅទីកន្លែងប្រកួតរូបសម្បត្តិ ដោយសារតែគេជឿជាក់លើសោភ័ណភាពរបស់គេ ។ ឧទាហរណ៍ យុវជនដែលចូលរួមប្រលង “Freshy Boy and Girl” ដែលបង្ហាញពីរូបរាងកាយរបស់គេជាសក្ខីភាព បង្ហាញថា ពួគេទាំងនោះមានការអោយតំលៃលើរូបសម្បត្តិរបស់គេ ។ លោក Freud បានអះអាងថា វាសនា របស់មនុស្សយើងជាប់ទាក់ទងទៅនឹងការចំលងនៃតំណពូជ (genetic blueprint) ហើយរឿងនោះធ្វើអោយ យើងកាន់តែខិតខំកែច្នៃធ្វើឱ្យលក្ខណៈធម្មជាតិរបស់យើងក្លាយទៅជាមនុស្សបែបណាមួយ ហើយរឿងដែល យើងធ្វើមានឥទ្ធិពលដោយសារលក្ខណៈសរីរាង្គរបស់យើង[៥២] ។

សុខភាពផ្លូវចិត្ត និងផ្លូវកាយមានភាពប្រសើរជួយជំរុញអោយកុមារមានអារម្មណ៍ល្អ និងទទួលខុស ត្រូវ ។ សុខភាពផ្លូវកាយ សរីរាង្គខាងក្នុង ឈាម គោលិការក្រហម ដំណើរវិវត្តន៍ផ្លូវដង្ហើមដើរតួនាទីក្នុងការកំ-ណត់ដល់រូបរាងកាយអោយដំណើរការល្អ លើសនេះទៅទៀត វាជួយដល់ការភិវឌ្ឍការអោយតំលៃខ្លួនឯងរបស់ មនុស្ស ។ លោក Zeman (2003) បានអះអាងថា មនុស្សដែលមានសុខភាពល្អមាំទាំមានការអោយតំលៃខ្លួន ឯងខ្ពស់[៥៣] ។

### ២.២.៥- ការកសាងការអោយតំលៃខ្លួនឯង

ការអោយតំលៃខ្លួនឯងអាចត្រូវបានគេស្ថាបនាបាន ហើយវាអាចរីកចំរើនជាប្រចាំ ។ មូលដ្ឋានស្នូល ក្នុងការកសាងការអោយតំលៃខ្លួនឯងគឺអាស្រ័យលើបុគ្គលខ្លួនឯងផ្ទាល់ជាមុន ប៉ុន្តែ មជ្ឈដ្ឋានខាងក្រៅក៏មាន ឥទ្ធិពលដល់ការអោយតំលៃខ្លួនឯង ព្រោះមនុស្សគ្រប់រូបទទួលឥទ្ធិពលនេះចាប់តាំងពីទារកភាពរហូតមកដល់

---

[52] James V. Mc Connell, Understand Human Behavior, CBS College publishing, 1986, p.267

[53] Miller, The correlation between sense of Humor and Mental health, on line : Http:clearinghouse mwsc. edu/manscripts/405.asp

ជីវិតបច្ចុប្បន្នរបស់គេ ។ ឥទ្ធិពលចំរុះពិណបានដក់ជាប់ក្នុងរូបភាពចិត្តដែលកំណត់ដល់ការរីកលូតលាស់ការឱ្យតំលៃខ្លួនឯងរបស់មនុស្សគ្រប់រូប ។

### ២.២.៥.១ - ការកសាងការអោយតំលៃខ្លួនឯងពីសំណាក់គ្រួសារ

#### - អនុភាពរបស់ឳពុកម្តាយ

ឳពុកម្តាយដើរតួនាទីយ៉ាងសំខាន់ដំបូងគេបង្អស់ក្នុងការជួយកសាង និងអភិវឌ្ឍការអោយតំលៃខ្លួនរបស់បុត្រធីតា ព្រោះពួកគាត់មានទំនាក់ទំនងជាប់ជានិច្ចជាមួយកូនៗរបស់គាត់ ។ កាយវិការ សរិយាបថ និងទង្វើរបស់ឳពុកម្តាយប្រៀបបានជាកញ្ចក់ដ៏មានឥទ្ធិពលដល់អារម្មណ៍របស់កូនពួកគាត់ និងអាចជួយអោយពួកគេចេះពីរបៀបទំនាក់ទំនងនៅក្នុងគ្រួសារ ព្រមទាំងជួយអោយពួកគេមានភាពកក់ក្តៅ និងមានអារម្មណ៍ចេះស្រលាញ់ គោរព និងការអោយតំលៃខ្លួន [៥៤] ។ ឳពុកម្តាយជាអ្នកជួយដឹកនាំកូនរបស់ខ្លួនអោយមើលឃើញពីខ្លួនឯងថាជាមនុស្សមានសមត្ថភាព រឺ គ្មានសមត្ថភាព ជាមនុស្សឆ្លាត ឬល្ងង់ខ្លៅ ជាមនុស្សមានប្រសិទ្ធភាព ឬគ្មានប្រយោជន៍ និងជាមនុស្សគ្មានតំលៃ ឬគួរអោយស្រលាញ់ ។ ការស្រលាញ់ ការគោរព និងការសសើររបស់ឳពុកម្តាយមានកំលាំងខ្លាំងក្លា និងមានអត្ថន័យខ្លាំងណាស់ចំពោះកុមារ ដើម្បីជួយអោយពាស្គាល់ខ្លួនឯង ចេះធ្វើគ្រាប់តាម និងទទួលបាននូវការអោយតំលៃខ្លួនឯង ព្រមទាំទទួលបាននូវការពេញចិត្តខាងផ្នែកផ្លូវចិត្តដែលអាចបន្តរមួយជីវិត ។ តម្រូវការនៃសេចក្តីស្រលាញ់របស់ឳពុកម្តាយមានកំឡាំងខ្លាំងណាស់សំរាប់កូន ហើយអាចបន្តយ៉ាងយូរក្រោយពីឳពុកម្តាយរបស់គេស្លាប់ទៅទៀត [៥៥] ។ សេចក្តីស្រលាញ់នេះមានឥទ្ធិពលដ៏សែនជ្រាលជ្រៅនៅក្នុងជំរៅចិត្តកូន ។ លោក អាប្រាហាម លីនខុន បាននិយាយថា អ្វីៗទាំងអស់ដែលគាត់មានមកដល់ពេលនេះ និងមានបន្តទៅទៀតនេះ គឺជាសមិទ្ធផលបានមកពីម្តាយរបស់គាត់ ។ នេះបញ្ជាក់ថា សេចក្តីស្រលាញ់ និងទឹកចិត្តរបស់ឳពុកម្តាយាបានកប់យ៉ាងជ្រៅនៅក្នុងផ្លូវចិត្តរបស់កូនគ្រប់រូប ។ ទោះបីលោកអ្នកដែលជាឳពុកម្តាយពុំបានទទួលអំណោយនៃសេចក្តីស្រលាញ់ និងការថ្នាក់ថ្នមបានល្អពីឳពុកម្តាយរបស់អ្នកក៏ដោយតែអ្នកត្រូវតែផ្តល់នូវសេចក្តីស្រលាញ់ និងការទទួលយកដល់កូនរបស់អ្នក ។ ការជួយផ្តល់អោយកូនរបស់អ្នកនូវទំនាក់ទំនងល្អក្នុងគ្រួសារ ការទទួលស្គាល់ ការទទួលយក ការផ្តល់ភាពជាម្ចាស់ និងផ្តល់សិទ្ធិសេរីភាពដល់ពួកគេក្នុងការធ្វើការសម្រេចចិត្ត ការផ្តល់ភាពទូលាយខាងទំនាក់ទំនង និងការមើលឃើញពីសេចក្តីស្រលាញ់លើខ្លួនឯង ជួយអោយកុមារមានការអោយតំលៃខ្លួនឯងបានល្អដើម្បីការពារខ្លួនគេក្នុងជីវិតរស់នៅ ។

[54] Matthew Mckay, Ph.D, Patrick Fanning, Self-Esteem, op.cit., p.279
[55] Ibid., p.280

- ការប្រើប្រាស់ភាសា

ការប្រើភាសាជាឧបករណ៍ដ៏មានឥទ្ធិពលក្នុងការកសាងការអោយតំលៃខ្លួនឯងបានល្អ ។ រៀងរាល់ថ្ងៃ មាតាបិតាតែងតែប្រើភាសាសំរាប់ទំនាក់ទំនងជាមួយកូនរបស់ពួកគាត់ ។ ការប្រើភាសាដែលមានប្រសិទ្ធភាពគួរមើលពេលវេលា និងប្រភេទបុគ្គលដែលអ្នកប្រាស្រ័យទៅកាន់នោះ ។ ពាក្យទំនៀមខ្មែរក៏បានបញ្ជាក់ថា "ស្លាប់ព្រោះតែមាត់" ដោយធ្វើការប្រៀបធៀបប្រភេទត្រីកំភ្លាញដែលអ្នកនេសាទប្រមាញ់បាន ដោយសារមាត់របស់វា ។ សំដី និងការបន្លឺសម្លេងរបស់ឪពុកម្តាយមានឥទ្ធិពលដល់អារម្មណ៍ខ្លួនអ្នកផង និងអ្នកដទៃផង ។ ការប្រើភាសាគួរត្រូវធ្វើតាមការប្រើភាសាពិពណ៌នាវិជ្ជមាន ដូចជាការនិយាយថា ក្មេងឆ្លាត កូនល្អវាមានប្រយោជន៍ជាងពោលថា ក្មេងល្ងង់ ក្មេងទុយមុយជាដើម ។ ការប្រើភាសាវិជ្ជមាន មានប្រយោជន៍ជាងការប្រើភាសាអវិជ្ជមានសំរាប់កុមារ ។ ការប្រើភាសាល្អៗជួយលើកតម្កើងការអោយតំលៃខ្លួនឯង ប៉ុន្តែគេមិនត្រូវប្រើភាសាសសើរអោយជ្រុលហួសហេតុពេកនោះទេ ព្រោះអាចនាំអោយកុមារមានភាពមិនស្រួលក្នុងចិត្ត និងមិនមានអារម្មណ៍កក់ក្តៅក្នុងចិត្ត ។ ការសសើរច្រើនជ្រុលហួសហេតុ មិនអាចទ្រាំទ្របាន និងមិនអាចទទួលយកបានទេ ។ ការពិពណ៌នាអំពីអាកប្បកិរិយា( អ្វីដែលអ្នកបានឃើញ បានឮ និងអ្វីបានកើតឡើង) ផ្តល់ផលដល់កុមារនូវចំលើយឆ្លើយតបដ៏ត្រឹមត្រូវអំពីរបៀបដែលពួកគេធ្វើសកម្មភាព ហើយសកម្មភាពទាំងនោះជះឥទ្ធិពលដល់អ្នកដទៃទៀតផង [៥៦] ។

ម្យ៉ាងវិញទៀត ប្រតិកម្មនៃការប្រើភាសារបស់មនុស្សក៏ជះឥទ្ធិពលដល់ការឱ្យតំលៃខ្លួន ការពេញចិត្ត ឬ ការមិនពេញចិត្ត ការរីករាយ និងការខឹងសម្បារ ។ កុមារអាចមើលឃើញពីតំលៃខ្លួនរបស់គេបែបណាមួយនៅពេលណាមនុស្សធំមានប្រតិកម្មទៅលើគេ ប៉ុន្តែប្រតិកម្មវិជ្ជមាន ដូចជា ការនិយាលើកទឹកចិត្ត និងការនិយាយសរសើរ មានភាពប្រសើរដល់ការអោយតំលៃខ្លួនឯងរបស់កុមារ ។ លោក Judith Mckay R.Nបានបញ្ជាក់ថា ពាក្យសំដីវិនិច្ឆ័យ សំលេងរិះគន់ខ្លាំងៗ ដែលអ្នកទទួលបានពីឪពុកម្តាយហើយបានដក់ជាប់មកខាងក្នុងខួរក្បាលនោះ គឺជាសូរសំលេងដែលអ្នកបានឮតាំងពីកុមារភាព ។ ភាពភ័យខ្លាច ការកំណត់ព្រំដែនអារម្មណ៍នៃការឥតប្រយោជន៍ដែលអ្នកព្យាយាមនៅពេលបច្ចុប្បន្ន ក៏មានមកជាមួយរូបអ្នកតាំងពីកុមារភាពមកដែរ [៥៧] ។ ការសរសើរមានឥទ្ធិពលដល់ផ្លូវចិត្តរបស់កុមារ ។ ប្រសិនបើឪពុកម្តាយធ្វើការសសើរកុមារ ពួកគាត់កំពុងជួយអោយវាទទួលស្គាល់តំលៃ និងទទួលស្គាល់ការប្រឹងប្រែងរបស់វា ។ ឪពុកម្តាយដែលតែងតែ

[56] Matthew Mckay, Ph.D , Patrick Fanning, Self-Esteem, op.cit.,p. 293
[57] Ibid., p.279

ប្រើភាសាថ្លែងអំណរគុណដល់កូនកំពុងជួយឱ្យពួកវាមានការជឿជាក់ និងការពេញចិត្តពីខ្លួនរបស់វា ។ ការពេញចិត្តរបស់អ្នកគឺជារឿងដែលមានឥទ្ធិពលដល់អាកប្បកិរិយារបស់កុមារ [៥៨] ។

**- វិន័យ និងការត្រួតពិនិត្យរបស់ឪពុកម្តាយ**

វិន័យត្រូវបានគេយកមកអនុវត្តក្នុងការបង្ហាត់បង្រៀនក្នុងគ្រួសារ សាលារៀន និងទីកន្លែងផ្សេងទៀត ។ វិន័យជួយអោយមនុស្សមានសីលធម៌ល្អ និងជួយជំរុញផ្លូវចិត្តរបស់មនុស្សបានល្អប្រសើរ នៅពេលណាវិន័យត្រូវបានគេយកមកអនុវត្តបានសមរម្យ ។ កុមារធំធាត់ឡើងដោយគ្មានវិន័យមានការអោយតំលៃខ្លួនឯងទាប ហើយតែងតែមានភាពមិនឯករាជ្យ និងសម្រេចបានសមិទ្ធផលតិចតួច ព្រមទាំងមានលទ្ធភាពគ្រប់គ្រងស្ថានភាពជុំវិញខ្លួនបានតិចតួចបំផុត ។ ជាងនេះទៅទៀត ពួកគេនឹងមានអារម្មណ៍តានតឹងឡើង ដោយសារពួកគេមិនប្រាដកថា រឿងរ៉ាវមួយត្រូវបានកំណត់ត្រឹមណា ដែលនេះជាហេតុនាំអោយពួកគេធ្លាក់ចូលក្នុងបញ្ហា ។ វិន័យដែលធ្វើឡើងបានត្រឹមត្រូវ សមហេតុផល និងសមស្របតាមអាកប្បកិរិយារបស់កុមារមានសារសំខាន់ណាស់ តែបើមិនសមស្របវិញនោះ វាអាចបណ្តាលឱ្យពួកគេមានបញ្ហាចំពោះជំនឿលើខ្លួនគេ ។ ប្រសិនបើវិន័យមានភាពត្រឹមត្រូវ យុត្តិធម៌ និងការគិតទុកជាមុន ព្រមទាំងការទទួលយកបានពីកុមារ នោះកុមារអាចយល់ដឹង និងកាន់តែលូតលាស់ជាមួយការអោយតំលៃខ្លួនឯងរបសវាថែមទៀត ។

ជាមួយគ្នានេះ ឪពុកម្តាយដើរតួនាទីសំខាន់ក្នុងនាមជាអ្នកសង្កេតមើលចំណុចវិជ្ជមាន និងអវិជ្ជមានរបស់កូន ។ ការមើលឃើញពីចំណុចវិជ្ជមាន និងអវិជ្ជមានអាចជួយអោយឪពុកម្តាយជ្រើសរើសវិធីសមស្របក្នុងការអភិវឌ្ឍការអោយតំលៃខ្លួនរបស់កូនខ្លួនបាន ។ ឪពុកម្តាយជាមនុស្សដំបូងគេក្នុងការទំនក់ទំនងជាមួយកុមារ ហើយឥទ្ធិពលនេះបានចាក់ឫសដល់ផ្លូវចិត្តរបស់ពួកគេមកដល់ពេលបច្ចុប្បន្ន តែឪពុកម្តាយត្រូវស្តាប់ហេតុផលកូនខ្លួនវិញដែរ និងផ្តល់ការយកចិត្តទុកដាក់ដល់កូនអោយបានគ្រប់គ្រាន់ ។ ពួកគាត់ជាអ្នកជួយកាត់បន្ថយការខូចចិត្តរបស់កូន និងជាអ្នកដឹកនាំអោយកូនគាត់ចេះវែកញែកពីហេតុនិងផល ។ គ្រួសារដែលមានការត្រួតពិនិត្យ និងមានតំរោងកាលវិភាគធ្វើការក្នុងផ្ទះច្បាស់លាស់តែងតែជួយដល់កុមារក្នុងគ្រួសារបែបនោះមានវិន័យ និងមានរបៀបរស់នៅបានល្អដែលសមដូចលោក Coppersmith (1967) បានបញ្ជាក់ថាកុមារដែលមានការអោយតំលៃខ្លួនឯងខ្ពស់ ត្រូវបានគេមើលឃើញចំពោះកុមារណាដែលមានឪពុកម្តាយមានការដាក់វិន័យសមហេតុផល និងមានការប្រុងប្រយ័ត្នប្រយែងជាបន្តបន្ទាប់ [៥៩] ។ ប៉ុន្តែនៅពេលណាវិន័យត្រូវបានគេធ្វើឡើងក្នុងការបង្ខិតបង្ខំតាមតែអំពើចិត្ត និងប្រព្រឹត្តឡើងម្តងបែបនេះម្តងបែបនោះ ឬក៏ធ្វើអោយ

[58] Matthew Mckay, Ph.D , Patrick Fanning, Self-Esteem, op.cit., p.294

[59] Zimbado, Psychology and Life, op.cit., p.59-60

កុមារមានអារម្មណ៍អៀនខ្មាស់ ស្តីបន្ទោស និងប្រើកំឡាំងជ្រុល និងមានការធ្វើអោយអាមាស់មុខ ពេលនោះកុមារយល់ថា ខ្លួនគេគ្មានតំលៃ ហើយបាត់បង់លើការជឿជាក់លើខ្លួនឯង ដែលជាហេតុនាំអោយពួកគេធ្វើរឿងរាវមិនបានត្រឹមត្រូវ [៦០] ។ ដូច្នេះ វិន័យនៅក្នុងគ្រួសារជួយអោយកុមារមានកំលាំងផ្លូវចិត្តដែលជាជំនួយដ៏ប្រសើរក្នុងការអភិវឌ្ឍដល់ការអោយតំលៃខ្លួនឯងដល់ពួកគេ ។

**- ការធ្វើគំរូនៃការអោយតំលៃខ្លួនឯង**

ឪពុកម្តាយប្រៀបបានកញ្ចក់សំរាប់កូនគាត់ឆ្លុះមើលជាប្រចាំថ្ងៃ ។ ការសង្កេតមើលពីគំរូរបស់ឪពុកម្តាយគ្រប់ពេលវេលា ទាំងការសប្បាយ និងសេចក្តីទុក្ខព្រួយរបស់គាត់ជួយអោយកុមារដក់ជាប់នូវអារម្មណ៍ពីគំរូនៃអំពើរបស់ឪពុកម្តាយ ។ លោក Dorothy Law Nolte បានផ្តល់នូវការអះអាងគោលការណ៍ណែនាំសំរាប់ជាជំនួយដល់ការលើកតំលៃដល់កុមារក្នុងការអភិវឌ្ឍការអោយតំលៃខ្លួនឯង ។ គោលការណ៍ទាំងនោះរួមមាន :

ប្រសិនបើកុមាររស់នៅដោយមានការរិះគន់ ពួកគេនឹងរៀនពីរបៀបថ្កោលទោស

ប្រសិនបើកុមាររស់នៅជាមួយគំរូអាកប្បកិរិយាច្រឡោងខាង ពួកគេនឹងរៀនពីរបៀបឈ្លោះប្រកែកគ្នា

ប្រសិនបើកុមាររស់នៅដោយមានការសើចចំអកអោយ ពួកគេនឹងរៀនពីរបៀបអៀនខ្មាស់

ប្រសិនបើកុមាររស់នៅជាមួយភាពអៀនខ្មាស់ ពួកគេនឹងរៀនពីអារម្មណ៍កំហុសឆ្គង

ប្រសិនបើកុមាររស់នៅដោយមានការអធ្យាស្រ័យ និងយោគយល់ ពួកគេនឹងរៀនពីរបៀបចេះអត់ធ្មត់

ប្រសិនបើកុមាររស់នៅដោយមានការលើកទឹកចិត្ត ពួកគេនឹងរៀនពីការជឿជាក់

ប្រសិនបើកុមាររស់នៅដោយមានការសសើរ ពួកគេនឹងរៀនពីរបៀបលើកតំលៃ និងការយោគយល់គ្នា

ប្រសិនបើកុមាររស់នៅជាមួយភាពទៀតត្រង់យុត្តិធម ពួកគេនឹងរៀនពីយុត្តិធម

ប្រសិនបើកុមាររស់នៅជាមួយនឹងភាពមានសណ្តាប់ធ្នាប់ ពួកគេនឹងរៀនពីជំនឿទុកចិត្ត

ប្រសិនបើកុមាររស់នៅដោយមានការពេញចិត្ត និងការចូលចិត្ត ពួកគេនឹងរៀនពីរបៀបចូលចិត្តខ្លួនឯង

ប្រសិនបើកុមាររស់នៅដោយមានការទទួលយក និងមិត្តភាព ពួកគេនឹងរៀនពីរបៀបស្វែងរកសេចក្តីស្រលាញ់ក្នុងពិភពលោក ។ នៅក្នុងគោលការណ៍ណែនាំទាំងនេះ រឿងសំខាន់ដែលឪពុកម្តាយអាចជួយបណ្តុះបណ្តាលការអោយតំលៃខ្លួនឯងដល់បុត្រធីតា គឺត្រូវផ្តល់នូវការស្រលាញ់ដល់ពួកគេដោយគ្មានលក្ខខ័ណ្ឌ ធ្វើជាគំរូដល់ពួកគេ ណែនាំកូនរបស់ខ្លួនអោយចេះថែរក្សា និងគិតវិធីវិជ្ជមាន និងផ្តល់សភាពកក់ក្តៅដល់ពួកគេ ។

[60] Zimbado, Psychology and Life, op.cit., p.300

ជាមួយគ្នានេះដែរ ឪពុកម្តាយអាចជួយអោយកូនរបស់ខ្លួនមានការអោយតំលៃខ្លួនឯងល្អ ដោយជួយអោយពួកវាចេះដោះស្រាយស្ថានភាពលំបាក ចេះគ្រប់គ្រងកំហឹង ដោះស្រាយភាពតានតឹង នឹងចេះដោះស្រាយជំលោះ ។ ឪពុកម្តាយដើរតួនាទីយ៉ាងសំខាន់ក្នុងពង្រឹង និងពង្រីកការអោយតំលៃខ្លួនឯងរបស់កុមារដោយយកចិត្តទុក-ដាក់នូវការគោរពទទួលយកគំនិត និងទស្សនៈរបស់ពួកវា ព្រមទាំងបង្ហាញការយកចិត្តទុកដាក់ដល់ពួកគេឱ្យមានអារម្មណ៍កក់ក្តៅ សុខស្រួលក្នុងចិត្ត ។

យុទ្ធសាស្ត្រ និងវិធីដែលឪពុកម្តាយជួយអភិវឌ្ឍការអោយតំលៃខ្លួនឯងដល់កូន

មាតាបិតាតែងតែចង់អោយកូនរបស់ខ្លួនមានជំនឿចិត្តលើខ្លួនឯង និងមានការសំរេចចិត្តដោយខ្លួនឯងមានការឱ្យតំលៃខ្លួនឯងខ្ពស់ ។ ឪពុកម្តាយមួយចំនួនមានការយល់ដឹងពីរបៀបអប់រំកូនអោយមានការអោយតំលៃខ្លួនឯង រីឯឪពុកម្តាយខ្លះទៀតបានអប់រំកូនអោយមានការអោយតំលៃលើខ្លួនឯង និងមានការជឿជាក់លើខ្លួនឯង ខណៈពេលដែលពួកគាត់មិនបានដឹងថាវិធី និងយុទ្ធសាស្ត្រដែលគាត់កំពុងប្រើប្រាស់នោះជួយឱ្យកូនរបស់គាត់ក្លាយជាមនុស្សមានការជឿជាក់លើខ្លួនឯងឡើយ ។ ខាងក្រោមនេះជាយុទ្ធសាស្ត្រ និងវិធីដែលជួយអោយឪពុកម្តាយអប់រំកូនរបស់ខ្លួនអោយមានជំនឿជឿជាក់លើខ្លួនឯង :

- ផ្តល់ដល់កុមារអោយមានអារម្មណ៍យល់ថាឪពុកម្តាយកំពុងពេញចិត្តនឹងខ្លួន
- លើកទឹកចិត្តអោយកុមារធ្វើរឿងរ៉ាវអោយបានត្រឹមត្រូវតាមនិយាមសីលធម
- ទទួលស្គាល់ និងស្តាប់គំនិតរបស់កូនខ្លួន
- សរសើរកូនរបស់ខ្លួនអោយបានច្រើនជាងការរិះគន់
- ផ្តល់អោយកូនខ្លួនចេះគ្រប់គ្រងលើជីវិតរបស់គេអោយមានគំនិតឯករាជ្យ
- អោយកូនខ្លួនយល់ដឹងថា គេជាមនុស្សគួរអោយស្រលាញ់ និងមានសមត្ថភាព
- កុំផ្តល់អ្វីដល់កុមារនូវអ្វីដែលអ្នកមិនចង់អោយអ្នកដទៃផ្តល់ដល់ខ្លួនអ្នកនោះ
- ឪពុកម្តាយត្រូវដឹងពីកត្តាប្រថុយប្រថានដែលធ្វើអោយកូនខ្លួនធ្លាក់ទៅក្នុងស្ថានភាពងាយរងគ្រោះ
- គាំទ្រការខិតខំប្រឹងប្រែងរបស់កូនទាំងនៅក្នុងផ្ទះ និងក្រៅផ្ទះ
- លើកតម្កើងមិត្តភាព និងជួយអោយកូនមានបំណិនសង្គម
- ផ្តល់ឱកាសដល់កូនរបស់ខ្លួន ដើម្បីសំរេចបានជោគជ័យ
- យកចិត្តទុកដាក់ និងចាប់អារម្មណ៍ទៅនឹងសកម្មភាពរបស់កូនខ្លួន
- ត្រូវមើល និងតាមដានវាយតំលៃអាយត្រឹមត្រូវ ក្នុងគោលបំណងបំរែបំរួលអាកប្បកិរិយាអោយបានល្អ

- គ្រប់គ្រងកូនតាមប្រភេទពន្យល់ហេតុផល ដើម្បីអោយកូនយល់ និងឯកភាពព្រមទទួលយកដោយរីករាយ

- ទទួលស្គាល់សមត្ថភាព និងទេកោសល្យរបស់កូន និងជួយជំរុញអោយពួកគេទទួលស្គាល់នូវអ្វីដែលជាភាពពិសេសរបស់ពួកគេ

- ត្រូវយល់អំពីអាកប្បកិរិយារបស់កូនខ្លួនថា គេកំពុងស្ថិតក្នុងបរិបទបែបណា

- ត្រូវទទួលយកទាំងរឿងល្អ ទាំងអាក្រក់ពីកុមារ និងធ្វើអោយវាមានអារម្មណ៍ថា ខ្លួនវាត្រូវបានគេចាប់អារម្មណ៍ និងមើលឃើញសកម្មភាពរបស់វា [៦១] ។

២.២.៥.២ - ការកសាងការអោយតំលៃខ្លួនឯងពីសំណាក់សាលារៀន

តាមការស្រាវជ្រាវ និងការអង្កេតរបស់ក្រុមអ្នកស្រាវជ្រាវលើការអោយតំលៃខ្លួនឯងបានផ្តល់នូវទស្សនៈជាច្រើន ដើម្បីជួយលើកតម្កើងដល់ការអោយតំលៃខ្លួនឯងរបស់សិស្ស និស្សិតនៅក្នុងវិស័យអប់រំ ។ ខ្លឹមសារអប់រំ វិធីសាស្ត្រអប់រំបង្កប់អត្ថន័យពីភាពស្មុគស្មាញ និងមោទនភាពអរិយធម៌ជាតិ ជាការជួយដល់ការបណ្តុះបាននូវការអោយតំលៃខ្លួនឯងរបស់សិស្ស និងនិស្សិត ។ សិស្សអភិវឌ្ឍអារម្មណ៍អំពីសមត្ថភាពខាងបញ្ញាញាណ ប្រជាប្រិយភាពក្នុងចំណោមគ្នាគេ និងសមត្ថភាពបង្កើតនូវសកម្មភាពផ្សេងៗទៀត ។ ប្រសិនបើពួកគេទទួលបានជោគជ័យដោយសមហេតុផលចំពោះសមាសភាពខាងលើ សិស្សនឹងមានអារម្មណ៍វិជ្ជមានពីតំលៃផ្ទាល់ខ្លួនរបស់គេ ហើយសិស្សដែលមានអារម្មណ៍បែបនេះតែងតែចង់ចូលរួមប្រកួតប្រជែងក្នុងការសិក្សា ប៉ុន្តែបើពួកគេខកខានមិនបានសំរេចលើផ្នែកណាមួយនោះ គេនឹងមានទស្សនៈដែលឱ្យតំលៃទាបលើខ្លួនរបស់គេ ។ ដូច្នេះ ដើម្បីលើកតម្កើង និងបណ្តុះការឱ្យតំលៃលើខ្លួនឯងនៅក្នុងវិស័យអប់រំ គ្រូនិងអ្នកអប់រំត្រូវគិតដល់យុទ្ធសាស្ត្រ និងវិធីដូចខាងក្រោម :

- គ្រូត្រូវវាយតំលៃ និងទទួលស្គាល់ការខិតខំប្រឹងប្រែង និងបង្ហាញស្នាដៃរបស់សិស្ស

- បង្កើតបរិយាកាសដែលផ្តល់អោយសិស្សមានសុវត្ថិភាពផ្នែករាងកាយ និងផ្នែកផ្លូវចិត្ត

- ត្រូវយល់ដឹងពីភាពលំអៀងលើខ្លួនផ្ទាល់ខ្លួន និងក្តីសង្ឃឹមរបស់ខ្លួន

- ដឹងច្បាស់ពីទំរង់ការបង្រៀន និងការបែងចែកក្រុមសិស្សសំរាប់ជាមធ្យោបាយដោះស្រាយបញ្ហា និងផ្តល់អោយសិស្សមានភាពឯករាជ្យ

---

[61] *ប្រភព: អ៊ឹម កុច ២០០៤ ការអប់រំក្នុងគ្រួសារ; J. Bailey Molineux. Self-esteem; Engene Anderson. George Redman, Charlotte, self-esteem for tots to teens 1991; Werner, 1984, Building strong famiyl--Kids and Self-esteem; Mathew Mckay, Patrick Faning, self-esteem, 2000.*

- ធ្វើបទដ្ឋានវាយតំលៃអោយបានច្បាស់ និងជួយសិស្សអោយចេះវាយតំលៃពីសមិទ្ធផលរបស់ខ្លួន

- បង្កើតគំរូវិធីសមរម្យស្តីពីការរិះគន់លើខ្លួនឯង ស្មារតីលះបង់

- បញ្ចៀសការប្រៀបធៀប និងការប្រកួតប្រជែងដែលមានលក្ខណៈបំផ្លេចបំផ្លាញ

- លើកទឹកចិត្តសិស្សអោយប្រកួតប្រជែងជាមួយកម្រិតសមិទ្ធផលអាទិភាពរបស់ខ្លួន

- ទទួលយកតំលៃសិស្ស និងធ្វើអោយសិស្សមានអារម្មណ៍ជឿជាក់លើលទ្ធផល ទោះបានជោគជ័យ និងមិនបានជោគជ័យក៏ដោយ

- ត្រូវចាំថា បញ្ញត្តិលើខ្លួនវិជ្ជមានកើតចេញពីភាពជោគជ័យក្នុងប្រតិបត្តិការក្នុងមជ្ឈដ្ឋាន និងចេញពីការវាយតំលៃដោយមនុស្សសំខាន់នៅក្នុងមជ្ឈដ្ឋាននោះ

- លើកទឹកចិត្តសិស្សអោយចេះទទួលខុសត្រូវចំពោះប្រតិកម្មរបស់ខ្លួនទៅនឹងព្រឹត្តិការណ៍នានា និងបង្ហាញដល់ពួកគេថា ខ្លួនគេមានជំរើសជាច្រើនក្នុងរបៀបឆ្លើយតប

- បង្កើតក្រុមសិក្សាមិត្តជិតស្និទ្ធនៅក្នុងសាលារៀន និងបង្រៀនសិស្សពីរបៀបលើកទឹកចិត្តគ្នាទៅវិញទៅមក

-ផ្តល់ឱកាសអោយសិស្សធ្វើការសម្រេចចិត្ត និងធ្វើការងារជាក្រុម និងផ្តល់អោយសិស្សបង្ហាញទស្សនៈរបស់គេតាមស្ថានភាពផ្សេងៗ

- ជួយសិស្សអោយចេះកំណត់គោលដៅ និងគោលបំណងអោយបានច្បាស់លាស់ និងបង្កើតគំនិតនានាបែបផុសគំនិតអំពីធនធានដែលពួកគេមាន ដើម្បីសំរេចគោលបំណងរបស់ពួកគេ និង

- បង្ហាញពីតំលៃក្រុមនីមួយៗអំពីវប្បធម៌ និងការសំរេចស្នាដៃរបស់ពួកគេ [៦២] ។

**២.២.៥.៣ - ការកសាងការអោយតំលៃខ្លួនឯងដោយខ្លួនឯង**

មនុស្សយើងគ្រប់រូបអាចហាត់ពត្ទ័ចិត្តខ្លួនបាន ដើម្បីអភិវឌ្ឍការអោយតំលៃខ្លួនឯងដោយខ្លួនឯង ពីព្រោះមនុស្សគ្រប់រូបមិនអាចនៅតែពឹងពាក់ឪពុកម្តាយ ឬអាណាព្យាបាលរហូតនោះទេ ។ គេត្រូវការទំនាក់ទំនងជាមួយអ្នកផ្សេងទៀតដោយឯករាជ្យ ។ ការបង្រៀនពីជំនាញ និងចំណេះដឹងដល់ពួកគេមានសារប្រយោជន៍ណាស់ និងជាភារកិច្ចជាមូលដ្ឋាន ។ ការបង្រៀនអោយគេមានអារម្មណ៍ថា ខ្លួនគេមានសមត្ថភាពជឿ

---

[62] *ប្រភព : J. Canfield(1990), Improving students's self-esteem, Educational Leadership ; M. M. Kash & G. Borich (1978), Teacher behavior and Student self-concept (Menlo Park, CA: Addison-wesley) ; H. H. Marshall (1989), The development of self-concept, Young Children and www.dsea.org/teachingtip/tips/selfesteem.htm+self-esteem+in+teaching&hl=en&ie=UTF-8.*

ជាក់លើខ្លួនឯង ចេះរបៀបថែរក្សាខ្លួន និងចេះដោះស្រាយបញ្ហាដែលប្រឈមមុខដោយខ្លួនឯងនូវស្វ័យភាពខាងគំនិត ។ គេត្រូវតែបង្រៀនមនុស្សអោយសំរេចបាននូវស្វ័យភាពនេះចាប់តាំងពីកុមារវ្រៀងរហូតមក ។ អារម្មណ៍នៃស្វ័យភាពមានសារសំខាន់ក្នុងការបណ្តុះការអោយតំលៃខ្លួនរបស់មនុស្ស ។ វិធីដែលជួយអភិវឌ្ឍការអោយតំលៃខ្លួនឯង បុគ្គលគ្រប់រូបត្រូវ :

- លើកតម្កើងការជឿជាក់ និងគិតពីតំលៃខ្លួនឯងផ្ទាល់
- លើកតម្កើងអារម្មណ៍នៃភាពជោគជ័យ
- លើកតម្កើងភាពជោគជ័យនៅសាលារៀន និងនៅក្នុងការងារផ្សេងទៀត
- លើកតម្កើងជំនាញសង្គម
- ទទួលស្គាល់ខ្លួនឯង និងតំលៃរបស់ខ្លួន
- កំណត់គោលបំណងអោយបានជាក់លាក់
- អធ្យាស្រ័យដល់ខ្លួនឯងផង និងអ្នកដទៃផង
- បញ្ចាក់ពីអារម្មណ៍ខ្លួនឯង ដោយមានភាពស្មោះត្រង់នឹងខ្លួន
- មានជំនឿលើខ្លួនឯង និងអ្នកដទៃ
- ចេះធ្វើការប្រថុយអោយបានសមស្របតាមស្ថានការណ៍
- បង្កើតនូវគំនិតប្រឌិតញាណ
- ស្វែងយល់ពីជំនឿស្មារតីខ្លួនឯង
- កាត់បន្ថយនូវគំនិតអវិជ្ជមាន និង
- ត្រូវពេញចិត្តនឹងរូបរាងខ្លួនឯង [៦៣] ។

### ២.២.៧.៤ - ការកសាងការអោយតំលៃខ្លួនឯងពីសំណាក់មជ្ឈដ្ឋាន

កត្តាមជ្ឈដ្ឋានជាជំនួយមួយក្នុងការអភិវឌ្ឍការអោយតំលៃខ្លួនឯងដោយប្រយោល ។ មនុស្សបានមើលឃើញរឿងរ៉ាវទាំងល្អ ទាំងអាក្រក់ជារៀងរាល់ថ្ងៃនៅក្នុងជីវិតរបស់គេ ។ ឥទ្ធិពលសង្គមជួយបញ្ជ្រាបដល់ផ្លូវចិត្តរបស់មនុស្ស និងជួយអោយគេមើលឃើញពីតំលៃរបស់គេចំពោះមជ្ឈដ្ឋានសង្គមនោះ ។ ដូច្នេះដើម្បីកសាងការអោយតំលៃខ្លួនឯងតាមរយៈមជ្ឈដ្ឋាន គេត្រូវ :

---

[63] ប្រភព : Matthew Mckay, Ph.D , Patrick Fanning, Self-Esteem p. 307-309 និង *California task force : Promote selfesteem, p.on line* www .askdrsears.com/html/6/T061500.asp

- បណ្តុះជំនាញសង្គម បង្កើតការងារ មុខរបរ អោយច្រើនសមរម្យ និងត្រឹមត្រូវ
- ផ្តល់គំរូយុត្តិធម៌ ក្នុងសង្គម និងលុបបំបាត់អំពើពុករលួយ
- បង្ហាញគំរូ និងលើកតម្កើងសេរីភាព និងប្រជាធិបតេយ្យនៅក្នុងសង្គម
- ផ្សព្វផ្សាយពីមោទនភាពជាតិ និងអរិយធម៌ស្នប់ស្ញែងរបស់សង្គមជាតិ និង
- លើកតំលៃជនគំរូដល់សាធារណជនទូទៅ ។

## ២.៣ - គក្តាលក្ខណៈពិសេសផ្ទាល់ខ្លួន និង ការអោយតំលៃខ្លួនឯង

### ២.៣.ក - ការអប់រំ និងការអោយតំលៃខ្លួនឯង

ការអប់រំដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងបុគ្គលិកលក្ខណៈរបស់មនុស្ស ។ មនុស្សដែលមានចំ-ណេះដឹង និងមានការអប់រំខ្ពស់ច្រើនជាមនុស្សមានមុខមានមាត់នៅក្នុងសង្គម ។ ការអប់រំជាការលើកតម្កើងតំលៃមនុស្ស ។ តើមនុស្សដែលមានការអប់រំជាមនុស្សមានការជឿជាក់ និងអោយតំលៃខ្លួនឯងដែរឬទេ ? តើមនុស្សដែលមានការអប់រំក្នុងកម្រិតប្រហែលគ្នាមានការអោយតំលៃខ្លួនឯងដូចគ្នាដែរឬទេ ? ហើយតើការអោយតំលៃខ្លួនឯងរបស់មនុស្សមានទំនាក់ទំនងជាមួយការអប់រំវិញដែរឬទេ ? នៅក្នុងការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវនឹងធ្វើការសិក្សាទៅលើនិស្សិតកម្រិតឧត្តមសិក្សា ដើម្បីរកអោយឃើញពីទំនាក់ទំនងគ្នានេះ ។ ខាងក្រោមនេះគឺជាទ្រឹស្តី និងការស្រាវជ្រាវរបស់អ្នកអ្នកស្រាវជ្រាវមុនៗដែលទាក់ទងទៅនឹងបញ្ហានេះ ។

លោក Heather M. Hoppe បានធ្វើការសិក្សាពីឥទ្ធិពលរវាងការឱ្យតំលៃលើខ្លួនឯងជាមួយការអប់រំដោយបានបញ្ជាក់ថា មនុស្សដែលមានការស្គាល់ខ្លួនឯងកម្រិតខ្ពស់ (high self-concept) តែងតែធ្វើការងារបានប្រសើរនៅក្នុងសាលារៀន ហើយទទួលការអប់រំបានកាន់តែច្រើនឡើង ។ នេះបញ្ជាក់ថា អ្នកដែលមានកម្រិតអប់រំខ្ពស់ មានកម្រិតស្គាល់ពីខ្លួនឯងខ្ពស់ ។ លោក Heather M. Hoppe បានបញ្ជាក់ថា មានការស្រាវជ្រាវជាច្រើនបានរកឃើញថា មនុស្សដែលមានការកម្រិតនៃការអប់រំខ្ពស់គឺមានការអោយតំលៃខ្លួនឯងក្នុងកម្រិតខ្ពស់ជាងមនុស្សដែលមានប្រវត្តិនៃកាអប់រំបានតិច ។ លោក Hoppe (1995) បានសន្និដ្ឋានថា ការអប់រំ និងការអោយតំលៃខ្លួនឯងមានសហទំនាក់ទំនងគ្នាយ៉ាងវិជ្ជមាន [៦៤] ។

ទោះជាយ៉ាងនេះក៏ដោយ មនុស្សដែលមានកម្រិតអប់រំខ្ពស់ប្រហាក់ប្រហែលគ្នាទំនងជាមិនមានការអោយតំលៃខ្លួនឯងក្នុងកម្រិតស្មើគ្នាទេ ព្រោះវាអាចអាស្រ័យនឹងមជ្ឈដ្ឋាន និងវប្បធម៌ដែលគេបានទទួលចាប់តាំងពីវ័យកុមារភាពរបស់គេ ។ ប្រសិនបើកុមាររស់នៅជាមួយការលើកទឹកចិត្ត គេនឹងរៀនពីការជឿជាក់

[64] Heather M. Hoppe, The Effect of Self-Esteem on Education, 1995, p. on line: http// www. mwsc. edu/psychology /rescarch/psy302/ fell 95 / hooppe.htm.

លើខ្លួនឯង [៦៥] ។ យោងតាមទ្រឹស្តីចិត្តវិភាគរបស់លោក Freud កត្តានេះមានន័យថាមនុស្សដែលមានឥរិយា-បថ អាកប្បកិរិយា និងការជឿជាក់លើខ្លួនឯងនាពេលបច្ចុប្បន្នពិតជាមានឫសគល់ពីអតីតភាពរបស់គេមកជាមួយផង ។ ដូចនេះ ការអប់រំមានតួនាទីសំខាន់ណាស់ក្នុងការបណ្តុះមនុស្សអោយមានការអោយតំលៃខ្លួន ឯង ។ លោក Thymothy Owen (1992) បានសិក្សាលើកត្តាដែលទាក់ទងការអប់រំ និងការឱ្យតំលៃខ្លួនឯងដោយផ្តោតទៅលើបរិបទរបស់សិស្សក្រោយមធ្យមសិក្សា [66] ។ រីឯលោក Tootoonchi (1993) ដែលធ្វើការស្រាវជ្រាវលើនិស្សិតនៅមហាវិទ្យាល័យបានរកឃើញថា អ្នកចូលរួមឆ្លើយក្នុងការស្រាវជ្រាវបានបញ្ជាក់ថាការរៀនមុខវិជ្ជានៅមហាវិទ្យាល័យជួយអោយគេបង្កើននូវការយល់ដឹងពីខ្លួនឯង ពីការជឿជាក់លើខ្លួនឯង និងការអោយតំលៃខ្លួនឯងកាន់តែខ្លាំងឡើង [67] ។ គំនិតរបស់អ្នកស្រាវជ្រាវទាំងនេះឆ្លុះបញ្ចាំងអោយឃើញពីកត្តានៃការឱ្យតំលៃខ្លួនឯងមានទំនាក់ទំនងវិជ្ជមានបែបណាមួយជាមួយការអប់រំសំរាប់និស្សិតខ្មែរ ហើយការស្រាវជ្រាវរបស់អ្នកស្រាវជ្រាវរបស់លោកខាងលិចនេះបានបង្ហាញនូវអ្វីដែលខ្ញុំបានធ្វើផែនការសំរាប់ការស្រាវជ្រាវនេះ ។ អ្នកស្រាវជ្រាវរំពឹងថា ការអោយតំលៃខ្លួនឯងរបស់និស្សិតកម្រិតឧត្តមនៅកម្ពុជាជាមួយការអប់រំនឹងអាចរកឃើញ ។

### ២.៣.២ - ភេទ និង ការអោយតំលៃខ្លួនឯង

តើមនុស្សប្រុស ឬមនុស្សស្រីមានការជឿជាក់ និងអោយតំលៃខ្លួនឯងខ្ពស់ជាង ? ការស្រាវជ្រាវជា-ច្រើនបានបង្ហាញពីភាពផ្សេងគ្នាស្តីពីភេទ និងការអោយតំលៃលើខ្លួនឯងនេះ ។ ការស្រាវជ្រាវពីទំនាក់ទំនងការអោយតំលៃខ្លួនឯងជាមួយកត្តាភេទនេះបានបង្ហាញលទ្ធផលប្រទាញប្រទង់គ្នា ដោយអ្នកស្រាវជ្រាវមួយចំនួនរកឃើញថា មនុស្សប្រុសមានការអោយតំលៃខ្លួនឯងខ្ពស់ជាងមនុស្សស្រី ខណៈពេលការស្រាវជ្រាវផ្សេងទៀតបង្ហាញថា មនុស្សស្រីមានការអោយតំលៃខ្លួនឯងខ្ពស់ជាងមនុស្សប្រុសនោះ រីឯខ្លះទៀតអះអាងថាមនុស្សប្រុស និងមនុស្សស្រីមានការអោយតម្លៃខ្លួនឯងដូចគ្នា ។

លោក Harter (1993) បានធ្វើការសិក្សាត្រួតពិនិត្យពីភាពផ្សេងគ្នារវាងស្ត្រី និងបុរសជាមួយការឱ្យតំលៃលើខ្លួនឯងនេះ ។ លោកបានបង្ហាញថា បុរសមានការឱ្យតំលៃខ្លួនឯងខ្ពស់ជាងស្ត្រី តែការខុសគ្នានេះមានកម្រិតតិចតួចបំផុត ។ ទាក់ទងនឹងបញ្ហានេះ លោកបានបញ្ជាក់ថា ការអោយតំលៃខ្លួនឯងជាកម្រិតនៃការគោរពដែលគេមានសំរាប់ខ្លួនគេក្នុងនាមជាមនុស្ស [៦៨] ។ លោក OBrien (1991) បានសិក្សាស្រាវជ្រាវក្នុង

---

[65] profile: The Relationship Between Gender and Self-Esteem with Body image.
[66] Ibid., p. on line
[67] Ibid., p.on line
[68] profile: The Relationship Between Gender and Self-esteem with Body Image,op.cit, p.on line.

ទិដ្ឋភាពទូលាយទៅលើភាពផ្សេងគ្នារវាងភេទ និងការអោយតំលៃខ្លួនឯងនេះដែរ ។ ការស្រាវជ្រាវនេះបានបង្ហាញពីសារសំខាន់អំពីភាពផ្សេងគ្នារវាងបុរស និងស្ត្រី ដោយបានរកឃើញថា បុរសមានការឱ្យតំលៃខ្លួនឯងខ្ពស់ជាងស្ត្រីលើផ្នែកសមត្ថភាព ខណៈពេលដែលស្ត្រីមានការអោយតំលៃខ្លួនឯងខ្ពស់ជាងបុរសលើភក្តីភាព ។ រីឯការសិក្សាស្រាវជ្រាវរបស់លោក Hensley (1977) បានធ្វើទៅនិស្សិតមហាវិទ្យាល័យដោយសិក្សាលើភាពផ្សេងគ្នារវាងនិស្សិតប្រុស និងនិស្សិតស្រីជាមួយការអោយតំលៃខ្លួនឯងដោយប្រើមាត្រដ្ឋានការអោយតំលៃខ្លួនឯងរបស់លោក Rosenberg ។ លទ្ធផលបង្ហាញថា និស្សិតស្រី និងនិស្សិតប្រុសនៅមហាវិទ្យាល័យមានការអោយតំលៃខ្លួនឯងមិនមានភាពខុសគ្នាទេ ។

អ្នកស្រាវជ្រាវផ្សេងទៀតបានបង្ហាញលទ្ធផលផ្សេងពីនេះទៅវិញដោយបញ្ជាក់ថា សិស្សស្រីមានការអោយតំលៃខ្លួនឯងទាបជាងសិស្សប្រុសនៅក្នុងវ័យជំទង់ ។ មនុស្សដែលមានភេទផ្សេងគ្នាមានការឱ្យតំលៃខ្លួនឯងមានកំរិតខុសគ្នា ។ លោក Brower (1991) បានអះអាងពីហេតុផលនេះថា រឿងដែលសិស្សស្រីមានការអោយតំលៃខ្លួនឯងទាបជាងសិស្សប្រុសគឺមកពីគេខ្វល់ខ្វាយពីភិនភាគ រូបសម្ផស្ស ការមិនពេញចិត្តទៅនឹងទម្ងន់របស់ខ្លួន និងសេចក្តីប៉ងប្រាថ្នាមុខវិជ្ជាជីវៈច្រើនជាងសិស្សប្រុស [៦៩] ។

សរុបមកការស្រាវជ្រាវស្តីពីកត្តាភេទជាមួយនឹងការអោយតំលៃខ្លួនឯងនេះមានភាពប្រទាញប្រទង់គ្នា តែបើនិយាយអំពីកត្តាសមត្ថភាព មនុស្សប្រុសមានការអោយតំលៃខ្លួនឯងខ្ពស់ជាងមនុស្សស្រីតែស្ថិតក្នុងកម្រិតតិចតួចប៉ុណ្ណោះ ។ ការស្រាវជ្រាវទាំងនេះធ្វើតែទៅលើសិស្ស និងនិស្សិតនៅក្នុងប្រទេសលោកខាងលិចដែលមានវប្បធម៌ ទំនៀមទំលាប់ និងរបៀបរស់នៅខុសពីប្រទេសកម្ពុជា ។ របកគំហើញនៃការស្រាវជ្រាវទាំងនេះនឹងឆ្លុះបញ្ចាំងពីបញ្ហាស្រាវជ្រាវលើស្នាដៃត្រង់ចំណុចទំនាក់ទំនងរវាងភេទ និងការឱ្យតំលៃខ្លួនឯងរបស់និស្សិតនៅវិទ្យាស្ថានជាតិអប់រំ ។

### ២.៣.គ - អាយុ និងការអោយតំលៃខ្លួនឯង

តើមនុស្សដែលមានអាយុច្រើនមានការជឿជាក់លើខ្លួនឯង និងអោយតំលៃខ្លួនឯងខ្ពស់ជាងមនុស្សដែលមានអាយុក្មេងជាងឬទេ ? តើមនុស្សមានការអោយតំលៃខ្លួនខ្លាំងជាងគេនៅក្នុងវ័យណា ? ទាក់ទងទៅនឹងការអោយតំលៃខ្លួនឯងជាមួយអាយុនេះ លោក Heather M. Hoppe បានធ្វើការស្រាវជ្រាវទៅលើនិស្សិតនៅមហាវិទ្យាល័យដោយបានបង្ហាញថា មនុស្សដែលមានអាយុច្រើនមានការអោយតំលៃខ្លួនឯងខ្ពស់ជាងមនុស្សដែលមានអាយុក្មេងជាង ដោយមិនរាប់បញ្ចូលកម្រិតនៃការអប់រំទេ [៧០] ។

---

[69] Rot Plotnik, Introduction to Psychology, California, Wardsword,inc, 1990, p.401-4002
[70] Heather M. Hoppe, The Effect of Self-Esteem on Education.,op.cit., p. on line.

## ២.៤ - ការអោយតំលៃខ្លួនឯង និង ការពេញចិត្តនឹងការសិក្សា

លោក Thomask. Crowl បានបញ្ជាក់ថា ការជឿជាក់លើខ្លួនឯងរបស់សិស្សមានឥទ្ធិពលដល់ចំ-ណង់សិក្សារបស់គេ ។ ប្រសិទ្ធភាពផ្ទាល់ខ្លួន (self-efficacy) និងក្តីសង្ឃឹមរបស់គ្រូជះឥទ្ធិពលដល់ទឹកចិត្តចង់សិក្សារបស់សិស្សនៅក្នុងបន្ទប់រៀន ។ លោក Crowl បានអះអាងថា ការអោយតំលៃខ្លួនឯងរបស់និស្សិតមានការកើនឡើង ឬថយចុះ ដោយសារការអោយតំលៃខ្លួនឯងពឹងផ្អែកលើលទ្ធផលសិក្សា ជាជាងការប្រឹងប្រែងដែលទាក់ទងនឹងសមត្ថភាពសិក្សា [៧១] ។ នេះមានន័យថា សិស្ស និស្សិតមានកំលាំងចិត្តក្នុងការសិក្សានោះគេនឹងទទួលបានលទ្ធផលសិក្សាល្អ ហើយលទ្ធផលសិក្សាល្អនេះនឹងជះឥទ្ធិពលបញ្ច្រាសមកលើការអោយតម្លៃខ្លួនឯងវិញ ។

លោក Crocker (2002) ដែលធ្វើការស្រាវជ្រាវទៅលើការអោយតំលៃខ្លួនឯងរបស់និស្សិតនៅមហាវិទ្យាល័យបានបង្ហាញថា ការប្រែប្រួលនៃការអោយតំលៃខ្លួនឯងអាចមានឥទ្ធិពល អាស្រ័យដោយការទទួលបានជោគជ័យឬបរាជ័យរបស់បុគ្គលចំពោះមុខវិជ្ជាដែលគេបានជំនឿជឿជាក់លើខ្លួនគេ ។ លទ្ធផលស្រាវជ្រាវរបស់គាត់បានបង្ហាញថា ក្នុងបរិបទនៃការសម្រេចបានខាងការសិក្សា សិស្សដែលមានការអោយតំលៃខ្លួនឯងដែលពឹងផ្អែកទៅលើសមត្ថភាពសិក្សារបស់គេ គឺមិនមានការអោយតំលៃខ្លួនឯងមានស្ថេរភាពជាងសិស្សដែលមិនមានការពឹងផ្អែកលើការអោយតំលៃខ្លួនគេលើការសិក្សា ។ សិស្សដែលមានការអោយតំលៃខ្លួនឯងពឹងផ្អែកសមត្ថភាពសិក្សាបានបង្ហាញពីការកើនឡើងនៅពេលដែលមានការទទួលយកពីអ្នកដទៃ ប៉ុន្តែត្រូវបានធ្លាក់ចុះវិញនៅពេលដែលមានការបដិសេធ [៧២] ។ លោក Alexander W. Astin, (1993) បានធ្វើការស្រាវជ្រាវទាក់ទងទៅនឹងការពេញចិត្តសិក្សារបស់និស្សិតនៅមហាវិទ្យាល័យ ។ លោកបានអះអាងថា ការវាស់វែងអំពីការចូលរួមរបស់និស្សិតនៅមហាវិទ្យាល័យ មានទំនាក់ទំនងយ៉ាងវិជ្ជមានជាមួយការពេញចិត្តទៅនឹងមហាវិទ្យាល័យ ហើយឥទ្ធិពលវិជ្ជមានលើការពេញចិត្តនឹងមហាវិទ្យាល័យមានទំនាក់ទំនងទៅនឹងការឱ្យតំលៃខ្លួនឯងខាងបញ្ញាញាណ (intelletual self-esteem) របស់និស្សិត [៧៣] ។

លោក Bigh (1971) និង លោក Sass (1989) បានលើកឡើងថា មានកត្តាជាច្រើនដែលជះឥទ្ធិ-ពលដល់ទឹកចិត្តចង់រៀន និងការខំប្រឹងធ្វើការសិក្សាកាន់តែខ្លាំងឡើង ។ កត្តាទាំងនេះរួមមានការជឿជាក់លើខ្លួនឯង ការអោយតំលៃខ្លួនឯង ការចាប់អារម្មណ៍នឹងមុខវិជ្ជា ការយល់ដឹងពីសារៈសំខាន់របស់មុខវិជ្ជា បំណង

---

71 Thomask Crowl, Sally Kaminsky, David M. Podell, Educational Psychology - Window on Teaching , USA, Brown and Benchmark, 1997.

72 Heather M. Hoppe, The Effect of Self-Esteem on Education.,op.cit., p. on line.

73 Alexander W. Astin, What Matter in College?- Four Critical Years, Califonia, Jossey- Bass. Inc, 1993.

ចង់សំរេចបានជាទូទៅ ការអត់ធ្មត់ និងការជំនះលើខ្លួនឯង [៧៤] ។ លោក Bruner បានបញ្ជាក់ថា ការរៀនប្រកបដោយអត្ថន័យ អាស្រ័យលើទឹកចិត្តចង់រៀន (ចលករខាងក្នុង intrinsic motivation) របស់សិស្សដែលមានចិត្តចង់ចេះចង់ដឹងដោយខ្លួនគេ ។ រីឯលោក Maslow (1968) បញ្ជាក់ថា ក្រុមអ្នកទ្រឹស្តីមនុស្សនិយមជឿថា ការអោយតំលៃខ្លួនឯងជាវិជ្ជមាន គឺមិនត្រឹមតែជាគោលដៅដ៏មានសារៈសំខាន់ និងមានផលប្រយោជន៍ប៉ុណ្ណោះទេ តែថែមទាំងជួយអោយសិស្សដែលមានការអោយតំលៃខ្លួនឯងនេះកាន់តែមានទឹកចិត្តចង់រៀនកាន់តែខ្លាំងឡើង ។ លោកបញ្ជាក់ថា សារៈសំខាន់នៃការអភិវឌ្ឍការអោយតំលៃខ្លួនមិនត្រឹមតែជាគោលដៅខ្លួនឯងទេ តែថែមទាំងជាសញ្ញាសំគាល់នៃគុណភាពរៀនទៀតផង [៧៥] ។

លោក Purkey និងលោក Nivak (1984) បានលើកឡើងថា គំនិតដ៏សំខាន់មួយក្នុងចំណោមគំនិតដ៏សំខាន់ផ្សេងៗទៀតដែលទាក់ទងទៅនឹងគោលវិធីមនុស្សនិយមគឺថា ការអប់រំត្រូវតែបង្កើនការអោយតំលៃខ្លួនឯងរបស់សិស្ស [៧៦] ។ លោក Myers និងលោក Diener (1995) បញ្ជាក់ថា ការអោយតំលៃខ្លួនឯងនេះមានទំនាក់ទំនងជាមួយនឹងការពេញចិត្តទៅនឹងជីវិតទូទៅទៀតផង ។ ការសិក្សាជាមុខរបររបស់សិស្សសំរាប់ជាទុនទាពេលអនាគត ។ ពេលសិស្សពេញចិត្តនឹងមុខរបររបស់គេ គេនឹងចូលរួមក្នុងការងារ ហើយពេលដែលគេជឿជាក់លើការសិក្សារបស់គេ នោះលទ្ធផលនឹងអាចសម្រេចបានក្រោមជំនឿជឿជាក់លើខ្លួននេះឯង ពិ-សេសជំនឿលើសមត្ថភាពរបស់ខ្លួន ។ លោក Lofguist និងលោក Dawis បានបញ្ជាក់ថា ការពេញចិត្តមុខរបរគឺមានទំនាក់ទំនងយ៉ាងវិជ្ជមានជាមួយសីលធម៌ដែលគេជឿថាជាការពេញចិត្តរបស់និយោជិកម្នាក់ៗ [៧៧] ។

## ២.៥ - បញ្ញត្តិនៃគុណភាពសិក្សា

បញ្ញត្តិគុណភាពត្រូវបានគេបកស្រាយផ្សេងៗពីគ្នាដោយសំអាងលើការយល់ដឹង និងកាលៈទេសៈរបស់មនុស្សម្នាក់ៗ ។ គុណភាពច្រើនតែពឹងផ្អែកទៅលើតំលៃដែលគេផ្តល់ជាអាទិភាព ។ គុណភាពនៅក្នុងការបណ្តុះបណ្តាលស្ថិតនៅលើគំនិត និងការវាយតំលៃរបស់សិស្ស និស្សិត គ្រូ អាណាព្យាបាលសិស្ស បុគ្គលិកសិក្សា និងថ្នាក់ដឹកនាំគ្រប់គ្រងរបស់សាលា ។ គុណភាពនៅមហាវិទ្យាល័យគឺជាការសម្រេចបានស្នាដៃ និងទទួលបានលទ្ធផលល្អផ្នែកសិក្សារបស់និស្សិតលើចំណេះដឹង បំណិន និងសីលធម៌ ។ នៅពេលនិស្សិតទទួលបានចំណេះដឹងខាងទ្រឹស្តី ហើយគេមានលទ្ធភាពយកចំណេះដឹងនោះទៅអនុវត្តនៅក្នុងសហគម ស្របតាមតម្រូវ

---

[74] Barbara Gross Davis, Tool for Teaching, Jossey Bass Inc, 1993.
[75] Thomas L. Good; Jere E. Brophy, Educational Psychology, A Realistic Approach, Holt, Rinerhart & Winston, 1977, p.355-357
[76] Ibid-
[77] Gayle Avery Ellen Baker, Psychology at Work , Australia, Prentice Hall pty Ltd, 1990.

ការណាមួយ ដោយមានការទទួលខុសត្រូវខ្ពស់ និងប្រកបដោយមនុស្សធម៌លើទង្វើរបស់គេ ពេលនោះគេអាចចាត់ទុកថា ការបណ្តុះបណ្តាលនៅសាលានោះមានគុណភាព ។

រីឯនៅក្នុងគុណភាពបណ្តុះបណ្តាលវិញ គេច្រើនមើលទៅលើស្តង់ដា (កម្រិតគុណភាព) ដែលត្រូវបានកំណត់ទុកថា តើគេអាចបំពេញបានស្តង់ដាហើយឬនៅ តើការអនុវត្តការងារបានល្អឬទេសំរាប់ការបំពេញស្តង់ដានោះ ។ មូលដ្ឋានស្នូលដំបូងរបស់គុណភាពបណ្តុះបណ្តាលគឺស្ថិតនៅលើឆន្ទៈ និងចិត្តចង់រៀនរបស់សិស្ស និងចិត្តចង់បង្រៀនរបស់គ្រូ ។ ទឹកចិត្តចង់រៀន និងបង្រៀនជាលំនាំដែលនាំឱ្យការបណ្តុះបណ្តាលឈានដល់គោលដៅ ។ គុណភាពបណ្តុះបណ្តាលមិនត្រូវគេមើលរំលងអំពីលទ្ធផលសិក្សារបស់សិស្ស និងនិស្សិតឡើយ ព្រោះលទ្ធផលដែលគេបានកំណត់ត្រូវបានគេត្រួតពិនិត្យយ៉ាងម៉ត់ចត់សំរាប់ជាព័ត៌មាន និងទិន្នន័យ ដើម្បីធានាថា មហាវិទ្យាល័យធានាបានទៅដល់ស្តង់ដាហើយឬនៅ ។ មនុស្សដែលសម្រេចបានលទ្ធផលដល់ទីបញ្ចប់ពិតជាកើតតែចំពោះមនុស្សដែលមានកំលាំងចិត្ត និងមនុស្សដែលអោយតំលៃលើខ្លួនឯងខ្ពស់ ។

វត្ថុអ្វីមួយដែលមានគុណភាពត្រូវបានគេមើលឃើញថាមានលក្ខណៈងាយស្រួលក្នុងការនិយាយ ប៉ុន្តែពិបាកក្នុងការធ្វើ ។ គុណភាពអប់រំជាគោលបំណងរបស់ឧត្តមសិក្សា ។ លោក Glasser (1990) បានលើកឡើងថា គោលបំណងសំខាន់របស់សាលារៀនត្រូវតែជាគុណភាពសិក្សាខ្ពស់ [៧៨] ។ គុណភាពត្រូវបានគេប្រើប្រាស់ ដើម្បីបញ្ជាក់អ្វីមួយដែលមើលទៅឃើញថាល្អ ប៉ុន្តែការនិយាយអ្វីមួយថាល្អ ល្អល្មម ល្អណាស់ ឬល្អតិចតួចនោះ ហាក់ដូចជាគ្មានមូលដ្ឋានកំណត់បាន ហើយគេពិបាកនិយាយថា ល្អដោយពឹងផ្អែកលើមូលដ្ឋានអ្វី និងតាមមធ្យោបាយបែបណាមួយឡើយ ។ វាជាការពិបាកណាស់ក្នុងការវាយតំលៃអ្វីមួយថាមានគុណភាពណាស់ ប្រសិនបើយើងមិនបានដឹង និងកំណត់ថាយើងកំពុងរកអ្វីមួយនោះទេ ។ លទ្ធផលសំរេចស្តង់ដាអាចជួយអោយគេដឹងពីគុណភាពសិក្សាបាន ។ លោក Robert Pirgig បានបញ្ជាក់ពីបញ្ញត្តិគុណភាពដោយនិយាយថា "ខ្ញុំមិនអាចកំណត់អោយច្បាស់លាស់អំពីវាបានទេ ប៉ុន្តែខ្ញុំស្គាល់វានៅពេលណាដែលខ្ញុំឃើញវា" [៧៩] ។ ការអះអាងបែបនេះត្រូវបានគេមើលឃើញ និងដូចការគិតរបស់មនុស្សទូទៅ ដែលភាគច្រើនមនុស្សមើលទៅឃើញថារបស់នោះ ឬវត្ថុនោះល្អ តែគេពិបាកពឹងផ្អែកលើមូលដ្ឋានអ្វីឡើយ ។ បើពឹងផ្អែកតែទៅលើកែវភ្នែកនោះគេមិនអាចចាត់ ទុកថារបស់នោះល្អគ្រប់គ្រាន់ឡើយ លុះត្រាតែគេធ្វើការពិចារណាដោយសំអាងទៅលើលក្ខណៈវិនិច្ឆ័យ ឬ បទដ្ឋានដែលយើងយកមកធ្វើជាខ្នាតសំរាប់វាស់គោលដៅ និងធ្វើជាមូលដ្ឋានក្នុងការវាយ

[78] Thomas L. Good ; Jere E. Brophy, Educational Psychology, A Realistic Approach, op.cit, p.356

[79] Maria Jose Lemaitre, The Role of Quality Assurance in Higher Education: A Global Perspective, Workshop on accreditation & Higher Education in Cambodia, the Ministry of Education, Youth and Sports by the World Bank, Cambodia 2002

តំលៃ ទើបគេអាចចាត់ទុកថារបស់នោះមានប្រសិទ្ធភាព និងមានគុណភាព ។ លោក ម៉ារីយ៉ា ចូសេឡេម៉ែត បានបញ្ជាក់ថា គុណភាពជាលក្ខណៈល្អប្រសើរ ការអោយផលពេញចិត្ត ជាការប្រែប្រួល (រីកចំរើនរបស់សិស្ស .....ទាំងអស់មានគុណសម្បត្តិរបស់វា និងវាកំណត់ទាំងអស់មានប្រ យោជន៍នៅពេលគេដំណើរការចំពោះផ្នែកពិសេសនៅឧត្តមសិក្សា ឬគ្រឹះស្ថានអប់រំ ហើយទាំងអស់មាន លក្ខណៈទន់ខ្សោយមិនគ្រប់គ្រាន់ នៅពេលដែលគេពង្រីកទៅផ្នែកផ្សេងទៀត)[៨០] ។

ទោះជាបញ្ញត្តិគុណភាពមានន័យច្រើនយ៉ាងណាក៏ដោយ តែពាក្យនេះត្រូវបានគេយកចិត្តទុកដាក់តាំងពីអតីតកាលមកម្លេះនៅក្នុងពិភពអប់រំ ហើយពាក្យនេះត្រូវបានគេយល់ក្នុងន័យពីរប្រភេទនៅក្នុងការអប់រំដោយផ្អែកលើនិយមន័យក្នុងលក្ខណៈបែបប្រពៃណី និងនិយមន័យបែបទំនើប ។ តាមទស្សនៈបែបប្រពៃណីគុណភាពត្រូវបានគេមើលឃើញថា ជាអ្វីមួយមានលក្ខណៈល្អឥតខ្ចោះ ល្អប្រសើរ មានលក្ខណៈពិសេស និងមានតំលៃថ្លៃ ពោលគឺការចំណាយថវិកាដ៏ច្រើនសន្ធឹកសន្ធាប់ទើបអាចសំរេចបាន រីឯតាមទស្សនៈទំនើបបញ្ញត្តិគុណភាពអប់រំគឺស្ថិតនៅលើភាពស័ក្តិសម រឺសំរេចដូចបំណង ការដែលអាចសំរេចបានដូចក្តីរំពឹងទុកមានលក្ខណៈសន្សំសំចៃ និងប្រសិទ្ធភាព មិនខ្ជះខ្ជាយពេលវេលា និងថវិកា ដែលនេះមានន័យថាគុណភាពសំដៅទៅរក ឬឈានទៅរកតំលៃត្រឹមត្រូវ និងមានប្រសិទ្ធភាព[៨១] ។

លោក Garvin (1988) បានពិចារណាលើគុណភាពបណ្តុះបណ្តាលទៅលើសមាសធាតុចំនួនបី ។ បើកាលណាគេសំរេចបាននូវសមាសធាតុទាំងបីនេះបាន នោះការអប់រំនឹងទទួលបានគុណភាព ។

- ការផលិត : សមត្ថភាពអនុវត្តទៅនឹងតម្រូវការ និងភាពស័ក្តិសមសំរាប់គោលបំណង
- ផលិតផល : សមិទ្ធផលសិក្សារបស់សិស្ស
- តំលៃ: តំលៃខាងការសន្សំសំចៃ ជាតំលៃស្តង់ដាររបស់សិស្ស តំលៃផ្នែកការសិក្សា និងចំណេះដឹង ។

តាមន័យចង្អៀត គុណភាពអប់រំស្មើទៅនឹងលទ្ធផលសិក្សារបស់សិស្ស ។ កត្តាផលិតកម្មអប់រំរបស់សាលាត្រូវបានគេត្រួតពិនិត្យឡើង ដើម្បីកំណត់បញ្ជាក់ពីឥទ្ធិពលលើសមិទ្ធផលសិក្សារបស់សិស្ស ។ នៅក្នុងការអប់រំ និងការបណ្តុះបណ្តាលជំនាញ ជាធម្មតា គុណភាពត្រូវបានគេយល់ក្នុងន័យទូលំទូលាយដោយរួមមានការអភិវឌ្ឍផ្នែករាងកាយ បំណិនសង្គម និងផ្លូវចិត្តដែលជាតម្រូវការសំរាប់ការផ្លាស់ប្តូរសមត្ថភាពប្រកបមុខរបរ ។ គុណភាពបណ្តុះបណ្តាលត្រូវបានគេវាស់តាមរយៈការជោគជ័យ និងសម្រេចបានពេលបំពេញការងារ

---

[80] Maria Jose Lemaitre, The Role of Quality Assurance in Higher Education: A Global Perspective, op.cit.

[81] អ៊ីម កុច : បញ្ញត្តិគុណភាពអប់រំ ក្នុងអត្ថបទមេរៀន ឆ្នាំ ២០០៣

ក្នុងកម្មវិធីអ្វីមួយ [៨២] ។ ទាក់ទងទៅនឹងបញ្ញត្តិគុណភាពនេះដែរ លោក Beeby (1966) ដែលគំនិតរបស់លោកបាញ់ឆ្ពោះមកលើកត្តាសេដ្ឋកិច្ចផ្អែកលើការអប់រំនោះបានបញ្ជាក់ថា គុណភាពអប់រំត្រូវបានគេវាស់វែងតាមរយៈសកម្មភាពផលិត [៨៣] ។ នេះមានន័យថា និស្សិតអាចចាត់ទុកថាមានគុណភាពបាន លុះណាតែពួកគេមានសមត្ថភាពផលិតធនធានទាំងស្មារតី និង សម្ភារៈ ។

បញ្ញត្តិទាំនេះជាប្រទីបសំរាប់ឆ្លុះបញ្ចាំងក្នុងការស្រាវជ្រាវនេះ សំរាប់វាស់គុណភាពសិក្សារបស់និស្សិត ដែលគេយល់ថាការសម្រេចបានសមត្ថភាពរបស់គេនៅមហាវិទ្យាល័យ ។ គំនិតរបស់អ្នកស្រាវជ្រាវនៅទីនេះ ដើម្បីស្វែងរកកត្តាដែលនាំអោយការសិក្សាមានគុណភាព គឺផ្អែកទៅលើកំរិយាបថសមត្ថភាពរបស់និស្សិត ។ គុណភាពសិក្សានៅក្នុងគំនិតស្រាវជ្រាវនេះសំដៅទៅលើន័យចង្អៀតជាក់លាក់ ពោលគឺសំដៅទៅលើលទ្ធផលសិក្សា ឬ សមិទ្ធផលសិក្សារបស់សិស្ស និស្សិត (ពិន្ទុដែលនិស្សិតទទួលបាន និងអារម្មណ៍ ដែលគេថាពិជាទទួលបាននៅក្នុងរយៈពេលសិក្សារបស់គេ) សំរាប់សមត្ថភាពក្នុងការសិក្សា មុខវិជ្ជារបស់គេ ។

## ២.៦ - ការពេញចិត្តនឹងការសិក្សា និង សមិទ្ធផលសិក្សា

ការពេញចិត្តនឹងការសិក្សាជាមុខរបររបស់សិស្ស និងនិស្សិត ។ នៅទីនេះ ការពេញចិត្តមុខរបរគឺជាការពេញចិត្តនឹងការសិក្សារបស់សិស្ស និងនិស្សិត ។ លោក Gayle Avery បញ្ជាក់ថា ការពេញចិត្តមុខរបរសំដៅទៅលើអារម្មណ៍វិជ្ជមាន ឬអវិជ្ជមានរបស់បុគ្គលអំពីមុខរបររបស់គេ ។ យោងតាមលោក John Holland បញ្ជាក់ថា សមត្ថភាពអនុវត្តន៍ និងការពេញចិត្តមុខរបរដែលមានអំណោយផលកើនឡើង នៅពេលបំណិនសមត្ថភាព និងអារម្មណ៍ពេញចិត្តរបស់បុគ្គលស៊ីគ្នា ។ រីឯលោក Smart (1986) បានបញ្ជាក់ថា ការពេញចិត្តមុខរបរ មានទំនាក់ទំនងយ៉ាងវិជ្ជមានទៅនឹងភាពស្របគ្នារវាងប្រភេទបុគ្គលិកលក្ខណៈរបស់បុគ្គល និងបរិយាកាសការងាររបស់គេ ។ បរិយាកាសរបស់សិស្ស និងនិស្សិតគឺសាលារៀន បន្ទប់រៀន បណ្ណាល័យ និងបន្ទប់ពិសោធន៍ រីឯបុគ្គលិកលក្ខណៈរបស់បុគ្គល គឺទឹកចិត្ត និង អារម្មណ៍ចង់រៀន [៨៤] ។

លោក J. Bailey Molineux (2003) បានបញ្ជាក់ថា ជាទូទៅមនុស្សដែលមានភាពពូកែមានទំនាក់ទំនងបានល្អទៅនឹងកន្លែងការងារ ពួកគេកាន់តែមានការពេញចិត្តមុខរបររបស់ខ្លួនកាន់តែខ្លាំងឡើង [៨៥] ។ លោក Adlerman (1985) លោក Mc Clelland (1985) និងលោក Morris (1991) បានអះអាងថា

[82] Torsten Husen , T. Neville Postlethwaite , The International Encyclopedia of Education, Great Britian, Pergamon, 1994, p. 4858
[83] Elchanan Cohn; Terry G. Geske, The Economics of Education, USA, Pergamon Press, 1990, p.2
[84] Gayle Avery Ellen Baker, Psychology at Work , Australia, Prentice Hall pty Ltd, 1990.
[85] profile : http: www.solve your problem.com/artman/publish/article-195.shtml.

សិស្សដែលអនុវត្តសមត្ថភាពបានល្អក្នុងការប្រកួតប្រជែង និងមានការជឿជាក់កាន់តែខ្លាំងឡើង នាំអោយពួកគេមានចិត្តចង់រៀន ដើម្បីអាចសំរេចគោលដៅរបស់គេ [៨៦] ។

## ២.៧ - ការអោយតំលៃខ្លួនឯង និង សមិទ្ធផលសិក្សា

យោងតាមទ្រឹស្តីអត្តសញ្ញាណសង្គមអោយដឹងថា មនុស្សតែងតែមានចលករ ដើម្បីវាយតំលៃផ្ទាល់ខ្លួនរបស់គេដោយការវាយតំលៃនេះជំរុញឱ្យមានការអោយតំលៃខ្លួនរបស់គេ [៨៧] ។ និស្សិតដែលមានការជឿ-ជាក់លើខ្លួនឯងខ្ពស់ និងមានជំនឿទុកចិត្តលើសមត្ថភាពរបស់ខ្លួន នឹងក្លាយជាអ្នកសិក្សាបានជោគជ័យក្នុងការរៀនសូត្ររបស់គេ ។ លោក M.Alves-Martins លោក F. Peixoto លោក M.Goveia-Pereira លោក V. Amaral និងលោក I. Pedro បានរកឃើញថា សិស្ស និស្សិតដែលមានសមិទ្ធផលសិក្សាកំរិតខ្ពស់ធ្វើការវាយតំលៃលើខ្លួនឯងកាន់តែវិជ្ជមានលើមុខវិជ្ជាសិក្សារបស់គេជាងសិស្ស និស្សិតដែលមានការសំរេចបានស្នាដៃសិក្សាកម្រិតទាប [៨៨] ។ លោក Korman (1974) បានបញ្ជាក់ថា មនុស្សដែលមានរូបភាពចិត្ត (Self-image) និងសមត្ថភាពស្គាល់ពីខ្លួនឯងខ្ពស់ អាចសម្រេចបានការអនុវត្តស្នាដៃការងារបានប្រសើរជាងមនុស្សដែលមានសមត្ថភាពស្គាល់ពីខ្លួនឯងកម្រិតទាប មានក្តីរំពឹងពីការជោគជ័យកម្រិតទាប និងរូបភាពចិត្ត (Self-image) កម្រិតទាបអំពីការងារ ប៉ុន្តែការសម្រេចបានស្នាដៃផ្សេងពីគ្នាអាចមានការទទួលស្គាល់ពីខ្លួនរបស់គេ ។ នេះសន្និដ្ឋានថា ការអនុវត្តការងារត្រូវបានគេមើលឃើញថាមានតំលៃ [៨៩] ។

លោក ជេម (James) បានអះអាងថា មនុស្សអាចឈានដល់គោលដៅរបស់អ្នកកាន់តែប្រសើរ មនុស្សនោះមុខជាមានការអោយតំលៃកាន់តែប្រសើរសំរាប់ខ្លួនគេ . ហើយគេទំនងជាទទួលបានការឱ្យតំលៃកាន់តែខ្លាំងពីអ្នកដទៃទៀត [៩០] ។ លោកម៉ាស្លូអះអាងថា ប្រសិនបើអ្នកមិនមានការជឿជាក់លើខ្លួនឯង អ្នកនឹងមិនហ៊ានបង្ហាញពីខ្លួនឯងតាមមធ្យោបាយរបស់អ្នក ដោយធ្វើឱ្យការផ្តល់វិភាគទានពិសេសរបស់ខ្លួនអ្នកទៅក្នុងសង្គមបានទេ ដូច្នេះ អ្នកមិនអាចសំរេចបានអនុភាពពិសេសដែលមានពីកំណើតរបស់ខ្លួនបានឡើយ [៩១] ។

ទាក់ទងនឹងការអោយតំលៃខ្លួនឯងនិងសមិទ្ធផលសិក្សានេះដែរ លោក Walter បញ្ជាក់ថា ការឱ្យតំលៃខ្លួនឯងអាចត្រូវបានគេកំណត់ថាជាអារម្មណ៍ ដែលអាចមានសមត្ថភាពលៃលកដោះស្រាយភារកិច្ចប្រ-

---

[86] Woolfolk, Educational Psychology, Allyn and Bacon, 1995

[87] Richard A. Lippa, Introduction to Social Psychology, Wardsworth Publishing Company Inc, 1990.

[88] M.Alves-Martins etc. Selfesteem and Academic Achievement among adolescents , p.113

[89] John B. Miner, Industrial Organizational Psychology, New York. Mc. Graw-Hill Inc,1992 , p.152

[90] James V. Mc Connell, Understand Human Behavior, CBS College publishing, 1986.

[91] Richard A. Lippa, Introduction to Social Psychology, op.cit.

ឈមចំបងក្នុងជីវិត ហើយស័ក្តិសមនឹងទទួលបានសុភមង្គល ។ រីឯលោក Atkinson បានលើកឡើងថា ចលករសម្រេចសមិទ្ធផលសំរាប់បុគ្គលណាម្នាក់គឺជាកំលាំងបាញ់ឆ្ពោះទៅរកភារកិច្ច និងកំលាំងដែលឈានទៅការជៀសវាងភារកិច្ច ។ មនុស្សដែលមានចលករសម្រេចសមិទ្ធផលមានលទ្ធផលខ្ពស់ នៅពេលចលករនៃភាពជោគជ័យធំជាងចលករចង់ជៀសវាងការបរាជ័យ [៩២] ។ នៅក្នុងការទទួលបានជោគជ័យ ការអោយតំលៃខ្លួនដើរតួនាទីសំខាន់ណាស់ ក្នុងការសម្រេចលទ្ធផលសិក្សាដែលរាប់បញ្ចូលសមត្ថភាព តំលៃសីលធម និងសមត្ថភាពទំនាក់ទំនង ។ ការអោយតំលៃខ្លួនឯងអាចអោយសិស្សសម្រេចបានជោគជ័យខាងសមត្ថភាពការងារ ខាងរាងកាយ និងពុទ្ធិ ។ មនុស្សមានការអោយតំលៃខ្លួនខ្ពស់អាចមានឥទ្ធិពលដល់អ្នកដទៃទៀត ព្រោះគេអាចបញ្ចុះបញ្ចូលអ្នកដទៃអោយធ្វើតាមខ្លួនបាន ។ សិស្សល្អ និងសិស្សដែលធ្វើរឿងត្រឹមត្រូវមានសីលធមខ្ពស់ ជាចំណែកបានមកពីការអោយតំលៃខ្លួនឯងរបសសិស្សនោះ ។ សិស្សដែលមានសមត្ថភាពទំនាក់ទំនងអាចជំរុញអោយគេមានការគោរព ស្រលាញ់រាប់អានពីអ្នកដទៃ [៧២] ។

ភាពជោគជ័យខាងផ្នែកសិក្សាជាចំនែកបានមកពីភាពជោគជ័យខាងផ្នែកអោយតំលៃខ្លួនឯង ។ ការសម្រេចបានជោគជ័យខាងសមត្ថភាពជាប់ទាក់ទងទៅនឹងបញ្ញាញាណក្នុងសមាភាពផ្សេងៗ ដូចជា សមត្ថភាពខាងការសិក្សា សមត្ថភាពខាងសរសេរ និងសមត្ថភាពខាងគណិតវិទ្យាដែលគេចាត់ទុកថាជា សមត្ថភាពខាងពុទ្ធិ ។ សមត្ថភាពខាងការនិយាយនៅទីសាធារណៈ សមត្ថភាពក្នុងការដឹកនាំដែគេចាត់ទុកថា ជាសមត្ថភាពខាងការទំនាក់ទំនង ។ កំលាំងជំរុញដែលនាំអោយទៅសំរេចបានអ្វីមួយ និងការជឿជាក់លើខ្លួនឯងចំពោះបញ្ញាញាណជាកំលាំងចលករ ។ ការសម្រេចបានគុណភាពក្នុងការបណ្តុះបណ្តាលរបស់មហាវិទ្យាល័យជាសមិទ្ធផលដំបូងដែលលេចចេញពីការអោយតំលៃខ្លួនឯង ។ លោក Somers និងលោក Lefkowitz (1983) បានអះអាងថា សមត្ថភាពអនុវត្តការងារមានទំនាក់ទំនជានិច្ចជាមួយកម្រិតនៃការអោយតំលៃខ្លួនឯង ។ លោក John B. Miner (1992) បានលើកឡើងថា មនុស្សដែលមានការអោយតំលៃខ្លួនឯងទាបធ្វើការអនុវត្តការងារមិនបានល្អជាងមនុស្សដែលមានការឱ្យតំលៃខ្លួនឯងកម្រិតខ្ពស់ [៩៣] ។ លោក Bandura បញ្ជាក់ថា ការលើកតំលៃពិសិដ្ឋរបស់ខ្លួនកាន់តែខ្ពស់ សមត្ថភាពអនុវត្តលើការងារកាន់តែខ្ពស់ដែរ [៩៤] ។ លោកបានបញ្ជាក់បន្ថែមថា ការយល់ដឹងពីសមត្ថភាពរបស់មនុស្សដែលទាក់ទងនឹងមជ្ឈដ្ឋានរបស់គេ ។ អាកប្បកិរិយា

[92] Thomas L. Good ; Jere E. Brophy, Educational Psychology , A Realistic Approach, op.cit,p.356
[93] John B. Miner, Industrial Organizational Psychology , op.cit., p.152
[94] Audrey Harber ; Richard P. Runyon, Fundamentals of Psychology, New York, Random House, 1986.

គ្រប់ប្រភេទទាំងអស់ : ការសិក្សា ការទំនាក់ទំនង និងការប្រឌិតញាណ គឺមានឥទ្ធិពល ដោយសារការអោយតំលៃពិសិដ្ឋពីខ្លួនឯង [៩៥] ។

សរុបមកការស្រាវជ្រាវផ្នែកទ្រឹស្តីអាចកំណត់បានថា ការអោយតំលៃខ្លួនឯងជាការគិតគូខាងតំលៃ ឬលើកតំលៃខ្លួនរបស់បុគ្គលម្នាក់ៗអំពីខ្លួនរបស់គេក្នុងឋានៈជាមនុស្សមួយពេញលេញ( មនុស្សឱ្យតំលៃដោយខ្លួនឯង និងទទួលបានការឱ្យតំលៃពីអ្នកដទៃ ) ។ ការអោយតំលៃខ្លួនឯងរបស់យើងម្នាក់ៗកំណត់នូវអារម្មណ៍ដែលយើងគិតថាខ្លួនឯងមានតំលៃ មានការស្រលាញ់ខ្លួនឯង និងមានអារម្មណ៍ថាខ្លួនយើងមានប្រយោជន៍ ឬខ្លួនយើងជាមនុស្សបានការ និងមានអារម្មណ៍ថា ខ្លួនយើងមានសមត្ថភាពគ្រប់គ្រាន់ ។ ការរីកលូតលាស់នៃការអោយតំលៃខ្លួនឯង ចាប់ផ្តើមរីកលូតលាស់តាំងពីដើមវ័យកុមារ និងនៅតែបន្តជារៀងរហូតដល់មនុស្សពេញវ័យ នៅខណៈពេលកត្តាមជ្ឈដ្ឋានខាងក្រៅត្រូវបានគេផ្តល់អោយនូវភាពវិជ្ជមានដល់បុគ្គលនោះ ។ ជាទូទៅ ការអោយតំលៃខ្លួនមានការីកចំរើនឡើង ដោយសារឥទ្ធិពលរបស់របស់ឪពុកម្តាយ ( Warash និងលោក Makstrom – 2001 ) កត្តាមជ្ឈដ្ឋាន (Coopersmith -1981) កត្តាអប់រំ (Heather M. Hoppe -1995 ) និងកត្តាតំណពូជ (Patricia Kramer-1991) ។ ការអោយតំលៃខ្លួនឯងត្រូវបានគេធ្វើការវាស់វែងបានតាមរយៈការធ្វើតែស (Coppersmith & Rosenberge) ដោយត្រូវបានចាត់ចូលជាពីរកម្រិតសំរាប់មនុស្សគ្រប់រូប (Abraham Maslow) ។ មនុស្សខ្លះអោយតំលៃលើខ្លួនឯងខាងផ្នែកសមត្ថភាពអនុវត្តការងារ អ្នកខ្លះអោយតំលៃលើភាពទាក់ទាញរបស់ខ្លួន និងអ្នកខ្លះទៀតអោយតំលៃខ្លួនឯងលើគុណធម និងសីលធមរបស់ខ្លួនគេ ។ សមត្ថភាពទំនាក់ទំនងសង្គម សមត្ថភាពខាងបញ្ញាញាណ កោសល្យ លក្ខណៈរូបរាងកាយ ជំនាញសង្គមជាវិភាគទានផ្តល់នូវការបណ្តុះអារម្មណ៍នៃអោយតំលៃខ្លួនឯង ។ ដូច្នេះ គេអាចអភិវឌ្ឍការឱ្យតំលៃខ្លួនឯងវិជ្ជមានបាន តាមរយៈការបង្រៀនជំនាញសង្គម បំណិនជីវិត និងការផ្តល់បទពិសោធន៍ចំពោះវិភាគទានខាងលើ ដើម្បីអោយគេមានបញ្ញត្តិខ្លួនអោយបានច្រើន រីឯក្នុងគ្រួសារ ឪពុកម្តាយត្រូវតែថ្នាក់ថ្នមស្រលាញ់កូនដោយគ្មានលក្ខខណ្ឌ យកចិត្តទុកដាក់ ផ្តល់ភាពកក់ក្តៅ ផ្តល់ការលើកទឹកចិត្តត្រូវធ្វើអោយមានភាពយុត្តិធម៌សំរាប់ពួកគេ ព្រមទាំងជាអ្នកផ្តល់គំរូ និងយុទ្ធសាស្ត្រដោះស្រាយវិបត្តិ និងបញ្ហា ។ វិធីនេះអាចជួយអោយកុមារមានការអភិវឌ្ឍការអោយតំលៃលើខ្លួនឯង ។ នៅក្នុងសាលារៀន គ្រូត្រូវយកចិត្តទុកដាក់ផ្តល់ការសរសើរ ផ្តល់ភាពយុត្តិធម៌ដល់សិស្សគ្រប់រូប ក្នុងថ្នាក់រៀន បណ្តុះគំនិតចេះសហការគ្នាជាក្រុមតូច ក្រុមធំ បង្ហាញការសាកល្បងសំដែងសមត្ថភាព ទទួលស្គាល់គំនិតថ្មីរបស់សិស្សក្នុងគោលបំណងអោយសិស្សមានឯករាជ្យភាពខាងផ្លូវគំនិត ។ កម្មវិធីសិក្សាសាលារៀនត្រូវបង្កប់ខ្លឹមសារ និងអត្ថន័យវិជ្ជមាន ភាពស្ញប់ស្ញែង ។

[95] Patricia H. Miller, Theories of Developmeutal Psychology, W.H. Freeman & Lompany, 1993, p.205

សម្ភារៈសិក្សាត្រូវមានភាពសំបូរបែប និងប្រព្រឹត្តឡើងអោយសមស្របតាមអាយុចិន្តា (Mental Age) របស់សិស្សអោយបានសមរម្យ និងត្រឹមត្រូវ ។ ជាមួយគ្នានេះដែរ គុណភាពសិក្សាត្រូវបានគេមើលឃើញថា ជាការសម្រេចបានសមិទ្ធិផល(លទ្ធផលសិក្សា) ក្រោមបទដ្ឋានដែលគេបានគ្រោងទុក ប៉ុន្តែជាទូទៅ បញ្ញត្តិនេះត្រូវបានគេមើលឃើញនូវអ្វីដែលល្អប្រសើរ ល្អឥតខ្ចោះ និងភាពស័ក្តិសមដូចការរំពឹងទុកនិងប្រសិទ្ធភាព ។ មូលដ្ឋាននៃគុណភាពបណ្តុះបណ្តាលកើតចេញពីការចង់សិក្សារបស់សិស្ស និងការបង្រៀនរបស់គ្រូ ។ ដើម្បីមើលឃើញគុណភាព គេត្រូវតែរៀបចំនូវមូលដ្ឋានស្នូល ដូចជាការកំណត់គោលបំណង បទដ្ឋាន និងគោលការណ៍ ឬសុចនាករ ដែលជាឧបករណ៍សំរាប់វាស់កម្រិតគុណភាព និងវាយតំលៃអំពីការបណ្តុះបណ្តាលរបស់សាលា ។ ការស្រាវជ្រាវនេះនឹងត្រួតពិនិត្យមើលពីការអោយតំលៃខ្លួនឯង និងគុណភាពសិក្សារបស់គរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំ ដោយមានវិធីស្រាវជ្រាវច្បាស់លាស់ ។

# ជំពូកទី៣

# វិធីស្រាវជ្រាវ

ដើម្បីសំរេចគោលបំណងដែលបានកំណត់ខាងលើ អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីរៀបចំកម្រងសំណួរ ដោយបង្ហាញពីវិធីជ្រើសរើសមុខសញ្ញាដែលត្រូវចូលរួម វិធីវាស់វែងនៃការស្រាវជ្រាវ និងលំនាំស្រាវជ្រាវ ព្រមទាំងវិធីសម្ភាន៍ជាមួយមនុស្សដែលពាក់ព័ន្ធផ្សេងទៀត ។

## ៣.១ - មុខសញ្ញាដែលត្រូវចូលរួម

| ភេទ | អ្នកចូលរួម | មុខជំនាញ | | | |
|---|---|---|---|---|---|
| | | គណិតវិទ្យា | រូបវិទ្យា | គីមីវិទ្យា | ជីវវិទ្យា |
| ប្រុស | ៥៤ | ១៨ | ១៩ | ១៣ | ៤ |
| ស្រី | ២៣ | ៧ | ៤ | ៦ | ៦ |
| សរុប | ៧៧ | ២៥ | ២៣ | ១៩ | ១០ |

*តារាងទី១ : មុខសញ្ញាក្នុងការស្រាវជ្រាវ*

មនុស្សដែលចូលរួមក្នុងមុខសញ្ញាស្រាវជ្រាវនេះគឺជាគរុនិស្សិតដែលបានសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រនិង គណិតវិទ្យាជំនាន់ទី ៨ ឆ្នាំសិក្សា ២០០៣ នៅវិទ្យាស្ថានជាតិអប់រំ ( សាលាបណ្តុះបណ្តាលនិស្សិតក្រិតឧត្តមឱ្យក្លាយទៅជាគ្រូបង្រៀន) ។ និស្សិតដែលត្រូវសម្ភាសន៍សំរាប់ទិន្នន័យស្រាវជ្រាវមានចំនួនទាំងអស់ ៧៧នាក់ក្នុង នោះប្រុស ៥៤ នាក់ ស្រី ២៣ នាក់ ដោយរួមមានគរុនិស្សិតគណិតវិទ្យាចំនួន ២៥ នាក់ ( ប្រុស ១៨ ស្រី ៧) រូបវិទ្យាចំនួន ២៣ នាក់ ( ប្រុស ១៩ ស្រី ៤) គីមីវិទ្យាចំនួន ១៩ នាក់ ( ប្រុស ១៣ ស្រី ៦) និងជីវវិទ្យាចំនួន ១០ នាក់ ( ប្រុស៤ ស្រី៦) ។ គរុនិស្សិតចូលរួមទាំងនោះមានអាយុក្នុងចន្លោះពី ២០ឆ្នាំ ដល់ ២៧ឆ្នាំដែលមាន ពិន្ទុមធ្យមនៃអាយុ $\overline{X}$ = ២៣ ។ អ្នកចូលរួមទាំងអស់ត្រូវបានផ្តល់កម្រងសំណួរអំពីការជឿជាក់លើខ្លួនឯង មានចំនួន ៣០សំណួរស្ថិតក្នុងផ្នែកទីមួយ និងសំណួរដែលទាក់ទងសមត្ថភាពវិទ្យាសាស្ត្រស្ថិតក្នុងផ្នែកទី២ដែល រួមមានការពេញចិត្តនឹងការសិក្សា ការទទួលបានសមិទ្ធផលសិក្សា និងកត្តាលក្ខណៈពិសេសផ្ទាល់ខ្លួនរបស់គរុ-និស្សិត ។ អ្នកចូលរួមម្នាក់ៗអាចឆ្លើយកម្រងសំណួរទាំងអស់ក្នុងរយៈពេលប្រមាណពី២០ទៅ២៥នាទីក្នុងការ បំពេញកម្រងសំណួរចប់សព្វគ្រប់ ដោយមានការអនុញ្ញាតពីថ្នាក់ដឹកនាំ និងមានជំនួយពីសាស្ត្រាចារ្យរបស់ វិទ្យាស្ថាន ។ អ្នកឆ្លើយកម្រងសំណួរទាំងអស់មានស្រុកកំណើតមកពីបណ្តាខេត្តក្រុងចំនួន១៥ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ គរុនិស្សិតចំនួន ៥៤ នាក់ មានឪពុកម្តាយរស់នៅតាមខេត្តចំនួន ១៥ និងនិស្សិត ២២នាក់

ផ្សេងទៀតមានទីកន្លែងរស់នៅសព្វថ្ងៃនៅទីក្រុងភ្នំពេញ ។ បើគិតដោយឡែក និស្សិតដែលមានអាណាព្យាបាលរស់នៅក្នុងទីក្រុងភ្នំពេញមានចំនួនច្រើនជាងនិស្សិតមកពីខេត្តនីមួយៗ ។ គរុនិស្សិតដែលបានចូលរួមក្នុងការស្រាវជ្រាវនេះត្រូវបានវិទ្យាស្ថានជាតិអប់រំតម្រូវអោយរៀនរយៈពេល ៦ថ្ងៃក្នុងមួយសប្តាហ៍ ។ គរុនិស្សិតទាំងនោះត្រូវបានគេតម្រូវឱ្យសិក្សាមុខវិជ្ជាជំនាញទីមួយនិងទី២** ដែលរួមមានមុខវិជ្ជាឯកទេស មុខវិជ្ជាគរុកោសល្យ ចិត្តវិទ្យា រដ្ឋបាលសិក្សា សីលធម៌វិជ្ជាជីវៈ និងមុខវិជ្ជាទាក់ទងនឹងចំណេះដឹងទូទៅផ្សេងទៀត ។ លើសពីនេះទៅទៀត ពួកគេបានចំណាយពេលសិក្សាក្នុងបន្ទប់ពិសោធន៍ និងចុះធ្វើកម្មសិក្សាគរុកោសល្យបន្ទាប់ពីរៀនទ្រឹស្តីមួយរយៈក្នុងថ្នាក់រៀន និងផលិតសម្ភារៈឧបទេសវិទ្យាសាស្ត្រ ជំនាញធ្វើកិច្ចតែងការបង្រៀន និងជំនាញស្រាវជ្រាវវិទ្យាសាស្ត្រជាដើម ។ គរុនិស្សិតត្រូវបានអោយរៀនតាមរយៈបង្រៀនក្នុងថ្នាក់ដោយស្រង់អវត្តមានរៀងរាល់ម៉ោងសិក្សាក្នុងមុខវិជ្ជានីមួយៗ ។

បន្ថែមលើការបំពេញកម្រងសំណួរការស្រាវជ្រាវនេះក៏បាន ធ្វើការសំភាសន៍ដោយផ្ទាល់ជាមួយគរុនិស្សិតចំនួន ១១នាក់ផ្សេងទៀត ។ គរុនិស្សិតដែលត្រូវបានធ្វើសម្ភាន៍ នោះមកពីមុខវិជ្ជាគណិតវិទ្យាចំនួន ៣នាក់ រូបវិទ្យា ២នាក់ ជីវវិទ្យា ២នាក់ គីមីវិទ្យា ២នាក់ និងផែនដីវិទ្យា ចំនួន ២នាក់ ។ គរុនិស្សិតដែលត្រូវធ្វើការសម្ភាន៍នោះជានិស្សិតធ្នើមក្នុងការបង្ហាញស្នាដៃសម្ភារៈឧបទេសវិទ្យាសាស្ត្រ ដោយមានការអនុញ្ញាតពីថ្នាក់ដឹកនាំរបស់វិទ្យាស្ថាន និងការអនុញ្ញាតពីសាស្ត្រាចារ្យបង្រៀនឯកទេសនីមួយៗ ។ ការសម្ភាន៍នេះមានគោលបំណងស្វែងរកប្រភពដែលនាំអោយជះឥទ្ធិពលដល់ការឱ្យតំលៃខ្លួនឯង និងដល់កំលាំងចិត្តក្នុងការសិក្សាលើមុខវិជ្ជាសិក្សារបស់ពួកគេ ។

គំរូតាងនៃការស្រាវជ្រាវនេះមានលក្ខណៈអាចជឿជាក់ និងយកជាការបានសំរាប់តំណាងឱ្យនិស្សិតលើមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា ព្រោះពួកគេទាំងនោះតំណាងឱ្យនិស្សិតមកពីគ្រប់ខេត្តភាគច្រើននៅក្នុងប្រទេសកម្ពុជាដែលចេញពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងបានហ្វឹកហ្វឺនបន្តនៅវិទ្យាស្ថានជាតិអប់រំដែលជាគ្រឹះស្ថានសាធារណៈធំឈានមុខគេចំពោះវិស័យទាំងពីរនេះ ។ គរុនិស្សិតទាំអស់ត្រូវបានបំពេញកម្រងសំណួរយ៉ាងមានសេរីភាពនូវអ្វីដែលពួកគេយល់ឃើញអំពីខ្លួនឯង និងការសិក្សារបស់គេ ព្រមទាំងបានឆ្លើយកម្រងសំណួរដោយពុំមានការលំបាក ព្រោះសំណួរទាំងនោះទាក់ទងទៅនឹងការសិក្សារបស់គេ និងសំណួរទាក់ទងអាកប្បកិរិយានៃការអោយតំលៃលើខ្លួនគេផ្ទាល់ ។ ការបំពេញកម្រងសំណួររបស់គរុនិស្សិតត្រូវបានធ្វើឡើងនៅក្នុងបរិវេនវិទ្យាស្ថានជាតិអប់រំតែមួយ ។

---

** ១- គណិតវិទ្យា -រូបវិទ្យា ២- រូបវិទ្យា- គណិតវិទ្យា ៣- គីមីវិទ្យា-ជីវវិទ្យា ៤- ជីវវិទ្យា-គីមីវិទ្យា

## ៣.២ - ការវាស់វែងលទ្ធផលស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណងរកឱ្យឃើញកម្រិតនៃការអោយតំលៃខ្លួនឯង សមិទ្ធផលសិក្សា ការពេញចិត្តនឹងការសិក្សា និងលក្ខណៈពិសេសផ្ទាល់ខ្លួនរបស់គរុនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យា ។ ការអោយតំលៃខ្លួនឯងត្រូវបានធ្វើការវាស់វែងតាមរយៈការធ្វើតែស ( Self-Esteem Test ) រីឯការពេញ-ចិត្តនឹងការសិក្សា និងសមិទ្ធផលសិក្សាត្រូវធ្វើការវាស់វែងតាមរយៈការវិភាគទិន្នន័យ ដោយប្រើវិធីវិភាគស្ថិតិពិពណ៌នា ។ ជាមួយគ្នានេះដែរ ការស្រាវជ្រាវនឹងធ្វើការវាស់វែងពីទំនាក់ទំនងរវាងការអោយតំលៃខ្លួនឯងនិងលក្ខណៈពិសេសផ្ទាល់ខ្លួន ទំនាក់ទំនងការអោយតំលៃខ្លួនឯងនិងការពេញចិត្តនឹងការសិក្សា ទំនាក់ទំនងការ-អោយតំលៃខ្លួនឯងនិងសមិទ្ធផលសិក្សា ដោយប្រើគោលវិធីវិភាគ Regression ដើម្បីរកអោយឃើញពីទំនាក់ទំនងអថេរទាំងនោះ ។ ដូច្នេះ ដើម្បីងាយស្រួលក្នុងការវាស់វែង ការស្រាវជ្រាវនេះបានកំណត់នូវអថេរចំនួនពីរ គឺអថេរឯករាជ្យ (Independent Variable) និងអថេរមិនឯករាជ្យ (Dependent Variable) ដោយផ្តោតទៅលើវិធីសាស្ត្រទំនាក់ទំនងហេតុផលច្បាស់លាស់ ។ ការអោយតំលៃខ្លួនឯង និងលក្ខណៈពិសេសផ្ទាល់ខ្លួនជាអថេរឯករាជ្យ រីឯសមិទ្ធផលសិក្សា និងការពេញចិត្តនឹងការសិក្សាជាអថេរមិនឯករាជ្យ ឬជាអថេរសំរាប់ធ្វើការទោះទាយ ។

**៣.២.ក. អថេរឯករាជ្យ :** នៅក្នុងការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានកំណត់យកកត្តាលក្ខ-ណៈពិសេសផ្ទាល់ខ្លួន( ភេទ អាយុ និងការអប់រំ) និងកត្តាអោយតំលៃខ្លួនឯងរបស់និស្សិតជាអថេរឯករាជ្យ ។

- *កត្តាលក្ខណៈពិសេសផ្ទាល់ខ្លួន :* សំណួរដែលទាក់ទងនឹងព័ត៌មានលក្ខណៈពិសេសផ្ទាល់ខ្លួន ( ភេទ អាយុ និងកម្រិតអប់រំ ) ត្រូវបានដាក់បញ្ចូលនៅផ្នែកខាងក្រោមនៃកម្រងសំណួរដែលបានផ្តល់ទៅឱ្យគរុនិស្សិតបំពេញ ដើម្បីអ្នកធ្វើការស្រាវជ្រាវធ្វើការវិភាគទៅលើអាយុ ភេទ និងកម្រិតអប់រំរបស់គរុនិស្សិតកម្រិតឧត្តម ចំពោះការអោយតំលៃខ្លួនឯង និងសមិទ្ធផលសិក្សា ។ អាយុត្រូវបានកំណត់លើអាយុរបស់គរុ-និស្សិតដែលបានបំពេញកម្រងសំណួរ ។ ការអប់រំក៏ត្រូវបានកំណត់ចំពោះគរុនិស្សិតដែលបានបំពេញកម្រងសំណួរ ដើម្បីរកអោយឃើញពីកម្រិតអប់រំរបស់ពួកគេ ។ ភេទនេះត្រូវបានធ្វើការកំណត់ និងវាស់វែង ដើម្បីធ្វើការប្រៀបធៀបរវាងគរុនិស្សិតភេទស្រី និងគរុនិស្សិតភេទប្រុស ក្នុងគោលបំណងរកអោយឃើញថា ភេទមួយណាមានការអោយតំលៃខ្លួនឯងខ្ពស់ និងមានសមិទ្ធផលសិក្សាល្អជាង ។ កម្រងសំណួរនីមួយៗត្រូវបានកំណត់ជាលេខកូដ និងបានរៀបចំលេខជាលំដាប់បានច្បាស់លាស់ចំពោះឈ្មោះគរុនិស្សិតម្នាក់ៗ ដោយមានការរក្សាភាពសំងាត់ ។

*-កត្តាអោយតំលៃខ្លួនឯង :* ការឱ្យតំលៃខ្លួនឯងរបស់គរុនិស្សិតត្រូវបានវាស់ជាមាត្រដ្ឋាន ដើម្បីរកពិន្ទុនៃការអោយតំលៃខ្លួនឯងរបស់គរុនិស្សិត និងធ្វើការវិភាគលើពិន្ទុនៃការអោយតំលៃខ្លួនឯងនេះធៀបជាមួយនឹងសមិទ្ធផលសិក្សា និងការពេញចិត្តនឹងការសិក្សារបស់និស្សិត ។ ការវិភាគទៅលើពិន្ទុនៃការឱ្យតំលៃខ្លួនឯងនេះត្រូវបានធ្វើឡើងតាមរយៈការធ្វើតេសការអោយតំលៃខ្លួនឯងតាមប្រព័ន្ធអ៊ីនធឺណេត ដើម្បីស្វែងរកពិន្ទុរបស់គរុនិស្សិតម្នាក់ៗ បន្ទាប់មកធ្វើការរកមធ្យមភាគនៃការអោយតំលៃខ្លួនឯងសំរាប់គរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំទាំងមូល ។ សំណួរទាំងអស់នៅក្នុងផ្នែកនេះត្រូវបានគិតជាស្កេល ៥ កម្រិត ដើម្បីងាយនឹងយកមកធ្វើការវាស់វែង ។ ពិន្ទុនៃការឱ្យតំលៃខ្លួនរបស់អ្នកចូលរួមត្រូវកំណត់ពីពិន្ទុ សូន្យ ទៅ ១០០ ។ ពិន្ទុពីសូន្យទៅដល់ ៤៩ជាពិន្ទុកម្រិតទាប ពិន្ទុពី៥០ ដល់៦៤ជាពិន្ទុកម្រិតមធ្យម និងពិន្ទុពី៦៥ដល់១០០ជាពិន្ទុកម្រិតបង្គួរ និងខ្ពស់បំផុតនៃការអោយតំលៃខ្លួនឯង ។ ពិន្ទុខ្ពស់បញ្ជាក់ថាការអោយតំលៃខ្លួនឯងខ្ពស់ រីឯពិន្ទុទាបបង្ហាញថាការអោយតំលៃខ្លួនឯងទាប ។ ពិន្ទុ ៥០ ជាចំនុចកណ្តាលនៃការអោយតំលៃខ្លួនឯងនៅក្នុងការគ្រិតពិន្ទុនៃការអោយតំលៃខ្លួនឯងនេះ ។ លទ្ធផលវាស់វែងពិន្ទុនេះអាចអោយយើងដឹងពីកម្រិតនៃការអោយតំលៃខ្លួនឯងរបស់គរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំ ។ បន្ទាប់ពីបានពិន្ទុនៃការអោយតំលៃខ្លួននេះហើយ អ្នកស្រាវជ្រាវបានដំរៀបជាលេខលំដាប់ ដើម្បីកំណត់រកពិន្ទុមធ្យម មេដ្យាន និងម៉ូដរបស់ពិន្ទុ ហើយបន្ទាប់មកអ្នកស្រាវជ្រាវនឹងធ្វើការវិភាគប្រៀបធៀបពិន្ទុនេះទៅនឹងពិន្ទុបានមកពីលទ្ធផលសិក្សារបស់គរុនិស្សិត ។ ការឱ្យតំ-លៃខ្លួនឯងមានសំណួរចំនួន ៣០ ដែលមានអត្ថន័យផ្តោតទៅលើការស្រលាញ់ខ្លួន អារម្មណ៍ដែលគិតថាខ្លួនឯងនៅមានភាពមិនទាន់គ្រប់គ្រាន់ ការបន្ទាបតំលៃខ្លួនឯង សេចក្តីសង្ឃឹមលើខ្លួនឯង ការទំនាក់ទំនងសង្គម តំរូវការទទួលស្គាល់ពីអ្នកដទៃ ជំនឿទៅលើការឱ្យតំលៃខ្លួនឯងខ្ពស់ និងឥរិយាបថមិនខ្វល់លើរឿងរ៉ាវដែលបានកើតឡើង ។ អ្នកចូលរួមឆ្លើយសំណួរលើចំណុចនេះ ត្រូវបានស្នើរអោយឆ្លើយបញ្ជាក់អំពីអារម្មណ៍នៃការអោយតំលៃខ្លួនឯងដោយមានប្រភេទសំណួរពីរប្រភេទ ។ សំណួរផ្នែកទី១នៃការអោយតំលៃខ្លួនឯងមាន ១៧ សំណួរដែលត្រូវបានគ្រិតដោយស្កេលលេខ ៥-ឯកភាពទាំងស្រុង ៤-ឯកភាពច្រើន ៣-ឯកភាពតិចតួច ២-មិនឯកភាព និង ១-មិនឯកភាពទាំងស្រុង ។ រីឯសំណួរផ្នែកទីពីរនៃចំណុចនេះដែរមានចំនួន ១៣ សំណួរដែលគ្រិតដោយលេខ ១-ស្ទើរតែមិនដែលសោះ ២-កម្រណាស់ ៣-មានពេលខ្លះដែរ ៤-ញឹកញាប់ ឬញយដង និងលេខ ៥-ស្ទើរតែគ្រប់ពេល ។ អ្នកស្រាវជ្រាវប្រើប្រាស់កម្រងសំណួរទាំងនេះ ដើម្បីស្រង់យកពិន្ទុធ្វើជាមូលដ្ឋានវិភាគនៅក្នុងស្នាដៃស្រាវជ្រាវនេះទាំងមូល ។ ជាមួយគ្នានេះ អ្នកស្រាវជ្រាវនឹងធ្វើការសម្ភាសន៍ផ្ទាល់ជាមួយក្រុមគរុនិស្សិតសំរាប់ប្រមូលព័ត៌មានបន្ថែម ដើម្បីពង្រឹងលើការវិភាគបែបគុណវិស័យ ដើម្បីរក

កត្តាដែលមានឥទ្ធិពលដល់ការអោយតំលៃខ្លួនឯងរបស់ពួកគេ ។

**៣.២.ខ-អថេរមិនឯករាជ្យ :** កត្តាដែលត្រូវចាត់ចូលជាអថេរមិនឯករាជ្យនៅក្នុងការស្រាវនេះរួមមានការពេញចិត្តនឹងការសិក្សា និងសមិទ្ធផលសិក្សារបស់គរុនិស្សិត ។ អ្នកស្រាវជ្រាវនឹងប្រើវិធីអង្កេតអំពីទំនាក់ទំនងរវាងការពេញចិត្តនឹងការសិក្សាជាមួយនឹងសមិទ្ធផលសិក្សា ។

- *ការពេញចិត្តនឹងការសិក្សា :* កាពេញចិត្តនឹងការសិក្សានេះត្រូវបានវាស់វែងជាមាត្រដ្ឋានពិន្ទុសំរាប់ធ្វើការវាយតំលៃពីឥរិយាបថនៃការពេញចិត្តរបស់គរុនិស្សិតកម្រិតឧត្តមលើមុខវិជ្ជាសិក្សា និងមុខវិជ្ជាអាជីពរបស់គេ ។ សំណួរសំរាប់ការពេញចិត្តនឹងការសិក្សាមានកម្រងសំណួរចំនួន១៥ ហើយអ្នកដែលចូលរួមឆ្លើយត្រូវបានតម្រូវឱ្យឆ្លើយសំណួរដែលមិនមានចំលើយខុស ឬត្រូវទេ ដោយគ្រាន់តែបញ្ជាក់ពីចំណង់នៃការពេញចិត្តសិក្សាររបស់ខ្លួន ។ សំណួរនីមួយៗត្រូវបានដាក់ពិន្ទុពីខ្លាំងទៅខ្សោយដែលត្រូវបានកំណត់ដោយស្កេលលេខ ១-ពេញចិត្តណាស់ ២-ពេញចិត្តបង្គួរ ៣-ពេញចិត្តមធ្យម ៤- ពេញចិត្តតិចតួច និង លេខ ៥-មិនពេញចិត្តសោះ ។ ពិន្ទុដែលបានពីកម្រងសំណួរនីមួយៗនៃការពេញចិត្តនេះត្រូវបានគណនារកមធ្យមភាគ បន្ទាប់មកគណនាបន្តលើពិន្ទុមធ្យមនៃពិន្ទុនីមួយៗ ដើម្បីរកពិន្ទុមធ្យមរួមតែមួយសំរាប់អថេរនៃការពេញចិត្តនឹងការសិក្សានេះ ។ ខ្លឹមសារ និងអត្ថន័យនៃសំណួរក្នុងចំណុចនេះត្រូវបានឆ្លើយយកជាបានការទាំងអស់ដោយគ្មានភាពច្រលំលើចំនុចណាមួយឡើយ ។ នេះទំនងជាសំណួរមានភាពច្បាស់លាស់ និងសមស្របទៅនឹងជំនក់ចិត្តចំពោះបញ្ហាផ្ទាល់ខ្លួនរបស់ពួកគេ ។

- *សមិទ្ធផលសិក្សា:* កម្រងសំណួរស្តីពីសមិទ្ធផលសិក្សាផ្តោតទៅលើកំរិតសមត្ថភាពយល់ដឹង និងលទ្ធផលនៃការសិក្សារបស់គរុនិស្សិត ដោយត្រូវធ្វើការវាស់វែងជាមាត្រដ្ឋានផងដែរ ។ សំណួរចំនួន១៣ដែលអ្នកចូលរួមឆ្លើយត្រូវបានផ្តល់នូវចំលើយមិនខុសមិនត្រូវ ដោយកម្រិតនូវលំដាប់ចំនួន ៥ ដែលរួមមានកម្រិតដូចតទៅ : ១-ទទួលបានល្អណាស់ ២-ទទួលបានមធ្យម ៣-ទទួលបានតិចតួច ៤-មិនដឹងច្បាស់ថាបានទទួល និង ៥-មិនទទួលបានសោះ ។ ខ្លឹមសារនៃសមិទ្ធផលសិក្សាដែលត្រូវបានធ្វើការវាស់វែងផ្តោតទៅលើមុខវិជ្ជាសិក្សានៅក្នុងថ្នាក់រៀន ក្នុងមន្ទីពិសោធន៍ និងការចុះកម្មសិក្សាអនុវត្តជាក់ស្តែង ។ ជាមួយគ្នានេះដែរ ពិន្ទុសិក្សាប្រចាំឆ្នាំរបស់គរុនិស្សិត ត្រូវបានយកមកធ្វើការវិភាគពីសហទំនាក់ទំនងជាមួយការអោយតំលៃខ្លួនឯងដើម្បីរកអោយឃើញពីសហទំនាក់ទំនងរវាងការអោយតំលៃខ្លួនឯង និងសមិទ្ធផលសិក្សារបស់គេ ។

សរុបសេចក្តីមក កម្រងសំណួរទាំងអស់ត្រូវបានរៀបចំអនុវត្ត និងប្រើប្រាស់តាមចំណាត់ថ្នាក់ទៅតាមគោលបំណងដែលបានគ្រោងទុក ហើយសំណួរទាំងនោះត្រូវបានបែងចែជា៤ផ្នែកដែលផ្នែកទីមួយនិយាយ

ពីការអោយតំលៃខ្លួនឯង ផ្នែកទីពីរបង្ហាញពីការពេញចិត្តនឹងការសិក្សា ផ្នែកទី៣ផ្តោតទៅលើសមិទ្ធផលសិក្សា និងផ្នែកចុងក្រោយទី៤ និយាយអំពីកត្តាលក្ខណៈពិសេសផ្ទាល់ខ្លួន ។ ការស្រាវជ្រាវនេះនឹងធ្វើការវិភាគដោយប្រើលទ្ធផលពិន្ទុគិតជាលេខទៅជាអត្ថន័យ ដើម្បីរកអោយឃើញពីទំនាក់ទំនងនៃអថេរនីមួយៗ និងស្វែងរកកត្តាដែលនាំអោយមានឥទ្ធិពលដល់ការអោយតំលៃខ្លួនឯង ។ កម្រងសំណួរទាំងអស់ត្រូវបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធទី ១ ហើយរបកកំហើញនៃការស្រាវជ្រាវនឹងត្រូវបានបង្ហាញក្នុងជំពូកទី៤ ។

### ៣.៣ - លំនាំស្រាវជ្រាវ

លំនាំស្រាវជ្រាវនេះត្រូវបានអនុវត្តយ៉ាងសាមញ្ញដោយបានធ្វើឡើងជាដំណាក់កាលៗដោយចាប់ផ្តើមពីដំណើរការស្រាវជ្រាវដំបូងរហូតដល់ការស្រាវជ្រាវចេញជាលទ្ធផល ។ ទម្រង់ការនេះនឹងពិភាក្សាទៅលើរបៀបបង្កើតកម្រងសំណួរស្រាវជ្រាវ របៀបឬវិធីប្រមូលទិន្នន័យ របៀបជ្រើសរើសក្រុមគោលដៅស្រាវជ្រាវ វិធីសាកល្បងវាស់វែងកម្រងសំណួរ និងរបៀបវិភាគទិន្នន័យ និងលទ្ធផល ។

- ដំណាក់កាលបង្កើតកម្រងសំណួរ : អ្នកស្រាវជ្រាវបានសិក្សាទៅលើដែនកំណត់ និងទំហំនៃការស្រាវជ្រាវ ដោយផ្អែកលើការសង្កេត និងការត្រួតពិនិត្យទ្រឹស្តីដែលពាក់ព័ន្ធរបស់អ្នកស្រាវជ្រាវផ្សេងៗកន្លងមក ព្រមទាំងការផ្តល់យោបល់ និងជំនួយពីសាស្ត្រាចារ្យណែនាំ ទើបនាំអោយកម្រងសំណួរត្រូវបានបង្កើតឡើង ។ កម្រងសំណួរទាំងនេះផ្តោតទៅលើចំនុចការអោយតំលៃខ្លួនឯង សមិទ្ធផលសិក្សា ការពេញចិត្តនឹងការសិក្សា និងលក្ខណៈពិសេសផ្ទាល់ខ្លួន ។ កម្រងសំណួរ ដែលទាក់ទងនឹងការអោយតំលៃខ្លួនឯងត្រូវបានដកស្រង់ចេញពីកម្រងសំណួរតាមអ៊ីនធឺណេត យកមកធ្វើការកែច្នៃឱ្យសមស្របតាមស្ថានភាពអប់រំនៅប្រទេសកម្ពុជា ដោយសំណួរទាំងអស់មានចំនួន ៣០ ។ រីឯកម្រងសំណួរដែលទាក់ទងសមិទ្ធផលសិក្សា ការពេញចិត្តនឹងការសិក្សា និងសមិទ្ធផលសិក្សាផ្នែកវិទ្យាសាស្ត្រត្រូវបានបង្កើតឡើង ដោយផ្អែកទៅលើមុខវិជ្ជាសិក្សាជាក់ស្តែងរបស់វិទ្យាស្ថានជាតិអប់រំ ។

- ដំណាក់កាលប្រមូលទិន្នន័យ : ក្រដាស់សំណួរហ្វូតូកូពីត្រូវបានចែកជូននិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យាទាំងអស់ ។ គរុនិស្សិតម្នាក់ៗបានឆ្លើយទៅនឹងសំណួរដោយមានការអនុញ្ញាតពីថ្នាក់ដឹកនាំ និងមានជំនួយពីសាស្ត្រាចារ្យរបស់វិទ្យាស្ថានជាតិអប់រំ ហើយពួកគេត្រូវចំណាយពេលប្រម៉ាណពី២០ទៅ២៥នាទី ដើ-ម្បីអាចបំពេញកម្រងសំណួរទាំងអស់ចប់នៅក្នុងបរិវេនវិទ្យាស្ថានជាតិអប់រំនៅចុងឆ្នាំសិក្សារបស់ពួកគេ ។ ទិន្នន័យបានការ និងជឿទុកចិត្តបានដែលប្រមូលបានពីការស្រាវជ្រាវទាំងអស់មានចំនួន ៧៧ នាក់ ។ ជាមួយនេះដែរ ទិន្នន័យមួយប្រភេទទៀតគឺបានមកពីការធ្វើកាសម្ភាសន៍ផ្ទាល់មាត់ជាមួយគរុនិស្សិត ដើម្បីស្វែងរក និង

ប្រមូលព័ត៌មានដែលទាក់ទងរបៀបអប់រំរបស់ឪពុកម្តាយ និងការអប់រំនៅវិទ្យាស្ថានជាតិអប់រំ នឹងកំលាំងចិត្តចលកររបស់គរុនិស្សិតផ្ទាល់ ។

- *ដំណាក់កាលវាស់វែងកម្រងសំណួរ* :ស្ថិតក្នុងដំណាក់កាលនេះ អ្នកស្រាវជ្រាវបានជ្រើសរើសគំរូតាងដែលសុទ្ធតែជាគរុនិស្សិតកម្រិតឧត្តមផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ។ កម្រងសំណួរត្រូវបានកណត់ដាច់ដោយឡែកពីគ្នា និងត្រូវបានកណត់កម្រិតពិន្ទុផ្សេងគ្នា ។ កម្រងសំណួរដែលទាក់ទងទៅនឹងការអោយតំលៃខ្លួនឯងត្រូវកំណត់មាត្រដ្ឋាននៃពិន្ទុដូចតទៅ :

ផ្នែកទីមួយរួមមាន : ១ - យល់ព្រមខ្លាំង ២-យល់ព្រមបង្គួរ ៣- យល់ព្រមមធ្យម

៤- យល់ព្រមតិចតួច ៥- មិនយល់ព្រមទាំងស្រុង

ផ្នែកទីពីររួមមាន : ១-ញឹកញាប់ ២-ញឹកញាប់បង្គួរ ៣- ម្តងម្កាល

៤-កម្រ ៥-មិនដែលសោះ ។

សំណួរទាក់ទងសមិទ្ធផលសិក្សាត្រូវបានគ្រិតពិន្ទុដោយប្រើលំដាប់ខ្ពស់ទាបជា៥កម្រិត ដោយមានចំលើយមិនខុស មិនត្រូវ ។ មាត្រដ្ឋាននេះត្រូវបានកំណត់ដោយ :

ផ្នែកទីមួយរួមមាន : ១-ទទួលបានច្រើន ២-ទទួលបានបង្គួរ ៣-ទទួលបានមធ្យម

៤-មិនដឹងថាបានទទួល ៥-មិនទទួលបានសោះ

ផ្នែកទីពីររួមមាន : ១-ពេញចិត្តខ្លាំង ២-ពេញចិត្តបង្គួរ ៣-ពេញចិត្តមធ្យម

៤-ពេញចិត្តតិចតួច និង ៥-មិនពេញចិត្តសោះ និងកត្តាលក្ខណៈពិសេសផ្ទាល់ខ្លួនត្រូវបានកំណត់រកកត្តាភេទ កម្រិតអប់រំ និងកម្រិតអាយុ ។

- *ដំណាក់កាលវាស់វែងពិន្ទុ* :សំណួរទាក់ទងការអោយតំលៃខ្លួនឯងត្រូវបានដាក់បញ្ចូលតាមវេបសាយ ដើម្បីធ្វើការវិភាគពីការអោយតំលៃខ្លួនឯងដោយការដាក់បញ្ចូលចំលើយរបស់និស្សិតម្នាក់ៗ ដោយត្រូវចំណាយពេលពី ៥ ទៅ ៦នាទី ដើម្បីទទួលលទ្ធផលជាក់លាក់ថានិស្សិតទទួលបានពិន្ទុកម្រិតណា ។ បន្ទាប់មក ពិន្ទុនៃការអោយតំលៃខ្លួនឯងដែលធ្វើការវិភាគនោះត្រូវបានស្រង់ចូលក្នុងតារាងដើម្បីរកមធ្យមពិន្ទុ មូដពិន្ទុ និងមេដ្យានពិន្ទុ (*សូមមើលតារាងទី៩*) ។ នៅក្នុងពិន្ទុនេះ អ្នកស្រាវជ្រាវក៏បានបែងចែកកម្រិតពិន្ទុរវាងនិស្សិតប្រុស និងស្រី ដើម្បីរកមធ្យមពិន្ទុថាភេទណាមានការអោយតំលៃខ្លួនឯងខ្ពស់ជាង ។ ជាមួយនេះដែរអ្នកស្រាវជ្រាវក៏បានបែងចែកកម្រិតអាយុរបស់គរុនិស្សិតជាពីរកម្រិតគឺកំរិតទាបចាប់ពីអាយុ ២០ ដល់ ២៣ ឆ្នាំ និងកម្រិតខ្ពស់ចាប់ពី ២៤ដល់ ២៧ឆ្នាំក្នុងគោលបំណងរកឱ្យឃើញថាតើនិស្សិតដែលមានអាយុតិច ឬច្រើន

មានការអោយតំលៃខ្លួនឯងខ្ពស់ជាងគេ ។ រីឯសំណួរដែលទាក់ទងនឹងសមិទ្ធផលសិក្សាត្រូវបានកំណត់ជាមាត្រដ្ឋានមធ្យមភាគ និងលំងាកស្តង់ដា ។

- ដំណាក់កាលវិភាគលទ្ធផល : ដោយទទួលបានពិន្ទុពីដំណាក់កាលវាស់វែងពិន្ទុ ដំណាក់-កាលនេះនឹងត្រួតពិនិត្យពីសហសម្ព័ន្ធរវាងអថេរនៃលក្ខណៈពិសេសផ្ទាល់ខ្លួន និងការឱ្យតំលៃខ្លួនឯងជាមួយអថេរនៃការពេញចិត្តនឹងការសិក្សា និងសមិទ្ធផលសិក្សា ។ អ្នកស្រាវជ្រាវនឹងផ្ទៀងផ្ទាត់ពីលទ្ធផលបានមកពីការឆ្លើយសំណួរដោយប្រៀបធៀបគ្នារវាងពិន្ទុនៃអថេរនីមួយៗទាំងនោះ ។ លេខកូដសំរាប់និស្សិតម្នាក់ៗត្រូវបានរៀបចំជាលំដាប់លំដោយត្រឹមត្រូវ ដើម្បីងាយស្រួលយកពិន្ទុនៃការអោយតំលៃខ្លួនឯងទៅផ្ទៀងផ្ទាត់ជាមួយលទ្ធផលពិន្ទុសិក្សាជាក់ស្តែងរបស់និស្សិត ដើម្បីរកពីទំនាក់ទំនងអថេរទាំងនោះ ។ ដំណាក់កាលវិភាគលទ្ធផលនេះក៏នឹងផ្តោតទៅលើការពិភាក្សារកហេតុផលនានា ចំពោះកត្តាដែលមានឥទ្ធិពលដល់ការអោយតំលៃខ្លួនឯងដោយផ្អែកលើស្ថានភាពជាក់ស្តែងរបស់វិទ្យាស្ថានជាតិអប់រំ និងកត្តាសង្គមទាំងមូល ។ អ្នកស្រាវជ្រាវបានធ្វើការវិភាគលទ្ធផលស្រាវជ្រាវតាមរយៈស្ថិតិពិពណ៌នា និងគោលវិធីសហទំនាក់ទំនង ( Regression ) ចំពោះអថេរនីមួយៗ ដើម្បីរកអោយឃើញពីទំនាក់ទំនងរវាងអថេរនីមួយៗ ។ ជាមួយនេះដែរ អ្នកស្រាវជ្រាវបានប្រមូលព័ត៌មានពីការសម្ភាសន៍ផ្ទាល់មាត់មកដាក់ជំរៀបគ្នា បន្ទាប់មករកអោយឃើញចំណុចព័ត៌មានណាដែលបានកើតឡើងញឹកញាប់ជាងគេ ដើម្បីយកមកពិពណ៌នាបកស្រាយក្នុងការស្រាវជ្រាវនេះ ។

សរុបមក អ្នកស្រាវជ្រាវបានអនុវត្តតាមទាំងគន្លងទ្រឹស្តីនៃវិធីសាស្ត្រស្រាវជ្រាវផង និងតាមស្ថាន-ភាពជាក់ស្តែងផង ដោយគិតដល់ប្រពន្ធ័ទំនាក់ទំនងជាប្រចាំ ដោយរួមមានការរៀបចំជាកម្រងសំណួរ ការជ្រើសរើសក្រុមគោលដៅស្រាវជ្រាវសំរាប់បំពេញម្រងសំណួរ ការកំណត់មាត្រដ្ឋានដើម្បីធ្វើការវាស់វែងពិន្ទុ និងចុងក្រោយបំផុតធ្វើការវិភាគលើពិន្ទុអថេរនីមួយៗ ។ តាមរយៈទម្រង់ការនេះ ការស្រាវជ្រាវនេះនឹងរកឃើញនូវលទ្ធផលដែលគួរអោយជឿជាក់ និងអាចយកជាការបានសំរាប់ស្នាដៃស្រាវជ្រាវនេះទាំងមូល ។ លទ្ធផលស្រាវជ្រាវត្រូវបានរកឃើញនៅក្នុងជំពូកទី ៤ ស្តីពីលទ្ធផលស្រាវជ្រាវ និងជំពូកទី ៥ ស្តីពីការពិភាក្សា និងអនុសាសន៍ ។

# ជំពូកទី៤

## លទ្ធផលនៃការស្រាវជ្រាវ

លទ្ធផលនៃការស្រាវជ្រាវនេះនឹងបង្ហាញពីការអោយតំលៃខ្លួនឯងរបស់និស្សិតដោយប្រើក្បួនថ្វៃតែស របស់អ្នកប្រាជ្ញក្នុងចិត្តវិទ្យា បង្ហាញពីការពេញចិត្តនឹងការសិក្សា ពីសមត្ថភាពសិក្សា និងពីលក្ខណៈពិសេសផ្ទាល់ខ្លួនរបស់គរុនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ ដោយធ្វើការបកស្រាយតាមរយៈគោលវិធីស្ថិតិពិពណ៌នា (Descriptive Approach ) ។ លទ្ធផលស្រាវជ្រាវនេះក៏នឹងបកស្រាយពន្យល់អំពីសហាទំនាក់ទំនងរវាងការអោយតំលៃខ្លួនឯងជាមួយលក្ខណៈពិសេសផ្ទាល់ខ្លួន ការអោយតំលៃខ្លួនឯងជាមួយនឹងការពេញចិត្តនឹងការសិក្សា និងទំនាក់ទំនងរវាងការពេញចិត្តនឹងការសិក្សាជាមួយសមិទ្ធផលសិក្សា ដោយធ្វើការវិភាគបែបវិទ្យាសាស្ត្រតាមរយៈការប្រើស្ថិតិមេគុណទំនាក់ទំនង (Regression) ។

### ៤.១ - និដ្ឋភាពទូទៅនៃលទ្ធផលស្រាវជ្រាវតាមស្ថិតិពិពណ៌នា

លទ្ធផលស្រាវជ្រាវក្នុងចំណុចនេះត្រូវបានប្រើប្រាស់ស្ថិតិពិពណ៌នា ដើម្បីកំណត់រកមធ្យម លំងាកស្តង់ដា ពិន្ទុអប្បបរមា និងអតិបរមារាល់លើអថេរនីមួយៗដែលទាក់ទងនឹងលក្ខណៈពិសេសផ្ទាល់ខ្លួន ការអោយតំលៃខ្លួនឯង ការពេញចិត្តនឹងការសិក្សា និងសមិទ្ធផលសិក្សា ។

#### ៤.១.ក - លក្ខណៈពិសេសផ្ទាល់ខ្លួន ( ភេទ អាយុ និង កម្រិតអប់រំ )

លក្ខណៈពិសេសផ្ទាល់ខ្លួននៅក្នុងការស្រាវជ្រាវនេះសំដៅទៅលើ ភេទ អាយុ និងកម្រិតអប់រំរបស់គរុនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំដែលបានចូលរួមបំពេញកម្រងសំនួរ ។ លទ្ធផលនៃអ្នកចូលរួមឆ្លើយទាំងអស់ដែលអាចយកជាការបានមានចំនួន ៧៧ នាក់ ក្នុងនោះអ្នកចូលរួមភេទស្រីមានចំនួន ២៣ នាក់ ( ២៩.៨៧% ) និងភេទប្រុសមានចំនួន ៥៤ នាក់( ៧០.១៣% )( សូមមើលតារាងទី២ ) ។

| ភេទ | អ្នកចូលរួម | ភាគរយ |
|---|---|---|
| ប្រុស | ៥៤ | ៧០.១៣ |
| ស្រី | ២៣ | ២៩.៨៧ |
| សរុប | ៧៧ | ១០០ |

*តារាងទី២ : ចំនួននៃក្រុមគោលដៅស្រាវជ្រាវ និងភាគរយ*

អាយុរបស់អ្នកចូលរួមទាំងពីរភេទមាននៅក្នុងចន្លោះពី ២០ឆ្នាំ ដល់ ២៧ឆ្នាំ ដែលមានមធ្យមអាយុ $\overline{X}$ =២៣ និងលំងាកស្តង់ដា SD = ១.១២ ក្នុងចន្លោះអាយុអប្បបរមា ២០ ឆ្នាំ និងអតិបរមា ២៧ ឆ្នាំដែលមានមូដអាយុ ២៣ ( សូមមើលក្រាបទី ២ ខាងក្រោម) ។




*រូបទី២ : ដ្យាក្រាមបង្ហាញពីចំនួនប្រេកង់អាយុអ្នកចូលរួម*

អ្នកចូលរួមភេទស្រីមានចំនួន២៣នាក់ដែលមានមធ្យមអាយុ $\overline{X}$ = ២២.៦៩ និងលំងាកស្តង់ដា SD=១.២២ ដោយអាយុខ្ពស់បំផុត ២៧ និងទាបបំផុត ២២ រីឯអ្នកចូលរួមភេទប្រុសមានចំនួន ៥៤ នាក់ដែលមានមធ្យមអាយុ $\overline{X}$ = ២៣.០៥ និងលំងាកស្តង់ដានៃអាយុ SD = ១.០៧ ដោយស្ថិតក្នុងចន្លោះអាយុទាបបំផុត ២០ ឆ្នាំ និងអាយុខ្ពស់បំផុត ២៦ ឆ្នាំ ( សូមមើលតារាងទី៣) ។ លទ្ធផលនៃអាយុនេះបង្ហាញថា និស្សិតភេទស្រីមានអាយុក្មេងជាងនិស្សិតភេទប្រុសមួយឆ្នាំសំរាប់គរុនិស្សិតដែលបានចំណាយពេលរៀននៅវិទ្យាស្ថានជាតិអប់រំ ។

| ប្រភេទ | អ្នកចូលរួម | អាយុអប្បបរមា | អាយុអតិបរមា | $\overline{X}$ | លំងាកស្តង់ដា |
|---|---|---|---|---|---|
| ប្រុស | ៥៤ | ២០ | ២៦ | ២៣.០៥ | ១.០៧ |
| ស្រី | ២៣ | ២២ | ២៧ | ២២.៦៩ | ១.២២ |
| សរុប | ៧៧ | ២០ | ២៧ | ២២.៩៥ | ១.១២ |

*តារាងទី ៣ : អាយុរបស់អ្នកចូលរួម គិតជាមធ្យម និងលំងាកស្តង់ដា*

កម្រិតអប់រំរបស់អ្នកចូលរួមមានកម្រិតស្មើគ្នា ដោយពួកគេទាំងអស់នោះសុទ្ធតែជាគរុនិស្សិតកម្រិតឧត្តមសិក្សា "បរិញ្ញាបត្របូកមួយ" នៅវិទ្យាស្ថានជាតិអប់រំឆ្នាំសិក្សា ២០០២-២០០៣ ប៉ុន្តែពួកគេមានមុខ

ជំនាញខុស១គ្នា ។ និស្សិតទាំងនោះមានប្រភព និងមជ្ឈដ្ឋាន ព្រមទាំងមានរបៀបរស់នៅផ្សេង១ពីគ្នា ហើយអាណាព្យាបាលរបស់ពួកគេមានកំរិតអប់រំ និងមានមុខរបរផ្សេងគ្នាដែរ ។ លទ្ធផលស្រាវជ្រាវបានបង្ហាញថា អាណាព្យាបាលរបស់អ្នកចូលរួមមានមុខរបរជាកសិករមានចំនួន ២៩ នាក់ មន្ត្រីរាជការ ២៤ នាក់ អាជីវករ ១៤ នាក់ ពេទ្យ ៤ នាក់ មន្ត្រីចូលនិវត្ត ៥ នាក់ និងបុគ្គលិកក្រុមហ៊ុន ១ នាក់ (សូមមើលតារាងទី ៤ ខាងក្រោម) ។ ទោះជានិស្សិតមានការអប់រំក្នុងកម្រិតដូចគ្នាក្តី ប៉ុន្តែពួកគេមានប្រភពផ្សេងពីគ្នា ដែលនេះជាហេតុនាំអោយពួកគេមានការអោយតំលៃលើខ្លួនឯងក្នុងកម្រិតផ្សេងគ្នាដែរ ។

| មុខរបរ | កសិករ | មន្ត្រីរាជការ | អាជីវករ | មន្ត្រីចូលនិវត្ត | ពេទ្យ | បុគ្គលិកក្រុមហ៊ុន |
|---|---|---|---|---|---|---|
| ចំនួន | ២៩ | ២៤ | ១៤ | ៥ | ៤ | ១ |

*តារាងទី៤ : មុខរបរអាណាព្យាបាលរបស់អ្នកចូលរួមបំពេញកម្រងសំណួរ*

ជាមួយគ្នានេះដែរ លទ្ធផលស្រាវជ្រាវបានបង្ហាញថា គរុនិស្សិតទាំង ៧៧ នាក់ មានប្រភពមកពីបណ្តាខេត្តក្រុងចំនួន ១៥ នៅក្នុងប្រទេសកម្ពុជា ។ និស្សិតដែលកើតនៅក្នុងគ្រួសារដែលមានឪពុកម្តាយរស់នៅក្នុងទីក្រុងមានចំនួន ២១ នាក់ និងគ្រួសាដែលមានឪពុកម្តាយនៅតាមខេត្តមានចំនួន ៥១ នាក់ រីឯនិស្សិតមកពីតំបន់ដាច់ស្រយ៉ាលមានចំនួន ៥ នាក់ ។ ប្រភពទាំងនេះអាចមានឥទ្ធិពលដល់ការអោយតំលៃខ្លួនឯងរបស់គរុនិស្សិតក្នុងកម្រិតផ្សេងពីគ្នា ។ គរុនិស្សិតដែលត្រូវបានជ្រើសរើសអោយចូលរួមឆ្លើយមានការបែងចែកទៅតាមជំនាញឯកទេសដូចតទៅ : គរុនិស្សិតគណិតវិទ្យាមានចំនួន ២៥ នាក់ (ប្រុស ១៧ ស្រី ៨) គរុ-និស្សិតរូបវិទ្យា ២៣ នាក់ (ប្រុស ១៩ ស្រី ៤) គរុនិស្សិតគីមីវិទ្យា ១៩ នាក់ (ប្រុស ១៣ ស្រី ៦) និងគរុ-និស្សិតជីវវិទ្យា ១០ នាក់ (ប្រុស ៤ ស្រី ៦) ។

| ភេទ | អ្នកចូលរួម | មុខជំនាញ | | | | កំរិតអប់រំ |
|---|---|---|---|---|---|---|
| | | គណិតវិទ្យា | រូបវិទ្យា | គីមីវិទ្យា | ជីវវិទ្យា | |
| ប្រុស | ៥៤ | ១៨ | ១៩ | ១៣ | ៤ | បរិញ្ញា + ១ |
| ស្រី | ២៣ | ៧ | ៤ | ៦ | ៦ | បរិញ្ញា + ១ |
| សរុប | ៧៧ | ២៥ | ២៣ | ១៩ | ១០ | បរិញ្ញា + ១ |

*តារាងទី៥ : ប្រភេទនៃចំនួនអ្នកចូលរួមនិងកំរិតអប់រំនៃមុខជំនាញរបស់គេ*

## ៤.១.២ - ការអោយតំលៃខ្លួនឯង

លទ្ធផលស្រាវជ្រាវបង្ហាញថា ពិន្ទុមធ្យមនៃការអោយតំលៃខ្លួនឯងរបស់អ្នកចូលរួមមាន $\overline{X}$ =៦២.៣៦ និងលំងាកស្តង់ដា SD = ៥.៣៤ និងមេដ្យាន ៦៣.00 ស្ថិតក្នុងចន្លោះការអោយតំលៃខ្លួនឯងទាបបំផុតពិន្ទុ ៤៣ និងខ្ពស់បំផុត ៧៩ ដោយកំរិតពិន្ទុនៃការអោយតំលៃខ្លួនឯងចន្លោះពី ១ ទៅ ១០០ ។ ពិន្ទុពី ១ ដល់ ៤៩ មានន័យថាការអោយតំលៃខ្លួឯងទាប ពិន្ទុពី ៥០ ដល់ ៦៤ មានន័យថាការឱ្យតំលៃខ្លួនឯងស្ថិតក្នុងកំរិតមធ្យម ហើយពិន្ទុពី ៦៥ ដល់ ១០០ មានន័យថាការឱ្យតំលៃខ្លួនឯងមានកំរិតខ្ពស់ ។ ដូច្នេះ លទ្ធផលស្រាវជ្រាវនេះបង្ហាញថា គរុនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៃវិទ្យាស្ថានជាតិអប់រំមានការអោយតំលៃខ្លួនឯងក្នុងកម្រិតមធ្យម (សូមមើលតារាងទី៦ខាងក្រោម) ។

| អ្នកចូលរួម | អប្បបរមាពិន្ទុ | អតិបរមាពិន្ទុ | $\overline{X}$ | SD |
|---|---|---|---|---|
| ៧៧ | ៤៣ | ៧៩ | ៦ ២.៣៦៤ | ៥.៣៤០ |
| ពិន្ទុទាបបំផុត : ១ | | ពិន្ទុខ្ពស់បំផុត : ១០០ | | |

*តារាងទី៦ : ពិន្ទុនៃការអោយតំលៃខ្លួនឯងរបស់អ្នកចូលរួម*

ជាមួយគ្នានេះដែរ ការស្រាវជ្រាវនេះក៏បង្ហាញពីការអោយតំលៃខ្លួនឯងរបស់និស្សិតប្រុស និងនិស្សិតស្រីផងដែរ ។ លទ្ធផលបង្ហាញថា មធ្យមនៃការអោយតំលៃខ្លួនឯងរបស់និស្សិភេទប្រុស $\overline{X}$ =៦១.៧៥ លំងាកស្តង់ដា SD = ៣.៩៩ រីឯនិស្សិតភេទស្រីមានពិន្ទុមធ្យមនៃការអោយតំលៃខ្លួនឯង $\overline{X}$ =៦៣.៧៨ និងលំងាកស្តង់ដា SD=៧.៥៥ ។ លទ្ធផលនេះសបញ្ជាក់ថា គរុនិស្សិតភេទប្រុស និងគរុនិស្សិតភេទស្រីផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៃវិទ្យាស្ថានជាតិអប់រំមានការអោយតំលៃខ្លួនឯងកម្រិតមធ្យមដូចគ្នា ។ ពិន្ទុនៃការអោយតំលៃលើខ្លួនឯងនេះបានមកពីការធ្វើតែសការអោយតំលៃខ្លួនឯង (self-esteem test)[96] (មើលតារាងទី៧) ។

| ភេទ | អ្នកចូលរួម | ពិន្ទុអប្បបរមា | ពិន្ទុអតិបរមា | $\overline{X}$ | SD |
|---|---|---|---|---|---|
| ប្រុស | ៥៤ | ៤៩ | ៧១ | ៦១.៧៥ | ៣.៩៩ |
| ស្រី | ២៣ | ៤៣ | ៧៩ | ៦៣.៧៨ | ៧.៥៥ |
| សរុប | ៧៧ | ៤៣ | ៧៩ | ៦២.៣៦ | ៥.៣៤ |

*តារាងទី៧ : កត្តាភេទ និងការអោយតំលៃខ្លួនឯង*

[96] Profile : Self-Esteem Test , http://www.queendom.com/cgi-bin/tests/transfer.cgi

| ល.រ | ការអោយតំលៃខ្លួនឯង | ពិន្ទុសិក្សា |
|---|---|---|
| 1 | 79 | 7.89 |
| 2 | 73 | 7.71 |
| 3 | 71 | 7.66 |
| 4 | 70 | 7.28 |
| 5 | 70 | 7.52 |
| 6 | 69 | 7.48 |
| 7 | 68 | 7.43 |
| 8 | 68 | 7.32 |
| 9 | 68 | 7.19 |
| 10 | 68 | 7.08 |
| 11 | 68 | 7.49 |
| 12 | 68 | 7.5 |
| 13 | 68 | 7.31 |
| 14 | 67 | 7.17 |
| 15 | 66 | 7.13 |
| 16 | 66 | 7.12 |
| 17 | 65 | 7.04 |
| 18 | 65 | 7.05 |
| 19 | 64 | 6.64 |
| 20 | 64 | 7.35 |
| 21 | 64 | 7.59 |
| 22 | 64 | 7.24 |
| 23 | 63 | 7.28 |
| 24 | 63 | 7.05 |
| 25 | 63 | 7.51 |
| 26 | 63 | 7.23 |
| 27 | 63 | 7.03 |
| 28 | 63 | 6.76 |
| 29 | 63 | 6.91 |
| 30 | 63 | 6.89 |
| 31 | 63 | 6.87 |
| 32 | 63 | 6.98 |
| 33 | 63 | 7.18 |
| 34 | 63 | 6.89 |
| 35 | 63 | 7.1 |
| 36 | 63 | 6.94 |
| 37 | 63 | 7 |
| 38 | 63 | 7.16 |
| 39 | 63 | 7.03 |
| 40 | 63 | 6.78 |
| 41 | 63 | 7 |
| 42 | 63 | 6.99 |
| 43 | 63 | 6.69 |
| 44 | 62 | 6.77 |
| 45 | 62 | 7.03 |
| 46 | 62 | 6.68 |
| 47 | 62 | 6.92 |
| 48 | 62 | 6.68 |
| 49 | 62 | 6.87 |
| 50 | 62 | 6.61 |
| 51 | 62 | 6.72 |
| 52 | 61 | 7.11 |
| 53 | 61 | 7.12 |
| 54 | 61 | 6.9 |
| 55 | 61 | 6.5 |
| 56 | 61 | 6.66 |
| 57 | 61 | 6.52 |
| 58 | 61 | 6.64 |
| 59 | 60 | 6.5 |
| 60 | 60 | 6.43 |
| 61 | 60 | 6.45 |
| 62 | 60 | 6.86 |
| 63 | 60 | 6.49 |
| 64 | 60 | 6.55 |
| 65 | 59 | 6.23 |
| 66 | 59 | 6.72 |
| 67 | 58 | 6.19 |
| 68 | 58 | 6.43 |
| 69 | 58 | 6.15 |
| 70 | 56 | 6.27 |
| 71 | 55 | 6.08 |
| 72 | 54 | 6.17 |
| 73 | 54 | 6.14 |
| 74 | 53 | 6.16 |
| 75 | 49 | 6.07 |
| 76 | 47 | 5.82 |
| 77 | 43 | 5.73 |

*តារាងទី ៨ : ការអោយតំលៃខ្លួនឯង និងពិន្ទុសិក្សា*

នៅក្នុងមាត្រដ្ឋាននៃពិន្ទុនេះ អ្នកឆ្លើយមានពិន្ទុកាន់តែខ្ពស់ ការអោយតំលៃខ្លួនឯងកាន់តែខ្ពស់ តែពិន្ទុទាប ការអោយតំលៃខ្លួនកាន់តែទាបដែរ ។ ទោះយ៉ាងនេះក៏ដោយ ក៏លទ្ធផលស្រាវជ្រាវនេះបង្ហាញថា គរុនិស្សិតផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រពិតជាមានការអោយតំលៃលើខ្លួនឯងក្នុងកម្រិតត្រឹមតែមធ្យមដែលត្រូវយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាលបន្ថែមទៀត ។ លទ្ធផលក៏បានបង្ហាញផងដែរថា និស្សិតដែលមានការឱ្យតំលៃខ្លួនទាបមានចំនួនតិចតួច ទន្ទឹមនឹងនេះ និស្សិតដែលមានការអោយតំលៃខ្លួនឯងខ្ពស់មានចំនួនតិចតួចដែរ រីឯនិស្សិតដែលមានការអោយតំលៃខ្លួនឯងក្នុងកម្រិតមធ្យមមានចំនួនច្រើន ។ លទ្ធផលបែបនេះស្របតាមស្ថានភាពទូទៅដែលបង្ហាញថា អ្នកដែលមានជំនឿលើខ្លួនឯងក្នុងកម្រិតខ្ពស់បំផុត ឬមនុស្សកំពូលមានចំនួនតិច ហើយអ្នកខ្សោយ ឬ អ្នកអន់បំផុតនោះក៏មានចំនួនតិចដែរ ប៉ុន្តែមនុស្សដែលមានលក្ខណៈមធ្យមក្នុងសង្គមមានចំនួនច្រើន ។ លទ្ធផលនេះឆ្លុះបញ្ចាំងអោយឃើញពីធនធានមនុស្សរបស់យើងមិនទាន់ពេញលក្ខណៈនៅឡើយ ។ ដូច្នេះ ដើម្បីអោយសមស្របជាអ្នកដឹកនាំ គ្រូបង្រៀនចាំបាច់ត្រូវមានការអោយតំលៃខ្លួនឯងខ្ពស់ (high self-esteem) ព្រោះគ្រូបង្រៀនជាអ្នកដឹកនាំរបស់សិស្សដែលទាមទានូវលក្ខណៈត្រៀមទុកជាមុននូវគំនិតសុទិដ្ឋិនិយម កំលាំងចិត្តខ្ពស់ មានជំនឿទៅលើសកម្មភាពប្រឹងប្រែងដោយម្ចាស់ការទទួលខុសត្រូវខ្ពស់ ដើម្បីផ្ទេរនិងចែករំលែកបទពិសោធន៍នៃការអោយតំលៃខ្លួនឯងខ្ពស់នេះទៅសិស្ស និងនិស្សិតផ្សេងទៀត ។ ប៉ុន្តែផ្ទុយទៅវិញ បណ្តាចំណុចខាងលើនេះត្រូវបានវាស់ឃើញត្រឹមកម្រិតមធ្យមប៉ុណ្ណោះ ។ លទ្ធផលទាំងនេះបញ្ជាក់អោយដឹងជាមុនថា និស្សិតនឹងអាចបោះបង់វិជ្ជាជីវៈរបស់ខ្លួន ដោយភាគរយកម្រិតខ្ពស់ជាមិនខាន នៅពេលដែលគេចេញទៅបំពេញការងារ [៩៧] ។

– **ចំណាត់ថ្នាក់អាយុ**

លទ្ធផលនៃការស្រាវជ្រាវនេះបានបង្ហាញពីកម្រិតនៃអាយុរបស់អ្នកចូលរួមផងដែរ ។ កម្រិតអាយុរបស់អ្នកចូលរួមត្រូវបានបែងចែកជាពីរកម្រិត ។ កម្រិតអាយុក្រុមទីមួយគឺមានពីអាយុ ២០ ឆ្នាំ ដល់ ២៣ឆ្នាំ និងកម្រិតអាយុប្រភេទទីពីរគឺចាប់ពីអាយុ ២៤ ដល់ ២៧ឆ្នាំ ។ ការបែងចែកអាយុត្រូវបានធ្វើការបែងចែកជាអាយុខ្ពស់បំផុត និងទាបបំផុត ដើម្បីរកឱ្យឃើញនិស្សិតក្រុមអាយុណាមួយមានការឱ្យតំលៃខ្លួនឯងខ្ពស់ជាង ។ លទ្ធផលស្រាវជ្រាវបានបង្ហាញថា អ្នកចូលរួមក្នុងកម្រិតអាយុ ២០-២៣ ឆ្នាំ មានការឱ្យតំលៃខ្លួនឯងកម្រិតមធ្យម $\overline{X}$ = ៦៣.០៥ និងលំងាកស្តង់ដា SD = ៤.៩៨ រីឯនិស្សិតក្នុងប្រភេទអាយុ ២៤ ឆ្នាំ ដល់ ២៧ ឆ្នាំ ក៏មានការអោយតំលៃខ្លួនឯងកម្រិតមធ្យមដែរ $\overline{X}$ = ៥៩.៩៤ និងលំងាកស្តង់ដា SD = ៥.៩៩ ។ យោងតាមលទ្ធផលនេះ យើងឃើញថា អ្នកចូលរួមដែលមានអាយុក្មេងជាងមានការអោយតំលៃខ្លួនឯងខ្ពស់ជាង

[97] Unicef : Self-awareness , 2003, op.cit., p.9

អ្នកមានអាយុច្រើនជាង តែកម្រិតនៃការអោយតំលៃខ្លួនឯងនេះមានភាពខុសគ្នាបន្តិចបន្តួចប៉ុណ្ណោះ (សូមមើលតារាងទី៨ខាងក្រោម) ។ ដូច្នេះ ការឱ្យតំលៃខ្លួនឯងរបស់និស្សិតកម្រិតឧត្តមសិក្សាមិនអាស្រ័យទៅនឹងកម្រិតវ័យអាយុទេ ប៉ុន្តែវាអាចអាស្រ័យទៅនឹងកត្តាផ្សេងទៀត ទើបបណ្តាលឱ្យនិស្សិតកម្រិតវ័យរបស់គរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំមានអាយុក្មេងជាងមានការឱ្យតំលៃខ្ពស់ជាងនិស្សិតដែលមានអាយុចាស់ជាង ។ រឿងនេះអាចពន្យល់បានថា ការសិក្សាវិទ្យាសាស្ត្រ និងគណិតវិទ្យាត្រូវការអាយុវ័យសមស្រប ពោលគឺវ័យកាន់តែចាស់មិនសូវបានផលទេ ។

| កម្រិតអាយុ | $\overline{X}$ | SD |
|---|---|---|
| ២០ - ២៣ | ៥៩.៩៤ | ៥.៩៩ |
| ២៤ - ២៧ | ៦៣.០៥ | ៤.៩៨ |

តារាងទី៩ : ប្រៀបធៀបកម្រិតអាយុ និង ការអោយតំលៃខ្លួនឯង

បន្ថែមលើសនេះទៅទៀត ការស្រាវជ្រាវនេះក៏បង្ហាញកម្រិតនៃការអោយតំលៃខ្លួនឯងរបស់គរុនិស្សិតតាមបណ្តាមុខវិជ្ជានីមួយៗ ដើម្បីរកអោយឃើញនិស្សិតមកពីផ្នែកណាមានការអោយតំលៃខ្លួនឯងខ្ពស់ ។

**- ការអោយតំលៃខ្លួនឯងរបស់និស្សិតមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា**

ដូចបានដឹងហើយថា លទ្ធផលពិន្ទុនៃការអោយតំលៃខ្លួនឯងក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យាមានកំរិតមធ្យម $\overline{X}$ = ៦២.៣៦ ។ ប៉ុន្តែនិស្សិតមកពីមុខវិជ្ជានីមួយៗមានការអោយតំលៃខ្លួនឯងក្នុងកម្រិតមិនដូចគ្នាឡើយ ។ តើនិស្សិតមុខវិជ្ជាណាមានការអោយតំលៃខ្លួនឯងខ្ពស់ជាងគេ ?

| មុខវិជ្ជា | ពិន្ទុអប្បបរមា | ពិន្ទុអតិបរមា | ពិន្ទុមធ្យម | លំងាកស្តង់ដា |
|---|---|---|---|---|
| ជីវវិទ្យា | ៦២.០០ | ៧០.០០ | ៦៥.៤០ | ២.៩១៣ |
| គីមីវិទ្យា | ៤៩.០០ | ៧៥.០០ | ៦៤.១៥ | ៦.១០៣ |
| គណិតវិទ្យា | ៤៧.០០ | ៧០.០០ | ៦១.៨៨ | ៥.២២២ |
| រូបវិទ្យា | ៥៣.០០ | ៦៨.០០ | ៦១.០៨ | ៤.៤៣០ |

តារាងទី.១០ : កំរិតនៃការអោយតំលៃខ្លួនឯងរបស់និស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យា

លទ្ធផលស្រាវជ្រាវបង្ហាញថា គរុនិស្សិតគណិតវិទ្យាមានពិន្ទុមធ្យមនៃការអោយតំលៃខ្លួនឯង $\overline{X}$ = ៦១.៨៨ គរុនិស្សិតជីវវិទ្យាមានពិន្ទុមធ្យមនៃការអោយតំលៃខ្លួនឯង $\overline{X}$ = ៦៥.៤០ គរុនិស្សិតគីមីវិទ្យាមានការអោយតំលៃលើខ្លួនឯង $\overline{X}$ = ៦៤.១៥ និងគរុនិស្សិតរូបវិទ្យាមានការអោយតំលៃខ្លួនឯងក្នុងពិន្ទុមធ្យម

$\overline{X}$ =៦១.០៨ ។ លទ្ធផលនេះសបញ្ជាក់អោយឃើញថា គរុនិស្សិតសិក្សាមុខវិជ្ជាជីវវិទ្យាមានការឱ្យតំលៃខ្លួនឯងខ្ពស់ជាងគេបង្អស់ រីឯគរុនិស្សិតរូបវិទ្យាមានការអោយតំលៃខ្លួនឯងទាបជាងគេ ។ ទោះជាយ៉ាងនេះក៏ដោយ កម្រិតនៃការអោយតំលៃខ្លួនឯងមានមានការខុសគ្នាតិចតួចប៉ុណ្ណោះ (សូមមើលតារាងទី៩ខាងលើ) ។

### ៤.១.គ - ការពេញចិត្តលើមុខជំនាញឯកទេស

លទ្ធផលស្រាវជ្រាវបង្ហាញថា គរុនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំមានការពេញចិត្តខ្លាំងទៅនឹងមុខវិជ្ជាឯងទេសរបស់ពួកគេ ( $\overline{X}$ = ១.៤៤) ដោយមានគរុនិស្សិតចំនួន ៥២ នាក់ ត្រូវជា ៦១.២ ភាគរយពេញចិត្តមុខវិជ្ជាវិជ្ជាជីវៈរបស់គេខ្លាំង និស្សិតចំនួន ៣០ នាក់ ត្រូវជា ៣៥.៣ ភាគរយមានការពេញចិត្តបង្គួរ គរុនិស្សិតចំនួន ២ នាក់ ត្រូវជា ២.៣៥ ភាគរយ មានការពេញចិត្តមធ្យម និងគរុ-និស្សិតចំនួន ១នាក់ ត្រូវជា ១.២ ភាគរយមានការមិនពេញចិត្តចំពោះមុខរបររបស់ខ្លួន ។ ចំពោះការពេញចិត្តមុខវិជ្ជាឯកទេសវិញ លទ្ធផលស្រាវជ្រាវបានបង្ហាញថា គរុនិស្សិតទាំងពីរភេទផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិ អប់រំមានការពេញចិត្តទៅនឹងមុខវិជ្ជាឯកទេសរបស់គេកម្រិតបង្គួរ $\overline{X}$ = ១.៩០ ។

ចំនួនអ្នកពេញចិត្តមុខវិជ្ជាឯកទេស




កម្រិតនៃការពេញចិត្ត

រូបទី៣ : ការពេញចិត្តលើមុខជំនាញឯកទេស

### ៤.១.ឃ - ការពេញចិត្តលើមុខវិជ្ជាសិក្សា

ការស្រាវជ្រាវនេះបានបង្ហាញអំពីកម្រិតពេញចិត្តមុខវិជ្ជានីមួយៗដែលនិស្សិតបានសិក្សា ។ លទ្ធផលបានបង្ហាញថា គរុនិស្សិតមានការពេញចិត្តលើវិធីសាស្ត្របង្រៀនកម្រិតខ្លាំង $\overline{X}$ =១.៩៨ ពេញចិត្តលើកិច្ចតែងការបង្រៀនកម្រិតខ្លាំង $\overline{X}$ =១.៩៣ ពេញចិត្តលើសមត្ថភាពឯកទេសកម្រិតខ្លាំង $\overline{X}$ =១.៩០ ការពេញចិត្តលើការយល់ដឹងពីសីលធម៌វិជ្ជាជីវៈកម្រិតខ្លាំង $\overline{X}$ =១.៨៣ ពេញចិត្តលើសមត្ថភាពផលិតសម្ភារៈឧបទេស

កម្រិតបង្គួរ $\overline{X}$=២.០៣ ពេញចិត្តលើជំនាញបង្រៀនក្នុងថ្នាក់កម្រិតបង្គួរ $\overline{X}$=២.១០ ពេញចិត្តលើជំនាញស្រាវជ្រាវវិទ្យាសាស្ត្រកម្រិតបង្គួរ $\overline{X}$=២.២៣ ពេញចិត្តលើផ្នែករដ្ឋបាលសិក្សាកម្រិតបង្គួរ $\overline{X}$=២.២៥ ពេញចិត្តលើជំនាញតាក់តែងសំណួរវាយតំលៃសិស្សកម្រិតបង្គួរ $\overline{X}$=២.៣៣ ពេញចិត្តលើជំនាញប្រើប្រាស់កំព្យូទ័រកម្រិតបង្គួរ $\overline{X}$=២.៤០ ពេញចិត្តជំនាញខាងមេប្រយោគប្រលងកម្រិតបង្គួរ $\overline{X}$=២.៤៨ ពេញចិត្តជំនាញប្រើប្រាស់បណ្ណាល័យកម្រិតបង្គួរ $\overline{X}$=២.៥៧ និងពេញចិត្តជំនាញបង្រៀនក្នុងបន្ទប់ពិសោធន៍កម្រិតបង្គួរ $\overline{X}$=២.៥៨ ។ សូមបញ្ជាក់ថា កម្រិតពេញចិត្តនៃមុខវិជ្ជាសិក្សាត្រូវបានកំណត់ដោយតម្លៃ = ១ ចំពោះមតិដែលឆ្លើយថាពេញចិត្តខ្លាំង តម្លៃ = ២ ចំពោះមតិដែលឆ្លើយថាពេញចិត្តបង្គួរ តម្លៃ=៣ ចំពោះមតិដែលឆ្លើយថាពេញចិត្តមធ្យម តម្លៃ = ៤ ចំពោះមតិដែលឆ្លើយថាពេញចិត្តតិចតួច និងតម្លៃ = ៥ ចំពោះមតិដែលឆ្លើយថាមិនពេញចិត្តទាល់តែសោះ (សូមមើលតារាងទី១០) ។

បើធ្វើការប្រៀបធៀបទៅនឹងមុខវិជ្ជាសិក្សាទាំងអស់ គរុនិស្សិតមានការពេញចិត្តមុខវិជ្ជាសីលធម៌វិជ្ជាជីវៈជាងគេបំផុត ( $\overline{X}$=១.៨៣ ) បន្ទាប់មកមុខវិជ្ជាឯកទេសរបស់គេ ( $\overline{X}$=១.៩០) ។ ការពេញចិត្តនេះអាចសមស្របទៅតាមស្ថានភាពតំរូវការរបស់វិទ្យាស្ថានជាតិអប់រំ ដែលធ្វើការបណ្តុះបណ្តាលនិស្សិតឱ្យក្លាយទៅជាគ្រូបង្រៀន ដោយត្រូវតែមានសមត្ថភាពខាងវិធីសាស្ត្របង្រៀន ខាងការយល់ដឹងពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងត្រូវមានសមត្ថភាពខាងមុខវិជ្ជាឯកទេសរបស់ខ្លួន ពោលគឺវិទ្យាស្ថានជាតិអប់រំបានបំពាក់បំប៉ននិស្សិតអោយក្លាយទៅជាអ្នកជំនាញអាជីពជាគ្រូបង្រៀន ។ តាមលទ្ធផលស្រាវជ្រាវ យើងឃើញថា ពុំមានមុខវិជ្ជាណាមួយដែលគរុនិស្សិតមានការពេញចិត្តមធ្យម ឬតិចតួចឡើយ ។ នេះបង្ហាញអោយឃើញថាគរុនិស្សិតមិនត្រឹមតែពេញចិត្តលើមុខវិជ្ជាវិធីសាស្ត្រ និងឯកទេសរបស់ខ្លួនប៉ុណ្ណោះទេ តែថែមទាំងមានការពេញចិត្តទៅនឹងមុខវិជ្ជាផ្សេងទៀតដែរ ដោយអាចចាត់ទុកថា គរុនិស្សិតមានចំណេះដឹងទូទៅទូលំទូលាយ ។

ទោះជាយ៉ាងនេះក៏ដោយ លទ្ធផលស្រាវជ្រាវបង្ហាញថា ជំនាញខាងការប្រើប្រាស់កំព្យូទ័រ ជំនាញប្រើប្រាស់បណ្ណាល័យ និងជំនាញធ្វើពិសោធន៍នៅក្នុងបន្ទប់ពិសោធន៍ឈរនៅលំដាប់ចុងក្រោយគេ ដែលវិទ្យាស្ថានជាតិអប់រំត្រូវតែជំរុញ និងលើកទឹកចិត្តនិស្សិតអោយខិតខំធ្វើការស្រាវជ្រាវដោយខ្លួនឯងនៅបណ្ណាល័យ និងយកចិត្តទុកដាក់បង្កើនការប្រើប្រាស់កំព្យូទ័រដល់និស្សិត ព្រមទាំងផ្តល់ជំនាញខាងការធ្វើពិសោធអោយបានច្រើនបន្ថែមទៀតសំរាប់បង្កើនគុណភាពបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ ។

| ល.រ | អថេរនៃការពេញចិត្ត | អ្នកចូលរួម | $\overline{X}$ | SD |
|---|---|---|---|---|
| ១ | ការយល់ដឹងអំពីសីលធម៌វិជ្ជាជីវៈ | 77 | 1.83 | .801 |
| ២ | សមត្ថភាពឯកទេស | 77 | 1.90 | .814 |
| ៣ | សមត្ថភាពខាងកិច្ចតែងការបង្រៀន | 77 | 1.93 | .766 |
| ៤ | សមត្ថភាពវិធីសាស្ត្របង្រៀន | 77 | 1.98 | .769 |
| ៥ | សមត្ថភាពផលិតសម្ភារឧបទេស | 77 | 2.03 | .768 |
| ៦ | ជំនាញបង្រៀនវិទ្យាសាស្ត្រ ឬគណិតក្នុងថ្នាក់ | 77 | 2.10 | .882 |
| ៧ | ជំនាញស្រាវជ្រាវវិទ្យាសាស្ត្រ | 77 | 2.23 | .856 |
| ៨ | ការយល់ដឹងផ្នែករដ្ឋបាលសិក្សា | 77 | 2.25 | .919 |
| ៩ | ជំនាញតាក់តែងសំណួរវាយតំលៃសិស្ស | 77 | 2.33 | .897 |
| ១០ | ជំនាញប្រើប្រាស់កុំព្យូទ័រ | 77 | 2.40 | .949 |
| ១១ | ជំនាញខាងធ្វើជាមេប្រយោគប្រលង | 77 | 2.48 | .912 |
| ១២ | ជំនាញប្រើប្រាស់បណ្ណាល័យ | 77 | 2.57 | 1.19 |
| ១៣ | ជំនាញបង្រៀនពិសោធន៍ក្នុងមន្ទីរពិសោធន៍ | 77 | 2.58 | 1.01 |

**ពិន្ទុ : កំរិតពេញចិត្ត**

១ = ពេញចិត្តខ្លាំង

២ = ពេញចិត្តបង្គួរ

៣ = ពេញចិត្តមធ្យម

៤ = ពេញចិត្តតិចតួច

៥ = មិនពេញចិត្ត

*តារាងទី ១១ : ការពេញចិត្តចំពោះមុខជំនាញរបស់និស្សិត*

## ៤.១.១ - សមិទ្ធផលសិក្សា

ការស្រាវជ្រាវនេះបង្ហាញថា មធ្យមនៃពិន្ទុដែលនិស្សិតទទួលបានពីការសិក្សារបស់ពួកគេគឺមានកម្រិតបង្គួរ $\overline{X}$ = ៦.៨៧ លំងាកស្តង់ដា SD = .៤៥ មេដ្យានពិន្ទុ ៦.៩២ ដោយកម្រិតពិន្ទុពី១ដល់៤.៩ជាពិន្ទុខ្សោយ ពិន្ទុ៥ដល់៦.៤៩ជាពិន្ទុមធ្យម និងពិន្ទុចាប់ពី៦.៥ដល់១០ជាពិន្ទុស្ថិតក្នុងកម្រិតល្អបង្គួរ និងល្អប្រសើរ ។ យោងតាមលទ្ធផលស្រាវជ្រាវបានបង្ហាញថា និស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំទទួលបានពិន្ទុល្អបង្គួរ ។ ជាមួយគ្នានេះផងដែរ លទ្ធផលបង្ហាញថា និស្សិតភេទស្រីមានពិន្ទុមធ្យមខ្ពស់ជាងនិស្សិតភេទប្រុស ។ មធ្យមនៃពិន្ទុទទួលបានពីសមិទ្ធផលសិក្សារបស់និស្សិតភេទស្រី $\overline{X}$ = ៧.០២ និងនិស្សិតភេទប្រុស $\overline{X}$ = ៦.៨១ ។ លទ្ធផលបង្ហាញថា និស្សិតភេទស្រីមានពិន្ទុល្អជាងនិស្សិតភេទប្រុស ដែលមានន័យថានិស្សិតស្រីពូកែជាងនិស្សិតប្រុសសំរាប់មុខវិជ្ជាសិក្សាផ្នែកវិទ្យាសាស្ត្រនិងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ។

### សមិទ្ធផលសិក្សាលើមុខវិជ្ជានីមួយៗ

លទ្ធផលបង្ហាញថា មធ្យមពិន្ទុសិក្សារបស់គរុនិស្សិតផ្នែកគណិតវិទ្យា $\overline{X}$ = ៦.៨២ គរុនិស្សិតគីមីវិទ្យា $\overline{X}$ = ៧.០៦ គរុនិស្សិតជីវវិទ្យា $\overline{X}$ = ៧.១៩ និងគរុនិស្សិតរូបវិទ្យា $\overline{X}$ =៦.៦៣ ។ នេះមានន័យថា គរុនិស្សិតជីវវិទ្យាមានពិន្ទុសិក្សាខ្ពស់ជាងនិស្សិតក្នុងមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រផ្សេងទៀត រីឯគរុ-និស្សិតរូបវិទ្យាមានពិន្ទុសិក្សាទាបជាងគេងបង្អស់ ។ ទោះជាមានកំរិតពិន្ទុខុសគ្នាបែបនេះក៏ដោយ ក៏កម្រិតពិន្ទុសិក្សារបស់និស្សិតលើមុខវិជ្ជាទាំងនេះមានកំរិតខុសគ្នាតែបន្តិចបន្តួចប៉ុណ្ណោះ ហើយគរុនិស្សិតទាំងនោះសុទ្ធតែមានពិន្ទុសិក្សាកម្រិតល្អបង្គួរប្រហែលគ្នា ។

### សមិទ្ធផលសិក្សា និងអាយុរបស់គរុនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យា

លទ្ធផលបង្ហាញថា និស្សិតដែលមានអាយុពី២០ទៅ២៣ឆ្នាំមានពិន្ទុសិក្សាក្នុងកម្រិត $\overline{X}$ = ៦.៩៣ នៅខណៈពេលនិស្សិតអាយុ២៤ឆ្នាំដល់២៧ឆ្នាំមានមធ្យមនៃពិន្ទុសិក្សាកម្រិត $\overline{X}$ = ៦.៦៥ ។ យោងតាមលទ្ធផលពិន្ទុសិក្សានេះ គរុនិស្សិតដែលមានអាយុតិចជាងមានពិន្ទុសិក្សារបស់គេខ្ពស់ជាងគរុនិស្សិតមានអាយុច្រើនជាង ប៉ុន្តែកម្រិតខុសគ្នានេះមានភាពល្អៀងគ្នាបន្តិចបន្តួចប៉ុណ្ណោះ ។ ការស្រាវជ្រាវនេះរកឃើញថា និស្សិតវ័យក្មេងផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យាមានពិន្ទុសិក្សាខ្ពស់ជាងនិស្សិតដែលមានអាយុច្រើនជាង ដែលនេះមានន័យថា និស្សិតវ័យក្មេងរៀនពូកែជាងនិស្សិតវ័យចាស់ជាង ។ ខាងក្រោមគឺជាតារាងដែលបង្ហាញពីកំរិតសមត្ថភាពដែលនិស្សិតមានអារម្មណ៍ថាខ្លួនគេបានទទួល បន្ទាប់ពីរយៈពេលសិក្សារបស់គេនៅវិទ្យាស្ថានជាតិអប់រំ (សូមមើលតារាងទី ១២ ខាងក្រោម) ។

| សមត្ថភាពការយល់ដឹង | អ្នកចូលរួម | $\overline{X}$ | SD |
|---|---|---|---|
| សមត្ថភាពឯកទេសវិទ្យាសាស្ត្រ | 77 | 1.75 | .517 |
| ការផលិតសម្ភារឧបទេស | 77 | 1.71 | .625 |
| វិធីសាស្ត្របង្រៀនមុខវិជ្ជាឯកទេស | 77 | 1.84 | .540 |
| សីលធម៌វិជ្ជាជីវៈ | 77 | 1.51 | .719 |
| ជំនាញផ្នែករដ្ឋបាលសិក្សា | 77 | 2.03 | .760 |
| ជំនាញការធ្វើកិច្ចតែងការបង្រៀន | 77 | 1.68 | .572 |
| ជំនាញប្រលង | 77 | 2.01 | .752 |
| ជំនាញតាក់តែងសំណួរវាយតំលៃសិស្ស | 77 | 2.08 | .757 |
| ជំនាញស្រាវជ្រាវវិទ្យាសាស្ត្រ | 77 | 2.03 | .688 |
| ជំនាញបង្រៀនពិសោធន៍ក្នុងថ្នាក់ | 77 | 2.01 | .678 |
| ជំនាញបង្រៀនពិសោធន៍ក្នុងមន្ទីរពិសោធន៍ | 77 | 2.61 | 1.03 |
| ជំនាញប្រើប្រាស់កុំព្យូទ័រ | 77 | 2.22 | .853 |
| បណ្តាមតិផ្សេងទៀត | 77 | 3.17 | 1.40 |

ស្កេល : អក្សរកាត់ : ពាក្យពេញ

១ = ទ.ល : ទទួលបានល្អណាស់

២ = ទ.ម : ទទួលបានមធ្យម

៣ = ទ.ត : ទទួលបានតិចតួច

៤ = ម.ដ : មិនដឹងច្បាស់ថាបានទទួល

៥ = ម.ទ : មិនទទួលបានសោះ

*តារាងទី១២ : កម្រិតសមត្ថភាពដែលនិស្សិតទទួលបាន*

តាមរយៈពិន្ទុសិក្សា និងពិន្ទុដែលនិស្សិតយល់ថាខ្លួនបានទទួលលើមុខវិជ្ជាសិក្សារបស់គេបានបង្ហាញថា ពិន្ទុមធ្យមសិក្សារបស់អ្នកចូលរួមមានកំរិតបង្គួរ ខណៈពេលពិន្ទុដែលគេយល់ថាបានទទួលពីការសិក្សារបស់គេ មានកំរិតបង្គួរដូចគ្នា ។ ដូច្នេះ បើធៀបពិន្ទុនៃការសិក្សារបស់គេជាមួយពិន្ទុដែលគេបានឆ្លើយតបទៅនឹងមុខ

វិជ្ជាដែលគេយល់ថាបានទទួលអាចជាពិន្ទុគួរអោយជឿ និងទុកចិត្តបាន ព្រោះវាមានកំរិតប្រហាក់ប្រហែលគ្នាបំផុត ។ តារាងខាងក្រោមបង្ហាញសង្ខេបពីលទ្ធផលនៃអថេរនីមួយៗតាមរយៈស្ថិតិពណ៌នា ។

| អថេរ | អប្បបរមា | អតិបរមា | $\overline{X}$ | SD |
|---|---|---|---|---|
| អាយុ | ២០ | ២៧ | ២២.៩៤ | ១.១២២ |
| ភេទ / ប្រុស | ៥៤ | ៥៤ | ៥៤ | |
| ស្រី | ២៣ | ២៣ | ២៣ | |
| កម្រិតអប់រំ | បរិញ្ញាបត្រ ១ | បរិញ្ញាបត្រ ១ | បរិញ្ញាបត្រ ១ | |
| ការអោយតំលៃខ្លួនឯង | ៤៣ | ៧៩ | ៦២.៣៦៤ | ៥.៣៤០ |
| សមិទ្ធផលសិក្សា | ៥.៧៣ | ៧.៨៩ | ៦.៨៧៥ | .៤៥៧ |
| ការពេញចិត្តការសិក្សា | ៣.០០ | ៥.០០ | ៤.៥៨ | .៥៤៥ |

*តារាងទី១៣ : លទ្ធផលនៃអថេរការអោយតំលៃខ្លួនឯង លក្ខណៈពិសេសផ្ទាល់ខ្លួន ការពេញចិត្តការសិក្សា និងសមិទ្ធផលសិក្សា*

### ៤.១.៦ - លទ្ធផលបទសម្ភាសន៍

បន្ថែមលើការបំពេញកម្រងសំណួរ ការស្រាវជ្រាវនេះបានធ្វើសម្ភាសន៍ទៅលើគរុនិស្សិតផ្នែក វិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំចំនួន ១១ នាក់ថែមទៀត ក្នុងគោលបំណងរកអោយឃើញពីហេតុផលអប់រំនៅក្នុងគ្រួសារ និងសាលារៀនដែលមានការជះឥទ្ធិពលដល់ការអោយតំលៃខ្លួនឯងរបស់គរុនិស្សិត ។ លទ្ធផលនៃការសម្ភាសន៍និស្សិតដែលមានស្នាដៃល្អក្នុងការផលិតសម្ភារៈឧបទេសនេះបានបង្ហាញពីរបៀបអប់រំដែលមានខ្លឹមសារសំខាន់ៗដូចខាងក្រោម :

របៀបអប់រំរបស់ឪពុកម្តាយគរុនិស្សិត :

គរុនិស្សិតបានបញ្ជាក់ថា ឪពុកម្តាយរបស់គេបានផ្តល់ការលើកទឹកចិត្ត និងទូន្មានប្រៀនប្រដៅពួកគេអោយក្លាយទៅជាកូនល្អតាមរបៀបអប់រំផ្អែកលើគំនិតប្រពៃណីខ្មែរ និងព្រះពុទ្ធសាសនាដែលជំរុញអោយកូនខ្លួនមានចិត្តស្អាតស្អំ និងទូន្មានពួកគេអោយមានសីលធម៌ល្អ ។ ឪពុកម្តាយភាគច្រើនមានការការសរសើរការលើកទឹកចិត្ត និងស្រលាញ់ពួកគេ តែមិនសូវស្តាប់ហេតុផលរបស់កូនខ្លួនដោយសំអាងថា ពួកគេខ្វះបទពិសោធន៍ ប៉ុន្តែ ពួកគាត់បែរជាស្តាប់ហេតុផលនៅពេលដែលកូនរបស់ពួកពួកគាត់មានចំណេះដឹងខ្ពស់ ។ គរុនិស្សិតបានបញ្ជាក់ថា ពួកគេទទួលបានការលើកទឹកចិត្ត និងទទួលបានសេចក្តីស្រលាញ់ពីឪពុកម្តាយរបស់ខ្លួន

ប៉ុន្តែឪពុកម្តាយរបស់និស្សិតកម្រសរសើរកូនរបស់ខ្លួនទៅចំពោះមុខពួកគេណាស់ តែចូលចិត្តសរសើរក្រោយខ្នងទៅវិញ ។ គរុនិស្សិតភាគច្រើនមានការពេញចិត្តទៅនឹងវិធីអប់រំក្នុងគ្រួសាររបស់ឪពុកម្តាយរបស់គេ ។ គរុនិស្សិតស្ទើរតែទាំងអស់បានផ្តល់ចំលើយព្រមគ្នាថា ឪពុកម្តាយរបស់គេបានជំរុញឱ្យពួកគេខិតខំរៀនសូត្រចាប់តាំងពីតូចមក ហើយពួកគេខ្លះទៀតបង្រៀនកូនដោយចែកការងារអោយពួកគេរៀនធ្វើ និងផ្តល់ឱកាសអោយចេះទទួលខុសត្រូវលើការងារ ។ សរុបមក ឪពុកម្តាយរបស់គរុនិស្សិតបានផ្តល់ការលើកទឹកចិត្ត ការស្រលាញ់ សេចក្តីថ្នាក់ថ្នម ការគាំទ្រផ្លូវចិត្ត និងការទទួលយកគំនិតតិចតួចពីកូនរបស់ពួកគាត់ ។

ការអប់រំនៅក្នុងសាលារៀន :

លទ្ធផលស្រាវជ្រាវបានបង្ហាញថា គរុនិស្សិភាគច្រើនមានពេញចិត្តទៅនឹងកម្មវិធីសិក្សារៀនច្រើនម៉ោងនៅក្នុងថ្នាក់ ពេញចិត្តទៅលើវិន័យ ការវាយតំលៃត្រឹមត្រូវ និងសម្ភារសិក្សារបស់វិទ្យាស្ថានជាតិអប់រំ ។ គរុនិស្សិតបានបញ្ជាក់ថា ពួកគេមានការពេញចិត្តទៅនឹងរបៀបរៀនបែបអនុវត្ត ដូចជាការអោយនិស្សិតបង្ហាញស្នាដៃស្រាវជ្រាវ និងចុះធ្វើកម្មសិក្សារបង្រៀន ។ គរុនិស្សិតភាគច្រើនមានហេតុផលច្បាស់លាស់ និងមានការត្រៀមទុកជាមុនចំពោះបរាជ័យខាងមុខ ព្រមទាំងមើលឃើញពីគោលបំណងជាក់លាក់ចំពោះមុខរបររបស់គេ ។ គរុនិស្សិតភាគច្រើនបានឆ្លើយតបថា ហេតុផលសំខាន់ដែលពួកគេមានការពេញចិត្តមុខរបរបស់ខ្លួនគឺដោយសារមកពីខ្លួនគេមានចិត្តចង់ដោយផ្ទាល់ និងមានការតាំងចិត្តចង់សិក្សាតាំងពីតូច (និស្ស័យ) និងហេតុផលទីពីរដោយសារមកពីការលើកទឹកចិត្តរបស់ឪពុកម្តាយចាប់តាំងពីតូចរហូតមក និងហេតុផលមួយទៀតគឺការមើលឃើញពីបរិយាកាសអប់រំរបស់វិទ្យាស្ថាន ដូចជា គោលបំណងអនាគតចំពោះការងារ កម្មវិធីសិក្សា វិធីបង្រៀនរបស់គ្រូ វិន័យរបស់សាលា និងសម្ភារៈសិក្សា និងហេតុផលបន្ទាប់បន្សំផ្សេងទៀត ដូចជា ពួកគេមានចិត្តគំនិតចង់ជួយសង្គម និងមើលឃើញពីតំលៃចំណេះដឹង ។ ទោះជាយ៉ាងនេះក៏ដោយ គរុនិស្សិតមានការបារម្ភទៅលើកម្រិតសមត្ថភាពរបស់គ្រូរបស់ពួកគេពីបញ្ហាពុករលួយដែលកើតមានឡើងក្នុងពេលប្រលងចេញទៅបម្រើការងារ និងបារម្ភពីប្រាក់ឧបត្ថម្ភសំរាប់មុខរបររបស់ពួកគេដែលទាំងនេះនៅតែមានឥទ្ធិពលក្នុងគំនិតព្រួយបារម្ភរបស់គេ [៩៧] ។

បកស្រាយ : ទឹកចិត្តស្រលាញ់របស់ឪពុកម្តាយដែលតែងតែផ្តល់ដល់គរុនិស្សិតជាប្រចាំ បានជួយឱ្យពួកគេមានអារម្មណ៍ថា ម្តាយឪពុករបស់គេចូលចិត្ត និងស្រលាញ់រូបគេ ទោះបីរបៀបអប់រំរបស់គេមានវិធីផ្សេងគ្នាខ្លះក៏ដោយ ។ សេចក្តីស្រលាញ់របស់ឪពុកម្តាយបែបនេះជាជំនួយដល់កំលាំងចិត្ត និងបណ្តុះការឱ្យ

---

[97] បទសម្ភាសន៍ជាមួយគរុនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យា

តំលៃខ្លួនដល់កូនរបស់ពួកគាត់ ។ ទោះជាយ៉ាងនេះក៏ដោយ ការស្តាប់ហេតុផលរបស់កូនខ្លួននៅមានកម្រិតទាបនៅឡើយ ដែលការនេះអាចមានការប៉ះពាល់ដល់ជំនឿចិត្តរបស់កូនខ្លួន ប៉ុន្តែពួកគេមានភាពប្រសើរឡើងវិញ នៅពេលណាពួកគេមានចំណេះដឹងខ្ពស់ ។ អារម្មណ៍ទទួលបានសេចក្តីស្រលាញ់ និងការទទួលបានការអោយតំលៃពីឪពុកម្តាយបែបនេះ ពិតជាជួយបណ្តុះស្មារតីនៃការអោយតំលៃខ្លួនឯងដល់គរុនិស្សិត ។ រីឯរបៀបអប់រំនៅវិទ្យាស្ថានជាតិអប់រំវិញ ការផ្តល់អោយគរុនិស្សិតអនុវត្ត និងបង្ហាញស្នាដៃវិទ្យាសាស្ត្រ និងការចុះកម្មសិក្សាបង្រៀនជាការជួយជំរុញស្មារតីឯករាជ្យក្នុងការសិក្សាស្រាវជ្រាវរបស់ពួកគេ ។ ការផ្តល់នូវការលើកទឹកចិត្តពីសំណាក់គ្រូបង្រៀន និងវាយតំលៃមានភាពយុត្តិធម៌ជាការជួយជំរុញទឹកចិត្តគរុនិស្សិតឱ្យមានកំលាំងចិត្តចង់សិក្សាកាន់តែខ្លាំងឡើង ។ រីឯការផ្តល់អោយនិស្សិតមើលឃើញពីគោលបំណងជាក់លាក់ក្នុងមុខវិជ្ជាជីវៈរបស់គេ ក៏ជាការផ្តល់ជំនឿផ្លូវចិត្ត និងជួយអោយគេមានការជឿជាក់ចំពោះតំលៃសិក្សារបស់គេជាពិសេសជួយអោយគរុនិស្សិតមើលឃើញតំលៃដែលកើតពីសមត្ថភាព និងការខិតខំប្រឹងប្រែងចំពោះស្នាដៃរបស់គេ ដែលនេះជាការផ្តល់កំលាំងចិត្ត និងលើកតម្កើងតំលៃខ្លួនឯងរបស់គេ ។

### ៤.២ - មេគុណទំនាក់ទំនងរវាងអថេរ ( Regression )

ការស្រាវជ្រាវនេះនឹងបង្ហាញពីទំនាក់ទំនងរវាងកត្តាលក្ខណៈពិសេសផ្ទាល់ខ្លួនជាមួយការអោយតំលៃខ្លួនឯង ទំនាក់ទំនងរវាងការអោយតំលៃលើខ្លួនឯងជាមួយការពេញចិត្តនឹងការសិក្សា ទំនាក់ទំនងរវាងការអោយតំលៃលើខ្លួនឯងជាមួយសមិទ្ធផលសិក្សា និងទំនាក់ទំនងការពេញចិត្តនឹងការសិក្សាជាមួយសមិទ្ធផលសិក្សា ។ លទ្ធផលសង្ខេបពីសហទំនាក់ទំនងនឹងបង្ហាញក្នុងតារាងទី ១៤ ។

| អថេរ | សមិទ្ធផលសិក្សា | ការពេញចិត្តនឹងការសិក្សា | អាយុ |
|---|---|---|---|
| **ការអោយតំលៃខ្លួនឯង** | .៨៨៧ *** | .១៦៤ | -.៤១៦ ** |
| **សមិទ្ធផលសិក្សា** | —— | .៩៦០ *** | —— |

*តារាងទី១៤ : មេគុណទំនាក់ទំនងនៃអថេរឯករាជ្យ និងមិនឯករាជ្យ*

តារាងខាងលើបញ្ជាក់យ៉ាងច្បាស់ថា ការអោយតំលៃខ្លួនឯងខ្ពស់នាំអោយមានការតស៊ូស្វិតស្វាញនាំទៅដល់លទ្ធផលសិក្សាខ្ពស់ ។ ហើយម្យ៉ាងវិញទៀត សមិទ្ធផលសិក្សាខ្ពស់ក៏ជាមូលហេតុបណ្តាលអោយមានការពេញចិត្តខ្លាំងចំពោះការសិក្សាផងដែរ ។

**៤.២.ក - លក្ខណៈពិសេសផ្ទាល់ខ្លួន និង ការអោយតំលៃខ្លួនឯង**

*កត្តាអាយុ និង ការអោយតំលៃខ្លួនឯង*

លទ្ធផលស្រាវជ្រាវបានបង្ហាញថា គរុនិស្សិតដែលមានអាយុច្រើនជាងមានការឱ្យតំលៃខ្លួនឯងទាបជាងគរុនិស្សិតដែលមានអាយុតិចជាង តែកម្រិតខុសគ្នាមានសភាពតិចតួចប៉ុណ្ណោះ ។ គរុនិស្សិតអាយុពី ២០-២៣ឆ្នាំមានការអោយតំលៃលើខ្លួនឯងកម្រិតមធ្យម $\overline{X}$= ៦៣.០៥ រីឯគរុនិស្សិតអាយុពី ២៤-២៧ ឆ្នាំមានការអោយតំលៃខ្លួនឯងក្នុងកម្រិតមធ្យម $\overline{X}$ = ៥៩.៩៤ ។ ទោះជាយ៉ាងនេះក៏ដោយ គរុនិស្សិតកម្រិតឧត្តមសិក្សាម្នាក់ៗមានការអោយតំលៃខ្លួនឯងមិនមានកំរិតដូចគ្នាទេ ។ អ្នកអោយតំលៃលើខ្លួនឯងកម្រិតខ្ពស់មានចំនួនតិច ហើយគរុនិស្សិតមានការឱ្យតំលៃខ្លួនឯងក្រោមកម្រិតមធ្យមក៏មានចំនួនតិចតួចដែរ ប៉ុន្តែគរុ-និស្សិតដែលមានការអោយតំលៃខ្លួនឯងកម្រិតមធ្យមមានចំនួនច្រើន ។ ចំពោះលទ្ធផលសហទំនាក់ទំនងរវាងអាយុ និងការអោយតំលៃខ្លួនឯង ការស្រាវជ្រាវនេះបានបង្ហាញថា អាយុ និងការអោយតំលៃលើខ្លួនឯងមានទំនាក់ទំនងនឹងគ្នាអវិជ្ជមាន (r = -.៤១៦) ។ នេះមានន័យថា ចំពោះការអោយតំលៃខ្លួនឯងសំរាប់គរុនិស្សិតពីវ័យ ២០ ឆ្នាំ ដល់ ២៧ ឆ្នាំ នៅឧត្តមសិក្សា ការអោយតំលៃខ្លួនឯងមិនអាស្រ័យទៅលើអាយុទេ វាអាចអាស្រ័យទៅនឹងកត្តាផ្សេងទៀតជាច្រើន ព្រោះគរុនិស្សិតដែលមានអាយុក្មេងជាងក៏មានការអោយតំលៃខ្លួនឯងខ្ពស់ជាងគរុនិស្សិតដែលមានអាយុចាស់ជាង ។




*រូបទី៤ : ទំនាក់ទំនងអាយុ និងការអោយតំលៃខ្លួនឯង*

### កត្តាភេទ និង ការអោយតំលៃខ្លួនឯង

លទ្ធផលស្រាវជ្រាវបង្ហាញថា គរុនិស្សិតភេទស្រីមានការអោយតំលៃខ្លួនឯងប្រហាក់ប្រហែលទៅនឹងគរុនិស្សិតភេទប្រុស ។ គរុនិស្សិតភេទប្រុសមានការអោយតំលៃខ្លួនឯងក្នុងកម្រិត $\overline{X}$ = ៦១.៧៥ លំងាកស្តង់ដា SD=៣.៩៩ រីឯគរុនិស្សិតភេទស្រីមានការឱ្យតំលៃខ្លួនឯងក្នុងកម្រិត $\overline{X}$ = ៦៣.៧៨ លំងាកស្តង់ដា SD=៧.៥៥ ។ លទ្ធផលនេះអាចចាត់ទុកបានថា ការឱ្យតំលៃខ្លួនឯងរបស់គរុនិស្សិតភេទប្រុស និងគរុនិស្សិតភេទស្រីមានកម្រិតប្រហាក់ប្រហែលគ្នា ព្រោះកម្រិតទូរលេខនៃលទ្ធផលនេះខុសគ្នាតែបន្តិចបន្តួចបំផុត ។ ចំពោះលទ្ធផលសហទំនាក់ទំនងវិញ ការស្រាវជ្រាវបានបង្ហាញថា គរុនិស្សិតភេទស្រីមានទំនាក់ទំនងជាមួយការឱ្យតំលៃខ្លួនឯងវិជ្ជមាន ( r = .៥៨៣ ) នៅពេលដែលគរុនិស្សិតភេទប្រុសមានទំនាក់ទំនងជាមួយការអោយតំលៃខ្លួនឯង ( r=.២៦១ ) ។ នេះមានន័យថា គរុនិស្សិតភេទស្រីមានទំនាក់ទំនងការអោយតំលៃខ្លួនឯងវិជ្ជមានជាងគរុនិស្សិតភេទប្រុស ។

### ទំនាក់ទំនងកម្រិតអប់រំ និង ការអោយតំលៃខ្លួនឯង

កម្រិតអប់រំ "កំរិតវប្បធម " នៅក្នុងការស្រាវជ្រាវនេះមានកម្រិតស្មើគ្នា ព្រោះអ្នកចូលរួមឆ្លើយកម្រងសំណួរនៅក្នុងការស្រាវជ្រាវនេះសុទ្ធតែជាគរុនិស្សិតកំរិតបរិញ្ញាបត្រ័បូក១ទាំងអស់គ្នា។ លទ្ធផលស្រាវជ្រាវរកឃើញថា គរុនិស្សិតមានការអោយតំលៃលើខ្លួនឯងកម្រិតមធ្យម $\overline{X}$ = ៦២.៣៦ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏មានគរុនិស្សិតខ្លះមានការឱ្យតំលៃខ្លួនឯងក្រោមមធ្យមរហូតធ្លាក់មកដល់កម្រិត៤៣ ប៉ុន្តែក៏មានគរុនិស្សិតខ្លះទៀតមានការអោយតំលៃខ្លួនឯងខ្ពស់រហូតដល់កម្រិត៧៩ ដោយពិន្ទុនៃការអោយតំលៃខ្លួនត្រូវបានក្រិតពីចំនុចសូន្យដល់ ១០០ ។ លទ្ធផលនេះសរបញ្ជាក់អោយឃើញថា ទោះជាក្រុមគោលដៅស្រាវជ្រាវមានចំណេះដឹងកម្រិតខ្ពស់ក៏ដោយ ក៏ពួកគេនៅតែមានការអោយតំលៃខ្លួនឯងនៅកម្រិតមធ្យមដែលត្រូវការពង្រឹង និងយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីបណ្តុះនូវអារម្មណ៍ជឿជាក់លើខ្លួនឯង និងការអោយតំលៃលើខ្លួនឯងដល់សិស្ស និងនិស្សិតខ្មែរ ។ ដូច្នេះ ការអោយតំលៃខ្លួនឯងអាស្រ័យលើកត្តាជាច្រើនផ្សេងទៀត បន្ថែមពីលើកត្តាអប់រំ ។ ការអោយតំលៃខ្លួនឯងមិនអាស្រ័យតែលើការអប់រំប៉ុណ្ណោះទេ តែថែមទាំងអាស្រ័យលើកត្តាជាច្រើនផ្សេងទៀត ។ ទោះជាយ៉ាងនេះក៏ដោយ តាមការស្រាវជ្រាវឯកសារទ្រឹស្តី ការអោយតំលៃខ្លួនឯងមានទំនាក់ទំនងទៅនឹងកម្រិតនៃការអប់រំក្នុងសាលារៀន កត្តាគ្រួសារ និងឥទ្ធិពលរបស់មជ្ឈដ្ឋានសង្គមផង ។

ជាសង្ខេបអំពីទំនាក់ទំនងរវាងកត្តាកល្លណៈពិសេសផ្ទាល់ខ្លួនជាមួយការអោយតំលៃខ្លួនឯង យើងឃើញថា អាយុមានទំនាក់ទំនងអវិជ្ជមានជាមួយនឹងការអោយតំលៃខ្លួនឯង ហើយគរុនិស្សិតភេទស្រីមានការអោយតំលៃខ្លួនឯងប្រហាក់ប្រហែលនឹងគរុនិស្សិតភេទប្រុស ហើយនិស្សិតដែលមានកម្រិតអប់រំថ្នាក់បរិញ្ញា

ប័ត្រមានការឱ្យតំលៃខ្លួនឯងកម្រិតមធ្យម ។ គរុនិស្សិតភេទស្រីមានសហទំនាក់ទំនងវិជ្ជមានជាងគរុនិស្សិតភេទប្រុស ចំពោះការអោយតំលៃខ្លួនឯងបើធៀបទៅនឹងអាយុរបស់ពួកគេ ។

### ៤.២.១ - ទំនាក់ទំនងការអោយតំលៃខ្លួនឯង និង សមិទ្ធផលសិក្សា

លទ្ធផលស្រាវជ្រាវបង្ហាញថា ការអោយតំលៃខ្លួនឯងមានទំនាក់ទំនងវិជ្ជមានជាមួយសមិទ្ធផលសិក្សា (r = .887) ។ ពិន្ទុមធ្យមនៃការអោយតំលៃខ្លួនឯងស្ថិតក្នុងកម្រិតមធ្យម ($\overline{X}$ = ៦២.៣៦) រីឯមធ្យមនៃសមិទ្ធផលសិក្សាមានកម្រិតបង្គួរ ($\overline{X}$ = ៦.៨៧ ) ។ នេះមានន័យថា គរុនិស្សិតដែលមានការឱ្យតំលៃខ្លួនឯងកាន់តែខ្ពស់មានការទទួលបានសមិទ្ធផលខ្ពស់ជាងគរុនិស្សិតដែលមានការអោយតំលៃខ្លួនឯងទាប នៅក្នុងការសិក្សារបស់គេ ។ គរុនិស្សិតដែលមានការអោយតំលៃខ្លួនឯងខ្ពស់តែងតែមានភាពម្ចាស់ការក្នុងការសិក្សា និងមានអារម្មណ៍ជឿជាក់លើសមត្ថភាពសិក្សារបស់ខ្លួន ។ នៅពេលណាគរុនិស្សិតមានភាពម្ចាស់ការ និងមានការជឿជាក់ក្នុងការសិក្សា នោះពួកគេនឹងទទួលបានលទ្ធផលសិក្សាបានកាន់តែប្រសើរឡើង ។




*រូបទី៥ ៖ ការអោយតំលៃខ្លួនឯង និងសមិទ្ធផលសិក្សា*

ទោះជាយ៉ាងនេះក៏ដោយ តាមលទ្ធផលស្រាវជ្រាវបង្ហាញថា គរុនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យាសំរាប់មុខវិជ្ជានីមួយៗមានការអោយតំលៃលើខ្លួនឯងមិនដូចគ្នាទេ រីឯទំនាក់ទំនងនៃការអោយតំលៃខ្លួនឯង និងពិន្ទុសិក្សារបស់និស្សិតលើផ្នែកទាំងនេះក៏មានលក្ខណៈមិនដូចគ្នាដែរ ។ លទ្ធផលស្រាវជ្រាវបង្ហាញថា ការអោយតំលៃខ្លួនឯងរបស់គរុនិស្សិតផ្នែកគីមីវិទ្យា គណិតវិទ្យា រូបវិទ្យា និងជីវវិទ្យាមានទំនាក់ទំនងវិជ្ជមានជាមួយពិន្ទុសិក្សារបស់គេផ្សេងៗគ្នា ។

### ៤.២.១.១ - ការអោយតំលៃខ្លួនឯង និង សមិទ្ធិផលសិក្សារបស់គរុនិស្សិតជីវវិទ្យា




*រូបទី៦ : ការអោយតំលៃខ្លួនឯង និងពិន្ទុសិក្សានិស្សិតជីវវិទ្យា*

ពិន្ទុមធ្យមនៃការអោយតំលៃខ្លួនឯងមានកម្រិតបង្គួរ ($\overline{X}$= ៦៥.៤០) រីឯពិន្ទុសិក្សារបស់គេមានកម្រិតបង្គួរដែរ ($\overline{X}$ = ៧.១៩) ។ ចំពោះលទ្ធផលពីទំនាក់ទំនងរវាងការអោយតំលៃខ្លួនឯងរបស់ក្រុមគរុនិស្សិតជីវវិទ្យាជាមួយនឹងពិន្ទុសិក្សាបង្ហាញថា អថេរទាំងពីរនេះមានទំនាក់ទំនងគ្នាយ៉ាងវិជ្ជមានជាមួយគ្នា និងមានសហទំនាក់ទំនងគ្នាខ្ពស់ជាងគេបង្អស់ក្នុងចំណោមគរុនិស្សិតផ្នែកគណិតវិទ្យានិងវិទ្យាសាស្ត្រ (r=.៨៧) ។ នេះមានន័យថា គរុនិស្សិតដែលមានការអោយតំលៃខ្លួនឯងខ្ពស់តែងតែមានភាពម្ចាស់ការក្នុងការសិក្សា និងបំពេញការងារសិក្សាដោយគំនិតច្នៃប្រឌិត តស៊ូព្យាយាម ព្រមទាំងមានជំនក់ចិត្តក្នុងការធ្វើការពិសោធរហូតដល់ការសិក្សារៀនសូត្ររបស់គេទទួលបានលទ្ធផលល្អ ។

### ៤.២.១.២ - ការអោយតំលៃខ្លួនឯង និង សមិទ្ធិផលសិក្សារបស់គរុនិស្សិតគីមីវិទ្យា

ពិន្ទុសិក្សារបស់គរុនិស្សិតគីមីវិទ្យាមានកម្រិតបង្គួរ ( $\overline{X}$=៧.០៦ ) រីឯការអោយតំលៃលើខ្លួនឯងមានកម្រិតលើធម្យម ( $\overline{X}$=៦៤.១៥ ) ។ លទ្ធផលបង្ហាញថា ការឱ្យតំលៃខ្លួនឯងរបស់ក្រុមគរុនិស្សិតគីមីវិទ្យាមានទំនាក់ទំនងយ៉ាងវិជ្ជមានជាមួយនឹងសមិទ្ធផលសិក្សាដែលមានពិន្ទុសហទំនាក់ទំនង (r = .៨៤៧) ដោយមានលំអៀងនៃលំងាកស្តង់ដា SE = .២៧៥ ។

ពិន្ទុសិក្សានិស្សិតគីមីវិទ្យា




ការអោយតំលៃខ្លួនឯង

*រូបទី៧ : ការអោយតំលៃខ្លួនឯង និងពិន្ទុសិក្សានិស្សិតគីមីវិទ្យា*

យោងតាមលទ្ធផលទំនាក់ទំនងគ្នាខាងលើនេះ អ្នកស្រាវជ្រាវកត់សំគាល់ឃើញថា នៅពេលណាគរុ-និស្សិតផ្នែកគីមីវិទ្យាមានការឱ្យតំលៃខ្លួនឯងក្នុងកម្រិតខ្ពស់ គុណភាពសិក្សារបស់គេមានការកើនឡើងខ្ពស់ដែរ ។ ផ្ទុយទៅវិញ បើគរុនិស្សិតជីវវិទ្យាមិនមានការឱ្យតំលៃលើខ្លួនឯងខ្ពស់ទេ ពួកគេអាចទទួលបានពិន្ទុសិក្សារបស់គេថយចុះដែរ ។ ដូច្នេះ ការយកចិត្តទុកដាក់ទៅលើវិធីធ្វើការពិសោធ និងអោយសិស្សរៀនដោយឯករាជ្យជាកត្តានាំអោយនិស្សិតមានកំលាំងចិត្តសិក្សា និងមានជំនឿលើសមត្ថភាពសិក្សារបស់ខ្លួនដែលទាំងនេះជាហេតុនាំអោយពួកគេមានការអោយតំលៃខ្លួនឯងកាន់តែខ្ពស់ថែមទៀត ។

### ៤.២.១.៣ . ការអោយតំលៃខ្លួនឯង និង សមិទ្ធិផលសិក្សារបស់គរុនិស្សិតគណិតវិទ្យា

គរុនិស្សិតគណិតវិទ្យាមានការឱ្យតំលៃខ្លួនឯងកម្រិតលើមធ្យម $\overline{X}$=៦១.៨៨ និងពិន្ទុសិក្សារបស់គេមានកម្រិតបង្គួរ $\overline{X}$=៦.៨២ ។ លទ្ធផលបង្ហាញថា ការអោយតំលៃខ្លួនឯង និងពិន្ទុសិក្សារបស់គរុនិស្សិតគណិតវិទ្យាមានសហទំនាក់ទំនងយ៉ាងវិជ្ជមាន ( r = .៨៣ ) និងលំអៀងស្តង់ដា ( SE= .២០៥ ) ។ លទ្ធផលទំនាក់ទំនងនេះបង្ហាញថា នៅពេលណាគរុនិស្សិតផ្នែកគណិតវិទ្យាមានការអោយតំលៃខ្លួនឯងកាន់តែខ្ពស់ ពិន្ទុសិក្សារបស់គេក៏ទទួលបានកាន់តែខ្ពស់ដែរ ។ ដូច្នេះ ការយកចិត្តទុកដាក់លើទ្រឹស្តីគណិតវិទ្យា ការប្រើវិធី-សាស្ត្រផ្តល់អោយនិស្សិតរៀនស្រាវជ្រាវដោយខ្លួនឯងជួយអោយពួកគេមានការពេញចិត្តនឹងការសិក្សា ហើយពួកគេនឹងគិតពីតំលៃសមិទ្ធផលនៃការសិក្សារបស់គេ ។ កត្តាទាំងនេះជួយអោយពួកគេមើលឃើញអំពីតំលៃដែលកើតចេញពីស្នាដៃរបស់ខ្លួន ។ វិធីទាំងនេះអាចជួយអោយគរុនិស្សិតគណិតវិទ្យាមានការអោយតំលៃខ្លួនឯងខ្ពស់ឡើង ។ តាមលទ្ធផលនេះ គេអាចនិយាយបានថា នៅពេលគរុនិស្សិតមានការអោយតំលៃខ្លួនឯងខ្ពស់

ជាងនេះ នោះសមិទ្ធផលសិក្សារបស់គេកាន់តែល្អប្រសើរជាងនេះទៅទៀត ។




*រូបទី៨ : ការអោយតំលៃខ្លួនឯង និងពិន្ទុសិក្សានិស្សិតគណិតវិទ្យា*

### ៤.២.១.៤ . ការអោយតំលៃខ្លួនឯង និង សមិទ្ធផលសិក្សារបស់គរុនិស្សិតរូបវិទ្យា




*រូបទី៩ : ការអោយតំលៃខ្លួនឯង និងពិន្ទុសិក្សានិស្សិតរូបវិទ្យា*

គរុនិស្សិតរូបវិទ្យាមានការឱ្យតំលៃខ្លួនឯងលើកម្រិតមធ្យម $\overline{X}$=៦១.០៨ និងមានពិន្ទុសិក្សារបស់គេកម្រិតបង្គួរ $\overline{X}$=៦.៦៣ ។ លទ្ធផលស្រាវជ្រាវបង្ហាញថា ការអោយតំលៃខ្លួនឯង និងពិន្ទុសិក្សារបស់គរុ-និស្សិតរូបវិទ្យាមានទំនាក់ទំនងវិជ្ជមាន ( r = .៧៨២ ) ដោយមានលំអៀងស្តង់ដា (SE = .២៦៦ ) ។ ក្នុង

ចំណោមលទ្ធផលស្រាវជ្រាវនេះ យើងឃើញថា គរុនិស្សិតរូបវិទ្យាមានការឱ្យតំលៃខ្លួនឯងទាបជាងគរុនិស្សិតផ្នែកវិទ្យាសាស្ត្រផ្សេងៗទៀត រីឯពិន្ទុសិក្សារបស់ពួកគេក៏មានកម្រិតទាបជាងគេដែរ ប៉ុន្តែការខុសគ្នាទាំងនេះមានកម្រិតតិចតួចបំផុត ។ លទ្ធផលបញ្ជាក់អោយដឹងថា នៅពេលណាពិន្ទុសិក្សាកាន់តែខ្ពស់ ការអោយតំលៃខ្លួនឯងក៏កាន់តែកើនឡើងខ្ពស់ដែរ ។ គរុនិស្សិតដែលមានការសិក្សាអនុវត្ត និងរៀនដោយម្ចាស់ការដោយខ្លួនឯងច្រើន ព្រមទាំងមានការលើកទឹកចិត្តពីគ្រូបង្រៀនជួយឱ្យពួកគេមានកំលាំងចលករចង់សិក្សាថែមឡើង ដែលនេះជាការជួយបណ្តុះការអោយតំលៃខ្លួនឯងរបស់គរុនិស្សិតរូបវិទ្យាកាន់តែខ្ពស់ឡើងដែរ ។ តារាងទី១៤ ជាសេចក្តីសង្ខេបអំពីការវិភាគសហាទំនាក់ទំនងសំរាប់អថេរនៃការអោយតំលៃខ្លួនឯងជាមួយសមិទ្ធផលសិក្សារបស់គរុនិស្សិតសំរាប់មុខវិជ្ជានីមួយៗនៅវិទ្យាស្ថានជាតិអប់រំ ។

| មុខវិជ្ជា | មធ្យមពិន្ទុ | មធ្យមការអោយតំលៃខ្លួន | r | SE |
|---|---|---|---|---|
| ជីវវិទ្យា | ៧.១៩ | ៦៥.៤០ | .៨៧៧ | .១១៣ |
| គីមីវិទ្យា | ៧.០៦ | ៦៤.១៥ | .៨៤៧ | .២៧៥ |
| គណិតវិទ្យា | ៦.៨២ | ៦១.៨៨ | .៨៣៦ | .២០៥ |
| រូបវិទ្យា | ៦.៦៣ | ៦១.០៨ | .៧៨២ | .២៦៦ |
| សរុប | ៦.៨៧ | ៦២.៣៦ | .៨៨៧ | .២១២ |

*តារាងទី១៥ : សហាទំនាក់ទំនងនៃមុខវិជ្ជាវិទ្យាសាស្ត្រនិងគណិតវិទ្យាជាមួយការអោយតំលៃខ្លួនឯង*

សរុបសេចក្តីមក លទ្ធផលបានបង្ហាញថា ក្នុងចំណោមគរុនិស្សិតរៀនមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិត-វិទ្យា មានតែគរុនិស្សិតជីវវិទ្យាទេដែលមានការអោយតំលៃខ្លួនឯងខ្ពស់ជាងគេ រីឯគរុនិស្សិតរូបវិទ្យាមានការអោយតំលៃខ្លួនឯងទាបជាងគេ ។ រីឯសមិទ្ធផលសិក្សា គរុនិស្សិតគីមីវិទ្យាមានលទ្ធផលសិក្សាខ្ពស់ជាងគេ ហើយគរុនិស្សិតវិទ្យាសាស្ត្រ និងគណិតវិទ្យាមានលទ្ធផលកម្រិតបង្គួរ $\overline{X}$=៦.៨៧ ។ លទ្ធផលស្រាវជ្រាវនេះនាំអោយគេដឹងថា ការអោយតំលៃខ្លួនឯងកើនកាន់តែខ្ពស់ ការសិក្សារបស់ពួកគេកាន់តែទទួលបានលទ្ធផលល្អ ដែលនេះជាការបញ្ជាក់ថា សមិទ្ធផលសិក្សាអាស្រយ័យ៉ាងសំខាន់លើការអោយតំលៃខ្លួនឯង ហើយការអោយតំលៃខ្លួនឯងជាស្នូលដ៏ចំបងនាំអោយសិស្ស និស្សិតមានការសិក្សាបានល្អ ។ ដូច្នេះ អ្នកអប់រំទាំងឡាយត្រូវយកចិត្តទុកដាក់ដល់វិធីសាស្ត្រស្តីពីការអភិវឌ្ឍការអោយតំលៃខ្លួនឯងក្នុងគោលបំណង ដើម្បីជួយអោយសិស្ស និងនិស្សិតមានគុណភាពសិក្សាខ្ពស់ ។

### ៤.២.គ - ទំនាក់ទំនងការអោយតំលៃខ្លួនឯង និង ការពេញចិត្តនឹងការសិក្សា

លទ្ធផលស្រាវជ្រាវបានបង្ហាញថា គរុនិស្សិតមានការពេញចិត្តលើមុខវិជ្ជាជីវៈរបស់ខ្លួនក្នុងកំរិតបង្គួរ $\overline{X}$=១.៩៨ រីឯការឱ្យតំលៃខ្លួនឯងរបស់ពួគេមានកម្រិតលើមធ្យម $\overline{X}$=៥៩.៦ ។ លទ្ធផលបានបង្ហាញថា ការពេញចិត្តនឹងការសិក្សា និងការឱ្យតំលៃខ្លួនឯងមានទំនាក់ទំនងគ្នា ( r = .១៦៤ ) ប៉ុន្តែទំនាក់ទំនងនេះមានលក្ខណៈវិជ្ជមានតិចតួច ។ លទ្ធផនេះមានន័យថា គរុនិស្សិតមានការពេញចិត្តនឹងការសិក្សាកើនឡើងលុះណាតែពួកគេមានការអោយតំលៃខ្លួនឯងកាន់តែខ្ពស់ដែរ ។ នៅពេលណានិស្សិតមានការឱ្យតំលៃខ្លួនឯងខាងសមត្ថភាពជំនាញ និងខាងបញ្ញាញាណ នោះនិស្សិតនឹងមានការពេញចិត្តនឹងការសិក្សារបស់គេខ្លាំង ។ ដូច្នេះការអោយតំលៃខ្លួនឯងមានឥទ្ធិពលដល់ទឹកចិត្តចង់រៀន និងការខិតខំប្រឹងប្រែងសិក្សារបស់គរុនិស្សិត ។ បើមិនច្រើនក៏តិចដែរ ការអោយតំលៃខ្លួនឯងនឹងជួយអោយគរុនិស្សិតមានការពេញចិត្តនឹងការសិក្សារបស់គេនេះបើយោងតាមលទ្ធផលស្រាវជ្រាវខាងលើ ។

### ៤.២.ឃ - ទំនាក់ទំនងការពេញចិត្តនឹងការសិក្សា និង សមិទ្ធផលសិក្សា




*រូបទី១០ : ការពេញចិត្តនឹងការសិក្សា និងសមិទ្ធផលសិក្សា*

លទ្ធផលបង្ហាញថា ការពេញចិត្តនឹងការសិក្សា និងសមិទ្ធផលសិក្សារបស់និស្សិតមានទំនាក់ទំនងគ្នាយ៉ាងវិជ្ជមានបំផុត ( r = .៩៦០ ; SE = .១២៥ ) ។ នៅក្នុងលទ្ធផលស្រាវជ្រាវក្នុងស្ថិតិពិពណ៌នាបង្ហាញថា គរុនិស្សិតមានការពេញចិត្តនឹងការសិក្សាក៏រិតខ្ពស់ ហើយលទ្ធផលសិក្សារបស់គេមានកម្រិតបង្គួរ ។ លទ្ធផលនេះបង្ហាញថា ការពេញចិត្តនឹងការសិក្សា និងសមិទ្ធផលសិក្សាមានទំនាក់ទំនងគ្នាយ៉ាងមានសារៈសំខាន់បំផុត ហើយសមិទ្ធផលសិក្សារបស់គរុនិស្សិតអាស្រ័យលើការពេញចិត្តការសិក្សារបស់ពួកគេ ។ គរុនិស្សិតដែល

មានការពេញចិត្តនឹងការសិក្សារបស់គេកាន់តែខ្លាំង ពិន្ទុសិក្សារបស់គេកាន់តែខ្ពស់ដែរ ។ បរិយាកាសនៅក្នុងបន្ទប់រៀន និងក្នុងសាលារៀនដើរតួនាទីក្នុងការជួយអោយសិស្សទទួលបានពិន្ទុល្អ ។

ជាមួយគ្នានេះដែរ ការស្រាវជ្រាវកត់សំគាល់ឃើញថា ការពេញចិត្តនឹងមុខវិជ្ជាសិក្សានានារបស់គរុ-និស្សិតមានទំនាក់ទំនងទៅនឹងអារម្មណ៍ដែលនិស្សិតយល់ថាបានទទួលពីការសិក្សារបស់ពួកគេ ។ ការពេញចិត្តសមត្ថភាពឯកទេសវិទ្យាសាស្រ្តរបស់និស្សិតមានទំនាក់ទំនងទៅនឹងកម្រិតសមត្ថភាពយល់ដឹងមុខវិជ្ជាឯកទេសរបស់គេ ។ ការពេញចិត្តចំពោះការផលិតសម្ភារៈឧបទេស វិធីសាស្រ្តបង្រៀន សីលធម៌វិជ្ជាជីវៈឯកទេសរដ្ឋបាលសិក្សា ជំនាញប្រលង ជំនាញកិច្ចតែងការបង្រៀន ជំនាញតាក់តែងសំណួរវាយតំលៃសិស្ស ជំនាញស្រាវ-ជ្រាវវិទ្យាសាស្រ្ត ជំនាញបង្រៀនពិសោធន៍ក្នុងថ្នាក់និងក្នុងមន្ទីរពិសោធន៍ និងជំនាញប្រើប្រាស់កុំព្យូទ័ររបស់និស្សិតផ្នែកវិទ្យាសាស្រ្ត និងគណិតវិទ្យាមានទំនាក់ទំនងទៅនឹងសមត្ថភាពចំណេះដឹងដែលគេគិតថាបានទទួលលើមុខវិជ្ជាសិក្សាទាំងអស់នោះ ។ ដូច្នេះ នៅពេលណាគរុនិស្សិតមានការពេញចិត្តនឹងការសិក្សាលើមុខវិជ្ជាសិក្សារបស់គេ នោះពួកគេនឹងទទួលបានលទ្ធផលខ្ពស់ ចំពោះសមត្ថភាពសិក្សាលើមុខវិជ្ជានីមួយៗទាំងនោះ ។ លទ្ធផលនេះអាចបញ្ជាក់បានថា នៅពេលនិស្សិតមានការពេញចិត្តខ្លាំងលើមុខវិជ្ជាណាមួយហើយ ពួកគេនឹងសម្រេចបានលទ្ធផលខ្ពស់ចំពោះមុខវិជ្ជាសិក្សានោះ ។

ជាការសង្ខេបអំពីលទ្ធផលសហទំនាក់ទំនងនៃការស្រាវជ្រាវ យើងឃើញថា ការពេញចិត្តនឹងការសិ-ក្សា និងសមិទ្ធផលសិក្សាមានសហទំនាក់ទំនងវិជ្ជមានជាងគេបំផុត ( r = .960 ) បន្ទាប់មកទំនាក់ទំនងរវាងការឱ្យតំលៃខ្លួនឯង និងសមិទ្ធផលសិក្សាក៏មានទំនាក់ទំនងវិជ្ជមានដែរ ( r = .887 ) រីឯការពេញចិត្តនឹងការសិក្សា និងការអោយតំលៃខ្លួនឯងមានទំនាក់ទំនងនឹងគ្នាតិចតួច ( r = .164 ) ប៉ុន្តែមានតែកត្តាអាយុវ័យទេដែលមានទំនាក់ទំនងអវិជ្ជមានជាមួយការអោយតំលៃខ្លួនឯង ( r = -.416) ។ គរុនិស្សិតផ្នែកវិទ្យាសាស្រ្តនិងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំមានការអោយតំលៃខ្លួនឯងលើកម្រិតមធ្យម ។

## ៤.៣ - កត្តាដែលមានឥទ្ធិពលលើការអោយតំលៃខ្លួនឯង




*រូបទី១១ : កត្តាដែលមានឥទ្ធិពលដល់ការអោយតំលៃខ្លួនឯង*

ការស្រាវជ្រាវអាចកត់សំគាល់ឃើញថា កត្តាគ្រួសារ សាលារៀន មជ្ឈដ្ឋាន និងកត្តាស្វ័យផ្ទាល់ខ្លួន មានឥទ្ធិពលដល់ការអោយតំលៃខ្លួនឯងរបស់មនុស្សគ្រប់រូប ។ មនុស្សមានការអោយតំលៃខ្លួនឯងពេញលេញ នៅពេលណាគេទទួលបាន ឬបំពេញបានគ្រប់គ្រាន់នូវការទាក់ទាញខាងរូបរាងកាយ សមត្ថភាពចំណេះដឹង តំលៃគុណធម៌ និងសីលធម៌ ដែលសមាសធាតុទាំងនេះមានប្រភពចេញពីកត្តាមជ្ឈដ្ឋាន សាលារៀន គ្រួសារ សង្គម និងកត្តាខ្លួនបុគ្គលផ្ទាល់ ។ ប្រសិនបើមនុស្សមានការអោយអោយតំលៃផ្នែកណាមួយចុះខ្សោយ នោះការអោយតំលៃខ្លួនឯងរបស់មនុស្សនោះមានការចុះខ្សោយ ។

### ៤.៣.ក - វិធីអប់រំក្នុងគ្រួសារ និង ការអោយតំលៃខ្លួនឯង

កត្តាគ្រួសារដើរតួនាទីចំបងដំបូងគេបង្អស់ក្នុងការកសាងការឱ្យតំលៃខ្លួនឯងរបស់មនុស្ស ចាប់តាំងពីវ័យកុមារ ពិសេសក្នុងវ័យដើមឆ្នាំដំបូងរបស់មនុស្ស ។ ឪពុកម្តាយជាមនុស្សដែលនៅជាប់ជិតដិត និងមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយកូនច្រើនជាងគេ និងជាអ្នកផ្តល់ភាពកក់ក្តៅ ផ្តល់សេចក្តីស្រលាញ់ និងការទូន្មានចំពោះកុមារ ។ ឪពុកម្តាយប្រភេទនេះជួយអោយកុមារមានការជឿជាក់លើខ្លួនឯង និងជួយអោយពួកគេមានកំលាំងចិត្តខ្លាំងឡើងថែមទៀត ។ ក្រុមអ្នកស្រាវជ្រាវ និងអ្នកនិពន្ធជាច្រើនដែលយកចិត្តទុកដាក់ទៅលើឥទ្ធិពលគ្រួសារមកលើការអោយតំលៃខ្លួនឯងរួមមានលោក Cooppersmith (1967) ; Baumrind (1967), Yabiku, Nunley, Axinn (1999) ; Matthew Mckay & Partick Fanning (2000) ។ ពួកគេបានធ្វើការសន្និដ្ឋានព្រមគ្នាថា កត្តាគ្រួសារ ពិសេសឪពុកម្តាយមានតួនាទីចំបងគេបង្អស់ក្នុងការអភិវឌ្ឍការឱ្យតំលៃខ្លួនឯងរបស់កុមារ ។ លើសនេះទៅទៀត សេចក្តីស្រលាញ់របស់ម្តាយមានឥទ្ធិ-ពលចាក់កប់យ៉ាងជ្រៅដល់ផ្លូវចិត្តរបស់កូនចាប់ផ្តើមពីកំណើតរហូតដល់ពេញវ័យ ហើយអាកប្បកិរិយានៃការឱ្យតំលៃខ្លួនឯងពេលបច្ចុប្បន្នជាការទទួលបានពីបទពិសោធន៍ពីអតីតកាលចាប់តាំងពីវ័យកុមារភាពមកម្លេះ ។

### ៤.៣.ខ - វិធីអប់រំនៅសាលារៀន និង ការអោយតំលៃខ្លួនឯង

សាលារៀនមានឥទ្ធិពលមកលើការឱ្យតំលៃខ្លួនឯងរហូតដល់លោក Lilian G. Katz បានជំរុញឱ្យអ្នកអប់រំគិតពីយុទ្ធសាស្ត្រធ្វើយ៉ាងណា ដើម្បីជំរុញអោយការអោយតំលៃខ្លួនឯងរបស់សិស្សចំរើនឡើង ។ លោក Marsh (1990), Cansley & Tyler (1989) , Matclfe( 1981) Reynolds (1980) & Good & Weinstein (1981) បានសន្និដ្ឋានស្រដៀងគ្នាអំពីឥទ្ធិពលរបស់សាលារៀនជាមួយការឱ្យតំលៃខ្លួនឯងដោយបានបង្ហាញថា កត្តាសាលារៀនជាកត្តាជំរុញអោយមានការអោយតំលៃលើខ្លួនឯង ជាពិសេសសកម្មភាពចូលរួមរបស់សិស្ស និងគ្រូក្នុងការទំនាក់ទំនងក្នុងការបណ្តុះសមត្ថភាពចំណេះដឹង បណ្តុះផ្នែកបុគ្គ-

លិកលក្ខណៈ សីលធម៌ និងបណ្តុះបានរូបភាពផ្លូវចិត្តដល់សិស្ស ។ ក្រុមអ្នកស្រាវជ្រាវទាំងនេះបានបញ្ជាក់ប្រហាក់ប្រហែលគ្នាថា សិស្ស និស្សិតដែលមានការអោយតំលៃខ្លួនឯងខ្ពស់តែងតែទទួលបានជោគជ័យនៅសាលារៀន ហើយឥរិយាបថចង់សិក្សាក៏កាន់តែខ្លាំងឡើងដែរ ។ សាលារៀនបណ្តុះបានទូវចំណេះដឹងឯងទេស តំលៃសីលធម៌ដែលជាការជំរុញការឱ្យតំលៃខ្លួនឯងអភិវឌ្ឍឡើង ។ ដូច្នេះនៅពេលណាសាលារៀនបានយកចិត្តទុកដាក់ដល់យុទ្ធសាស្ត្រលើកតម្កើងការអោយតំលៃខ្លួនឯង នោះសាលារៀននោះបានដើរតួនាទីចំបងដល់ការបណ្តុះការឱ្យតំលៃខ្លួនឯងដល់សិស្ស និងនិស្សិតហើយ ។

### ៤.៣.គ - ឥទ្ធិពលមជ្ឈដ្ឋាន និង ការអោយតំលៃខ្លួនឯង

ឥទ្ធិពលមជ្ឈដ្ឋានជាវិសាលភាពធំធេងចំរុះបែបដែលមានឥទ្ធិពលដល់ផ្លូវចិត្តរបស់មនុស្ស ព្រោះមនុស្សរស់នៅជាមួយមជ្ឈដ្ឋានទាំងនោះជាប្រចាំថ្ងៃ ។ បើមិនច្រើនក៏តិចដែរ ឥទ្ធិពលមជ្ឈដ្ឋានពីខាងក្រៅនេះមានឥទ្ធិពលដល់ការឱ្យតំលៃខ្លួនឯងរបស់មនុស្សគ្រប់រូបដោយមិនអាចជៀសរួច ។ លោក Patricia Kramer (1991) , Constantine & Marilyn & Mecca etc (1989) , Maruk (1995) បានធ្វើការស្រាវជ្រាវទាក់ទងទៅនឹងកត្តាមជ្ឈដ្ឋានមានឥទ្ធិពលដល់ការអោយតំលៃខ្លួនឯង ដោយបង្ហាញថា ឥទ្ធិពលសាសនា វប្បធម៌រស់នៅ ប្រព័ន្ធផ្សព្វផ្សាយមានឥទ្ធិពលដល់ផ្លូវចិត្តរបស់មនុស្សដែលជាការជួយជំរុញការអោយតំលៃខ្លួនឯងរបស់មនុស្សតម្រង់ទៅបែបណាមួយ ។ ពួកគេបានបញ្ជាក់ថា មនុស្ស និងវត្ថុនៅជុំវិញខ្លួនអ្នកមានឥទ្ធិពលដល់រូបអ្នក ហើយបរិយាកាសនៅជុំវិញ និងសាសនាមានឥទ្ធិពលដល់រូបភាពចិត្តរបស់មនុស្ស ហើយកត្តាឥទ្ធិពលវប្បធម៌ជះឥទ្ធិពលដល់ការអោយតំលៃខ្លួនឯងរបស់មនុស្ស ។ ការទទួលស្គាល់សង្គម និងអន្តរទំនាក់ទំនងបុគ្គលជាមួយសង្គមមានឥទ្ធិពលដល់ការអោយតំលៃខ្លួនឯងរបស់មនុស្ស ។ ជារឿយៗ មនុស្សមិនអាចជៀសវាងបានពីមនោគមសាសនា មតិកវប្បធម៌ទំនៀមទំលាប់ដែលកត្តានេះបានបញ្ជ្រាបដល់ផ្លូវចិត្តរបស់មនុស្ស តាមរយៈប្រពន្ធ័ផ្សព្វផ្សាយ និងអន្តរទំនាក់ទំនងផ្សេងៗចាបពីវ័យកុមាររៀងរហូតមក ។

### ៤.៣.ឃ - ឥទ្ធិពលការអោយតម្លៃផ្ទាល់ខ្លួន និង ការអោយតំលៃខ្លួនឯង

មនុស្សយើងមានការអោយតំលៃខ្លួនឯង ឬមិនអោយតំលៃខ្លួនឯងគឺអាស្រ័យលើខ្លួនរបស់យើង វាពុំមែនអាស្រ័យលើអ្នកដទៃឡើយ ប៉ុន្តែកត្តាខាងក្រៅអាចមានឥទ្ធិពលដល់ការឱ្យតំលៃខ្លួនឯងដែរ ។ ចំពោះកត្តាបុគ្គល ការអោយតំលៃខ្លួនឯងមានប្រភពពីលក្ខណៈរូបរាងខាងក្រៅរបស់មនុស្ស ដែលទទួលបានពីមតិកបុព្វបុរសរបស់ខ្លួន ។ ក្រៅពីនេះ កត្តាចំណេះដឹង សមត្ថភាព បញ្ញាញាណនិងគុណធម៌ជាមិតកផ្ទាល់ខ្លួន

របស់គេក្នុងការកំណត់អោយគេមើលឃើញពីការអោយតំលៃខ្លួនឯង ។ លោក Maslow បានធ្វើការបញ្ជាក់ថា មនុស្សដែលមានការអោយតំលៃ និងការពេញចិត្តលើខ្លួនឯងខ្លាំងជាងកត្តាខាងក្រៅអោយតំលៃមកលើខ្លួនឯង ហើយការទទួលស្គាល់តំលៃខ្លួននេះជាមូលដ្ឋានស្នូលក្នុងការឱ្យតំលៃខ្លួនឯងខ្ពស់ ។ តាមទ្រឹស្តីលោក Freud បង្ហាញថា ការអោយតំលៃខ្លួនឯងកើតមានឡើង នៅពេលការវិនិច្ឆ័យរវាងកំលាំងអញ្ញាណ (id) ដែលតំណាងដោយគោលការណ៍សប្បាយរីករាយជាមួយកំលាំងនិយាមសង្គម (Super Ego) តំណាងដោយកត្តាសីលធម៌សង្គមដែលសុទ្ធតែជាដើមចមដល់ការអោយតំលៃខ្លួនឯងរបស់មនុស្ស ។ មនុស្សដែលមានរូបសម្បត្តិល្អច្រើនមានការអោយតំលៃខ្លួនឯងក្នុងបរិការប្រកួតប្រជែងរូបសម្បត្តិក្នុងទីសាធារណៈ ខណៈពេលមនុស្សដែលមានកត្តាសីលធម៌ច្រើនអោយតំលៃជឿជាក់លើខ្លួនឯងលើគុណធម៌ ក្នុងការប្រាស្រ័យទាក់ទងគ្នា ហើយអ្នកដែលមានសមត្ថភាពបញ្ញាច្រើនជឿជាក់លើខ្លួនឯង និងអោយតំលៃខ្លួនឯងក្នុងបរិបទប្រកួតប្រជែងសមត្ថភាព ។ លទ្ធផលស្រាវជ្រាវបានកត់សំគាល់ឃើញថា កត្តាសាលារៀន គ្រួសារ មជ្ឈដ្ឋាន និងកត្តាខ្លួនឯងផ្ទាល់មានឥទ្ធិពលដល់ការរីកលូតលាស់ និងចាក់ឫសគល់ដល់ការអោយតំលៃខ្លួនឯងរបស់មនុស្ស និងជួយឱ្យមនុស្សមានការតំលៃខ្លួនឯងក្នុងកម្រិតបែបណាមួយ ។ ការពេញចិត្តលើខ្លួនឯង ជំនឿចិត្ត សមត្ថភាព និងសីលធម៌ជាសសរស្តម្ភចំពោះការអោយតំលៃខ្លួនឯង ។

រួមសេចក្តីមក ការអោយតំលៃខ្លួងឯងទទួលឥទ្ធិពលពីកត្តាសាលារៀន គ្រួសារ សង្គម និងកត្តាបុគ្គល ហើយកត្តាទាំងបួនខាងលើនេះក៏ជះត្រឡប់មកលើការអោយតំលៃខ្លួនឯងរបស់មនុស្សវិញដែរ ដោយគេអាចនិយាយបានថា វាអាចបំពេញឱ្យគ្នាទៅវិញទៅមក ។ ទោះជាយ៉ាងនេះក៏ដោយ ឥទ្ធិពលទាំងនោះមានឥទ្ធិពលមកលើផ្លូវចិត្តរបស់មនុស្សមិនដូចគ្នាទេ ទោះស្ថិតក្នុងស្ថានភាពដូចគ្នាយ៉ាងណាក៏ដោយ ហើយឥទ្ធិពលមកលើការអោយតំលៃខ្លួនឯងនេះនឹងត្រូវលើកយកមកពិភាក្សានៅក្នុងជំពូកទីប្រាំ ដើម្បីរកទឡ្ហីករណ៍យកមកអំណះអំណាងចំពោះការឱ្យតំលៃខ្លួនឯងរបស់គរុនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ ។

### ៤.៣.១ - ការផ្ទៀងផ្ទាត់លទ្ធផលស្រាវជ្រាវជាមួយសម្មតិកម្មស្រាវជ្រាវ

លទ្ធផលស្រាវជ្រាវនេះនឹងត្រូវផ្ទៀងផ្ទាត់ជាមួយសម្មតិកម្មស្រាវជ្រាវដែលបានធ្វើការប៉ាន់ប្រមាណទុកជាមុននោះ ។ លទ្ធផលស្រាវជ្រាវនេះបានឆ្លុះបញ្ចាំងទៅនឹងសម្មតិកម្មស្រាវជ្រាវដូចខាងក្រោម :

សម្មតិកម្មទី១ : និស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានឹងមានការអោយតំលៃខ្លួនឯងកម្រិតខ្ពស់ ហើយរបៀបអប់រំនៅក្នុងគ្រួសារ និងសាលារៀនជះឥទ្ធិពលដល់ការរីកចំរើននៃការអោយតំលៃខ្លួនឯង ។

លទ្ធផលស្រាវជ្រាវបង្ហាញច្បាស់ថា គរុនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យាមានការអោយតំលៃខ្លួនឯងកម្រិតមធ្យម $\overline{X}$=៦២.៣៦ ។ ការស្រាវជ្រាវនេះបានកត់សំគាល់ឃើញថា កត្តាគ្រួសារ និងសាលារៀនជួយបណ្តុះការអោយតំលៃខ្លួនឯងរបស់សិស្ស និងនិស្សិត ។

សម្មតិកម្មទី២ : ការអោយតំលៃខ្លួនឯងមានទំនាក់ទំនងវិជ្ជមានជាមួយសមិទ្ធផលសិក្សា ។

លទ្ធផលស្រាវជ្រាវបានបង្ហាញថា អថេរទាំងពីរនេះមានទំនាក់ទំនងគ្នាយ៉ាងវិជ្ជមាន ( r = .887 ) ។

សម្មតិកម្មទី៣ : កត្តាលក្ខណៈពិសេសផ្ទាល់ខ្លួន (អាយុ ភេទ កម្រិតអប់រំ) មានឥទ្ធិពលដល់ការឱ្យតំលៃខ្លួនឯង ។ លទ្ធផលស្រាវជ្រាវបង្ហាញថា ក្នុងចំណោមសមាសធាតុនៅក្នុងកត្តាលក្ខណៈពិសេសផ្ទាល់ខ្លួនមានតែអថេរអាយុទេដែលមានទំនាក់ទំនងអវិជ្ជមានជាមួយការអោយតំលៃខ្លួនឯង ( r = -.416 ) ។ ការឱ្យតំលៃខ្លួនឯងរបស់គរុនិស្សិតភេទស្រីមានទំនាក់ទំនងវិជ្ជមានដូចគរុនិស្សិតភេទប្រុសដែរ រីឯកម្រិតអប់រំនិស្សិតមានកម្រិតដូចគ្នា ប៉ុន្តែគរុនិស្សិតម្នាក់ៗមានការអោយតំលៃខ្លួនឯងមិនដូចគ្នាទេ ។

សម្មតិកម្មទី៤ : ការអោយតំលៃខ្លួនឯងមានទំនាក់ទំនងវិជ្ជមានជាមួយការពេញចិត្តនឹងការសិក្សា ។

លទ្ធផស្រាវជ្រាវបង្ហាញថា ការអោយតំលៃខ្លួនឯងមានទំនាក់ទំនងតិចតួចបំផុតជាមួយនឹងការពេញចិត្តនឹងការសិក្សា ( r = .164) ។

សម្មតិកម្មទី៥ : ការពេញចិត្តនឹងការសិក្សាមានទំនាក់ទំនងវិជ្ជមានជាមួយសមិទ្ធផលសិក្សា ។

លទ្ធផលស្រាវជ្រាវបានបង្ហាញថា អថេរនៃការពេញចិត្តនឹងការសិក្សា និងសមិទ្ធផលសិក្សាមានទំនាក់ទំនងនឹងគ្នាយ៉ាងវិជ្ជមានបំផុត ( r = .960 ) ។ ចំពោះសម្មតិកម្មខាងលើ លទ្ធផលស្រាវជ្រាវមិនបញ្ជាក់ថា វាអាចពិតទាំងស្រុងនោះទេ តែវាអាចមានការជ្រៀតជ្រែកពីកត្តាដទៃទៀតដែលជាសភាពធម្មតារបស់វិទ្យាសាស្ត្រសង្គម ។ សេចក្តីពន្យល់យ៉ាងក្បោះក្បាយស្តីពីសម្មតិកម្មខាងលើនឹងត្រូវបានយកមកបកស្រាយក្នុងគោលបំណងបង្ហាញទទ្បិករណ៍ចំពោះហេតុ និងផលនៃការឱ្យតំលៃខ្លួនឯងនៅក្នុងជំពូកទី ៥ ខាងក្រោម ។

# ជំពូកទី៥
# ការពិភាក្សា

គោលបំណងសំខាន់រួមនៅក្នុងការស្រាវជ្រាវនេះគឺរកអោយឃើញនូវបណ្តាកត្តានានាដែលជះឥទ្ធិពលដល់ការអោយតំលៃខ្លួនឯង និងរកអោយឃើញពីទំនាក់ទំនងរវាងការអោយតំលៃខ្លួនឯងដែលជះឥទ្ធិពលទៅដល់កត្តាដទៃទៀត ដូចជា សមិទ្ធផលសិក្សា លក្ខណៈពិសេសផ្ទាល់ខ្លួន និងការពេញចិត្តនឹងការសិក្សារបស់និស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ ដោយផ្អែកលើហេតុផលនិងទ្រឹស្តីច្បាស់លាស់។ ការស្រាវជ្រាវនេះនឹងផ្តោតទៅលើការពិភាក្សារកមូលហេតុចំពោះកត្តាដែលនាំឱ្យរីកចំរើន និងរាំងស្ទះដល់ការអោយតំលៃខ្លួនឯង និងរកហេតុផលពីទំនាក់ទំនងការអោយតំលៃខ្លួនឯងជាមួយកត្តាលក្ខណៈពិសេសផ្ទាល់ខ្លួន ការអោយតំលៃខ្លួនឯងជាមួយការពេញចិត្តនឹងការសិក្សា ការអោយតំលៃខ្លួនឯងជាមួយសមិទ្ធផលសិក្សា និងរកឱ្យឃើញពីហេតុផលនៃទំនាក់ទំនងរវាងការពេញចិត្តនឹងការសិក្សាជាមួយសមិទ្ធផលសិក្សា ។ ការពិភាក្សានេះនឹងធ្វើឡើងក្នុងដំណាក់កាលបន្តបន្ទាប់ដូចខាងក្រោម :

## ៥.១ - កត្តាដែលនាំអោយរីកចំរើន និងរាំងស្ទះដល់ការអោយតំលៃខ្លួនឯង

តើនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំមានការអោយតំលៃខ្លួនឯងក្នុងកំរិតណា ? តើមានកត្តាអ្វីដែលមានឥទ្ធិពលមកលើការអោយតំលៃខ្លួនឯងរបស់និស្សិតទាំងនោះ ?

លទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថា និស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំមានការឱ្យតំលៃខ្លួនឯងក្នុងកម្រិតមធ្យម $\overline{X}$ = ៦២.៣៦ ។ លទ្ធផលស្រាវជ្រាវនេះបានឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដែលបានលើកឡើងថា តើគរុនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យា-ស្ថានជាតិអប់រំមានការអោយតំលៃខ្លួនឯងក្នុងកម្រិតណា ? ជាទូទៅ ទោះជាគរុនិស្សិតទាំងនោះមានកម្រិតសិក្សាថ្នាក់ឧត្តមសិក្សាដូចគ្នាក៏ដោយ ក៏មាននិស្សិតមួយចំនួនមានការអោយតំលៃខ្លួនឯងខ្ពស់ ហើយនិស្សិតខ្លះទៀតមានការអោយតំលៃខ្លួនឯងនៅកម្រិតទាបនៅឡើយដែរ ។ លទ្ធផលនេះស័ក្តិសមទៅនឹងបរិបទនៅសង្គមមនុស្សទូទៅដែលគេកត់សំគាល់ឃើញថា មនុស្សពូកែ និងមានភាពប៉ិនប្រសប់បំផុតនោះមានចំនួនតិច ហើយអ្នកខ្សោយ ឬមិនពូកែក៏មានចំនួនតិចដែរ ប៉ុន្តែមនុស្សដែលស្ថិតក្នុងស្ថានភាពកម្រិតមធ្យមមានចំនួនច្រើននៅក្នុងសង្គមជាក់ស្តែង ។ យោងតាមយុទ្ធសាស្ត្រ និងវិធីក្នុងការអភិវឌ្ឍការអោយតំលៃខ្លួនឯង គេសង្កេតឃើញថា ការអោយតំលៃខ្លួនឯងរីកលូតលាស់ ឬពុំសូវរីកលូតលាស់បានយ៉ាងណាមួយនោះ វាអាស្រ័យហេតុផលរបស់វាពិតប្រាកដណាស់ ។ ហេតុផលសំខាន់ៗដែលអាចកើតឡើងបានក្នុងចំណោមហេតុផលផ្សេង

ទៀតគឺស្ថិតលើវិធីអប់រំនៅក្នុងគ្រួសារ កត្តាអប់រំនៅតាមសាលារៀន កត្តាសង្គមដែលនិស្សិតបានជួបប្រទះរៀងរាល់ថ្ងៃ និងការវិនិច្ឆ័យលើខ្លួនឯងដោយខ្លួនគេផ្ទាល់ ។ កត្តាទាំងនេះជាហេតុផលនាំអោយនិស្សិតមើលឃើញពីតំលៃខ្លួនគេ និងពេញចិត្តលើខ្លួនគេ និងបណ្តុះបាននូវអារម្មណ៍នៃការអោយតំលៃខ្លួនឯង ។ ការពិភាក្សាខាងក្រោមនេះនឹងរកហេតុផលចំពោះកត្តានីមួយៗ ដែលមានឥទ្ធិពលដល់ការអោយតំលៃខ្លួនឯងរបស់និស្សិតនៅវិទ្យាស្ថានជាតិអប់រំ ។

### ៥.១.ក - ស្ថានភាពអប់រំក្នុងគ្រួសារជាមួយការអោយតំលៃខ្លួនឯង

តើការអប់រំនៅក្នុងគ្រួសាររបស់និស្សិតនៅកម្ពុជាមានដំណើរប្រព្រឹត្តទៅបែបណា ដែលបានកំណត់ការអោយតំលៃខ្លួនឯងរបស់និស្សិតក្នុងកម្រិតមធ្យមដូចនេះ ?

ជាទូទៅ មាតាបិតានៅក្នុងសង្គមខ្មែរតែងតែចង់អោយកូនរបស់ខ្លួនមានជំនឿចិត្តលើខ្លួនឯង មានការសំរេចចិត្តដោយខ្លួនឯង និងមានការអោយតំលៃខ្លួនឯងខ្ពស់ ។ ឪពុកម្តាយមួយចំនួនមានការយល់ដឹងពីរបៀបនិងវិធីអប់រំកូនរបស់ខ្លួន ដើម្បីជួយឱ្យពួកគេមានការអោយតំលៃខ្លួនឯងខ្ពស់ រីឯឪពុកម្តាយភាគច្រើនផ្សេងទៀតបានអប់រំកូនរបស់ខ្លួនអោយមានការអោយតំលៃលើខ្លួនឯង និងមានការជឿជាក់លើខ្លួនឯង ដោយពួកគាត់មិនបានដឹងថាវិធី និងយុទ្ធសាស្ត្រដែលពួកគាត់កំពុងប្រើប្រាស់នោះបាននឹងកំពុងជួយបណ្តុះការជឿជាក់លើខ្លួនឯង និងការអោយតំលៃខ្លួនដល់កូនរបស់គាត់ឡើយ ។ ទន្ទឹមពេលនេះដែរ ក៏មានឪពុកម្តាយខ្លះទៀតពុំបានយល់ដឹងពីរបៀបអប់រំកូនអោយមានការអោយតំលៃខ្លួនឯងនេះឡើយ ហើយថែមទាំងបង្ករអោយកូនរបស់ខ្លួនបាត់បង់នូវការជឿជាក់លើខ្លួនឯងដោយមិនដឹងខ្លួន ដោយពួកគាត់ធ្វើទៅតាមទំលាប់មិនល្អដែលៗ ដែលជាការចំលងមតិកអប់រំពីមនុស្សជំនាន់មួយទៅជំនាន់មួយទៀត ។ ជាការជាក់ស្តែង មាតាបិតាជនជាតិខ្មែររមែងខិតខំអប់រំ ណែនាំកូនតាំងពីកូនមិនទាន់ដឹងក្តី ប្រកបដោយមេត្តាព្រហ្មវិហាធម៌ឥតព្រំដែន ។ ទឹកចិត្តប្រកបដោយក្តីអាណិតអាសូរនេះស្តែងចេញតាមការបីបាច់ថែរក្សា ការថ្នាក់ថ្នមកូន ការអប់រំកូនរហូតដល់ធំពេញវ័យ សូម្បីកូនបែកមានគ្រួសារទៅហើយ ក៏លោកនៅតែណែនាំ និងឧបត្ថម្ភកូនរហូតដល់ទីបំផុតនៃជីវិតលោក ។ ទង្វើរបស់មាតាបិតាខ្មែរបែបនេះមិនត្រឹមតែចេញពីចិត្តសណ្តោសមេត្តារបស់ពួកគាត់ប៉ុណ្ណោះទេ តែវាថែមបានបណ្តុះគំនិតការអោយតំលៃខ្លួនឯងដល់កូនរបស់ខ្លួនថែមទៀត ដែលសមដូចលោក Patricia Kramer បានសរសេរថា ប្រសិនបើកុមាររស់នៅដោយមានការលើកទឹកចិត្ត និងការពេញចិត្តពីអ្នកជិតខាងពួកគេនឹងរៀនពីការជឿជាក់ និងរៀនពីរបៀបចូលចិត្តខ្លួនឯង[៩៨] ។ ដូច្នេះ ទង្វើនិងកាយវិការរបស់ឪពុកម្តាយ

[98] Patricia Kramer, Self esteem Library, Discovering the Real You, op.cit., p.9

របស់និស្សិតបានបញ្ច្រាបចូល ក្នុងចិត្តគំនិតរបស់ពួកគេ ហើយកាយវិការរបស់និស្សិតនៅពេលបច្ចុប្បន្ននេះជាការទទួលមរតកផ្លូវចិត្តពីឪពុកម្តាយរបស់គេ ។

ជាមួយគ្នានេះដែរ មាតាបិតាខ្មែរជាទូទៅចង់អោយបុត្រធីតារបស់ខ្លួនល្អ ដោយណែនាំអោយចេះប្រើពាក្យពេចន៍ពិរោះ ចេះមានឫកពាសុភាពរាបសារ អោនលំទោន និងចេះគោរពចាស់ទុំ [៩៩] ។ លោក Matt-hew Mckay និងលោក Patrick Fanning បានបញ្ជាក់ថា ភាសាជាឧបករណ៍ដ៏មានឥទ្ធិពលក្នុងការកសាងការអោយតំលៃខ្លួនឯង ហើយការស្រលាញ់ ការគោរព ការសសើររបស់ឪពុកម្តាយមានអត្ថន័យខ្លាំងណាស់ចំពោះក្មេង ដើម្បីជួយវាអោយស្គាល់ខ្លួនឯង និងទទួលបាននូវការអោយតំលៃខ្លួនឯង [១០០] ។

ហេតុផលមួយផ្សេងទៀតដែលមាតាបិតាអប់រំកូនអោយមានការអោយតំលៃខ្លួនឯង គឺកើតឡើងដោយសារពួកគាត់មានការថែទាំ ការស្រលាញ់ និងការផ្តល់ភាពកក់ក្តៅដល់កូន ។ មនោសញ្ចេតនារបស់ឪ-ពុកម្តាយជនជាតិខ្មែរជាមនោសញ្ចេតនាដ៏សែនជ្រៅ ទឹកចិត្តស្រលាញ់ និងការថែទាំកូនមានភាពស៊ីជំរៅដែលគោលបំណងសំខាន់ចង់អោយកូនល្អ ចង់អោយកូនទទួលបានសុភមង្គល [១០១] ។ តាមការសម្ភាសន៍និស្សិតនៅវិទ្យាស្ថានជាតិអប់រំបានអោយដឹងថា ឪពុកម្តាយរបស់ពួកគេភាគច្រើនបានអប់រំពួកគេអោយប្រតិបត្តិគំនិតតាមប្រពៃណី ដោយអោយពួកគេយល់ដឹងខ្ពស់ទាប និងមានរបៀបរៀបរយ មានសីលធម៌ និងមានសណ្តាប់ធ្នាប់នៅក្នុងគ្រួសារ ។ ខ្លឹមសារអប់រំកូននៅក្នុងគ្រួសាររបស់និស្សិតទាំងនេះជាការជួយបណ្តុះពួកគេឱ្យមានជំនឿទុកចិត្តលើខ្លួនឯងដល់ពួកគេ ។ លោក Dorothy Law Nolte បានអះអាងថា ប្រសិនបើកុមាររស់នៅក្នុងភាពមានសណ្តាប់ធ្នាប់ពួកគេនឹងរៀនពីជំនឿទុកចិត្ត [១០២] ។

ឪពុកម្តាយដែលមានចំណេះដឹង និងចេះពីរបៀបអប់រំកូនជួយអោយកុមារមានការអោយតំលៃខ្លួនឯងខ្ពស់ ។ ហើយឪពុកម្តាយដែលមានការជឿជាក់ និងអោយតំលៃខ្លួនឯងខ្ពស់ក៏ជួយបណ្តុះការអោយតំលៃខ្លួនឯងដល់កូនរបស់គាត់កាន់តែខ្ពស់ថែមទៀត ។ នៅក្នុងប្រទេសខ្មែរ ពុំទាន់មានគោលនយោបាយណាមួយកំណត់អោយគ្រួសារជាអ្នកអប់រំទីមួយនៅឡើយ ។ ប៉ុន្តែ ឥទ្ធិពលប្រពៃណីក្នុងការអប់រំនៅក្នុងគ្រួសារបានដក់ជាប់នៅក្នុងផ្នត់គំនិតរបស់ពួកគាត់ ។ របៀបអប់រំឪពុកម្តាយនៅប្រទេសកម្ពុជាធ្វើទៅតាមទំលាប់ដែល

---

[៩៩] កៅ គីមហ៊ួន និង សំរ៉ាង កំសាន្ត : វិធីសាស្រ្តក្នុងការដោះស្រាយទំនាស់ - ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ទំព័រ ៣២ - ៣៣

[100] Read : Matthew Mckay , Ph.D Patrick Fanning , Self-Esteem, op.cit.

[101] ប៉ាង ខាត់ : ទឹកចិត្តម្តាយ ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ

[102] Dorothy Law Nolte, Guidance Tips to Enhance Positive Self-Esteem , http:/www.newhorizonchildcare.com/Home/Resources/self-esteem.html.

មនុស្សចាស់មើលឃើញពីរបៀបអប់រំមុនៗយកមកបន្តអប់រំដល់អ្នកជំនាន់ក្រោយបន្តទៀត ដោយមិនសូវគិតហេតុផលពីផលចំណេញ និងខាតដែលជះឥទ្ធិពលដល់អាកប្បកិរិយារបស់កូនខ្លួនឡើយ ។ ឪពុកម្តាយរបស់គរុនិស្សិតភាគច្រើនមានចំណេះដឹងនៅទាប ភាគច្រើនពួកគាត់ទាំងនោះជាកសិករ និងពាណិជ្ជករ ។ ឥទ្ធិពលនៃចំណេះដឹង និងការអប់រំរបស់ឪពុកម្តាយនេះក៏អាចជះឥទ្ធិពលដល់ការឱ្យតំលៃខ្លួនឯងរបស់គរុនិស្សិតទាំងនេះដែរ ។ ម្យ៉ាងវិញទៀត ឪពុកម្តាយជនជាតិខ្មែរនៅតែប្រកាន់ខ្ជាប់នៅឥទ្ធិពលប្រពៃណីនុំមិនធំជាងនាលដដែរ ហើយផ្នត់គំនិតចាស់នេះនៅតែមានឥទ្ធិពលដល់គ្រួសារខ្មែរបច្ចុប្បន្ន ។ នេះបង្ហាញថា ឪពុកម្តាយមានឥទ្ធិពល និងអំណាចលើកូនរបស់ខ្លួន ទោះកូនរបស់ខ្លួនមានហេតុផល និងគំនិតអាចទទួលយកបានក៏ដោយ ។ ការអប់រំធ្វើទៅតាម ទំលាប់ដោយអ្នកក្មេងជាងត្រូវធ្វើតាម និងគោរពតាមអ្នកចាស់ជាង ជាពិសេសឪពុកម្តាយ ព្រោះពួកគាត់ជាមេគ្រួសារដែលតែងតែមានឥទ្ធិពលលើសមាជិកនានាក្នុងគ្រួសារ ពិសេសលើកូនចៅ ។ ឪពុកម្តាយមិនសូវខ្វាយខ្វល់នឹងយល់ពីផលប៉ះពាល់ និងការបណ្តុះទឹកចិត្តដល់កូនរបស់គេឡើយ តែអាណាព្យាបាល មានការយកចិត្តទុកដាក់ដល់តំលៃលើកូនរបស់ខ្លួនត្រឹមតែចង់ឱ្យកូនរបស់ខ្លួនក្លាយជាមនុស្សល្អត្រឹមត្រូវប៉ុណ្ណោះ ។ ជាធម្មតា ឪពុកម្តាយជនជាតិខ្មែរមានការទូន្មានកូនរបស់ខ្លួនឱ្យក្លាយទៅជាមនុស្សល្អ ហើយស្រឡាញ់កូនខ្លួនដោយមិនស្តាប់ហេតុផល និងទទួលស្គាល់គំនិតរបស់កូនខ្លួនឡើយ ដោយពួកគាត់គិតថា កូនរបស់គាត់នៅក្មេងសេចក្តី ខ្វះការពិសោធន៍ក្នុងសង្គម ដូច្នេះពុំចាំបាច់ស្តាប់ហេតុផលរបស់កូនខ្លួនឡើយ ។ តាមការសម្ភាសន៍គរុនិស្សិតស្តីពីការអប់រំនៅក្នុងគ្រួសារបានបង្ហាញថា ឪពុកម្តាយរបស់ពួកគេមានការស្រលាញ់កូនខ្លួនប៉ុន្តែកម្រស្តាប់ហេតុផលរបស់ពួកគេឡើយ ហើយពួកគាត់ស្តាប់ហេតុផលនៅខណៈពេលកូនរបស់គាត់មានចំណេះដឹងខ្ពស់ ។ សកម្មភាពអប់រំនៅក្នុងគ្រួសារបែបនេះអាចមានផលប៉ះពាល់ដល់ការអោយតំលៃខ្លួនឯងរបស់មនុស្ស ។ លោក អ៊ឹម កុច បានបញ្ជាក់ថា កូនដែលមានភាពម្ចាស់ការ និងការអោយតំលៃខ្លួនឯងខ្ពស់សុទ្ធតែស្ថិតនៅក្នុងគ្រួសារដែលមានការពន្យល់ហេតុផល[១០៣] ។

ជាមួយគ្នានេះដែរ គ្រួសារនៅក្នុងសង្គមខ្មែរមានភាពក្រីក្រ ដែលជាកត្តាជំរុញអោយពួកគាត់មិនបានយកចិត្តទុកដាក់ និងអប់រំកូនអោយបានដិតដល់នៅឡើយ ។ អាណាព្យាបាលមានភាពក្រីក្រធ្វើអោយពួកគេមិនខ្វល់ខ្វាយដល់តម្រូវការខ្ពស់ ក្រៅតែពីការធ្វើយ៉ាងណារកស៊ីចិញ្ចឹមជីវិត និងមានជំរកសមរម្យដែលជាតម្រូវការទាបបំផុតរបស់មនុស្ស ។ ជាងនេះទៅទៀតអាណាព្យាបាលរបស់និស្សិតនៅវិទ្យាស្ថានជាតិអប់រំភាគច្រើនជាកសិករ និងពាណិជ្ជករដែលមានការអប់រំបានតិចតួច ។ ពួកគេរស់ក្នុងភាពក្រីក្រ ប្រទេសជាតិជួប

[103] អ៊ឹម កុច : របៀបអប់រំកូនក្នុងគ្រួសារ ដ.ឯ.ម. ទំព័រ ១៦

សង្គ្រាមស៊ីវិល ដោយមិនបានយកចិត្តទុកដាក់ក្នុងការទ្រទ្រង់ និងថែទាំដល់កូនរបស់ខ្លួនអោយបានហ្មត់ចត់ឡើយ ។ ប្រការនេះអាចកំណត់ដល់ជំនឿលើខ្លួនឯងរបស់គរុនិស្សិត ព្រោះនៅពេលនោះ ពួកគេបានស្ថិតនៅក្នុងស្ថានភាពបែបនោះ ។ នេះជាហេតុផលនាំអោយគរុនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យាមានការឱ្យតំលៃខ្លួនឯងមានកម្រិតមធ្យម ។ លោក Copper លោក Hulman និង លោក Brainwaite (1983) បានបញ្ជាក់ថា កុមារដែលមានគ្រួសារមិនមានការគាំទ្រ យកចិត្តទុកដាក់តែងតែមានការអោយតំលៃខ្លួនឯងទាប[១០៤] ។

ជាការពិត ការអោយតំលៃខ្លួនឯងរបស់និស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំនាពេលបច្ចុប្បន្នជាការទទួលបានមិតកពីបុព្វហេតុអតីតកាលជាមួយម្តាយឳពុករបស់ពួកគេ ។ អ្នកជំនាញខាងការអោយតំលៃខ្លួនជាច្រើនបានអះអាងប្រហាក់ប្រហែលគ្នាថា គ្រួសារជាអ្នកដើរតួនាទីដំបូងគេបង្អស់ក្នុងការកសាង និងស្ថាបនាការអោយតំលៃខ្លួនឯង ។ លោក Matthew Mckay និង លោក Patrick Fanning (2000) បានលើកឡើងថា ការជួយកុមារឱ្យរីកធំធាត់ជាមួយការអោយតំលៃខ្លួនឯងខ្ពស់គឺជាការកិច្ចដ៏សំខាន់បំផុតរបស់ឪពុកម្តាយ[១០៥] ។ រីឯតាមទ្រឹស្តីចិត្តវិភាគ យើងសង្កេតឃើញមានភាពប្រហែលគ្នានេះដែរ ព្រោះតាមទ្រឹស្តីនេះ អ្វីៗដែលមនុស្សមានរហូតមកដល់ពេលបច្ចុប្បន្នសុទ្ធតែមានឫសគល់ពីអតីតភាពរបស់ខ្លួន ។ តួយ៉ាងអាកប្បកិរិយានៃការឱ្យតំលៃខ្លួនឯងរបស់មនុស្សនាពេលបច្ចុប្បន្នសុទ្ធតែជាប់មរតកពីអតីតកាលរបស់ខ្លួន ពិសេសដំណើរវិវត្តន៍នៃដំណាក់កាលវ័យដំបូងរបស់មនុស្សនៅក្នុងគ្រួសារ ។ បទពិសោធន៍និងស្លាកស្នាមពីអតីតកាលដែលមនុស្សបានជួប និងឆ្លងបទពិសោធន៍នេះមានឥទ្ធិពលដល់អាកប្បកិរិយារបស់គេនាពេលបច្ចុប្បន្ន ។ ដូច្នេះ ទោះជានិស្សិតវិទ្យាស្ថានជាតិអប់រំមានការចំរើនវ័យវឌ្ឍការ និងមានចំណេះដឹងខ្ពស់នៅពេលបច្ចុប្បនេះក៏ដោយ ក៏ការអោយតំលៃខ្លួនឯងពិតជាទទួលឥទ្ធិពលពីកត្តាអប់រំក្នុងគ្រួសារ ។

សរុបសេចក្តីមក របៀបរបប និងវិធីអប់រំនៅក្នុងគ្រួសារនៅក្នុងសង្គមខ្មែរមានចំណុចវិជ្ជមានផងនិងអវិជ្ជមានផងក្នុងការបណ្តុះនូវអារម្មណ៍ការឱ្យតំលៃខ្លួនឯងរបស់មនុស្ស ។ ការអប់រំនៅក្នុងគ្រួសារ ដោយប្រើភាសាទន់ភ្លន់ ការស្រលាញ់ ការគាំទ្រគំនិតកូន ការផ្តល់អោយកូនមានគំនិតឯករាជ្យ និងការទទួលខុសត្រូវនៅមិនទាន់មានភាពរលូន និងនៅមានភាពស្មុកស្មាញ ច្របូកច្របល់នៅឡើយ ព្រោះឪពុកម្តាយជនជាតិខ្មែរនៅមានទង្វើ និងឥរិយាបថមិនទាន់យល់ហេតុផលក្នុងការបណ្តុះការអោយតំលៃខ្លួនឯង និងចំណេះដឹងនៅទាប ។ មាតាបិតាខ្មែរត្រូវតែមានរបៀបអប់រំកូនដោយប្រើប្រាស់ភាសាសរសើរអោយបានច្រើនជាងការ

---

[104] Rochhelle L. James, Correlation Between Adolescent Self-esteem Religiosity and Perceive Family Support, op.cit., p.on line.

[105] Matthew Mckay, Ph.D & Patrick Fanning , Self-Esteem, op.cit, p. 293-294

រិះគន់ មានហេតុផលក្នុងការវាយតំលៃដល់កូន និងផ្ដល់ចំណេះដឹងអប់រំខាងសីលធម៌ និងជំនាញសង្គម ព្រមទាំងផ្ដល់លទ្ធភាពអោយក្មេងចេះទទួលខុសត្រូវនិងជួយឱ្យពួកគេមានគំនិតឯករាជ្យខាងស្មារតី ។ ប្រការទាំងនេះជាចំណែកមួយដ៏សំខាន់ក្នុងការអភិវឌ្ឍដល់ការអោយតំលៃខ្លួនឯងរបស់គរុនិស្សិត ។

### ៥.១.២ - ស្ថានភាពអប់រំនៅសាលារៀនជាមួយការអោយតំលៃខ្លួនឯង

ការអប់រំនៅសាលារៀនជាហេតុផលមួយដ៏សំខាន់ក្នុងការអភិវឌ្ឍការឱ្យតំលៃខ្លួនឯងរបស់សិស្ស និងនិស្សិត ។ ជាទូទៅ ការអប់រំនៅប្រទេសកម្ពុជាបានដើរតួនាទីសំខាន់ក្នុងការបណ្ដុះបាននូវសីលធម៌ ចំណេះ ដឹង និងចំណេះធ្វើសំរាប់សិស្ស និងនិស្សិត ពោលគឺជួយអោយពួកគេក្លាយជាអ្នកតស៊ូស្និតស្នាញ ឬជាអ្នកផលិត ។ ខ្លឹមសារមេរៀននៅតាមកម្មវិធីសិក្សាបានបង្កប់នូវអត្ថន័យ សីលធម៌ ចរិយាធម៌រួចជាស្រេច ។ ជាការជាក់ស្ដែង នៅវិទ្យាស្ថានជាតិអប់រំ មុខវិជ្ជាសីលធម៌វិជ្ជាជីវៈត្រូវបានយកមកអនុវត្តក្នុងកម្មវិធីសិក្សា ។ សីលធម៌ជាសរសរស្ដម្ភមួយនៅក្នុងសមាសធាតុនៃការឱ្យតំលៃខ្លួនឯងរបស់មនុស្សគ្រប់រូប និងសំរាប់ទ្រទ្រង់ដល់ការជឿជាក់ និងការអោយតំលៃខ្លួនឯងរបស់មនុស្ស ។ និស្សិតមានសីលធម៌មានសុខភាពផ្លូវចិត្តល្អ មានចិត្តរួសរាយ រាក់ទាក់ ដោយគេមានជំនឿចិត្តលើតំលៃខ្លួនឯងចំពោះក្រសែភ្នែករបស់មនុស្សជុំវិញ ។ ខ្លឹមសារសីលធម៌នៅក្នុងសាលារៀនត្រូវបានគេបញ្ចូលនៅក្នុងមេរៀនសីលធម៌វិជ្ជាជីវៈ មេរៀនសុជីវធម៌ និងបង្កប់នៅក្នុងខ្លឹមសារមេរៀននៃមុខវិជ្ជាផ្សេងៗទៀត ។ មនុស្សមានការជឿជាក់ហ៊ានសំដែងអាកប្បកិរិយាទំនាក់ទំនងជាមួយអ្នកដទៃដោយគេសំអាងទៅលើគុណធម៌របស់គេ ។ ដូចនេះ ការអប់រំបង្កប់ខ្លឹមសារសីលធម៌នៅតាមកម្មវិធីសិក្សាចាប់ពីថ្នាក់ក្រោមរហូតមកដល់វិទ្យាស្ថានជាតិអប់រំនេះពិតជាជួយរួមចំណែកក្នុងការអភិវឌ្ឍការអោយតំលៃខ្លួនឯងរបស់សិស្ស និងនិស្សិតមួយផ្នែក ។

ហេតុផលដែលកំណត់ដល់ការអោយតំលៃខ្លួនឯងរបស់និស្សិតនៅមហាវិទ្យាល័យអាចមកពីកត្តាជីវភាពរស់នៅរបស់គ្រូបង្រៀន ។ ស្ថានភាពរស់នៅរបស់គ្រូបង្រៀនស្ថិតក្នុងភាពក្រីក្រ ខ្វះខាតក្នុងជីវភាពរស់នៅដែលជាកត្តាអាចបង្កអោយមានអំពើវាយតំលៃមិនយុត្តិធម៌ចំពោះសិស្ស ។ គ្រូបង្រៀនខ្វះការស្រាវជ្រាវអោយបានដិតដល់ដោយគ្រូមិនបានស្រាវជ្រាវរកវិធីល្អនិងទំនើប ដើម្បីរកវិធីសាស្ត្រនិងបច្ចេកទេសបង្រៀនដើម្បីជួយដល់ការឱ្យតំលៃខ្លួនឯងរបស់សិស្សនិងនិស្សិត ។ គ្រូបង្រៀនមួយចំនួនសម្រេចចិត្តធ្វើការអាជីពមួយផ្សេងទៀតបន្ថែម ដើម្បីទ្រទ្រង់ជីវភាពរបស់ពួកគេ នេះជាហេតុផលដែលនាំអោយពួកគាត់មានការបង្រៀនមិនបានល្អ មិនយកចិត្តទុកដាក់ឱ្យបានដិតដល់ក្នុងការងារបង្រៀនរបស់ខ្លួន ។ ការនេះអាចនាំអោយសិស្សនិស្សិតមានអារម្មណ៍ធ្វើយណាយ អស់ថាមពលផ្លូវចិត្ត និងគ្មានចិត្តចង់រៀន ។ លើសពីនេះទៅទៀត អំពើអយុត្តិធម៌ក្នុងការវាយតំលៃ និងការជ្រើសរើសតាមបក្សពួកក៏ជាកត្តាជំរុញអោយមានការប៉ះពាល់ដល់ការឱ្យ

តំលៃខ្លួនឯងរបស់សិស្សនិងនិស្សិតផងដែរ ។ និស្សិតបានមើលឃើញពីគំរូមិនល្អរបស់គ្រូបង្រៀនដែលជាហេតុនាំអោយពួកគេមិនសូវមានកំលាំងចិត្តក្នុងការសិក្សា ឡើយណាយ ទៅនឹងភាពមិនស្មោះត្រង់នឹងវិជ្ជាជីវៈរបស់គ្រូបង្រៀន ។ សមាសធាតុនេះបានដក់ជាប់ក្នុងចិត្តរបស់និស្សិតបន្តិចម្តងៗ ដែលជាហេតុជំរុញអោយការឱ្យតំលៃខ្លួនឯងរបស់និស្សិតមានការថយចុះ ។ តាមគោលការណ៍ណែនាំរបស់អង្គការយូនីសែហ្វស្តីពីការអោយតំលៃខ្លួនឯងបានកំណត់ថា នៅពេលណាមនុស្សមានកំលាំងចិត្តខ្សោយ និងមិនមានលក្ខណៈយុត្តិធម៌ នោះមនុស្សនោះមានការអោយតំលៃខ្លួនឯងក្នុងកម្រិតទាប[១០៦] ។

សាលារៀននៅ ប្រទេសកម្ពុជាបានបញ្ចូលនូវកម្មវិធីកាយសិក្សា(ការអប់រំកាយ)ចាប់ពីបឋមសិក្សារហូតដល់មធ្យមសិក្សា រីឯនៅវិទ្យាស្ថានជាតិអប់រំក៏មានកម្មធីកាយសិក្សានេះដែរ ។ ការអប់រំរាងកាយជួយឱ្យកាយសម្បទារបស់សិស្ស និស្សិតមានភាពមាំទាំ រហ័សរហួន និងជួយដល់ការរីកលូតលាស់បញ្ញាញាណរបស់សិស្សប៉ុណ្ណោះទេ តែថែមទាំងបណ្តុះការជឿជាក់ និងការអោយតំលៃខ្លួឯងរបស់គេថែមទៀត ។ លោក Kirchner និងលោក Fishburne (1995) បានបញ្ជាក់ថា បរិយាកាសអប់រំខាងរាងកាយជួយទាំងជំរុញនិងរាំងដល់រូបភាពចិត្ត (self-image) របស់សិស្ស[១០៧] ។

ទោះជាយ៉ាងនេះក៏ដោយ ការអប់រំនៅកំឡុងទស្សវត្ស ១៩៨០ វិធីសាស្ត្រអប់រំច្រើនតែធ្វើតាមលក្ខណៈគ្រូមជ្ឈមណ្ឌល ដោយសិស្សមិនបានពិភាក្សាដេញដោល បញ្ចេញយោបល់ក្នុងក្រុម ដើម្បីបណ្តុះភាពក្លាហាន ហ៊ានទទួលខុសត្រូវចំពោះគំនិតរបស់ខ្លួន ក្រៅតែស្តាប់គ្រូឧទ្ទេស និងការសូត្រតាមគ្រូ ។ រីឯខ្លឹមសារមេរៀនច្រើនផ្តោតទៅលើសីលធម៌នយោបាយកម្មុយនីស បណ្តុះចិត្តសិស្សអោយស្រលាញ់តែលិទ្ធិមួយ ដោយមិនបានបង្ហាញលិទ្ធិមួយទៀតអោយសិស្សមើលឃើញ និងធ្វើការប្រៀបធៀប ។ និស្សិតវិទ្យាស្ថានជាតិអប់រំទាំងនេះបានទទួលមិតកអប់រំមិនប្រកបដោយលទ្ធិប្រជាធិបតេយ្យ កាលពីពួកគេជាសិស្សនៅកម្រិតសិក្សាតំបូង ។ តាមឯកសាររបស់អង្គការយូនីសែហ្វបានអោយដឹងថា លក្ខណៈប្រជាធិបតេយ្យជាសមាសធាតុមួយជួយឱ្យមានការអោយតំលៃខ្លួឯងខ្ពស់[១០៨] ។

នៅវិទ្យាស្ថានជាតិអប់រំ គ្រូមានការយកចិត្តទុកដាក់ និងការវាយតំលៃស្នាដៃសិស្សមានលក្ខណៈយុត្តិធម៌ ។ និស្សិតដែលធ្វើការសម្ភាសន៍ភាគច្រើនបានបញ្ជាក់ថា ការវាយតំលៃស្នាដៃប្រលង និងវិន័យមានលក្ខណៈហ្មត់ចត់ត្រឹមត្រូវ ។ រីឯសម្ភារៈសិក្សា និងឧបករណ៍វិទ្យាសាស្ត្រមានលក្ខណៈទំនើប ។ គរុនិស្សិតក៏

[106] Unicef : Guide Self – Awareness,op.cit., p.9
[107] Kirchner & Fishburne, Physical Education for Elementary School Children, USA, WCB. Brown & Benchmark, 1995, p.9
[108] Unicef : Guide Self – Awareness,op.cit., p.9

មានការពេញចិត្តទៅនឹងកម្មវិធីសិក្សាដែលមានការសិក្សាច្រើនម៉ោងនៅក្នុងថ្នាក់រៀន ។ បរិយាកាសនៅវិទ្យាស្ថានជាតិអប់រំជួយអោយនិស្សិតមានកំលាំងចិត្តចង់សិក្សា ដែលនេះជាជំនួយក្នុងការបណ្តុះការឱ្យតំលៃខ្លួនឯងរបស់ពួកគេនៅពេលបច្ចុប្បន្នបន្ថែមទៀត ។ ទោះជាបែបនេះក៏ដោយ កម្រិតសមត្ថភាពរបស់សាស្ត្រាចារ្យនៅវិទ្យាស្ថានជាតិអប់រំអាចបង្ករអោយមានការប៉ះពាល់ដល់អារម្មណ៍របស់គរុនិស្សិតផងដែរ ដោយភាគច្រើន និស្សិតបានមើលឃើញថា គ្រូរបស់ពួកគេមានកម្រិតតសមត្ថភាពនៅមានកំណត់ ។ ប្រការខាងលើនេះជាការបណ្តុះបានដល់ការអោយតំលៃខ្លួនឯងរបស់និស្សិតមានកំណត់ ។ ទោះជាយ៉ាងនេះក៏ដោយ ការឱ្យតំលៃខ្លួនឯងមិនត្រឹមតែកើតឡើងនៅពេលនិស្សិតទទួលបានការអប់រំនៅវិទ្យាស្ថានជាតិអប់រំនោះទេ វាមានប្រភពនិងឫសគល់របស់វានៅក្នុងការអប់រំចាប់តាំងពីនិស្សិតទាំងនោះបានទទួលការអប់រំចាប់ពីកម្រិតមូលដ្ឋានមកម្លេះ ។ នៅប្រទេសកម្ពុជា ការបង្ហាញ ការពន្យល់ប្រាប់អំពីមោទនភាពជាតិ តំលៃសីលធម៌ និងគុណធម៌ត្រូវបានគេយកមកពិភាក្សា និងអនុវត្តនៅក្នុងថ្នាក់រៀន ជាពិសេសលើមុខវិជ្ជាពលរដ្ឋវិជ្ជាជាដើម ។ ការណែនាំអំពីអំពើល្អ ការចេះគោរពគ្នា ការទំនាក់ទំនងគ្នារបស់សិស្សត្រូវបានបង្កប់នៅក្នុងការពិភាក្សានៅក្នុងថ្នាក់រៀន ។ លើសពីនេះទៅទៀត វិធីពិភាក្សានេះរឹតតែជួយពួកគេឱ្យមើលឃើញពីតំលៃនិងភាពខ្លាំងរបស់គេ ។ ទាំងនេះជាការបណ្តុះការអោយតំលៃខ្លួនឯងរបស់សិស្ស ។ ប៉ុន្តែ គ្រូបង្រៀនទាំងនោះនៅខ្វះខាតការយល់ដឹងអំពីវិធីនិងយុទ្ធសាស្ត្របង្រៀនដែលជួយអោយសិស្សរីកលូតលាស់ស្មារតីខាងការអោយតំលៃខ្លួនឯង ពីព្រោះកាលនៅពេលដែលពួកគាត់នៅសិក្សាគ្មានមេរៀនណាមួយជាក់លាក់បង្ហាញបច្ចេកទេស និងពីរបៀបបណ្តុះការអោយតំលៃខ្លួនឯងនេះឡើយ ។ ចំណុចនេះមានការលំបាកក្នុងការផ្ទេរ និងផ្តល់ការអោយតំលៃខ្លួនឯងទៅសិស្ស ព្រោះពេលនោះ មនុស្សមានចំណេះដឹងច្រើនបង្រៀនមនុស្សមានចំណេះដឹងតិច ហើយអ្នកមានចំណេះដឹងតិចតួចបង្រៀនអ្នកមិនមានចំណេះដឹងសោះ ដោយសារតែកង្វះខាតធនធានមនុស្ស ពោលការឱ្យតំលៃខ្លួនឯងរបស់សិស្សទទួលបានតែពីការបង្កប់ខ្លឹមសារនៅក្នុងកម្មវិធីសិក្សាតែប៉ុណ្ណោះ ។ ការអប់រំនៅសាលារៀននេះមានសារៈសំខាន់ក្នុងការបណ្តុះបានការឱ្យតំលៃខ្លួនឯងរបស់សិស្សនិងនិស្សិត ។ មើលឃើញពីតំលៃដ៏មានសារៈសំខាន់ ដើម្បីអភិវឌ្ឍការអោយតំលៃរបស់មនុស្សតាមរយៈសាលារៀន ទើបលោក Lilian G. Katz បានផ្តល់តំបូន្មានថា អ្នកអប់រំត្រូវគិតឡើងវិញអំពីយុទ្ធសាស្ត្រធ្វើយ៉ាងណា ដើម្បីជំរុញការអោយតំលៃខ្លួនឯងរបស់សិស្ស និស្សិតចំរើនឡើង[១០៩] ។

[109] Lilian G. Katz, Distinction between Self-esteem and Narcissism: implications for Practice, op.cit., p.on line.

សរុបសេចក្តីមក ការអប់រំដោយរួមមានខ្លឹមសារការអោយតំលៃខ្លួនឯងក្នុងកម្មវិធីសិក្សា វិធីសាស្ត្របង្រៀនរបស់គ្រូ សម្ភារៈសិក្សា និងបរិយាកាសសាលារៀនជួយអោយនិស្សិតសំរេចបាននូវចំណេះដឹង ចំណេះធ្វើ និងតំលៃសីលធម ។ នៅពេលនិស្សិតសម្រេចបាននូវសមិទ្ធផលទាំងនេះ សិស្ស និងនិស្សិតនឹងទទួលបានការអោយតំលៃខ្លួនឯងខ្ពស់ ។

**៥.១.គ - ស្ថានភាពបរិស្ថានជាមួយការអោយតំលៃខ្លួនឯង**

ហេតុផលមួយផ្សេងទៀតដែលកំណត់ដល់ការឱ្យតំលៃខ្លួនឯងក្នុងកម្រិតមធ្យមរបស់និស្សិតនៅវិទ្យាស្ថានជាតិអប់រំគឺអាស្រ័យដោយកត្តាមជ្ឈដ្ឋាន ដែលរាប់បញ្ចូលប្រព័ន្ធផ្សព្វផ្សាយ ឥទ្ធិពលសាសនា ទំនៀមទំលាប់ប្រពៃណី និងរបបដឹកនាំសង្គមជាដើម ។ តាមប្រវត្តិសាស្ត្រចុងក្រោយនេះ ប្រទេសកម្ពុជាបានទទួលរងសង្គ្រាម ការឈ្លោះប្រកែកបាក់បែកគ្នា ដោយខកខានមិនបានកសាងគំរូមនុស្សល្អនៅក្នុងសង្គមអោយបានច្រើន ។ ឥទ្ធិពលសង្គ្រាមនេះមិនត្រឹមតែធ្វើអោយប្រទេសជាតិខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធសង្គមប៉ុណ្ណោះទេ តែថែមទាំងបណ្តាលអោយមនុស្សក្នុងសង្គមនោះមានសីលធម៌ធ្លាក់ចុះ និងធ្វើអោយជំនឿលើការអោយតំលៃខ្លួនឯងមានការថយចុះដែរ ទាំងនេះហើយដែលជាកត្តាធ្វើអោយប្រជាពលរដ្ឋខ្មែរកើតជំងឺមិនទុកចិត្តគ្នាឯង ។ លោក កៅ គីមហ៊ួន បានសរសេរថា សង្គ្រាម និងវិនាសកម្មរ៉ាំរ៉ៃក្នុងពីរទសវត្សចុងក្រោយនេះបានធ្វើអោយប្រជារាស្ត្រកម្ពុជាបាត់បង់អស់ជំនឿ ទំនុកចិត្ត និងក្តីសង្ឃឹមរបស់ខ្លួនចំពោះអនាគត និងសុភមង្គលរបស់ប្រទេសជាតិ [១១០] ។ បន្ទាប់ពីសង្គ្រាម ប្រជាពលរដ្ឋ រួមទាំងអាណាព្យាបាលនិស្សិតនៅវិទ្យាស្ថានជាតិអប់រំពុំសូវខ្វាយខ្វល់យកចិត្តទុកដាក់លើតំលៃសីលធម ដោយពួកគាត់គិតតែកែខៃជីវិតរបស់ខ្លួន ដើម្បីតែរស់នៅឱ្យបានសមរម្យប៉ុណ្ណោះ ដោយពុំទាន់គិតគូ និងនឹកឃើញទៅដល់តម្រូវការខ្ពស់បំផុតឡើយ ។

ម៉្យាងវិញទៀត ប្រព័ន្ធផ្សព្វផ្សាយក៏ជាចំណែកក្នុងការបណ្តុះដល់ផ្លូវចិត្តរបស់មនុស្សផងដែរ ។ ប្រព័ន្ធផ្សព្វផ្សាយដែលបង្ហាញនូវវប្បធម៌ពាលា ហិង្សា ជំលោះទាស់ទែងគ្នា និងការផ្សព្វផ្សាយគ្មានការត្រួតពិនិត្យគិតដល់ការប៉ះពាល់ដល់ផ្លូវចិត្តរបស់អ្នកអាន អ្នកមើល ពិតជាសមាសធាតុសំខាន់ដែលមានឥទ្ធិពលលើមនុស្សគ្រប់រូប ដោយនាំអោយពួកគេដក់ជាប់ក្នុងផ្លូវចិត្តរបស់គេពីមួយថ្ងៃទៅមួយថ្ងៃ ហើយឥទ្ធិពលនេះពិតជាប៉ះពាល់ដល់ការអោយតំលៃខ្លួនឯងរបស់មនុស្សគ្រប់រូប ។ ក្នុងនោះ និស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យាក៏ស្ថិតក្រោមឥទ្ធិពលនៃប្រពន្ធ័ផ្សព្វផ្សាយនោះដែរ ហើយពួកគេបានរៀនតាមគំរូកាយវិកា និងទទួលបាននូវខ្លឹមសារហិង្សាឃោឃៅពីប្រពន្ធ័ផ្សព្វផ្សាយជារៀងរាល់ថ្ងៃ ។ តាមគោលការណ៍ណែនាំស្តីពីការស្គាល់ខ្លួនឯងរបស់

---

[110] កៅ គីមហួន និងស សុកន្តន័យ សន្តិភាពផ្លូវចិត្ត - ជ.ឯ.ម- ទំព័រ ៣៥

អង្គការយូនីសេហ្វបានលើកឡើងថា គំនិតឈ្លោះទាស់ទែងគ្នា ការប្រើការបង្ខិតបង្ខំ អារម្មណ៍គ្មានភាពគាំទ្រ (Aggressive, insecure, Arrogance) ជាអាកប្បកិរិយានាំឱ្យមានការអោយតំលៃខ្លួនឯងកម្រិតទាប[១១១] ។

តាមហេតុការណ៍ចុងក្រោយ ប្រទេសកម្ពុជាបានប្រកាន់នូវរបបនយោបាយកម្មុយនីសពីឆ្នាំ ១៩៧៥ ដល់ចុងទស្សវត្ស១៩៨០ ដែលនៅក្នុងរបបនេះគេមិនបានផ្តល់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិអោយទូលាយ ហើយរឿងរ៉ាវដែលគេចង់បញ្ចេញត្រូវបានរាំងស្ទះ ទោះជាគេមានគំនិតសមហេតុផលក៏ដោយ ។ ប្រជាពលរដ្ឋខ្មែរនៅសម័យប៉ុលពតមិនបានប្រកាន់នូវរបបប្រជាធិបតេយ្យ និងគ្មានសេរីភាពគ្រប់គ្រាន់ ហើយរស់នៅយ៉ាងអយុត្តិធម៌ដែលការនេះជះឥទ្ធិពលដល់មជ្ឈដ្ឋានដែលគេកំពុងរស់នៅ ។ របបសង្គមនេះបានធ្វើអោយមនុស្សខួបក្លាចបាក់ស្បាត និងបានបន្តមិតកទាំងនេះរហូតដល់សព្វថ្ងៃនេះទៀត ។ បន្ទាប់មកទៀត របបសង្គមមានសភាពធូរស្រាល ប៉ុន្តែសង្គមនៅតែមិនបានបើកចំហទូលាយខាងការបញ្ចេញមតិ គ្មានចរិតប្រជាធិបតេយ្យ គ្មានតម្លាភាព និងមានអំពើពុករលួយ ។ ឥទ្ធិពលនេះពិតជាមានឥទ្ធិពលដល់និស្សិត ព្រោះម្តាយឪពុក និងមនុស្សក្នុងសង្គមបានចែករំលែក និងផ្ទេរមិតកផ្លូវចិត្តទាំងនេះដល់កូនរបស់ខ្លួនទាំងមិនដឹងខ្លួន ។ ដូចនេះ ពលរដ្ឋនៅក្នុងរបបសង្គមនេះពិតជាមានការឱ្យតំលៃខ្លួនឯងក្នុងកម្រិតមួយទាបបំផុត ព្រោះតាមអ្នកប្រាជ្ញរបស់អង្គការយូនីសេហ្វបានបញ្ជាក់ថា អាកប្បកិរិយាដែលបង្ហាញអំពីគំនិតទុទិដ្ឋិនិយម អារម្មណ៍គ្មានសុវត្ថភាពផ្លូវចិត្ត និងសកម្មភាពឃោឃៅកំរោលចូល គ្មានភាពយុត្តិធម៌ និងគ្មានគំនិតប្រជាធិបតេយ្យច្រើនតែជាអាកប្បកិរិយារបស់មនុស្សមានការអោយតំលៃខ្លួនឯងក្នុងកម្រិតទាប (Low Self-Esteem)[១១២] ។ គរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំទាំងនេះ ពិតជាទទួលឥទ្ធិពលអវិជ្ជមានទាំងនោះជាក់ជាមិនខានពីសង្គមរបស់គេសព្វថ្ងៃនេះ ពីព្រោះពួកគេបាននឹងកំពុងតែរស់នៅជាមួយមនុស្សដែលធ្លាប់ឆ្លងកាត់នៅរបបសង្គមបែបនោះ ។

ជាមួយគ្នានេះដែរ ការអោយតំលៃខ្លួនឯងក៏ទទួលបានពីឥទ្ធិពលវប្បធម៌រស់នៅប្រចាំថ្ងៃផងដែរ ។ របៀបទំនាក់ទំនងក្នុងសង្គម ផ្នត់គំនិតរស់នៅរបស់ពលរដ្ឋខ្មែរក្នុងអំណោយផលធម្មជាតិរស់ស្រួល និងរបៀបរស់នៅដោយមានមនោសញ្ចេតនាជ្រាលជ្រៅជាងផ្លូវច្បាប់ជាការចម្លងនូវសកម្មភាពផ្លូវចិត្ត (mentality) ពីមនុស្សជំនាន់មួយទៅជំនាន់មួយទៀត ។ និស្សិតខ្មែរក៏ដូចជាប្រជាពលរដ្ឋខ្មែរភាគច្រើនធ្វើអ្វីៗអាងមានគ្នា មិនមានលក្ខណៈឯកត្តបុគ្គលឡើយ ។ មរតកនេះបានចាក់ឫស នៅក្នុងសង្គមខ្មែរយូរលង់មកហើយ ដូចជាគេបានមើលឃើញនៅក្នុងឃ្លាប្រយោគមួយដែលលើកឡើងថា "ដើរអោយមានបី ស្រដីអោយមានបួន" ជាដើម ។ ការនេះបង្ហាញថា ពលរដ្ឋខ្មែរធ្វើអ្វីត្រូវមានគ្នាធ្វើជាមួយ ដើម្បីចែករំលែកការជួយគ្នា និងពឹងពាក់

---

[111] Unicef $P^2D$ Guide : Self – Awareness , op.cit., p.9
[112] Ibid., p.9

គ្នាទៅវិញទៅមក ប៉ុន្តែវាបានកំណត់ដល់ការអោយតំលៃខ្លួនឯងរបស់ពលរដ្ឋខ្មែរ ។ ឧទាហរណ៍ សិស្ស និង និស្សិតខ្មែរធ្វើការប្រលង ឬរាត់ការទំនាក់ទំនងផ្សេងៗតែងតែពឹងពាក់មនុស្សដទៃទៀតអោយជួយខ្លួន ដើម្បី ខ្លួនសម្រេចគោលដៅ ។ លោក Lilian G. Katz (1993) បានបង្ហាញពីភាពខុសគ្នានៃការអោយតំលៃ ខ្លួនឯងរបស់ពលរដ្ឋលោកខាងកើត និងលោកខាងលិចថា ប្រជាពលរដ្ឋនៅអាស៊ីមានការអោយតំលៃខ្លួនឯង បែបអន្តរឯករាជ្យ (inter-independent self-esteem ) រីឯពលរដ្ឋនៅក្នុងសង្គមលោកខាងលិចមានការ អោយតំលៃខ្លួនឯងបែបស្វ័យឯករាជ្យ (independent self-esteem) [១១៣] ។ ផ្នត់គំនិតខ្មែរដែលមានមនោ សញ្ចេតនាយ៉ាងជ្រៅក្នុងការជួយគ្នា និងពឹងពាក់គ្នាជាការជួយអោយពលរដ្ឋខ្មែរមានការអោយតំលៃខ្លួនឯង អន្តរឯករាជ្យដែលទាល់តែមានគ្នា ទើបនាំអោយគេមានការជឿជាក់ក្នុងការងារ ។ ក្នុងនោះគរុនិស្សិតផ្នែក វិទ្យាសាស្ត្រ និងគណិតវិទ្យាក៏ស្ថិតក្រោមឥទ្ធិពលវប្បធម៌នេះដែរ ។ ដូច្នេះ និស្សិតមានជំនឿលើខ្លួនឯង និង ការអោយតំលៃខ្លួនឯងកម្រិតមធ្យមនេះក៏ទទួលបានពីឥទ្ធិពលវប្បធម៌សង្គមទាំងនេះដែរ ។

ជាការជាក់ស្តែង និស្សិតនៅវិទ្យាស្ថានជាតិអប់រំនឹងមើលឃើញពីមុខរបរជាក់លាក់របស់គេនៅថ្ងៃ អនាគត ។ ពួកគេនឹងក្លាយទៅជាគ្រូបង្រៀន ។ ការនេះជួយអោយនិស្សិតមើលឃើញពីបំណងច្បាស់លាស់ របស់គេដែលជួយជំរុញពួកគេអោយមានកំលាំងចិត្តចង់សិក្សាកាន់តែខ្លាំងថែមទៀត ។ និស្សិតភាគច្រើនបាន បញ្ជាក់ថា ពួកគេមានចិត្តចង់រៀនក៏ដោយសារពួកគេមើលឃើញពីបំណងរបស់គេជាគ្រូបង្រៀន។ ពួកគេគិតថា វាជាមុខរបរដែលមានសុវត្ថភាព ។ ផ្អែកលើលទ្ធផលស្រាវជ្រាវបង្ហាញថា និស្សិតដែលមានគោលបំណងជាក់ លាក់មានកំលាំងចិត្តចង់សិក្សា ដោយសារពួកគេឱ្យតំលៃលើខ្លួនឯង ។ ដូច្នេះការឱ្យតំលៃខ្លួនឯងរបស់មនុស្ស ពិតជាអាស្រ័យលើការមើលឃើញគោលបំណងជាក់លាក់ ។ ការដែលនិស្សិតមើលឃើញពីបំណងច្បាស់លាស់ ពួកគេនឹងមានកំលាំងចិត្តចង់សិក្សា និងធ្វើសកម្មភាពកាន់តែខ្លាំងក្លាឡើងដែលជួយឱ្យពួកគេមានការជឿជាក់ លើខ្លួនឯង ។ ទោះជាយ៉ាងនេះក៏ដោយ កម្រៃនៃមុខរបរមិនគ្រប់គ្រាន់សំរាប់និស្សិតដែលចេញពីសាលារៀន ជាការជំរុញឱ្យពួកគេមានអារម្មណ៍អស់សង្ឃឹម មានអារម្មណ៍មិនសូវមានសុវត្ថភាពក្នុងគោលបំណងរបស់ខ្លួន និងមិនសូវមានការពេញចិត្តទៅនឹងស្ថានភាពបែបនេះដែរ ។ គេមានការដុះគំនិត ទុទិដ្ឋិនិយមចំពោះការសិក្សា និងចំពោះអនាគតការងារដែលមានប្រាក់បៀវត្សរ៍មិនសមរម្យ ។ សមាសធាតុនេះជាចលករខាងក្រៅ ប៉ុន្តែវា ធ្វើអោយប៉ះពាល់ដល់ផ្លូវចិត្តរបស់សិស្សនិងនិស្សិត ។ តាមអ្នកប្រាជ្ញរបស់ អង្គការយូនីសេហ្វបានបញ្ជាក់ថា

[113] Lilian G. Katz, Distinction between Self-esteem and Narcissism: implications for Practice, op.cit., p.on line

អារម្មណ៍មិនមានសុវត្ថភាព គ្មានការគាំទ្រ និងមានគំនិតទុទិដ្ឋិនិយមជាអាកប្បកិរិយា ដែលតម្រង់ទៅរកការអោយតំលៃខ្លួនឯងក្នុងកម្រិតទាប [១១៤] ។

ថ្វីត្បិតតែសមាសធាតុមួយចំនួននៃមជ្ឈដ្ឋានសង្គមបានជះឥទ្ធិពលដល់ការឱ្យតំលៃខ្លួនឯងអវិជ្ជមាន និងមានការប៉ះពាល់ដល់ការអោយតំលៃខ្លួនរបស់សិស្ស និងនិស្សិតខ្មែរក៏ដោយ តែឥទ្ធិពលព្រះពុទ្ធសាសនាដើរតួនាទីយ៉ាងចំបងក្នុងការបណ្តុះជំនឿដល់ពលរដ្ឋខ្មែរ ដែលអាចនិយាយបានថា លទ្ធិ និងទស្សនៈវិជ្ជាព្រះពុទ្ធសាសនាដើរតួក្នុងការជួយអភិវឌ្ឍការអោយតំលៃខ្លួនឯងរបស់ពលរដ្ឋកម្ពុជា ក្នុងនោះគឺនិស្សិតនៅវិទ្យាស្ថានជាតិអប់រំផងដែរ ។ នៅក្នុងសង្គមខ្មែរ ប្រជាពលរដ្ឋមានជំនឿលើព្រះពុទ្ធសាសនាតាំងតែនៅពេលកុមារមកម្លេះ ។ ពួកគេបានមើលឃើញការប្រតិបត្តិសាសនារបស់ឪពុកម្តាយរបស់គេជាប្រចាំ ។ ឥទ្ធិពលរបស់មនុស្សចាស់ (ឪពុកម្តាយ) ក្នុងការអោយកូនឃើញ និងជាគំរូដល់កូនពីមួយថ្ងៃទៅមួយថ្ងៃអាចស្ថិតក្នុងចិត្តគំនិតនិងអារម្មណ៍របស់កូនខ្លួន ។ ម្យ៉ាងវិញទៀត ដោយសារសាសនានេះមានខ្លឹមសារ និងអត្ថន័យបង្កប់នូវការអោយតំលៃលើមនុស្សខ្ពស់បំផុត ដូចជាខ្លឹមសារលើកឡើងថា ខ្លួនត្រូវតែទីពឹងខ្លួន នោះមនុស្សប្រកាន់សាសនានេះមានការអោយតំលៃខ្លួនឯង និងជឿជាក់លើខ្លួនឯងកាន់តែខ្ពស់ ដោយមិនជឿជាក់លើកំលាំងអទិទេពឬព្រះជាម្ចាស់ឡើយ ។ លោក មីសែល ត្រាណេ បានលើកឡើងថា ដើម្បីអោយខ្មែរមានការទុកចិត្តលើខ្លួនឯង និងលើវាសនាជាតិខ្មែរឡើងវិញ បន្ទាប់ពីបែកបាក់សង្គ្រាម នោះស្តេចជ័យវរ្ម័នទី៧ បានអនុលោមផែនការនយោបាយតាមគន្លងលទ្ធិព្រះពុទ្ធសាសនា ដោយលើកតំលៃខ្ពស់លើវិស័យសីលធម៌ ព្រហ្មវិហារធម៌ ពោលគឺមនោគមវិជ្ជាសាសនា ។ ប្រភពនៃជំនឿជឿជាក់លើខ្លួនឯងនេះត្រូវបានព្រះអង្គរកឃើញនៅក្នុងព្រះពុទ្ធសាសនាដែលបានផ្តល់ជូនចំពោះព្រះអង្គ និងជនជាតិខ្មែររបស់ព្រះអង្គនូវថាមពលដ៏ធំធេងមួយដែលមិនចេះរីងស្ងួតនឹងកសាងប្រទេសជាតិឡើងវិញ [១១៥] ។ ហេតុផលនេះដែលបង្ហាញថា ព្រះពុទ្ធសាសនាជួយឱ្យប្រជាពលរដ្ឋខ្មែរមានការឱ្យតំលៃខ្លួនឯង ហើយឥទ្ធិពលសង្គមដែលប្រកាន់ជំនឿព្រះពុទ្ធសាសនាជួយដល់ការឱ្យតំលៃខ្លួនឯងរបស់ពលរដ្ឋខ្មែរ ជាពិសេស សិស្ស និងនិស្សិតខ្មែរដែលមានចំណេះដឹងជ្រៅជ្រះ ។ ឥទ្ធិពលសាសនាមានឥទ្ធិពលដល់ផ្លូវចិត្តរបស់និស្សិតនៅវិទ្យាស្ថានជាតិអប់រំ ដោយពួកគេបានទទួលនូវជំនឿជាមួយគ្រួសាររបស់គេតាំងពីកុមារ ហើយពេលគេធំឡើងគេបានយល់ជ្រាបនូវខ្លឹមសារព្រះពុទ្ធសាសនា តាមរយៈការសិក្សារបស់គេ

[114] Unicef P$^2$D Guide : Self – Awareness , op.cit., p.9

[115] មី សែល ត្រាណេ : ប្រវត្តិសាស្ត្រនៃកម្ពុជា-សង្គមខ្មែរក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ទំព័រ ១៤ - ២៤

និងពីមជ្ឈដ្ឋានជិវិញខ្លួនគេថែមទៀត ។ លោក Habib បានបញ្ជាក់ថា និស្សិតនៅសាកលវិទ្យាល័យដែលមានជំនឿលើសាសនាស៊ុបខ្លាំង គឺមានការអោយតំលៃខ្លួនឯងខ្ពស់ជាងនិស្សិតដែលមានជំនឿមិនស៊ុប [១១៦] ។

សរុបសេចក្តីមក ឥទ្ធិពលសង្គម ដោយរួមមានប្រពៃណីរស់នៅ ជំនឿពុទ្ធសាសនា ប្រព័ន្ធផ្សព្វផ្សាយ និងនយោបាយគ្រប់គ្រងសង្គមមានឥទ្ធិពលដល់ចិត្តគំនិតប្រជាពលរដ្ឋខ្មែរ ។ ទោះជាវាជាប្រភពខាងក្រៅខ្លួនក៏ដោយ ប៉ុន្តែវាជាឫសគល់ និងជាមូលដ្ឋានដ៏សំខាន់ក្នុងការបណ្តុះការជឿជាក់ និងកំណត់ដល់ការអោយតំលៃខ្លួនឯងរបស់និស្សិតខ្មែរ ។ របបសង្គមកម្ពុជាដែលមានភាពអយុត្តិធម៌ មានអំពើពុករលួយ និងហិង្សាតាមប្រពន្ធ័ផ្សព្វផ្សាយអាចជាហេតុនាំអោយការអោយតំលៃខ្លួនឯងរបស់ពលរដ្ឋខ្មែរមានកម្រិតទាប ។

### ៥.១.ឃ - កត្តាផ្ទាល់ខ្លួនជាមូលការអោយតំលៃខ្លួនឯង

ដូចយើងបានឃើញហើយថា គរុនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំមានការអោយតំលៃខ្លួនឯងក្នុងកម្រិតមធ្យម ។ ហេតុផលដែគេវាយតំលៃ និងអោយតំលៃខ្លួនឯងក្នុងកម្រិតនេះគឺដោយសារខ្លួនរបស់គេជាចំបង ។ ហេតុផលសំខាន់មួយក្នុងចំណោមហេតុផលផ្សេងទៀតនៃការអោយតំលៃខ្លួនឯងគឺអាស្រ័យទៅលើចំណេះដឹង និងសមត្ថភាពផ្ទាល់ខ្លួនរបស់មនុស្ស ។ ការដែលគេមើលឃើញពីតំលៃ និងការអោយតំលៃខ្លួនឯងរបស់គេគឺអាស្រ័យដោយខ្លួនគេ វាមិនអាស្រ័យដោយអ្នកដទៃឡើយ ។ ខ្លួនរបស់គេផ្ទាល់ជាអ្នកវិនិច្ឆ័យយ៉ាងត្រឹមត្រូវ និងច្បាស់លាស់ពីខ្លួនរបស់គេ ។ មនុស្សដែលមានចំណេះដឹង និងបញ្ញាញាណតែងតែមានមោទនភាពទៅនឹងខ្លួនរបស់គេ ដោយគេយល់ថា គេមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហា និងហ៊ានប្រឈមមុខរាល់បញ្ហានានាដែលកើតឡើងចំពោះមុខគេ ។ បញ្ញាញាណ សមត្ថភាព ចំណេះដឹងជួយអោយនិស្សិតមានការសម្រេចចិត្តបានឆាប់រហ័ស និងមានប្រសិទ្ធភាព និងជួយអោយគេអាចសម្របសម្រួលខ្លួនបានគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ។ អ្នកនិពន្ធជនជាតិខ្មែរធ្លាប់បញ្ជាក់ថា ចំណេះដឹងលើកតំលៃមនុស្ស ប្រៀបដូចរសជាតិផ្អែមលើកតំលៃផ្លែឈើ ។ ទោះតិចក្តី ឬច្រើនក្តី មនុស្សដែលមានចំណេះដឹង និងសមត្ថភាពគ្រប់គ្រាន់ពិតជាមានការអោយតំលៃខ្លួនឯងខ្ពស់ ។

ហេតុផលមួយផ្សេងទៀតអាចមកពីរូបសម្បត្តិផ្នែករាងកាយរបស់និស្សិត ។ និស្សិតនៅវិទ្យាស្ថានជាតិអប់រំមុនអនុញ្ញាតអោយចូលសិក្សា ពួកគេត្រូវឆ្លងកាត់ការត្រួតពិនិត្យកាយសម្បទា និងសុខភាពរាងកាយ និងផ្លូវចិត្តជាមុន ព្រោះគរុនិស្សិតត្រូវចេញទៅធ្វើជាអ្នកដឹកនាំ គ្រូបង្រៀន ដូចនេះពួកគេត្រូវតែជាអ្នកគំរូដល់សិស្ស ក៏ដូចជាមហាជនផ្សេងទៀត ។ គ្រូបង្រៀនជាឧត្តមគតិក្នុងគំនិតមហាជនដែលប្រជាពលរដ្ឋ

---

[116] Rochell L. Jame , The Correlation between Adolescent Self-esteem, Religiousity and Perceive Family, op.cit., p. on line.

មើលឃើញតំលៃរបស់គ្រូមុនគេបង្អស់នៅក្នុងគំនិតរបស់ពួកគេ ។ និស្សិតដែលបាត់បង់កាយសម្បទាផ្នែកណាមួយមិនត្រូវបានគេអនុញ្ញាតឱ្យសិក្សានៅវិទ្យាស្ថានជាតិអប់រំឡើយ ។ ផ្អែកលើគុណសម្បត្តិកាយសម្បទានេះគរុនិស្សិតនឹងមានមោទនភាពពីគុណសម្បត្តិរាងកាយរបស់ពួកគេ ដែលពួកគេទទួលបានពីមិតកតំណពូជរបស់ឪពុកម្តាយខ្លួន ។ មតិកតំណពូជរបស់ឪពុកម្តាយដែលសំដៅលើរូបរាងកាយនេះមានឥទ្ធិពលដល់រូបភាពចិត្ត (Self-image) របស់មនុស្ស ។ និស្សិតនៅវិទ្យាស្ថានបានមើលឃើញពីតំលៃគ្រប់គ្រាន់ខាងផ្នែករូបរាងកាយរបស់គេដែលជាគ្រឹះដ៏ចំបងក្នុងការកំណត់ការអោយតំលៃខ្លួនឯងរបស់ពួកគេ ។ លោក ហ្វ្រើដ បានបញ្ជាក់ថាវាសនារបស់មនុស្សយើងមានការជាប់ទាក់ទងទៅនឹងការចំលងនៃតំណពូជ ហើយរឿងនោះរឹតតែធ្វើអោយមនុស្សយើងខិតខំកែច្នៃពីលក្ខណៈធម្មជាតិដើមរបស់ខ្លួនអោយទៅជាមនុស្សបែបណាមួយ ។ ហើយរឿងរ៉ាវដែលយើងមានឥទ្ធិពលនោះគឺដោយសារលក្ខណៈសរីរាង្គរបស់យើង [១១៧] ។

ហេតុផលសំខាន់មួយផ្សេងទៀត ដែលកំណត់ដល់ការឱ្យតំលៃខ្លួនឯងរបស់និស្សិតផ្នែកវិទ្យាសាស្ត្រនិងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំស្ថិតនៅលើកត្តាសីលធម៌ និងសុខភាពផ្លូវចិត្ត ។ មនុស្សដែលអាចធ្វើការទំនាក់ទំនងជាមួយមនុស្សដទៃគឺដោយសារមនុស្សនោះយល់ថា គេមានគុណសម្បត្តិផ្នែកសីលធម៌ដែលនាំអោយគេអាចចុះសម្រុងក្នុងសង្គមបានស្រួល ។ និស្សិតនៅមហាវិទ្យាល័យមានចំណេះដឹងជ្រៅជ្រះ ដូច្នេះ គេអាចមើលឃើញអ្វីដែលល្អ និងអ្វីដែលអាក្រក់សំរាប់ខ្លួនគេ ។ បន្ថែមលើសនេះទៅទៀត និស្សិតបានឆ្លងកាត់ការសិក្សាពលរដ្ឋវិជ្ជា និងមុខវិជ្ជាសីលធម៌តាំងពីការសិក្សាពីកម្រិតដំបូងរៀងរហូតមក ហើយមកដល់វិទ្យាស្ថានជាតិអប់រំ ពួកគេបានធ្វើការសិក្សាលើមុខវិជ្ជាសីលធម៌វិជ្ជាជីវៈថែមទៀត ដែលរឿងនេះកាន់តែជួយជំរុញអោយគេពេញចិត្ត និងយល់ពីរបៀបរបបក្នុងការរស់នៅ និងទំនាក់ទំនងសង្គម ។ ជាងនេះទៅទៀត ពួកគេរស់នៅក្នុងសង្គមប្រកាន់ខ្ជាប់លើព្រះពុទ្ធសាសនាដែលអប់រំមនុស្សអោយមានគុណធម៌ ចរិយាធម៌ និងដុសខាត់ចិត្តអោយស្អប់ខ្ពើមនូវអំពើអាក្រក់ និងអំពើបាប ។ ហេតុផលនេះហើយដែលជួយអោយនិស្សិតខ្លួនគេផ្ទាល់មើលឃើញពីតំលៃសីលធម៌ មើលឃើញពីមោទនភាពរបស់គេលើតំលៃរបស់ខ្លួនឯងដែលជាហេតុនាំឱ្យនិស្សិតមានសុខភាពផ្លូវចិត្តបានល្អ ។ លោក Zeman (2003) បានអះអាងថា មនុស្សដែលមានសុខភាពល្អមានការអោយតំលៃខ្លួនឯងខ្ពស់ [១១៨] ។

ទោះជាយ៉ាងនេះក៏ដោយ ការអោយតំលៃខ្លួនឯងរបស់សិស្ស និងនិស្សិតមានការឱ្យតំលៃខ្លួនឯងមានលក្ខណៈសហឯករាជ្យ ដោយពួកគេបានរស់នៅជាប់ជាមួយអាណាព្យាបាលរបស់ខ្លួនរយៈពេលយូរ ។ ជូនកាល

---

[117] James V. Mc Connell , Understand Human Behavior, op.cit., p.267
[118] Miller, The Correlation between Sense of humor and metal health, p. on line: Http: clearing house mwsc.edu/manscripts/405.asp

កូនប្រុសស្រីបានស្នាក់នៅជាមួយឪពុកម្តាយរបស់ខ្លួនរហូតដល់រៀបការទើបមានការផ្តាច់ចេញពីពួកគាត់ ។ ពួកគេហាក់ដូចជាពុំមានសេរីភាពខាងគំនិតឯករាជ្យពីតូចមកឡើយ ទាល់តែពួកគេពេញវ័យ ទើបមានការសម្រេចចិត្តដោយខ្លួនឯងដោយឯករាជ្យ ។ និស្សិតភាគច្រើនតែងតែពឹងពាក់ ឬអាងគ្នានៅពេលគេធ្វើអ្វីមួយ ដូចជាការប្រលង ឬការធ្វើទំនាក់ទំនងផ្សេងៗ ។ ការមានគ្នានៅជាមួយនេះហាក់បីដូចជាជួយអោយពួកគេមានការជឿជាក់លើខ្លួនឯងកាន់តែខ្លាំងឡើងក្នុងការងារផ្សេងៗ ប៉ុន្តែ នៅពេលពួកគេនៅម្នាក់ឯងហាក់ដូចជាធ្វើអោយពួកគេមានអារម្មណ៍ជឿជាក់លើខ្លួនឯងដូចជាមិនសូវសុខស្រួលចំពោះការងារ និងស្ថានភាពថ្មី ។

ជាការជាក់ស្តែង និស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំមានសម្បត្តិផ្ទាល់ខ្លួនរបស់គេគ្រប់គ្រាន់ ដូចជា រូបរាងកាយសមរម្យ បញ្ញាញាណ ចំណេះដឹង សមត្ថភាព សីលធម៌ និងចរិយាធម៌ ។ ការដែលគេមើលឃើញលក្ខណៈសម្បត្តិទាំងនេះជាការជួយអោយនិស្សិតមានកំលាំងចិត្ត និងការឱ្យតំលៃខ្លួនឯងខ្ពស់ ។ នៅពេលណានិស្សិតទាំងនោះមានអារម្មណ៍គ្រប់គ្រាន់លើចំណេះដឹង សមត្ថភាព បញ្ញាញាណ និងតំលៃសីលធម៌របស់គេ នោះការអោយតំលៃខ្លួនឯងនឹងចាក់ឫសយ៉ាងជ្រៅនៅក្នុងស្មារតីរបស់គេ ។ លោកស្រី Dunn (1988) អ្នកឯកទេសខាងការអោយតំលៃខ្លួនឯងបានបញ្ជាក់ថា លក្ខណៈនៃការអោយតំលៃខ្លួនឯងទាក់ទងទៅនឹងវិសាលភាពដែលមនុស្សមើលឃើញពីតំលៃរបស់ខ្លួនគេដោយមានហេតុ និងផលហើយការយល់ដឹងពីបុព្វហេតុគឺជាការបង្ហាញដ៏សំខាន់ពីអារម្មណ៍របស់ខ្លួន ។ ការយល់ដឹងអំពីហេតុនឹងជះឥទ្ធិពលលើព្រឹត្តការណ៍ និងបញ្ហាផ្សេងទៀត[១១៩] ។ ដូច្នេះ ការអោយតំលៃខ្លួនឯងរបស់និស្សិតផ្នែកវិទ្យាសាស្ត្រគឺអាស្រ័យលើប្រភពខ្លួនឯងប្រសើរជាងកត្តាខាងក្រៅដែលជំរុញដល់ការអោយតំលៃខ្លួនឯង ។ ប្រភពនៃការឱ្យតំលៃខ្លួនឯងដំបូងកើតចេញពីការដែលនិស្សិតត្រូវណែនាំដោយខ្លួនឯង ស្វែងយល់បញ្ញត្តិខ្លួនឯង រៀនស្គាល់ និងសង្កេតពីខ្លួនឯងទាំងលក្ខណៈខាងក្នុង និងលក្ខណៈខាងក្រៅ ។ បន្ទាប់មកនិស្សិតត្រូវអះអាងពីប្រភពផ្ទាល់នៃតំលៃខ្លួនឯង ដោយបង្ហាញពីតំលៃរបស់ខ្លួនឯងផ្ទាល់ និងក្រោយមកនិស្សិតត្រូវមើលដំណើរទិសដៅនៃតំលៃខ្លួនឯងដែលជាលំនាំសំដៅលទ្ធផលរបស់គោលបំណង ។ ការអោយតំលៃខ្លួនឯងគឺអាស្រ័យជាចំបងទៅលើកត្តាផ្ទាល់ខ្លួនរបស់និស្សិត ចំពោះការអោយតំលៃ ឬមិនអោយតំលៃពីភាពខ្លាំង និងភាពខ្សោយរបស់គេ ។ គេអាចនិយាយថាកត្តាខ្លួនឯងនេះជាមូលដ្ឋានស្នូលក្នុងការអោយតំលៃខ្លួនឯងរបស់មនុស្ស ។

សរុបសេចក្តីមក រូបសម្ផស្សរបស់និស្សិតមានលក្ខណៈគ្រប់គ្រាន់ ( អ្នកអាចក្លាយជាគ្រូបង្រៀនត្រូវមានកាយសម្បទាសមរម្យ និងមិនមានការបាត់បង់ផ្នែកណាមួយនៃរូបរាងកាយ ) ជាការជម្រុញអោយគេ

[119] Lilian G. Katz, Distinction between Self-esteem and Narcissism: implications for Practice, op.cit., p.on line

ឃើញពីរូបភាពចិត្តរបស់គេ រីឯសមត្ថភាព ចំណេះដឹងផ្ទាល់ខ្លួនរបស់គេអាចជួយលើកតម្កើងការពេញចិត្តចំ-ពោះខ្លួនគេ ។ ការជឿលើតំលៃនៃចំណេះវិជ្ជា ហើយគំនិតយល់ដឹងខាងតំលៃសីលធម៌ គុណធម៌ និងបញ្ញាញាណរបស់និស្សិតជួយអោយពួកគេមានការអោយតំលៃខ្លួនឯងខ្ពស់ ។

### ៥.២ - ទំនាក់ទំនងលក្ខណៈពិសេសផ្ទាល់ខ្លួន និង ការអោយតំលៃខ្លួនឯង

តើលក្ខណៈពិសេសផ្ទាល់ខ្លួនមានទំនាក់ទំនងជាមួយនឹងការអោយតំលៃខ្លួនឯងដែរឬទេ ?

តើនិស្សិតភេទប្រុស និងភេទស្រីមានការអោយតំលៃខ្លួនឯងដូចគ្នាដែរឬទេ ?

តើហេតុផលអ្វីដែលនិស្សិតទាំងពីរភេទមានការអោយតំលៃខ្លួនឯងក្នុងកម្រិតដូចគ្នា ឬខុសគ្នានោះ ?

ការស្រាវជ្រាវបង្ហាញថា និស្សិតភេទប្រុស និងនិស្សិតភេទស្រីផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំមានការអោយតំលៃខ្លួនឯងប្រហាក់ប្រហែលគ្នា ដែលសុទ្ធតែស្ថិតក្នុងកម្រិតមធ្យមដូចគ្នា $\overline{X}$ =៦២.៣៦ ។ និស្សិតភេទស្រីមានការអោយតំលៃខ្លួនឯងក្នុងកម្រិត $\overline{X}$ =៦៣.៧៨ រីឯនិស្សិតភេទប្រុសមានការអោយតំលៃខ្លួនឯងកម្រិត $\overline{X}$ =៦១.៧៥ ។ លទ្ធផលស្រាវជ្រាវនេះមានភាពប្រហាក់ប្រហែលទៅនឹងការស្រាវជ្រាវរបស់ក្រុមអ្នកស្រាវជ្រាវលោកខាងលិច ដូចជា លោក Hensley (1977) និង លោក OBrien (1991) ដែលបានរកឃើញថា និស្សិតមហាវិទ្យាល័យភេទស្រី និងភេទប្រុសមានការអោយតំលៃខ្លួនឯងមិនខុសគ្នាឡើយ [១២០] ។ ទោះជាយ៉ាងណាក៏ដោយ លទ្ធផលនៃការស្រាវជ្រាវពីទំនាក់ទំនងរវាងកត្តាភេទ (Gender) និងការឱ្យតំលៃខ្លួនឯងនេះនូវមានភាពប្រទាញប្រទង់គ្នា ។ ការស្រាវជ្រាវទាំងនោះគ្រាន់តែរកឃើញថា និស្សិតប្រុសមានការអោយតំលៃខ្លួនឯងលើកម្រិតសមត្ថភាព នៅខណៈពេលនិស្សិតស្រីមានការអោយតំលៃខ្លួនឯងលើផ្នែកភក្តីភាពប៉ុណ្ណោះ ។ នៅប្រទេសកម្ពុជា និស្សិតប្រុស និងនិស្សិតស្រីមានការអោយតំលៃខ្លួនឯងដូចគ្នា ។ ហេតុផលនិស្សិតស្រីមានការអោយតំលៃខ្លួនឯងដូចនិស្សិតប្រុសនោះអាចមកពីវប្បធម៌ប្រពៃណីសង្គម និងចំណេះដឹងរបស់ពួកគេ ។

គរុនិស្សិតទាំងពីរភេទបានរស់នៅក្នុងវប្បធម៌ ប្រពៃណី ទំនៀមទំលាប់សង្គមដូចគ្នា ។ ពួកគេមិនត្រឹមតែទទួលឥទ្ធិពលពីវប្បធម៌នោះប៉ុណ្ណោះទេ តែថែមទាំងបានយល់ដឹងពីជុំវៅខ្លឹមសាររបស់វាថែមទៀតតាម-រយៈការសិក្សារបស់គេ ។ ចំពោះនិស្សិតស្រី ពួកគេមានមោទនភាពទៅនឹងមរតកវប្បធម៌ និងទំនៀមទំលាប់ប្រពៃណីដែលមានឥទ្ធិពលលើផ្លូវចិត្តជនជាតិខ្មែរគ្រប់រូប ។ នៅក្នុងរបបគ្រប់គ្រងប្រទេសជាតិ ទោះបីបច្ចុប្ប-ន្ន ស្ត្រីខ្មែរដែលមានតួនាទីខ្ពស់មានចំនួនតិចតួចក៏ដោយ តែវប្បធម៌ខ្មែរបានអោយតំលៃតួនាទីស្ត្រីខ្ពស់បំផុត ។

[១២០] Profile: The Relationship Between Gender and Self-Esteem with Body Image, op.cit., p.on line

តំលៃស្ត្រីត្រូវបានគេផ្តល់អោយតាំងពីដើមអាណាចក្រខ្មែរមកម្លេះ ពេលដែលខ្មែរមានស្តេចស្រីសោយរាជតំបូងមកម្លេះ ។ រីឯក្នុងវប្បធម៌ខ្មែរវិញ គេឃើញមានពាក្យ មេ ដែលតំណាងអោយស្ត្រីមាននៅក្នុងគ្រប់វិស័យ ដូចជា មេផ្ទះ មេទ័ព ។ល។ ជាការជាក់ស្តែង សង្គមខ្មែរបានដក់ជាប់នូវការអនុវត្តរបបមាតាធិបតេយ្យ ហើយប្រលឹងមាតាធិបតេយ្យនេះនៅតែមានអត្ថិភាពនៅឡើយនៅក្នុងសង្គមខ្មែរដែលយកស្ត្រីជាធំ ដូចជា នៅក្នុងអាពាហ៍ពិពាហ៍ កូនប្រុសត្រូវស្តីដណ្តឹងកូនស្រី ។ រីឯនៅក្នុងជំនឿ ប្រពន្ធស្លាគស្លំ នាំអោយប្តីស្លាត់ស្លំ ។ នៅក្នុងវប្បធម៌ និងអរិយធម៌ គេឃើញមានការកសាងប្រាសាទ ដើម្បីជានិមិត្តរូប និងលើកតម្លៃឧត្តមភាពស្ត្រី ដូចជាការសាងប្រាសាទបន្ទាយស្រី និងប្រាសាទនាងខ្មៅជាដើម ។ នៅក្នុងប្រវត្តិសាស្ត្រ គេក៏មើលឃើញ ស្ត្រីជាមេដឹកនាំ ដូចជាព្រះនាងលីវយី ព្រះនាងឥន្ទ្រទេវីជាដើម ។ នៅក្នុងអក្សរសាស្ត្រខ្មែរ គេឃើញមានការលើកតំលៃស្ត្រីជាធំ ពាក្យតំណាងស្ត្រីត្រូវនាំមុខបុរស ដូចជា មេភូមិ មាតាបិតា មាតុភូមិ ។ល។ ដូចនេះសង្គមខ្មែរគេលើកតំលៃតួនាទីនារីជាចំបងនៅក្នុងគ្រួសារ ក៏ដូចជានៅក្នុងសង្គម ហើយប្រជាពលរដ្ឋខ្មែរតែងតែបានទទួលឥទ្ធិពលនេះតាំងពីតូចរហូតដល់ធំ ហើយគេនៅតែនាំគ្នាអនុវត្តជាបន្តបន្ទាប់ដោយក្តីស្រលាញ់ជឿជាក់ និងមានមោទនភាព [121] ។ វប្បធម៌ឱ្យតំលៃស្ត្រីជាធំនេះមានឥទ្ធិពលទៅលើរូបភាពចិត្តរបស់នារីខ្មែរដែលបញ្ជ្រាបដល់ផ្លូវចិត្តរបស់ពួកគេបន្តិចម្តងៗ និងជួយឱ្យស្ត្រីខ្មែរមើលឃើញពីតំលៃខ្លួនរបស់គេដែលការនេះជាសមាសធាតុក្នុងការកសាងការអោយតំលៃខ្លួនឯងរបស់នារីខ្មែរ ។ នេះអាចចាត់ទុកបានថាហេតុផលវប្បធម៌សង្គមជួយអភិវឌ្ឍការអោយតំលៃខ្លួនឯងរបស់ស្ត្រីខ្មែរ ។

ម៉្យាងវិញទៀត តាមទំនៀមទំលាប់ប្រពៃណីខ្មែរ នារីមានតួនាទី និងភារកិច្ចអប់រំក្នុងគ្រួសារធំជាងបុរស ។ ស្ត្រីជាម្តាយល្អ ជាអ្នកអប់រំល្អ និងជាទីប្រឹក្សាល្អ ។ ឪពុកម្តាយតែងយកច្បាប់ស្រី សុភាវធម៌ សុជីវធម៌ខ្មែរជាមូលដ្ឋានក្នុងការអប់រំចរិយាសម្បត្តិកូនស្រី [122] ។ នៅប្រទេសកម្ពុជា កូនស្រីត្រូវបានគេយកចិត្តទុកដាក់ និងប្រយត្ន័ប្រយ៉ែងជាងកូនប្រុស ។ ផ្នត់គំនិតរបស់ប្រជាជនខ្មែរបានចាត់ទុកស្ត្រីជាភេទដែលងាយរងគ្រោះ ។ ទស្សនៈនេះត្រូវបានគេមើលឃើញនៅក្នុងប្រពៃណីដែលបន្សល់ទុកមកដល់សព្វថ្ងៃ ហើយមានឥទ្ធិពលដល់នារីខ្មែរគ្រប់រូប ក្នុងនោះគរុនិស្សិតភេទស្រីនៅវិទ្យាស្ថានជាតិអប់រំផងដែរ ។ ទស្សនៈនេះត្រូវបានគេមើលឃើញនៅក្នុងប្រយោគមួយលើកឡើងថា "កូនស្រីប្រៀបបានផ្ទាំងក្រណាត់ស រីឯកូនប្រុសប្រៀបបានមាសទឹកដប់" ។ ឥទ្ធិពលប្រពៃណីនេះជួអោយមាតាបីតាខិតខំដុះខាត់កិរិយាមាយាទ និងសីលធម៌ដល់កូនស្រី

[121] សូមមើល : ងួន ញិល : ប្រលឹងមាតាធិបតេយ្យ ការបោះពុម្ពផ្សាយរបស់កាសែតប្រជាជន ១៩៩២

[122] -ដ- ទំព័រ ១២៧-១៧០

ដែលការនេះមិនត្រឹមតែជួយអោយកូនស្រីរស់នៅក្នុងភាពមានសណ្ដាប់ធ្នាប់ និងមានចរិយាធម៌ល្អប៉ុណ្ណោះទេ តែថែមទាំងជួយអោយពួកគេមានការអោយតំលៃខ្លួនឯងខ្ពស់ ។ មនុស្សដែលមានសីលធម៌ខ្ពស់គឺជាមនុស្សដែលមានការអោយតំលៃខ្លួនឯងខ្ពស់ ។

ហេតុផលមួយផ្សេងទៀតដែលនិស្សិតស្រីមានការអោយតំលៃខ្លួនឯងដូចនិស្សិតប្រុសអាចមកពីការអប់រំ ។ ជាការជាក់ស្ដែង ការស្រាវជ្រាវបានកត់សំគាល់ឃើញថា គរុនិស្សិតភេទស្រីមានពិន្ទុសិក្សាខ្ពស់ជាងនិស្សិតប្រុស ។ រីឯនៅតាមកម្រិតសិក្សាផ្សេងទៀតក៏មានភាពប្រហាក់ប្រហែលគ្នានេះដែរ ។ នេះបង្ហាញថា និស្សិតស្រីមានសមត្ថភាព និងចំណេះដឹងដូចនិស្សិតប្រុសផងដែរ ។ ចំណេះដឹងនេះអាចជួយអោយគេមើលឃើញពីតំលៃរបស់គេដូចបុរសដែរ ។ លើសនេះទៅទៀត គរុនិស្សិតភេទស្រីមានការអោយតំលៃខ្លួនឯងទំនងជានៅពេលបច្ចុប្បន្នមានការអោយតំលៃសិទ្ធិនារី និងការផ្សព្វផ្សាយយ៉ាងផុសផុលអំពីសិទ្ធនេះ ដូចជា ស្ត្រីជាមាតាពិភពលោក ឬនារីរតនៈជាដើម ។ ប្រការនេះជួយអោយស្ត្រីមានមោទនភាពពីខ្លួនគេ និងតំលៃរបស់គេ ។ នៅពេលគេមើលឃើញពីតំលៃខ្លួនរបស់គេ ពួកគេនឹងកាន់តែអោយតំលៃខ្លួនឯងថែមទៀត ដែលគេអាចនិ-យាយបានថា ថ្ងៃទិវាសិទ្ធិនារីនេះ គឺមកពីនារីមានការអោយតំលៃខ្លួនឯងខ្ពស់ ហើយការអោយតំលៃខ្លួនឯងខ្ពស់នេះហើយដែលជំរុញចិត្តពួកគេអោយទាមទារ និងបង្កើតបាននូវទិវាជាប្រវត្តិសាស្ត្រសាកលលោកនេះ ។ ដូច្នេះ សមាសធាតុវប្បធម៌ ប្រពៃណី ទំនៀមទំលាប់ និងការប្រកាន់ខ្ជាប់នូវប្រលឹងមាតាធិបតេយ្យបានបញ្ជ្រាបចូលទៅក្នុងអត្តសញ្ញាណខ្លួនរបស់នារីខ្មែរ និងដក់ជាប់ក្នុងផ្នត់គំនិតរបស់គេដ៏ជ្រាលជ្រៅ ។ សមាស-ធាតុទាំងនេះ ព្រមទាំងចំណេះដឹងនាំអោយមានឥទ្ធិពលដល់រូបភាពចិត្តរបស់នារីខ្មែរដែលជាការជួយជំរុញឱ្យពួកគេមើលឃើញនូវតំលៃខ្លួនឯង និងជួយបណ្ដុះការអោយតំលៃខ្លួនឯងដល់ពួកគេ ។ ហេតុផលទាំងនេះជួយអោយគរុនិស្សិភេទស្រីមានតំលៃមានសមត្ថភាព និងមានការអោយតំលៃខ្លួនឯងស្មើបុរស ។

ចំពោះការអោយតំលៃខ្លួនឯងរបស់គរុនិស្សិតភេទប្រុស ជាក់ស្ដែងនៅក្នុងសង្គមខ្មែរ គេមើលឃើញថា បុរសមានតួនាទីសំខាន់ក្នុងការដឹកនាំ ហើយចំនួនបុរសមានមុខតំណែងច្រើននៅក្នុងវិស័យរដ្ឋនិងឯកជន ។ ហេតុផលដែលនិស្សិតប្រុសមានការឱ្យតំលៃខ្លួនឯងដូចនិស្សិតស្រីអាចមកពីសេរីភាពក្នុងការរស់នៅ ។ ក្នុងរបៀបរបបរស់នៅ និងការទំនាក់ទំនងជាក់ស្ដែងក្នុងផ្នត់គំនិតនៃសង្គមខ្មែរ មនុស្សប្រុសត្រូវបានគេផ្ដល់សិទ្ធិដើរហើរបានគ្រប់យ៉ាង និងគ្រប់ពេលវេលា ដោយឪពុកម្ដាយមិនបារម្ភពីកូនប្រុសដូចកូនស្រីឡើយ ប្រការដែលសំខាន់កុំអោយតែពួកគេមានគ្រោះថ្នាក់ បង្ករឿងពាលាផ្ដេសផ្ដាស និងបង្ខូចកិត្តិយសគ្រួសារ ។ ភាសារបុរាណខ្មែរតែងពោលថា មនុស្សប្រុសប្រៀបបានមាសទឹកដប់ រីឯមនុស្សស្រីប្រៀបបានក្រណាត់សរ ។ នេះជា

ការអោយតំលៃដល់បុរសក្នុងការដើរហើរ និងទំនាក់ទំនងខាងក្រៅបានទូលាយ ។ ការដើរច្រើនមានលក្ខណៈសមហេតុផលជួយអោយគេមានចំណេះដឹងបន្ថែម និងដឹងពីរបៀបរបបសង្គម និងប៉ិនប្រសប់ជីវិតកាន់តែច្រើនឡើង ។ នៅពេលនិស្សិតមានសមត្ថភាព និងមានចំណេះដឹងខ្ពស់ នោះការអោយតំលៃខ្លួនឯងកាន់តែខ្ពស់ដែរ ដែលសមដូចការអះអាងក្នុងទ្រឹស្តីអភិវឌ្ឍការអោយតំលៃខ្លួនឯងថា ការមានប៉ិនប្រសប់សង្គម (Social Skills) និងចំណេះដឹងជួយអភិវឌ្ឍការអោយតំលៃខ្លួនឯងកាន់តែខ្ពស់ឡើង។ លោក Somers និងលោក Lefkowitz (1983) បានអះអាងថា សមត្ថភាពអនុវត្តការងារមានទំនាក់ទំនងជានិច្ចជាមួយកម្រិតនៃការអោយតំលៃខ្លួនឯង [១២៣] ។

**តើនិស្សិតអាយុច្រើនជាង និងនិស្សិតអាយុក្មេងជាង មួយណាមានការអោយតំលៃខ្លួនឯងខ្ពស់ជាង ?**

ការស្រាវជ្រាវបង្ហាញថា និស្សិតដែលមានអាយុចន្លោះពី២០ឆ្នាំដល់២៣ឆ្នាំមានការអោយតំលៃខ្លួនឯងខ្ពស់ជាងនិស្សិតដែលមានអាយុចន្លោះ២៤ឆ្នាំដល់២៧ឆ្នាំបន្តិច ។ និស្សិតអាយុ២០ឆ្នាំដល់២៣ឆ្នាំ មានពិន្ទុមធ្យមនៃការអោយតំលៃខ្លួនឯង $\overline{X}$ =៦៣.០៥ រីឯនិស្សិតអាយុ ២៤ឆ្នាំ ដល់២៧ឆ្នាំមានពិន្ទុមធ្យមនៃការឱ្យតំលៃខ្លួនឯង $\overline{X}$ =៥៩.៩៤ ។ ការអោយតំលៃខ្លួនឯងរបស់និស្សិតកំរិតមហាវិទ្យាល័យដូចគ្នា មិនអាស្រ័យទៅលើអាយុទេ ។ លទ្ធផលសហទំនាក់ទំនងរវាងអថេរអាយុ និងអថេរការអោយតំលៃខ្លួនឯង មានទំនាក់ទំនងអវិជ្ជមាន $r = -.416$ ។ លទ្ធផលស្រាវជ្រាវនេះមិនបានឆ្លើយតបទៅនឹងការស្រាវជ្រាវរបស់លោក Hoppe ដែលបានបង្ហាញថា និស្សិតដែលមានអាយុច្រើនមានការអោយតំលៃខ្ពស់ជាងនិស្សិតដែលមានអាយុក្មេងជាង ដោយមិនបានគិតបញ្ចូលកំរិតអប់រំទេ [១២៤] ។ តាមលោក Hoppe គេឃើញថា បើគេមិនគិតបញ្ចូលកម្រិតអប់រំ មនុស្សដែលមានអាយុចាស់ជាងមានការអោយតំលៃខ្លួនឯងខ្ពស់ជាងមនុស្សក្មេងជាង ដូច្នេះ ចំណេះដឹងកម្រិតអប់រំបានជួយអោយមនុស្សមានការអោយតំលៃខ្លួនឯងកាន់តែខ្ពស់ ។ ប៉ុន្តែនេះបង្ហាញថា នៅពេលណានិស្សិតរៀននៅកម្រិតមហាវិទ្យាល័យដូចគ្នា ការអោយតំលៃខ្លួនឯងមិនអាស្រ័យអាយុឡើយ ។

ហេតុផលដែលនិស្សិតក្មេងជាងមានការអោយតំលៃខ្លួនឯងខ្ពស់ជាងនេះពិតជាងអាស្រ័យយ៉ាងជិតស្និតជាមួយបញ្ហា សមត្ថភាពខិតខំធ្វើការសិក្សារបស់និស្សិត ដែលជួយអោយពួកទទួលបានភាពវាងវៃក្នុងសមត្ថភាពដោះស្រាយបញ្ហា ក៏ដូចជាសមត្ថភាពក្នុងការរៀនសូត្រ ។ ការស្រាវជ្រាវទៅលើនិស្សិតចំនួន ៧៧នាក់ ផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំបានបង្ហាញថា និស្សិតក្នុងចន្លោះអាយុ២០ឆ្នាំដល់៣០ឆ្នាំមានសារៈសំខាន់ណាស់ក្នុងការបន្តការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រអោយបានស៊ីជំរៅ និងមានសម្ភារៈ

---

[123] John B. Miner, Industrial Organizational Paychology, op.cit., p.152
[124] Heather M. Hoppe, The effect of self esteem on education, op.cit., p.on line.

ពិសោធ ដើម្បីអោយសិស្សមានជំនក់ចិត្តក្នុងការសិក្សាស្រាវជ្រាវ ។ ដូច្នេះ និស្សិតដែលមានការយកចិត្តទុកដាក់មានការចូលចិត្តការសិក្សាទាំងទ្រឹស្តី និងពិសោធន៍ ប្រាកដជាមានការជឿជាក់លើសមត្ថភាពរបស់ខ្លួនដោយមិនគិតពីវ័យអាយុឡើយ ។ នៅពេលណានិស្សិតមានស្នាដៃស្រាវជ្រាវយ៉ាងសកម្ម បញ្ញាញាណ និងសមត្ថភាពសិក្សារបស់គេកាន់តែខ្លាំងដែលជាគ្រឿងជំនួយដល់ការជឿជាក់លើខ្លួនគេ ។ និស្សិតដែលទទួលបានសមិទ្ធផលខ្ពស់តែងតែមានកំលាំងចិត្តចង់សិក្សា ។ ដូចនេះ និស្សិតនៅកំរិតនេះ ការអោយតំលៃខ្លួនឯងរបស់គេពិតជាមិនអាស្រ័យលើអាយុទេ តែវាអាស្រ័យលើការអប់រំ សមត្ថភាពសិក្សា និងបញ្ញាញាណរបស់គេទៅវិញ ។ នៅក្នុងដំណាក់កាលអាយុកម្រិត២០ដល់៣០ឆ្នាំនៅមហាវិទ្យាល័យ អាយុមិនមានទំនាក់ទំនងជាមួយការអោយតំលៃខ្លួនឯងទេ តែវាមានទំនាក់ទំនងជាមួយកំរិតអប់រំ សមត្ថភាពខិតខំប្រឹងប្រែងសិក្សា និងបញ្ញារបស់និស្សិតទៅវិញ ។

ដូច្នេះ ក្នុងចំណោមកត្តាលក្ខណៈពិសេសផ្ទាល់ខ្លួន គេឃើញមានតែកត្តាអាយុទេដែលមានទំនាក់ទំនងអវិជ្ជមានជាមួយការអោយតំលៃខ្លួនឯង ។ ហើយនិស្សិតស្រី និងនិស្សិតប្រុសមានការអោយតំលៃខ្លួនឯងកម្រិតមធ្យមដូចគ្នា សំរាប់វ័យសិក្សានៅមហាវិទ្យាល័យ ។ ទាំងនេះពិតជាមកពីបុព្វហេតុពីអតីតកាលផងនិងបុព្វហេតុបច្ចុប្បន្នផង ពិសេសការដក់ជាប់នូវឥទ្ធិពលវប្បធម៌មកលើរបៀបរស់នៅ និងផ្នត់គំនិតរបស់ប្រជាពលរដ្ឋខ្មែរ ព្រមទាំងចំណេះដឹង និងសមត្ថភាពរបស់គេបច្ចុប្បន្ន ។

## ៥.៣ - ទំនាក់ទំនងរវាងការអោយតំលៃខ្លួនឯង និង សមិទ្ធផលសិក្សា

តើការអោយតំលៃខ្លួនឯងមានទំនាក់ទំនងជាមួយសិមិទ្ធផលសិក្សាដែរឬទេ ?

ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា ការអោយតំលៃខ្លួនឯងរបស់និស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំមានទំនាក់ទំនងយ៉ាងវិជ្ជមានជាមួយនឹងសមិទ្ធផលសិក្សា ( r = .887 ) ។ ដូច្នេះ លទ្ធផលនៃការស្រាវជ្រាវនេះពិតជាគាំទ្រទៅនឹងសម្មតិកម្មស្រាវជ្រាវដែលលើកឡើងថា ការអោយតំ-លៃខ្លួនឯងមានទំនាក់ទំនងទៅនឹងសមិទ្ធផលសិក្សា ។ ម្យ៉ាងវិញទៀត លទ្ធផលស្រាវជ្រាវនេះក៏សមស្របទៅនឹងគំនិតរបស់អ្នកប្រាជ្ញអប់រំ Bandura ដែលពោលថា ការលើកតំលៃខ្លួនកាន់តែខ្ពស់ និងកាន់តែពិសិដ្ឋ នោះសមត្ថភាពអនុវត្តការងារកាន់តែខ្ពស់ [១២៥] ។ អាស្រ័យលទ្ធផលស្រាវជ្រាវនេះ យើងអាចសន្និដ្ឋានថា សមិទ្ធ-ផលសិក្សាពិតជាអាស្រ័យទៅលើការជឿជាក់ និងការអោយតំលៃខ្លួនឯងរបស់និស្សិត ។ នៅពេលនិស្សិតមានការឱ្យតំលៃខ្លួនឯងកាន់តែខ្ពស់ នោះគេនឹងទទួលបានពិន្ទុសិក្សាកាន់តែល្អ ហើយនៅពេលនិស្សិតមានការជឿ-

[125] Zimbado, Psychology and Life, op.cit., p.401

ជាក់លើខ្លួនឯងក្នុងការរៀនសូត្រ នោះគេនឹងទទួលបានសមិទ្ធផលខ្ពស់ ។ ដូចនេះការសិក្សាពិតជាអាស្រ័យទៅលើការអោយតំលៃខ្លួនឯង មិនត្រឹមតែក្នុងបរិបទសិក្សារបស់ប្រទេសលោកខាងលិចតែប៉ុណ្ណោះទេ តែថែមទាំងក្នុងបរិបទសិក្សានៅប្រទេសកម្ពុជាផងដែរ ។ ដូចនេះ អថេរចំណេះដឹងជួយអោយយើងធ្វើការសន្និដ្ឋានថា ការអោយតំលៃខ្លួនឯងជួយដល់ការសិក្សារបស់និស្សិត ដោយអថេរទាំងពីរមានទំនាក់ទំនងនឹងគ្នាយ៉ាងខ្លាំង ហើយដើម្បីបានគុណភាពសិក្សា គេត្រូវតែយកចិត្តទុកដាក់ដល់ការអប់រំធ្វើយ៉ាងណាអោយសិស្សមានជំនឿ-ចិត្ត និងការអោយតំលៃខ្លួនឯងជាមុន ។

ជាមួយគ្នានេះដែរ ការស្រាវជ្រាវនេះបានបញ្ជាក់ច្បាស់ថា ការអោយតំលៃខ្លួនឯងមានទំនាក់ទំនងយ៉ាងវិជ្ជមានជាមួយសមិទ្ធផលសិក្សា ដែលលទ្ធផលនេះវាសមស្របទៅនឹងលទ្ធផលស្រាវជ្រាវរបស់លោក Meathe M. Hoppe (1995) ដែលរកឃើញថា សិស្ស និស្សិតដែលមានបញ្ញត្តិផ្ទាល់ខ្លួនឯងកម្រិតខ្ពស់តែងតែធ្វើការបានប្រសើរនៅក្នុងសាលារៀន ហើយទទួលការអប់រំបានកាន់តែច្រើនឡើង [១២៦] ។ នៅក្នុងបន្ទប់រៀន ឬសាលារៀន ការបង្កអោយនិស្សិតមានការជឿជាក់ និងមានការអោយតំលៃខ្លួនឯងទាបនាំអោយនិស្សិតឈានទៅសំរេចពិន្ទុទាប ការមានសមត្ថភាពតិចតួច ការសិក្សាខ្សោយ និងពុំមានគោលដៅសំរាប់ការសិក្សារបស់គេ ។ ដូច្នេះជំនឿលើខ្លួនឯងទាបនាំអោយការសិក្សារបស់គេធ្លាក់ចុះ ។ លោក Walter បញ្ជាក់ថា ការឡើងចុះនៃការឱ្យតំលៃខ្លួនឯងគឺមានឥទ្ធិពលដោយសារភាពជោគជ័យ និងបរាជ័យនៅក្នុងមុខរបរ និងជំ-នាញរបស់គេ ។ ដូច្នេះ ការទទួលបានជោគជ័យនៅក្នុងការសិក្សាពិតជាអាស្រ័យលើការដែលនិស្សិតមានជំ-នឿជឿជាក់លើខ្លួនឯង ។ កត្តានេះសមទៅនឹងលទ្ធផលស្រាវជ្រាវដែលបានបង្ហាញថា និស្សិតដែលមានពិន្ទុសិក្សាទាប ការអោយតំលៃខ្លួនឯងទាបដែរ ។ បន្ថែលើការគាំទ្រគំនិតនេះ លោកស្រី Crocker (2002) បានបញ្ជាក់ថា ការអោយតំលៃរបស់និស្សិតមហាវិទ្យាល័យមានការឡើងចុះពេញមួយថ្ងៃៗ នៅពេលណាពួគេមានការទទួលយក និងបដិសេធ ។ ជាការពិត និស្សិតដែលការអោយតំលៃខ្លួនឯង អាស្រ័យយ៉ាងខ្លាំងទៅលើសមត្ថភាពសិក្សា ព្រោះកាអោយតំលៃខ្លួនឯងកើនខ្លាំងឡើង នៅចំពេលណាមានការទទួលយក និងទទួលព្រម ប៉ុន្តែធ្លាក់ចុះទៅវិញនៅពេលណាមានការជំទាស់មិនទទួលយក [១២៧] ។ នេះមានន័យថា ការសិក្សាអា-ស្រ័យយ៉ាងខ្លាំងលើការឱ្យតំលៃលើខ្លួនឯងរបស់និស្សិត ។ ទោះជាយ៉ាងនេះក៏ដោយ ការសិក្សាល្អមិនមែនអា-ស្រ័យតែលើការឱ្យតំលៃខ្លួនឯងប៉ុណ្ណោះទេ តែវាអាស្រ័យកត្តាច្រើនទៀត ។ ការឱ្យតំលៃខ្លួនឯង ការជឿជាក់លើខ្លួនឯង ការពេញចិត្តលើសមត្ថភាពខ្លួនឯង ជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការជួយឱ្យសិស្សទទួលបានពិន្ទុល្អ ។

---

126 Heather M. Hoppe, The Effects of Self-Esteem on Education, op.cit., p. on line.
127 Profile : www.wetheliving.com/pipermail/psychology/2003-april/000356.html.

ក្នុងបរិបទសិក្សាផ្នែកវិទ្យាសាស្ត្រ និស្សិតមានការអោយតំលៃខ្លួនឯងកំរិតមធ្យម រីឯពិន្ទុសិក្សារបស់គេមានកំរិតបង្គួរ នេះបើគេមានការជឿជាក់កាន់តែខ្លាំងជាងនេះ វាទំនងជាជំរុញអោយលទ្ធផលសិក្សារបស់គេកាន់តែប្រសើរជាងនេះថែមទៀត ។ គុណភាពសិក្សាមិនអាស្រ័យតែការអោយតំលៃខ្លួនឯងរបស់និស្សិតតែប៉ុណ្ណោះទេ តែវាអាស្រ័យលើខ្លឹមសារកម្មវិធីសិក្សាដែលធ្វើយ៉ាងណាអោយនិស្សិតមានជំនឿលើការសិក្សា និងអាស្រ័យលើគ្រូមានវិធីសាស្ត្របែបណាធ្វើអោយសិស្សមានការអោយតំលៃលើខ្លួនគេក្នុងការសិក្សា ព្រមទាំងអាស្រ័យលើការអនុវត្តជាក់ស្តែងបែបណាមួយ ដែលជួយអោយសិស្សជឿលើផលប្រយោជន៍អនាគត និងមានគោលបំណងច្បាស់លាស់ ។ គរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំបានទទួលនូវសមត្ថភាពឯកទេសបង្រៀនតាមរយៈការបណ្តុះបណ្តាល និងមានក្តីសង្ឃឹមចំពោះមុខរបររបស់ពួកគេ បន្ទាប់ពីបញ្ចប់ការសិក្សានៅវិទ្យាស្ថានជាតិអប់រំ ។ ការមើលឃើញពីតំលៃសមត្ថភាព និងក្តីសង្ឃឹមរបស់គេនេះជួយអោយពួកគេមានការសិក្សាកាន់តែល្អថែមទៀត ។ លោក Jane S. Halonen និងលោក John W. Santrock (1996) បានអះអាងថា សិស្ស និស្សិតដែលមានការជឿជាក់អំពីសមត្ថភាព និងក្តីសង្ឃឹម ជួយអោយពួកគេមានការយកចិត្តទុកដាក់កាន់តែប្រសើរឡើង និងរៀនបានកាន់តែមានប្រសិទ្ធភាព[១២៨] ។

តើការអោយតំលៃខ្លួនឯងរបស់និស្សិតលើមុខវិជ្ជានីមួយៗផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យាមានទំនាក់ទំនងជាមួយសមិទ្ធផលសិក្សាដែរឬទេ ?

លទ្ធផលស្រាវជ្រាវបង្ហាញថា ការអោយតំលៃខ្លួនឯងរបស់ក្រុមនិស្សិតគ្រប់មុខវិជ្ជាទាំងអស់សុទ្ធតែមានទំនាក់ទំនងយ៉ាងវិជ្ជមានជាមួយនឹងលទ្ធផលសិក្សារបស់គេ ( ជីវវិទ្យា r = .877 គីមីវិទ្យា r = .847 គណិតវិទ្យា r = .836 និងរូបវិទ្យា r = .782 ) ។ លទ្ធផលនៃការស្រាវជ្រាវនេះឃើញដូចលទ្ធផលនៃការស្រាវជ្រាវរបស់អ្នកប្រាជ្ញលោកខាងលិច និងស្របជាមួយទ្រឹស្តីដែលនិយាយថា ការឱ្យតំលៃលើខ្លួនឯងមានទំនាក់ទំនងវិជ្ជមានជាមួយនឹងសមិទ្ធផលសិក្សារបស់សិស្ស និងនិស្សិត ។ ទោះជាលទ្ធផលស្រាវជ្រាវនេះបង្ហាញថា ការឱ្យតំលៃខ្លួនឯងរបស់គរុនិស្សិតរូបវិទ្យាមានទំនាក់ទំនងតិចជាងមុខវិជ្ជាវិទ្យាសាស្ត្រផ្សេងទៀតយ៉ាងណាក៏ដោយ ក៏លទ្ធផលសិក្សារបស់ពួកគេនៅតែមានទំនាក់ទំនងជាមួយការអោយតំលៃខ្លួនឯង ។ ការអប់រំដោយប្រើវិធីសាស្ត្រផ្តោតលើសកម្មភាពម្ចាស់ការ និងការអនុវត្តការពិសោធន៍របស់និស្សិតផ្ទាល់ ការផលិតសម្ភារៈឧបទេស ព្រមទាំងការទទួលស្គាល់នូវស្នាដៃរបស់គេ ជាកត្តាសំខាន់បំផុតក្នុងការរួមចំណែកអភិវឌ្ឍន៍ការអោយតំលៃខ្លួនឯងរបស់សិស្ស និងនិស្សិត ។ នៅវិទ្យាស្ថានជាតិអប់រំ គរុនិស្សិតបានសិក្សាទ្រឹស្តីនៅ

[128] Jane S. Halonen & John W. Santrock, Psychology Contexts of Behavior, USA, Brown &Benchmark, 1996, p.452.

ក្នុងថ្នាក់ និងបានបង្ហាញស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រ តាមរយៈការតាំងពិព័តន៍សម្ភារៈវិទ្យាសាស្ត្របង្រៀន ។ បន្ថែមលើសនេះទៅទៀត គរុនិស្សិតត្រូវបានគេផ្តល់ឱកាសអោយបង្ហាញសមត្ថភាពចំពោះស្នាដៃរកឃើញរបស់ពួកគេ ។ ពួកគេក៏ត្រូវបំពេញកម្មសិក្សាចុះទៅបង្រៀនបន្ទាប់ពីរៀនទ្រឹស្តីនៅក្នុងបន្ទប់រៀនដែលនេះជារបៀបរៀនធ្វើផ្ទាល់តែម្តង ។ ការផ្តល់រង្វាន់ជូនគរុនិស្សិតពូកែត្រូវបានធ្វើការវាយតម្លៃយ៉ាងយុត្តិធម ។ តាមការសម្ភាសនិស្សិតបានកត់សំគាល់ឃើញថា នៅពេលណានិស្សិតបានអនុវត្តស្រាវជ្រាវដោយផ្ទាល់ខ្លួន ពួកគេនឹងមានកំលាំងចិត្តចង់សិក្សាកាន់តែខ្លាំងឡើង ។ នេះមានន័យថា ការផ្តល់ឱកាសអោយនិស្សិតរៀនធ្វើជួយអោយពួកគេមានកំឡាំងចិត្តចង់សិក្សាទ្វេដង ។ កំលាំងចិត្តសិក្សាជាស្នូលនាំអោយពួកគេមានការអោយតំលៃលើខ្លួនឯងខ្ពស់ ។

## ៥.៤ - ទំនាក់ទំនងរវាងការអោយតំលៃខ្លួនឯង និង ការពេញចិត្តនឹងការសិក្សា

តើការអោយតំលៃខ្លួនឯងមានទំនាក់ទំនងទៅនឹងការពេញចិត្តនឹងការសិក្សាដែរឬទេ ?

លទ្ធផលស្រាវជ្រាវបានបង្ហាញថា ការអោយតំលៃខ្លួនឯងមានទំនាក់ទំនងវិជ្ជមានតិចតួចជាមួយការពេញចិត្តនឹងការសិក្សា (r=.១៦៤) ។ លទ្ធផលស្រាវជ្រាវនេះឆ្លុះបង្ហាញទៅនឹងសម្មតិកម្មស្រាវជ្រាវដែលលើកឡើងថា ការអោយតំលៃខ្លួនឯងមានទំនាក់ទំនងជាមួយការពេញចិត្តនឹងការសិក្សា ។ និស្សិតមានការឱ្យតំលៃខ្លួនឯងគឺដោយសារពួកគេមើលឃើញអំពីតំលៃសិក្សា តំលៃចំណេះដឹង និងការពេញចិត្តនឹងគុណសម្បត្តិផ្ទាល់ខ្លួនរបស់គេ ។ គ្រូដែលផ្តល់ការលើកទឹកចិត្ត និងបង្ហាញពីគោលបំណងជាក់លាក់ដល់និស្សិតជួយអោយនិស្សិតមានការពេញចិត្តនឹងការសិក្សារបស់គេ ។ ការផ្តល់ឱកាសអោយសិស្ស និស្សិតបញ្ចេញស្នាដៃក៏ជួយអោយនិស្សិតមើលឃើញពីតំលៃស្នាដៃរបស់គេ ហើយពួកគេនឹងអោយតំលៃលើខ្លួនឯង ។ ការពេញចិត្តនឹងការសិក្សាកើតចេញពីបរិយាកាសរបស់សាលារៀន សមត្ថភាពរបស់គ្រូ កម្មវិធីសិក្សាល្អ សាលារៀនមានវិន័យនិស្សិតមើលឃើញពីគោលបំណងជាក់លាក់របស់គេ សម្ភារៈសិក្សាទំនើប និងកើតចេញពីកំលាំងចិត្តចង់សិក្សារបស់សិស្ស និស្សិតផ្ទាល់ ។ នៅវិទ្យាស្ថានជាតិអប់រំ ការអោយនិស្សិតបង្ហាញស្នាដៃវិទ្យាសាស្ត្រតាមរយៈការតាំងពិព័តន៍វិទ្យាសាស្ត្រ និងការចុះកម្មសិក្សាបង្រៀន ពិតជាបណ្តុះការអោយតំលៃខ្លួនឯងរបស់និស្សិតអោយកាន់តែមានស្វ័យសិក្សា និងចង់រៀនដោយខ្លួនឯង ។ នៅពេលនិស្សិតមានការសិក្សាដោយឯករាជ្យម្ចាស់ការលើខ្លួនឯង គេនឹងពេញចិត្តលើមុខវិជ្ជាសិក្សានោះ ។ លោក Deci Sheinman និងលោក Ryan (1981) បានបញ្ជាក់ថា នៅពេលសិស្ស និស្សិតដែលមានការជ្រើសរើសភារកិច្ចការងារ និងចាប់អារម្មណ៍លើការដោះស្រាយដោយខ្លួនឯងផ្ទាល់ នោះការស្វែងយល់ពីសិទ្ធិស្វ័យសម្រេច និងកំឡាំងចិត្តខាងក្នុងរបស់គេនឹងកើន

ឡើងខ្ពស់ [១២៩] ។ និស្សិតមានការអោយតំលៃខ្លួនឯងពិតជាមានការពេញចិត្តនឹងការសិក្សារបស់គេ ទោះតិចក្តី ឬច្រើនក្តី ព្រោះការអោយតំលៃខ្លួនឯងជាធាតុដ៏សំខាន់ក្នុងការជួយអោយនិស្សិតមានការពេញចិត្តនឹងការសិក្សារបស់គេ ។ ការជឿជាក់លើសមត្ថភាពរបស់ខ្លួន ការពេញចិត្តនឹងអាជីពរបស់ខ្លួន សុទ្ធតែបណ្តុះការអោយតំលៃខ្លួនឯងកាន់តែខ្លាំងឡើង ។ បញ្ច្រាសទៅវិញ ការជឿជាក់លើការអោយតំលៃខ្លួនឯងនេះបែជាជួយអោយនិស្សិតមានការពេញចិត្តទៅលើការសិក្សារបស់គេវិញដែរ ។ នៅមហាវិទ្យាល័យ ក៏ដូចជាវិទ្យាស្ថានជាតិអប់រំ ដើម្បីអោយនិស្សិតមានការពេញចិត្តទៅនឹងមុខវិជ្ជាសិក្សារបស់ពួកគេ លុះណាតែនិស្សិតខ្លួនឯងមានអារម្មណ៍ជឿជាក់លើខ្លួនឯងជាមុន ។ និស្សិមានការជឿជាក់លើតំលៃខ្លួនឯងតិច ការពេញចិត្តទៅនឹងមុខវិជ្ជាសិក្សារបស់គេក៏មានកម្រិតតិចដែរ ។ លោក Lilian G. Zatz បញ្ជាក់ថា មនុស្សដែលមានការអោយតំលៃខ្លួនឯងខ្ពស់មានទឹកចិត្តសប្បាយរីករាយ ( Cheerful mood ) មានគំនិតសុទិដ្ឋិនិយម និងមានថាមពលវិជ្ជមានខ្ពស់ [១៣០] ។

គរុនិស្សិតបានមើលឃើញពីការខិតខំសិក្សា និងកំរិតអប់រំថ្នាក់ខ្ពស់របស់គេ ព្រោះពួកគេមានការប្រលងប្រជែងសមត្ថភាពជារៀងរហូតមក ចាប់តាំងពីកំរិតមូលដ្ឋានរហូតដល់វិទ្យាស្ថានជាតិអប់រំថែមទៀត ។ ការមើលឃើញពីតំលៃបញ្ញាញាណ និងការខិតខំប្រឹងប្រែងទាំងនោះ ក៏ជួយអោយគេកាន់តែមានមោទនភាព និងមើលឃើញពីតំលៃខ្លួនគេបន្ថែមទៀត ។ ជាមួយនេះដែរ គេក៏មានមោទនភាពទៅនឹងតំលៃសីលធម៌របស់គេ ដោយអ្នកដទៃទីងកោតសរសើរ និងអោយតំលៃចំណេះដឹង និងសីលធម៌របស់គេ ។ ឥទ្ធិពលនេះធ្វើអោយពួកគេពេញចិត្តនឹងមុខវិជ្ជាដែលគេខិតខំកសាងជាយូរមកហើយ ។ម្យ៉ាងវិញទៀត ការពេញចិត្តនឹងការសិក្សារបស់គេគឺដោយសារទេពកោសល្យ និងសម្បទាពីកំណើតរបស់គេ ។ គរុនិស្សិតដែលត្រូវបានធ្វើសម្ភាសន៍ភាគច្រើនបានអះអាងថា ការដែលគេពេញចិត្តមុខវិជ្ជាឯកទេសរបស់គេគឺដោយសារមកពីគេមាននិស្ស័យពីកំណើត និងបំណងពីអតីតកាលរបស់គេដែលចង់ក្លាយជាអ្នកវិទ្យាសាស្ត្រ ។ ដូច្នេះ ការពេញចិត្តនឹងការសិក្សាមានទំនាក់ទំនងទៅនឹងកត្តាជាច្រើនដោយរាប់បញ្ចូលទាំងសាលារៀន គ្រួសារ និងខ្លួនគេផ្ទាល់ ហើយការឱ្យតំលៃខ្លួនឯងរបស់និស្សិតក៏ជាការជួយអោយពួកគេមានការពេញចិត្តទៅនឹងការសិក្សារបស់គេដែរ ។

## ៥.៥ - ទំនាក់ទំនងរវាងការពេញចិត្តនឹងការសិក្សា និង សមិទ្ធផលសិក្សា

**តើការពេញចិត្តនឹងការសិក្សាមានទំនាក់ទំនងជាមួយសមិទ្ធផលសិក្សាដែរឬទេ ?**

---

[129] Cheryl L. Spaulding, Motivation in the Classroom, USA, Mc Graw-Hill, Inc, , 1992, p.23
[130] Lilian G. Katz, Distinction between Self-esteem and Narcissism: implications for Practice, op.cit., p.on line.

ការស្រាវជ្រាវបង្ហាញថា ការពេញចិត្តនឹងការសិក្សាមានទំនាក់ទំនងយ៉ាងវិជ្ជមានជាមួយសមិទ្ធផលសិក្សាបំផុត ( r = .96 ) ។ និស្សិតមានការពេញចិត្តនឹងការសិក្សាកាន់តែខ្លាំង សមិទ្ធផលសិក្សារបស់គេកាន់តែប្រសើរឡើង ។ សមិទ្ធផលសិក្សាពិតជាអាស្រ័យលើការពេញចិត្តនឹងការសិក្សារបស់និស្សិត ដូចនេះកំលាំងចិត្តសិក្សារបស់សិស្ស និងនិស្សិតជាកត្តាសំខាន់បំផុត ដោយមិនត្រឹមតែជួយអោយនិស្សិតមានការឱ្យតំលៃខ្លួនឯងខ្ពស់ប៉ុណ្ណោះទេ តែថែមទាំងជួយឱ្យពួកគេទទួលបានលទ្ធផលសិក្សាកាន់តែល្អឡើងថែមទៀត ។ នៅពេលណានិស្សិតមើលឃើញពីតំលៃមុខវិជ្ជាសិក្សារបស់គេ នោះនិស្សិតនឹងមានការពេញចិត្តនឹងការសិក្សា ហើយនៅពេលដែលនិស្សិតមានការពេញចិត្តនឹងការសិក្សា នោះគេនឹងទទួលបានសមិទ្ធផលល្អ ។ លទ្ធផលនេះគាំទ្រទៅនឹងការសង្កេតដែលសន្មតនៅក្នុងសម្មតិកម្មស្រាវជ្រាវដែលលើកឡើងថា ការពេញចិត្តនឹងការសិក្សាមានទំនាក់ទំនងយ៉ាងវិជ្ជមានជាមួយសមិទ្ធផលសិក្សា ។ ជាមួយគ្នានេះដែរ លទ្ធផលនៃការស្រាវជ្រាវនេះក៏សមស្របទៅតាមគំនិតរបស់លោក John Holland ដែលបានអះអាងថា សមត្ថភាពអនុវត្តការងារ និងការពេញចិត្តមុខរបរកើនឡើងបាន នៅពេលណាការពេញចិត្តរបស់គេ និងបំនិនសមត្ថភាពរបស់គេមានភាពស៊ីគ្នា[១៣១] ។ ការស្រាវជ្រាវនេះបង្ហាញយ៉ាងច្បាស់ពីភាពស៊ីគ្នារវាងការពេញចិត្តនឹងការសិក្សារបស់និស្សិត និងសមិទ្ធផលសិក្សាដែលកើតចេញពីស្នាដៃ និងសមត្ថភាពផ្ទាល់ខ្លួនរបស់គេ ។

ហេតុផលសមទំនងមួយដែលគរុនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំមានការពេញចិត្តនឹងការសិក្សារបស់គេគឺមកពីទីកន្លែងសិក្សាមានលក្ខណៈល្អ មានសម្ភារៈទំនើប និងមានបន្ទប់ពិសោធន៍ថ្មីទំនើបដោយមានការជួយឧបត្ថម្ភពីអង្គការ JICA របស់ប្រទេសជប៉ុន ។ បរិយាកាសសាលារៀនបន្ទប់រៀនមានផាសុខភាព និងមានឧបករណ៍សិក្សាទំនើប ព្រមទាំងមានបន្ទប់ពិសោធន៍បែបនេះជួយអោយនិស្សិតកាន់តែមានការពេញចិត្ត និងមានជំនក់ចិត្តលើការធ្វើពិសោធន៍របស់ពួកគេ ។ ដូច្នេះ សម្ភារៈសិក្សាមានឥទ្ធិពលណាស់ក្នុងការទាក់ទាញទឹកចិត្តសិស្ស និស្សិតឱ្យមានចិត្តចង់រៀនសូត្រ ។ លោក Smart (1986) បានបញ្ជាក់ថា បុគ្គលិកលក្ខណៈរបស់សិស្សគឺទឹកចិត្ត និងអារម្មណ៍ល្អចំពោះការរៀនសូត្រ ព្រមទាំងបរិយាកាសបន្ទប់រៀនសុទ្ធតែមានឥទ្ធិពលនាំអោយសិស្សមានចិត្តចង់រៀន ពោលគឺឥទ្ធិពលសាលារៀន បន្ទប់រៀន បន្ទប់ពិសោធន៍ និងបណ្ណាល័យ ។ នៅពេលទឹកចិត្តចង់សិក្សា និងបរិយាកាសនៃការសិក្សាមានទំនាក់ទំនងគ្នា នោះគុណភាពសិក្សាបានកាន់តែប្រសើរឡើង[១៣២] ។

---

131 Cheryl L. Spaulding, Motivation in the Classroom, op.cit., p.23
132 Ibid., p. 23

ហេតុផលមួយផ្សេងទៀតដែលគរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំមានការពេញចិត្តនឹងការសិក្សាអាចមកពីសកម្មភាព និងសមត្ថភាពបង្រៀន និងទឹកចិត្តរាក់ទាក់របស់គ្រូនៅវិទ្យាស្ថានជាតិអប់រំ ។ ទាំងអស់នេះជាសមាសធាតុខាងក្រៅដែលជាចលករជំរុញអោយសិស្ស និស្សិតចូលចិត្ត និងពេញចិត្តនឹងការសិក្សារបស់គេ ។ លើសពីនេះទៅទៀត និស្សិតដែលសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំបានមើលឃើញច្បាស់ពីគោលបំណងជាក់លាក់របស់ខ្លួននៅពេលអនាគត ដែលពួកគេនឹងក្លាយទៅជាគ្រូបង្រៀន។ កត្តានេះជាចលករជំរុញអោយពួកគេមានការពេញចិត្តនឹងការសិក្សារបស់គេកាន់តែខ្លាំងឡើង សមដូចលទ្ធ-ផលស្រាវជ្រាវបានបង្ហាញថា គរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំមានការពេញចិត្តខ្លាំងលើមុខរបររបស់គេដល់ទៅ ៩៩ ភាគរយដែលនេះជាកម្រិតខ្ពស់បំផុត ។

កម្មវិធីសិក្សាដែលមានពេលវេលាសិក្សាច្រើននៅសាលាក៏ផ្ដល់ឱកាសអោយគរុនិស្សិតខិតខំធ្វើការសិក្សាបានខ្លាំងដែរ ហើយប្រព័ន្ធអប់រំតាមបែបរបបសាលារៀន (school regime) ជាហេតុផលជួយអោយសិស្សខិតខំរៀន និងជួយអោយគេមើលឃើញពីតំលៃសិក្សារបស់គេ ។ ការស្រាវជ្រាវបានរកឃើញថា រាល់មុខវិជ្ជានានានៅក្នុងកម្មវិធិសិក្សាផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យាត្រូវបាននិស្សិតមានការពេញចិត្តពីកំរិតបង្គួរ ។ ម៉ោងសិក្សាច្រើននៅសាលារៀនកាន់តែជួយអោយសិស្សមើលឃើញពីតំលៃនៃការខិតខំប្រឹងប្រែងសិក្សារបស់គេ ដែលជាប្រការជួយអោយនិស្សិតមានការសិក្សាបានប្រសើរ ។ អ្នកស្រាវជ្រាវសង្កេត ឃើញថាសាលារៀនដែលមានពេលវេលាច្រើន សំរាប់អោយសិស្សរៀននៅសាលារៀនច្រើនមានប្រសិទ្ធភាពជាងសា-លាដែលមានពេលវេលាខ្លីសំរាប់សិស្សនៅសាលា ។ ភស្តុតាងនេះត្រូវបានសង្កេតឃើញចំពោះសិស្ស និងនិ-ស្សិតនៅប្រទេសជប៉ុនដែលតំរូវអោយរៀនច្រើនម៉ោងនៅតាមសាលារៀន ហើយសិស្ស និងនិស្សិតជប៉ុនទទួលបានលទ្ធផលល្អជាងគេក្នុងការធ្វើតែសស្តង់ដាអន្តរជាតិឆ្នាំ១៩៨៥ [១៣៣] ។ ដូច្នេះ គោលបំណងជាក់លាក់ និងកម្មវិធីសិក្សារបស់វិទ្យាស្ថានជាតិអប់រំដែលផ្ដល់អោយនិស្សិតរៀនច្រើននៅសាលា ជួយអោយពួកគេចូលចិត្តការសិក្សា និងពេញចិត្តមុខវិជ្ជារបស់គេកើនឡើង ហើយគុណភាពសិក្សាក៏ប្រសើរដែរ ។

ជាមួយគ្នានេះដែរ វិន័យក្នុងការសិក្សា និងការវាយតំលៃសមិទ្ធផលសិក្សាប្រកបដោយភាពយុត្តិ-ធមដល់សិស្ស និស្សិត ក៏ជាគ្រឿងជំនួយជួយអោយពួកគេមានការពេញចិត្តទៅនឹការសិក្សារបស់គេដែរ ។ គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រនៅវិទ្យាស្ថានជាតិអប់រំនេះត្រូវបានគេជ្រើសរើសចេញពីនិស្សិតឆ្នើមរបស់សាលា ។ ការមើលឃើញនូវគំរូល្អរបស់គ្រូជួយអោយសិស្សមានទឹកចិត្តស្រលាញ់អាជីពរបស់គេ ។ នេះជាគំរូមួយធ្វើឱ្យ

[133] Thomask. Crowl ; Sally Kaminsky ; David M. Podel , Educational Psychology - Window on Teaching, op.cit., p.9

និស្សិតជំនាន់ក្រោយខិតខំស្រាវជ្រាវ និងមានមោទនភាពចំពោះគ្រូបង្រៀន និង សាលារបស់គេ ។

ទោះជាយ៉ាងនោះក៏ដោយ បញ្ហាយុត្តិធម៌ និងវិន័យនេះនៅពុំទាន់បានល្អទាំងស្រុងនៅឡើយ ដោយនិស្សិតខ្លះបានបញ្ជាក់ថា សាលាត្រូវបន្ថែមវិន័យ និងផ្តល់ភាពយុត្តិធម៌អោយកាន់តែសុក្រិតបន្ថែមទៀត ។រីឯកំរិតសញ្ញាបត្ររបស់គ្រូភាគច្រើននៅមានកម្រិតថ្នាក់បរិញ្ញាបត្របូកមួយ ដែលនេះជាហេតុនាំអោយមានការរាំងស្ទះដល់សមត្ថភាពបណ្តុះបណ្តាល និងដល់គុណភាពសិក្សារបស់និស្សិត ហើយគ្រូបង្រៀនខ្លះដែលបានចេញទៅបង្រៀនមួយរយៈពេលនៅតាមខេត្តត្រូវបានវិលត្រលប់មកបង្រៀននៅវិទ្យាស្ថានវិញ ដែលនេះក៏ជាហេតុនាំអោយមានបញ្ហាដល់សមិទ្ធផលសិក្សារបស់គរុនិស្សិតនៅមានកម្រិត ។ ជាការសំខាន់បំផុតនោះ ការពេញចិត្តនឹងការសិក្សារបស់និស្សិត គឺពឹងផ្អែកទៅលើកំលាំងចិត្តខាងក្នុងរបស់និស្សិតប្រសើរជាងកំលាំងចលករខាងក្រៅ ។ គោលបំណងសំខាន់របស់វិទ្យាស្ថានជាតិអប់រំត្រូវធ្វើយ៉ាងណាអោយនិស្សិតខ្លួនគេមានការពេញចិត្តដោយខ្លួនឯង ។ កំលាំងចិត្តលើមុខវិជ្ជាសិក្សារបស់និស្សិតដើរតួនាទីយ៉ាងសំខាន់ក្នុងការសិក្សារបស់គេ ហើយជួយអោយពួកគេទទួលបានលទ្ធផលកាន់តែល្អឡើង ។ ជាការជាក់ស្តែង គរុនិស្សិតផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យាពេញចិត្តទៅនឹងសមត្ថភាពសិក្សារបស់គេ ដោយពួកគេបានមើលឃើញពីតួនាទីរបស់គេក្នុងការទ្រ-ទ្រង់ជីវិតរបស់គេ ហើយតួនាទីក្នុងនាមជាគ្រូនេះមិនត្រឹមតែជួយខ្លួនគេមើលឃើញពីតំលៃសំរាប់គេម្នាក់ៗប៉ុណ្ណោះទេ តែថែមទាំងផ្តល់នូវកិត្តិយសសំរាប់គ្រួសារ និងសង្គមជាតិរបស់គេថែមទៀត ។ ដូចនេះ គរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំពិតជាមានមោទនភាពចំពោះមុខវិជ្ជាសិក្សា និងមុខរបររបស់គេណាស់ ។ និស្សិតដែលមានការតម្រង់ទិសដៅដោយខ្លួនឯងនឹងមានកំលាំងចិត្តខ្លាំង និងមានការអោយតំលៃខ្លួនឯងខ្ពស់ ដែលទាំងនេះជួយអោយពួកគេទទួលបានសមិទ្ធផលខ្ពស់ ។

រួមសេចក្តីមក ចលករខាងក្រៅ ដូចជា កត្តាគ្រូ សម្ភារៈសិក្សា បរិយាកាសរបស់វិទ្យាស្ថានជាតិអប់រំជួយអោយនិស្សិតមានការពេញចិត្តការសិក្សារបស់គេ និងមានកំលាំងចិត្តផ្ទាល់ខ្លួនរបស់គេ ។ កត្តាទាំងនេះពិតជាជួយឱ្យនិស្សិតទទួលបានលទ្ធផលសិក្សាខ្ពស់ ។ ការពេញចិត្តនឹងការសិក្សារបស់សិស្ស និស្សិតមិនត្រឹមតែជួយឱ្យពួកគេបានទទួលលទ្ធផលល្អតែប៉ុណ្ណោះទេ តែការពេញចិត្តនេះជួយជំរុញអោយគុណភាពសិក្សាកាន់តែប្រសើរសំរាប់ខ្លួនគេ និងសំរាប់វិទ្យាស្ថានបណ្តុះបណ្តាលផ្សេងទៀតដែរ ។ ដូច្នេះ ប្រការសំខាន់បំផុតសំរាប់ជួយអោយសាលាទទួលបានគុណភាព គេត្រូវយកចិត្តទុកដាក់ដល់កត្តានានាដែលធ្វើ ឱ្យគរុនិស្សិតមានការពេញចិត្តការសិក្សាមានចំណង់សិក្សាលើមុខវិជ្ជាឯកទេសរបស់គេដោយខ្លួនគេជាមុន ព្រោះលទ្ធផលស្រាវជ្រាវបង្ហាញថា ការពេញចិត្តនឹងការសិក្សាមានទំនាក់ទំនងយ៉ាងវិជ្ជមានជាមួយសិមិទ្ធផលសិក្សា ។

# សេចក្ដីសន្និដ្ឋាន

លទ្ធផលស្រាវជ្រាវនេះមានលក្ខណៈគួរអោយចាប់អារម្មណ៍ និងមានសារៈសំខាន់ក្នុងការជួយអភិវឌ្ឍការអោយតំលៃខ្លួនឯងរបស់សិស្ស និងនិស្សិត ព្រមទាំងជាកត្តាជួយជំរុញអោយការសិក្សារបស់សិស្ស និងនិស្សិតគ្រប់រូបទទួលបានលទ្ធផលល្អ ។ ដូច្នេះការសិក្សាស្រាវជ្រាវនេះនាំទៅដល់ការធ្វើសន្និដ្ឋានដូចតទៅ :

- សមិទ្ធផលល្អក្នុងការសិក្សាជាកត្តាបណ្ដាលអោយមានមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍការអោយតំលៃខ្លួនឯងរបស់សិស្ស និង និស្សិត ។

- ការអោយតំលៃខ្លួនឯងមានសារៈសំខាន់ខ្លាំងណាស់សំរាប់បុគ្គលម្នាក់ៗ ។ វាជាមូលដ្ឋានគ្រឹះក្នុងការបង្កើតបាននូវកំលាំងចិត្ត និងជំរុញឱ្យបុគ្គលម្នាក់ៗដែលតែងតែជួបឧបសគ្គមានការតស៊ូយ៉ាងស្វិតស្វាញនឹងការងារ ។ម្យ៉ាងវិញទៀត បុគ្គលដែលមានការអោយតំលៃខ្លួនឯងខ្ពស់តែងតែមានកំលាំងចិត្ត និងសុខភាពផ្លូវចិត្តល្អ ។ តាមរយៈការស្រាវជ្រាវនេះ លទ្ធផលបានបង្ហាញថា ការរីកចំរើននៃការអោយតំលៃខ្លួនឯងមិនអាស្រ័យទៅលើអាយុទេសំរាប់មនុស្សក្នុងវ័យឧត្តមសិក្សា ប៉ុន្តែកត្តាអប់រំនៅក្នុងគ្រួសារ សាលារៀន និងកត្តាមជ្ឈដ្ឋានមានឥទ្ធិពលដល់ការអោយតំលៃខ្លួនឯងរបស់មនុស្ស ។ បរិយាកាសគ្រួសារ ដូចជាការផ្ដល់ហេតុផលក្នុងការអប់រំរបស់ឪពុកម្ដាយ ការផ្ដល់សេចក្ដីស្រលាញ់ និងការផ្ដល់បាននូវសុខមាលភាពផ្លូវចិត្ត ការថែរក្សាការប្រើភាសាវិជ្ជមាន និងរបៀបអប់រំដោយមានការពន្យល់អំពីហេតុផលរបស់ឪពុកម្ដាយជួយអោយបុត្រធីតាមានការរីកលូតលាស់ការអោយតំលៃខ្លួនឯងបានល្អ និងជួយឱ្យគេអភិវឌ្ឍខ្លួនឯងទៅជាមនុស្សពេញលេញស្វិតស្វាញ តស៊ូក្នុងការងារដែលជាហេតុជួយអោយពួកគេទទួលបានជោគជ័យនៅថ្ងៃអនាគត ។

- ការអោយតំលៃខ្លួនឯងខ្ពស់ជាលក្ខខណ្ឌដ៏សំខាន់សំរាប់សំគាល់នូវការអភិវឌ្ឍ តាមរយៈការអប់រំដល់និស្សិត មន្ត្រីអប់រំ និងអ្នកគ្រប់គ្រងអោយបំពេញការងាររបស់ខ្លួនដោយភាពម្ចាស់ការ និងមានស្មារតីទទួលខុសត្រូវខ្ពស់ ។ ដូច្នេះនិស្សិតដែលជាអនាគតអ្នកអប់រំ និងមន្ត្រីគ្រប់គ្រង ត្រូវតែមានការអោយតំលៃខ្លួនឯងខ្ពស់ ព្រោះវាជាមូលដ្ឋានគ្រឹះនៃកំលាំងចិត្ត ក្នុងការតស៊ូយ៉ាងស្វិតស្វាញនឹងការងាររហូតទទួលបានលទ្ធផលសិក្សាបានល្អប្រសើរ ។ សិស្ស និស្សិតកាន់តែមានការអោយតំលៃខ្លួនឯងខ្ពស់ គុណភាពសិក្សារបស់គេកាន់តែប្រសើរឡើង ។ បរិយាកាសសាលារៀន បន្ទប់រៀន និងសម្ភារៈសិក្សា មានឥទ្ធិពលយ៉ាងខ្លាំងដល់កំលាំងចិត្តក្នុងការសិក្សារបស់និស្សិត ។ ជាមួយគ្នានេះដែរ កម្មវិធីសិក្សាបង្កប់ខ្លឹមសារពីងាយទៅលំបាក វិធីសាស្ត្របង្រៀនដែលផ្ដល់ឱកាសអោយមានការចូលរួមរបស់និស្សិត និងការផ្ដល់ឱកាសឱ្យនិស្សិតបញ្ចេញសមត្ថភាព

និងការវាយតម្លៃដែលមានបញ្ជាក់អំពីមូលវិចារណ៍ហេតុផល ជាល័ក្ខខ័ណ្ឌចាំបាច់សំរាប់ជួយអភិវឌ្ឍការអោយតំលៃខ្លួនឯងរបស់សិស្ស និស្សិតនៅក្នុងការអប់រំនៅតាមសាលារៀន ។

- ការវាយតំលៃសមិទ្ធផលសិក្សារបស់សិស្ស និស្សិត ដោយមានការចូលរួមពីតណកម្មាការខាងក្រៅប្រកបដោយតម្លាភាព មានឥទ្ធិពលយ៉ាងខ្លាំងដល់ការជឿជាក់លើសមត្ថភាពខ្លួនរបស់សិស្ស និស្សិត ។ ឥទ្ធិពលគ្រប់គ្រងនៃរបបសង្គម និងវប្បធម៌ប្រពៃណីរស់នៅក្នុងសង្គមក៏មានឥទ្ធិពលដល់ការឱ្យតំលៃខ្លួនឯងរបស់មនុស្សដែរ ។ មនុស្សដែលរស់នៅក្នុងស្ថានភាពសង្គមមានការគាំទ្រច្រើនមានការអភិវឌ្ឍការឱ្យតំលៃខ្លួនឯងខ្ពស់ ។

- និស្សិតដែលមានការអោយតំលៃខ្លួនឯងខ្ពស់នឹងទទួលបានសមិទ្ធផលសិក្សាបានល្អ និងមានកំលាំងចិត្តចង់សិក្សា ព្រមទាំងមានឆន្ទៈមោះមុតមិនរួញរានឹងឧបសគ្គ ហើយនៅទីបញ្ចប់ ពួកគេនឹងអាចសំរេចគោលបំណងដែលគេបានគ្រោងទុកនៅក្នុងជីវិតរបស់គេ ព្រោះគេជាមនុស្សមានការប្តេជ្ញាចិត្តខ្ពស់មិនរាថយ ចំពោះបរាជ័យ ។ ការអោយតំលៃខ្លួនឯងត្រូវបានអភិវឌ្ឍព្រមគ្នាទាំងនៅក្នុងបរិយាកាសគ្រួសារ សាលារៀន និងបរិយាសង្គមទាំងមូល ។ នៅពេលមនុស្សទទួលបានការអប់រំក្នុងគ្រួសារ និងសាលារៀនដែលបង្កប់នូវខ្លឹមសារការអោយតំលៃខ្លួនឯង មនុស្សនោះនឹងមានអារម្មណ៍ជឿជាក់លើខ្លួនឯងកាន់តែខ្លាំង ហើយបរិយាកាសល្អក្នុងសង្គមក៏ជាការរួមចំណែកដ៏សំខាន់ក្នុងការអភិវឌ្ឍការអោយតំលៃខ្លួនឯងរបស់មនុស្សដែរ ។ ដូច្នេះដើម្បីអភិវឌ្ឍសង្គមក្តី ឬសេដ្ឋកិច្ចសង្គមទាំងមូលក្តី គេត្រូវតែអភិវឌ្ឍធនធានមនុស្សជាមុនសិន ។ ហើយការអភិវឌ្ឍធនធានមនុស្សទាមទារនូវល័ក្ខខ័ណ្ឌបីសំខាន់ : ជីវភាពប្រសើរឡើង ការអោយតំលៃខ្លួនឯង ឬកិត្តិយស និងសេរីភាពក្នុងការជ្រើសរើស ។ ការស្រាវជ្រាវផ្តល់ជាមតិថា យើងត្រូវតែយកចិត្តទុកដាក់អភិវឌ្ឍការអោយតំលៃខ្លួនឯងរបស់សិស្ស និស្សិតនៅតាមផ្ទះ នៅតាមសាលារៀនជាមុនសិន ដើម្បីឈានទៅរកការអភិវឌ្ឍសង្គម ឬសេដ្ឋកិច្ចរបស់សង្គម ពោលគឺយើងត្រូវអភិវឌ្ឍសមត្ថភាពសិក្សារបស់សិស្ស និស្សិត ដើម្បីអភិវឌ្ឍការអោយតំលៃខ្លួនឯងអោយបានខ្ពស់ ។ ដើម្បីអភិវឌ្ឍគ្រួសារ ឬសេដ្ឋកិច្ចគ្រួសារ គេត្រូវតែអភិវឌ្ឍការឱ្យតំលៃខ្លួនឯងរបស់បុគ្គលម្នាក់ៗឱ្យមានស្មារតី និងមានសុខភាពផ្លូវចិត្តល្អជាមុន ។ វិធីល្អបំផុតគឺផ្តល់ឱកាសឱ្យសិស្សបញ្ចេញសមត្ថភាព ដោយជួយអោយពួកគេបានសំរេចជោគជ័យ តាមរយៈស្វ័យសិក្សាតាមបែបម្ចាស់ការ និងឡើងបង្ហាញស្នាដៃរបស់គេ ។ នៅពេលណាមនុស្សសម្រេចបានការអប់រំមានសមត្ថភាពខ្ពស់ គ្រួសារមានការស្តាប់ហេតុផលក្នុងការអប់រំ នោះមនុស្សនៅក្នុងសង្គមនោះពិតជានឹងមានការអភិវឌ្ឍការអោយតំលៃខ្លួនឯងខ្ពស់ ។ ដូច្នេះ ដើម្បីស្តាជំនឿចិត្ត និងជួយអោយប្រជាពលរដ្ឋខ្មែរមានការទុកចិត្តគ្នា គេត្រូវយកចិត្តទុកដាក់ដល់កត្តាដែលមានឥទ្ធិពលដល់ការឱ្យតំលៃខ្លួនឯង និងយុទ្ធសាស្ត្រអភិវឌ្ឍការអោយតំលៃខ្លួនឯង ។

# អនុសាសន៍

ការសិក្សាស្រាវជ្រាវនេះបានអង្កេតឃើញថា ការអោយតំលៃខ្លួនឯងទទួលឥទ្ធិពលពីកត្តាអប់រំក្នុងគ្រួសារ សាលារៀន និងមជ្ឈដ្ឋានសង្គម ហើយការអោយតំលៃខ្លួនឯងខ្ពស់របស់សិស្ស និស្សិតជាកត្តាកំណត់ដល់អារម្មណ៍ពេញចិត្តនឹងការសិក្សា និងគុណភាពសិក្សារបស់ពួកគេ ។ លទ្ធផលស្រាវជ្រាវនេះមានសារៈសំខាន់ក្នុងការជួយអភិវឌ្ឍការអោយតំលៃខ្លួនឯងរបស់មនុស្សគ្រប់រូប ជាពិសេស ជួយអោយប្រជាពលរដ្ឋខ្មែរមានទំនុកចិត្តលើខ្លួនឯង និងមានការទុកចិត្តគ្នា ។ ដូច្នេះ ការសិក្សាស្រាវជ្រាវនេះ បានឈានដល់ការលើកជាអនុសាសន៍ដូចខាងក្រោម :

១-សូមឱ្យគ្រួសារទាំងឡាយ ពិសេសមាតាបិតារបស់សិស្ស និងនិស្សិតត្រូវតែយកវិធីអប់រំកូនបែបស្តាប់ហេតុផលយកមកប្រើជាប្រចាំ ដើម្បីរួមចំណែកអភិវឌ្ឍការអោយតំលៃខ្លួនឯងអោយបានទាន់ពេលវេលា ។

២-មាតាបិតាត្រូវអប់រំកូនពីតូចរៀងរហូតមកអោយមានស្មារតីទទួលខុសត្រូវខ្ពស់ និងមានភាពម្ចាស់ការព្រមទាំងផ្តល់សិទ្ធិសេរីភាពដល់កូន និងឧស្សាហ៍បង្ហាញតំលៃស្នាដៃល្អៗរបស់កូនជាងការរិះគន់ ឬប្រើភាសាវិជ្ជមានប្រសើរជាងប្រើភាសាអវិជ្ជមានដល់កូនរបស់ខ្លួន ។

៣-សូមអោយលោកគ្រូ អ្នកគ្រូប្រកាន់ខ្ជាប់នូវគតិយុត្តិធម៌ក្នុងការវាយតំលៃសមិទ្ធផលសិក្សារបស់សិស្ស និស្សិត ដោយបញ្ជាក់អំពីហេតុផលច្បាស់លាស់លើសន្លឹកកិច្ចការរបស់សិស្ស និងនិស្សិត ។

៤-អ្នកអប់រំទាំងឡាយត្រូវផ្តល់ឱកាសឱ្យកុមារ និងយុវជនចូលរួមបានយ៉ាងសកម្មក្នុងការបញ្ចេញសមត្ថភាព និងបំណិនរបស់គេ ដើម្បីបង្ហាញដល់អ្នកដទៃអោយបានច្រើនបំផុតទៅតាមការដែលអាចធ្វើទៅបាន ។

៥-សាលារៀន និងគ្រឹះស្ថានបណ្តុះបណ្តាលនានាត្រូវតែរៀបចំអោយមានប័ណ្ណសរសើរ រង្វាន់លើកទឹកចិត្ត ដើម្បីជាសក្ខីភាពនៃការទទួលស្គាល់សមត្ថភាពប្រឹងប្រែងរបស់សិស្ស និស្សិត និងសិក្ខាកាម ។

៦-លោកគ្រូ អ្នកគ្រូត្រូវលើកទឹកចិត្តសិស្សអោយតស៊ូព្យាយាម ចេះវាយតំលៃខ្លួនឯង ព្រមទាំងខិតខំអភិវឌ្ឍខ្លួនជាបន្តបន្ទាប់ និងអោយគេមានចិត្តរំភើបក្នុងការបង្ហាញស្នាដៃរបស់គេ ។

៧- សាលារៀន សាលាបណ្តុះបណ្តាវិជ្ជាជីវៈ និងគ្រឹះស្ថានអប់រំនានាត្រូវបង្ហាញគោលបំណងជាក់លាក់ ដើម្បីអោយសិស្សមើលឃើញពីសារៈសំខាន់ និងផលប្រយោជន៍ចំពោះការសិក្សារបស់គេ ក្នុងគោលបំណងជួយឱ្យគេទទួលបានជោគជ័យក្នុងការសិក្សា ដែលជាមូលដ្ឋានគ្រឹះជួយអោយគេមានចិត្តចង់សិក្សា និងជួយអោយគេមានការជឿជាក់លើខ្លួនឯងចំពោះការសិក្សារបស់គេ ។

៨- សូមអោយក្រសួងអប់រំយុវជននិងកីឡា ចាត់វិធានការកាត់បន្ថយអំពើកេងប្រវ័ញ្ចពីសិស្ស ( លក់ក្រដាសមេរៀន...) ព្រមទាំងលើកតម្កើងការផ្សព្វផ្សាយអំពីអរិយធម៌ស្ងប់ស្ងែង និងបំផុសស្មារតីមោទនភាពជាតិ ព្រមទាំងបង្ហាញស្នាដៃជនគំរូឆ្នើមដល់សិស្សានុសិស្ស និងសាធារណៈជន ដើម្បីលើកតម្កើងតំលៃអ្នកមានសមត្ថភាព និងផ្តល់ឱកាសអោយសិស្សឡើងសំដែង បង្ហាញស្នាដៃរបស់ខ្លួនអោយបានច្រើន ។

៩- បុគ្គលផ្ទាល់ម្នាក់ៗត្រូវហ្វឹកហាត់ការងារផ្សេងៗ ដើម្បីយបទពិសោធន៍ ដោយប្រកាន់ខ្ជាប់នូវជំនឿថា ខ្លួនមានសមត្ថភាពជាមួយនឹងការប្រតិបត្តិការងារ និងបទពិសោធន៍ ហើយការអោយតំលៃមកលើខ្លួនឯងក៏រីកចំរើនទៅតាមនោះ ។

ការអនុវត្តនូវអនុសាសន៍ខាងលើនេះបាន នោះសិស្ស និស្សិត និងប្រជាពលរដ្ឋខ្មែរ នឹងមានការជឿជាក់លើខ្លួនឯង ព្រមទាំងជួយអោយពួកគេមានទឹកចិត្តតស៊ូស្វិតស្វាញក្នុងការងារ ដើម្បីចូលរួមអភិវឌ្ឍសង្គមជាតិ ។ ដោយមើលឃើញថា ការស្រាវជ្រាវលើការអោយតំលៃខ្លួនឯងជាការសិក្សាមួយដែលមានសារៈសំខាន់ណាស់ ដូច្នេះប្រសិនបើមានឱកាស អ្នកស្រាវជ្រាវអាចនឹងបន្តការសិក្សាស្រាវជ្រាវតទៅទៀតស្តីអំពីប្រធានបទទាក់ទងនឹងវិស័យ " ចិត្តរំភើបប្រកបដោយបញ្ញាញាណរបស់អ្នកដឹកនាំ " Emotional Intellectual Leaders ) សំរាប់ការសិក្សាស្រាវជ្រាវនៅថ្ងៃអនាគត ។

# គន្ថនិទ្ទេស

ឯកសារភាសាខ្មែរ


១- កៅ គីមហ៊ួន និង ស សុកន្តន័យ : សន្តិភាពផ្លូវចិត្ត -ដើម្បីសន្តិភាពពិតមួយស្ថិតស្ថេរយូរអង្វែង-ភ្នំពេញ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព ឆ្នាំ ១៩៩៦

២- កៅ គីមហ៊ួន និង សំរាំង កំសាន្ត : វិធីសាស្ត្រក្នុងការដោះស្រាយទំនាស់ ភ្នំពេញ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

៣- ងួន ញ៉ិល : ប្រលឹងមាតាធិបតេយ្យ ភ្នំពេញ ការផ្សាយរបស់កាសែតប្រជាជន ឆ្នាំ ១៩៩២

៤- ចាន់ រដ្ឋសុផា : "ការអភិវឌ្ឍនៃបុគ្គលិកលក្ខណៈរបស់មនុស្ស" នៅក្នុងអត្ថបទមេរៀន ឆ្នាំ ២០០៣

៥- ឆយ យីហ៊ាង : "វិធីសាស្ត្រស្រាវជ្រាវទូទៅ" នៅក្នុងអត្ថបទមេរៀន ឆ្នាំ ២០០២ - ២០០៣

៦- ជួនណាត : វចនានុក្រមខ្មែរ ភាគទី១ និងទី២ ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧-១៩៦៨

៧- នេត បារ៉ុម : "វិធីសាស្ត្រស្រាវជ្រាវវិទ្យាសាស្ត្រអប់រំ" នៅក្នុងអត្ថបទមេរៀន ឆ្នាំ ២០០២ - ២០០៤

៨- នូ ចាន់សុភី : "ប្រវត្តិអប់រំ និងទស្សនៈវិជ្ជាអប់រំ" : នៅក្នុងអត្ថបទមេរៀន ឆ្នាំ ២០០២ - ២០០៤

៩- ប៉ាង ខាត់ : ទឹកចិត្តម្តាយ ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ

១០- ពុទ្ធសាសនបណ្ឌិត្យ : ពុទ្ធសាសនា២៥០០ : ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ២០០០

១១- មីសែល ត្រាណេ : ប្រវត្តិសាស្ត្រនៃកម្ពុជា-សង្គមខ្មែរក្នុងរាជកាលព្រះបាទជ័យវរ្ម័នទី៧

១២- ស៊ា ប៊ុនភេង : សាងខ្លួនឯង-ទស្សនវិជ្ជាលំហាត់ចិត្តរឹងប៉ឹងសំរាប់ដឹកនាំមនុស្សជាតិ ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ១៩៧៣

១៣- ស៊ន សំណាង : "បទពិសោធន៍នៃការអភិវឌ្ឍប្រទេសម៉ាឡេស៊ី" នៅក្នុងសិក្ខាសាលា ខែធ្នូ ឆ្នាំ២០០៣

១៤- ស៊ន សំណាង : "សិល្បៈនៃការសរសេរនិក្ខេបបទ" នៅក្នុងអត្ថបទមេរៀន ២០០២-២០០៤

១៥- អ៊ីម កុច : "របៀបអប់រំកូនក្នុងគ្រួសារ" នៅក្នុងទស្សនាវដ្តីគ្រូបង្រៀន លេខ១៨ - ឆ្នាំ ២០០៤

១៦- អ៊ីម កុច : "បញ្ញត្តិគុណភាពអប់រំ" នៅក្នុង : អត្ថបទមេរៀន ឆ្នាំ ២០០៣

១៧- អ៊ីម កុច : "ចិត្តរំភើប និងកំលាំងចិត្ត" នៅក្នុងទស្សនាវដ្តីគ្រូបង្រៀន លេខ១៩ - ឆ្នាំ ២០០៤

## ឯកសារភាសាបរទេស


18- Allan C. Ornstein, Strategies for Effectivesness Teaching, Brown and Benchmark, 1995

19- Alexander W. Astin, What Matter in College? Four Critical Years, California, Jossey-Bass. Inc, 1993

20- Audrey Harbr, Richard P. Runyon , Fundmentals of Psychology, New York, Random House, 1986

21- Barbara Grosss Davis, Tool for Teaching Jossey Bass Inc, 1993

22- Bernard Rosner, Fundamentals of Biostatistics, Brooks/Cole, USA, 2000.

23- Birgitta Giertz , The Quality Concept in Higher Education , 2000 ON line: www.bl webit/esoe/tgmhez/23. PDF.

24- Bruce Narramor and Bill Counts, Freedom From Guilt , California, Harvest House Publisher, 1974.

25- Camile B. Wortman; Elizabeth F. Loftus, Psychology, New York , Alfred A. Knopf, 1988

26- Cheryl L. Spaulding, Motivation in the classroom, USA, Mc Graw-Hill, inc, 1992.

27- Collins. Australian School Dictionary, Harper Collins Publisher, 1992.

28- Constantine Sedikides. Marilynn B. Brewer, Individual Self, Relational Self , Collective Self, USA, UK Taylor and Francis Group, 2001.

29- Dennis Coon , Essentials of Psychology, Exploration and aplication, Soy Inc, 1994.

30- Donna M. Mertens, Research Methods in Education and Psychology : integrating diversity with quantitative and qualitative approaches , Sage Publications, USA ,1998.

31- David J. Kalupahana, A History of Buddhist Philosophy Continuities and Discontinuities , University of Hawaii Press, 1992.

32- Elchanan Cohn, Terry G. Geske, The Economics of Education, USA, Pergamon Press , 1990

33- Elizabeth Fiona King. To what extent does culture effect teacher education and practice in Cambodia. Thesis of Education , University of London, 2003.

34- Gayle Avery Ellen Baker, Psychology at Work , Australia , Prentice Hal pty Ltd, 1990

35- Heather M. Hoppe , The Effect of Self-esteem on Education , 1995, on line: http//www.mwsc. edu/psychology/research /psy302/fell95/hooppe. htm

36- James V. Mc Connell, Understand Human Behavior, CBS College Publishing, 1986.

37- Jane S. Halonen & John W. Santrock, Psychology Contexts of Behavior, USA, Brown & Benchmark, 1996.

38- Jess Feist, Theories of Personality, Holt , Rinehart & Winston Inc, 1990.

39- John B. Miner, Industrial Organizational Psychology , New York , Mc. Graw-Hill, 1992.

40- John F. Longres, Human Behavior in the Social Environment, Illinois, F. E Peacock Publisher Inc. 1995.

41- John W. Santrock , Psychology, Brown & Benchmark, 1994.

42- Karalynn Bodnovich, The Relationship between Preschoolers academic Self-esteem and The quality of their Child Care Center, 2002, on line: http: www//etd.wvu. edu.

43- K. Fillip . J., Foundation of Education, Key Reading. Sydney, UTS, 1992.

44- Kirchner & Fishburne, Physical Education for Elementary School Child, USA, Brown & Benchmark , 1995.

45- Lilian G. Katz, Distinction Between Self-esteem and Narcissism: Implications for Practice , 1993, on line : http://ericeece. org/pubs/books/selfe.html.

46- L.R. Gay. Educational Research, Competencies for analysis and Application, Florida. USA. Macmillan Publishing, 1992

47- Maria Jose Lemaitre, The Role of Quality Assurance in Higher Education : A Global Perspective . Workshop on accreditation & Higher Education in Cambodia, the Ministry of Education, Youth and Sports by the World Bank, Cambodia 2002.

48- Matthew Mckay, Ph. D, Patrick Fanning , Self-esteem, United States of America, New Harbinger Publications, 2000.

49- Michael Todaro, Economic Development. England. 2000.

50- Miller, The Correlation between Sense of Humor and Mental Health, on line : http: clearinghouse mwsc.edu/manscripts/405.asp.

51- Patricia H. Miller, Theories of Developmental Psychology, W. H. Freeman & Lompany, 1993.

52- Patricia Kramer, Self-esteem Library, Discovering the Real You, New York, the Resen Publishing group Inc, 1991.

53- Raghda I. Saba, Introduction To Personality Theories, in Lecture, 1999.

54- Rama Bhutel Ph D, How To Write Theses. in seminar, 2003.

55- Richard A. Lippa, Introduction to Social Psychology, Wardsworth Publishing Comany Inc, 1990.

56- Rochelle L. James , The Correlation between Adolescent Self-Esteem, Religiosity and perceive family support , on line : http:/// clearinghouse.mwse.edu /manuscripts /147.asp.

57- Rotplotnik , Introduction to Psychology, California, Wardsord, inc, 1990.

58- Sheldon P. Gordon, Florence S. Gordon, Contemporary Statistics, A Computer Approach, 1994, Mc Graw. Hill, inc, USA

59- Thomask Crowl, Sally Kaminsky, David M. Podell, Educational Psychology Window on Teaching , USA, Brown and Benchmark, 1997.

60- Thomas L. Good ; Jere E. Brophy, Educational Psychology, A Realistic Approach, Holt , Rinerhart & Winston, 1977.

61- Torsten Husen, T. Neville Postlethwait, The International Encyclopedia of Education, Great Britian, Pergamn, 1994.

62- Unicef : Self-Awareness, 2004.

63- Wade & Tavris, Psychology. Harper & Row Publish, Inc, 1990.

64- Zimbado, Psychology & Life. Scott Forman & Company, 1985.

65- Profile : The Relationship Between Gender and Self-esteem with body Image, on line: http://216.239.57.104/Search? q-cache. GTI 24 a I6 DM5: www.

66- Profile: http:www.wetheliving.com/pipermail/psychology/2003-april/000356.html.

67- Profile: http//rcgd.isr.umich.edu./stigma/theory.htm.

68- Profile: Self-Esteem Test, : http:www.queendom.com/cgi-bin/tests/ transfer.cgi

69- Profile: Self-esteem and the information age : http://joi.ito.com/archives /1999 /02/ 28 /self_ esteem_and _the_information_ age.html

70- Profile: http://www.calstatela.edu/faculty/jshindl/cm/self-esteem.htm.

71- Profile : Root of Self-Esteem: www. rice-lewislinic.com/articles/root.html.

72- Profile : Promote Self-Esteem : www.askdrsears.com/html/6/T061500.asp

73- Profile : Solve your Problem : http: www. solve your problem. com/artman/publish/ article-195shtml.

# ឧបសម្ព័ន្ធទី១
## កម្រងសំណួរស្រាវជ្រាវ

ខ្ញុំបាទឈ្មោះ សន ចាន់ថៃ និស្សិតបរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រអប់រំ ជំនាន់ទី៣ នៅរាជបណ្ឌិតសភាកម្ពុជា បានធ្វើការសិក្សាស្រាវជ្រាវស្តីពី "ការអោយតំលៃខ្លួនឯង និងគុណភាពសិក្សារបស់និស្សិតកំរិតឧត្តមផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យានៅវិទ្យាស្ថានជាតិអប់រំ" ។ ខ្ញុំបាទចង់ដឹងពីមតិ យោបល់របស់លោកអ្នកដោយផ្ទាល់ ដើម្បីយកមកចងក្រង និងធ្វើការវិភាគសំរាប់ការសិក្សាស្រាវជ្រាវនេះ ។ មតិយោបល់ និងព័ត៌មានពិតប្រាកដរបស់លោកអ្នកមានសរៈសំខាន់ខ្លាំងណាស់នៅក្នុងការស្រាវជ្រាវនេះ ។ សូមលោកអ្នកឆ្លើយដោយសេរីចំពោះសំណួរដែលអ្នកគិតថាត្រឹមត្រូវ និងទៅតាមទឹកចិត្តពិតប្រាកដរបស់លោកអ្នក ដោយព័ត៌មានទាំងអស់ត្រូវបានរក្សាការសំងាត់ ។ សូមថ្លែងអំណរគុណទុកជាមុនចំពោះការឆ្លៀតពេលវេលាដ៏មានតំលៃក្នុងកិច្ចសហប្រតិបត្តិការបំពេញកម្រងសំណួរនេះ ។

**ផ្នែកទី១ ៖ ការវាស់វែងការអោយតំលៃខ្លួនឯង** (Self-Esteem Test)

I- សូមគូសចំលើយទៅតាមកម្រិតណាមួយដែលអ្នកគិតថាសមស្របចំពោះការគិតទៅដល់ចិត្តឬខ្លួនរបស់អ្នកដែលមានឬធ្លាប់មានបណ្តាមតិដូចខាងក្រោម ៖ ជ្រើសរើសលេខ ១-មិនឯកភាពទាំងស្រុង ២- មិនឯកភាព ៣- ឯកភាពតិចតួច ៤- ឯកភាពច្រើន និង ៥- ឯកភាពទាំងស្រុង ។

| | | | | | | |
|---|---|---|---|---|---|---|
| ១ | មនុស្សភាគច្រើននៅជុំវិញខ្លួនខ្ញុំរីកចំរើនជាងខ្ញុំ | ១ | ២ | ៣ | ៤ | ៥ |
| ២ | មនុស្សទាំងឡាយតែងគោរព និងចូលចិត្តអោយតំលៃលើអ្វីដែលមានរូបរាងល្អ ឆ្លាតវាងវៃ មានទេពកោសល្យ ឬមានទ្រព្យធនច្រើន | ១ | ២ | ៣ | ៤ | ៥ |
| ៣ | ជោគជ័យមិនមែនជាកត្តាចាំបាច់ទេ។ កត្តាសំខាន់សំរាប់ខ្ញុំគឺការព្យាយាមសាកល្បង និងធ្វើទៅតាមអ្វីដែលខ្ញុំអាចធ្វើបាន | ១ | ២ | ៣ | ៤ | ៥ |
| ៤ | ខ្លួនខ្ញុំសក្តិសមនឹងទទួលបានសេចក្តីស្រលាញ់ និងការគោរព | ១ | ២ | ៣ | ៤ | ៥ |
| ៥ | នៅពេលដែលខ្ញុំដឹងថាខ្លួនខ្ញុំខុសពីគេ ខ្ញុំក៏បោះបង់ចោលអត្តចរិកដែលខ្ញុំមាន ដើម្បីសំរបសំរួលតាមមិត្តភ័ក្រ្ត | ១ | ២ | ៣ | ៤ | ៥ |
| ៦ | ប្រសិនបើមាននរណាម្នាក់ស្រលាញ់ខ្ញុំ ខ្ញុំរឹតតែប្រព្រឹត្តអោយបានល្អថែម | ១ | ២ | ៣ | ៤ | ៥ |

| | | | | | | |
|---|---|---|---|---|---|---|
| | ទៀត ព្រោះថារឿងបែបនេះកម្រមានណាស់សំរាប់ខ្លួនខ្ញុំ | | | | | |
| ៧ | ប្រកាន់កាយវិការដូចសព្វថ្ងៃដែលខ្ញុំមាន ពិតជាមិត្តដទៃមិនចូលចិត្តខ្ញុំទេ | ១ | ២ | ៣ | ៤ | ៥ |
| ៨ | បើខ្ញុំស្លាប់លាចាកលោកនេះទៅ នោះគ្មាននរណាម្នាក់ចាប់អារម្មណ៍សោកស្តាយខ្ញុំទេ | ១ | ២ | ៣ | ៤ | ៥ |
| ៩ | ការខុសឆ្គងមួយផ្នែក វាមានអត្ថន័យដូចជាខុសឆ្គងទាំងស្រុងដែរ | ១ | ២ | ៣ | ៤ | ៥ |
| ១០ | នៅក្នុងគ្រាអាសន្ន ទើបខ្ញុំដឹងថាអ្នកណាខ្លះដែលគិតគូដល់ខ្លួនខ្ញុំ តាមរយៈជំនួយការរបស់គេ | ១ | ២ | ៣ | ៤ | ៥ |
| ១១ | ប្រសិនបើខ្ញុំធ្វើអ្វីមួយមិនបានល្អ ដូច្នេះមិនចាំបាច់ធ្វើអ្វីទៀតទេ | ១ | ២ | ៣ | ៤ | ៥ |
| ១២ | ខ្លួនខ្ញុំមិនមានអ្វីដែលមានអត្ថន័យទេ | ១ | ២ | ៣ | ៤ | ៥ |
| ១៣ | ខ្ញុំមិនត្រូវការលើកទឹកចិត្តពីអ្នកដទៃ ដើម្បីអោយខ្ញុំពេញចិត្តនឹងខ្លួនខ្ញុំទេ | ១ | ២ | ៣ | ៤ | ៥ |
| ១៤ | ខ្ញុំត្រូវការចូលចុះទៅក្នុងសង្គម | ១ | ២ | ៣ | ៤ | ៥ |
| ១៥ | ខ្ញុំគិតថា ខ្ញុំជាមនុស្សបរាជ័យ | ១ | ២ | ៣ | ៤ | ៥ |
| ១៦ | អ្នកដែលជំទាស់ប្រឆាំងនឹងខ្ញុំជាមនុស្សគួរអោយស្រលាញ់ និងគោរពខ្ញុំ | ១ | ២ | ៣ | ៤ | ៥ |
| ១៧ | តាមរយៈធ្វើជាមិនដឹងមិនឮ នោះបញ្ហាទាំងឡាយវានឹងរលាយបាត់ដោយឯកឯង | ១ | ២ | ៣ | ៤ | ៥ |

II- សូមអ្នកគិតទៅដល់ចិត្ត ឬខ្លួនរបស់អ្នកដែលមាន ឬធ្លាប់មានបណ្តាមតិដូចខាងក្រោម :

១- ស្ទើរតែមិនដែលសោះ ២- កម្រណាស់ ៣- មានពេលខ្លះដែរ

៤- ញឹកញាប់ ឬញយដង ៥- ស្ទើរតែគ្រប់ពេល

| | | | | | | |
|---|---|---|---|---|---|---|
| ១ | នៅក្នុងអង្គប្រជុំ ឬចំណោមមនុស្ស ខ្ញុំមានរឿងសំខាន់យកមកនិយាយ | ១ | ២ | ៣ | ៤ | ៥ |
| ២ | នៅក្នុងអង្គប្រជុំចំណោមមនុស្ស ខ្ញុំមានមតិសំខាន់យកមកនិយាយ | ១ | ២ | ៣ | ៤ | ៥ |
| ៣ | ខ្ញុំពេញចិត្តនឹងខ្លួនខ្ញុំ នឹងព្រមទទួលរបៀបដែលខ្លួនខ្ញុំប្រព្រឹត្ត | ១ | ២ | ៣ | ៤ | ៥ |
| ៤ | ខ្ញុំធ្វើអោយរាយមាយអ្វីដែលខ្ញុំប្រើប្រាស់ | ១ | ២ | ៣ | ៤ | ៥ |
| ៥ | ពេលដែលខ្ញុំឃើញឱកាសល្អ ខ្ញុំនឹងដណ្តើមយកស្នាដៃ | ១ | ២ | ៣ | ៤ | ៥ |
| ៦ | ខ្ញុំអាចធ្វើការបានល្អ លុះត្រាតែមានអ្នកដទៃចង្អុលបញ្ហា | ១ | ២ | ៣ | ៤ | ៥ |
| ៧ | ខ្ញុំមានអារម្មណ៍ខ្មាចមិត្តភ័ក្រ្តគេឈប់រាប់រកខ្ញុំ | ១ | ២ | ៣ | ៤ | ៥ |

| | | | | | | |
|---|---|---|---|---|---|---|
| ៨ | ប្រសិនបើខ្ញុំធ្វើមិនបានល្អដូចអ្នកដទៃ មានន័យថា ខ្ញុំជាមនុស្សអន់ថយ | ១ | ២ | ៣ | ៤ | ៥ |
| ៩ | ខ្ញុំមានអារម្មណ៍ថា ខ្ញុំអាចមានការប្រព្រឹត្តខុសឆ្គង តែមិនមានការបាត់បង់សេចក្តីស្រលាញ់គោរពរាប់អានពីអ្នកដទៃឡើយ | ១ | ២ | ៣ | ៤ | ៥ |
| ១០ | ខ្ញុំបានធ្វើអោយស្រងាកចិត្តដល់អ្នកដែលបានយកចិត្តទុកដាក់សំរាប់ខ្ញុំ | ១ | ២ | ៣ | ៤ | ៥ |
| ១១ | អ្នកផងទាំងឡាយចាត់ទុកថា ខ្លួនខ្ញុំជាមនុស្សសំខាន់គួរជាទីចាប់អារម្មណ៍ និងជាទីស្រលាញ់ | ១ | ២ | ៣ | ៤ | ៥ |
| ១២ | ខ្ញុំមានអារម្មណ៍ថា មតិរបស់ខ្ញុំសំខាន់ជាងមតិរបស់អ្នកដទៃ | ១ | ២ | ៣ | ៤ | ៥ |
| ១៣ | សមត្ថភាពខ្ញុំមិនសក្តិសមនឹងខ្លួនខ្ញុំទេ | ១ | ២ | ៣ | ៤ | ៥ |

## ផ្នែកទី២ : សមត្ថភាពវិជ្ជាសាស្ត្រ និង ការពេញចិត្តនឹងការសិក្សា

III - កំរិតសមត្ថភាពដែលអ្នកទទួលបានថ្មី នៅពេលដែលបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ ?

| | ទទួលបានច្រើនណាស់ | ទទួលបានច្រើន | ទទួលបានមធ្យម | មិនសូវបានទទួល | មិនទទួលបានសោះ |
|---|---|---|---|---|---|
| ១- សមត្ថភាពឯកទេសវិទ្យាសាស្ត្រ | ☐ | ☐ | ☐ | ☐ | ☐ |
| ២- ការផលិតសម្ភារៈឧបទេស | ☐ | ☐ | ☐ | ☐ | ☐ |
| ៣- វិធីសាស្ត្របង្រៀនមុខវិជ្ជាឯកទេស | ☐ | ☐ | ☐ | ☐ | ☐ |
| ៤- សីលធម៌វិជ្ជាជីវៈ | ☐ | ☐ | ☐ | ☐ | ☐ |
| ៥- ជំនាញផ្នែករដ្ឋបាលសិក្សា | ☐ | ☐ | ☐ | ☐ | ☐ |
| ៦- ជំនាញធ្វើកិច្ចតែងការបង្រៀន | ☐ | ☐ | ☐ | ☐ | ☐ |
| ៧- ជំនាញប្រលង | ☐ | ☐ | ☐ | ☐ | ☐ |
| ៨- ជំនាញតាក់តែងសំណួរវាយតំលៃសិស្ស | ☐ | ☐ | ☐ | ☐ | ☐ |
| ៩- ជំនាញស្រាវជ្រាវវិទ្យាសាស្ត្រ | ☐ | ☐ | ☐ | ☐ | ☐ |
| ១០- ជំនាញបង្រៀនពិសោធន៍ក្នុងថ្នាក់រៀន | ☐ | ☐ | ☐ | ☐ | ☐ |

១១- ជំនាញបង្រៀនពិសោធន៍ក្នុងមន្ទីរពិសោធន៍ ☐ ☐ ☐ ☐ ☐
១២- ជំនាញប្រើប្រាស់កុំព្យូទ័រ ☐ ☐ ☐ ☐ ☐
១៣- បណ្ដាមតិផ្សេងទៀត ☐ ☐ ☐ ☐ ☐

## ផ្នែកទី៣ : ការពេញចិត្តនឹងការសិក្សា

IV - តើអ្នកពេញចិត្តនឹងសមត្ថភាពខ្លួនកំរិតណា បន្ទាប់ពីការបណ្ដុះបណ្ដាលមួយឆ្នាំកន្លងមកនេះ ?

| ល.រ | សមត្ថភាពការយល់ដឹង | ពេញចិត្តណាស់ | ពេញចិត្តបង្គួរ | ពេញចិត្តមធ្យម | ពេញចិត្តតិចតួច | មិនពេញចិត្ត |
|---|---|---|---|---|---|---|
| ១ | សមត្ថភាពឯកទេស | | | | | |
| ២ | សមត្ថភាពការផលិតសម្ភារៈឧបទេស | | | | | |
| ៣ | សមត្ថភាពវិធីសាស្ត្របង្រៀន | | | | | |
| ៤ | ការយល់ដឹងអំពីសីលធម៌វិជ្ជាជីវៈ | | | | | |
| ៥ | ការយល់ដឹងផ្នែករដ្ឋបាលសិក្សា | | | | | |
| ៦ | សមត្ថភាពខាងកិច្ចតែងការបង្រៀន | | | | | |
| ៧ | ជំនាញខាងធ្វើជាមេប្រយោគការប្រលង | | | | | |
| ៨ | ជំនាញតាក់តែងសំណួរវាយតំលៃសិស្ស | | | | | |
| ៩ | ជំនាញស្រាវជ្រាវវិទ្យាសាស្ត្រ | | | | | |
| ១០ | ជំនាញបង្រៀនវិទ្យាសាស្ត្រ ឬគណិតវិទ្យាក្នុងថ្នាក់រៀន | | | | | |
| ១១ | ជំនាញបង្រៀនពិសោធន៍ក្នុងមន្ទីរពិសោធ | | | | | |
| ១២ | ជំនាញប្រើប្រាស់កុំព្យូទ័រ | | | | | |
| ១៣ | ជំនាញប្រើប្រាស់បណ្ណាល័យ | | | | | |
| ១៤ | បណ្ដាមតិផ្សេងទៀត | | | | | |

V - តើអ្នកពេញចិត្តចង់ធ្វើជាគ្រូបង្រៀនវិទ្យាសាស្ត្រ ឬគណិតវិទ្យាកីឡាណា ?

☐ -ពេញចិត្តខ្លាំង ☐ -ពេញចិត្តបង្គួរ ☐ -ពេញចិត្តមធ្យម ☐ -ពេញចិត្តតិចតួច ☐ -មិនពេញចិត្ត

VI- តើអ្នកមានសំណូមពរអ្វីខ្លះ ?

............................................................................................................................................

............................................................................................................................................

............................................................................................................................................

..........................................................................................................................................។

៥-តើបណ្តាចំណុចណាខ្លះដែលជាមោទនភាពរបស់អ្នកក្នុងនាមជាគរុនិស្សិតកីឡាឧត្តមនៅវិទ្យាស្ថានជាតិអប់រំ?

............................................................................................................................................

............................................................................................................................................

............................................................................................................................................

..........................................................................................................................................។

## ផ្នែកទី ៤ : ព័ត៌មានផ្ទាល់ខ្លួន

ឈ្មោះ :........................................................................ ភេទ: .................. អាយុ : ..................

មុខវិជ្ជាឯកទេស: .....................................................

កន្លែងស្នាក់នៅសព្វថ្ងៃ : ..........................................................................................................

កន្លែងស្នាក់នៅរបស់ឪពុកម្តាយ: ...........................................................................................

មុខរបរឪពុកម្តាយ : ...................................................................................................................

**សូមអរគុណ !**

## ឧបសម្ព័ន្ធទី២

## សំណួរសំរាប់បទសម្ភាសន៍ជាមួយគរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំ

**I- ការអោយតំលៃខ្លួនឯង និងកត្តាអប់រំក្នុងគ្រួសារ**

១- តើឪពុកម្តាយរបស់អ្នកផ្តល់ការអប់រំដល់រូបអ្នកក្នុងលក្ខណៈបែបណា ?

២- តើឪពុកម្តាយរបស់អ្នកមានការស្តាប់ហេតុផលរបស់អ្នកដែរឬទេ ?

៣- តើឪពុកម្តាយរបស់អ្នកមានការលើកទឹកចិត្ត និងសសើររូបអ្នកញឹកញាប់ដែរឬទេ ?

៤- តើឪពុកម្តាយរបស់អ្នកផ្តល់នូវសេចក្តី និងអោយតំលៃអ្នកដែរឬទេ ?

៥- តើអ្នកពេញចិត្តទៅនឹងវិធីអប់រំរបស់ឪពុកម្តាយរបស់អ្នកដែរឬទេ ហើយវិធីបែបណាដែលអ្នកពេញចិត្ត ឬមិនពេញចិត្តនោះ ? តើមូលហេតុអ្វី ?

**II- ការអោយតំលៃខ្លួនឯង និងកត្តាអប់រំនៅសាលារៀន**

៦- តើហេតុអ្វីបានជារូបអ្នកជ្រើសរើសមុខវិជ្ជានេះជាឯកទេសទីមួយរបស់អ្នក ?

៧- តើអ្នកមានជំនឿជឿជាក់លើសមត្ថភាពរបស់ខ្លួនអ្នកក្នុងការបង្រៀនអោយបានល្អដែរឬទេ ?

៨- តើការបង្ហាញពីស្នាដៃរបស់អ្នកជួយអោយអ្នកសង្ឃឹមថានឹងទទួលបានលេខល្អដែរឬទេ ? ហេតុអ្វី ?

៩- តើខ្លួនអ្នកសក្តិសមនឹងបានការទទួលសេចក្តីស្រលាញ់ និងការគោរពពីអ្នកដទៃដែរឬទេ ?

១០- ក្នុងចំណោមនិស្សិតដែលរៀនជាមួយរូបអ្នក តើអ្នកគិតថាអ្នកជានិស្សិតមានកម្រិតសមត្ថភាពកម្រិតណា ?

១១- តើសម្ភារៈឧបទេសដែលសាលាបានផ្តល់ជូនក្នុងការសិក្សាជួយអោយអ្នកពេញចិត្តក្នុងកម្រិតណា ?

១២- តើអ្នកយល់ថា សាលាបានធ្វើការវាយតំលៃលើលទ្ធផលសិក្សារបស់អ្នកបានត្រឹមត្រូវដែរឬទេ ? ហេតុអ្វី?

១៣- តើអ្នកគិតថា គ្រូរបស់អ្នកចូលចិត្ត និងស្រលាញ់រូបអ្នកដែរឬទេ ? មូលហេតុអ្វី ?

១៤- ប្រសិនបើអ្នកធ្វើអ្វីមួយមិនបានល្អ មិនបានជោគជ័យ តើអ្នកគិតថាពុំចាំបាច់ធ្វើវាបន្តទៀតទេ ?

១៥- ប្រសិនបើការបង្ហាញស្នាដៃលទ្ធផលសិក្សាមិនបានល្អ តើអ្នកគិតថានឹងខិតខំផលិតសម្ភារៈឧបទេស ដើម្បីយកមកប្រកួតប្រជែងនៅពេលក្រោយទៀតដែរឬទេ ? ហេតុអ្វី ?

១៦- តើអ្នកធ្វើការពិសោធនេះមានគិតទុកជាមុនចំពោះហេតុផលមិនល្អកើតមានឡើងដែរឬទេ ?

១៧- តើអ្នកមានសាកសួរមតិយោបល់របស់អ្នកផ្សេងទៀតនៅក្នុងក្រុម ក្នុងការផលិតសម្ភារៈចូលរួមដែរ ឬទេ ?

១៨- តើមូលហេតុអ្វីដែលនាំអោយរូបអ្នកខិតខំសិក្សានេះ ? តើ គ្រូ សាលារៀន គ្រួសារ គោលបំណងជីវិតរបស់ខ្លួន ឬមជ្ឈដ្ឋានសង្គមដែលនាំអោយអ្នកខិតខំសិក្សា ?

២០- តើអ្នកមានមិតិផ្សេងទៀតចង់ប្រាប់បន្ថែមទៀតទេ ?

ឈ្មោះ :........................................................ ភេទ : ..........................មុខវិជ្ជា:.....................................

ស្រុកកំណើត :.................................មុខរបរឳពុកម្ដាយ:........................កម្រិតវប្បធម៌ឳពុកម្ដាយ: ..........។

## ឧបសម្ព័ន្ធទី៣

### រូបភាពនៃការបង្ហាញស្នាដៃវិទ្យាសាស្ត្ររបស់គរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំ




ការបង្ហាញស្នាដៃរបស់គរុនិស្សិតផ្នែកវិទ្យាសាស្ត្រនិងគណិតវិទ្យា (វិទ្យាស្ថានជាតិអប់រំ ឆ្នាំ ២០០៤)




ការបង្ហាញស្នាដៃរបស់គរុនិស្សិតផ្នែកវិទ្យាសាស្ត្រនិងគណិតវិទ្យា (វិទ្យាស្ថានជាតិអប់រំ ឆ្នាំ ២០០៤)



ការបង្ហាញស្នាដៃរបស់គរុនិស្សិតផ្នែកវិទ្យាសាស្ត្រនិងគណិតវិទ្យា (វិទ្យាស្ថានជាតិអប់រំ ឆ្នាំ ២០០៤)



ការបង្ហាញស្នាដៃរបស់គរុនិស្សិតផ្នែកវិទ្យាសាស្ត្រនិងគណិតវិទ្យា (វិទ្យាស្ថានជាតិអប់រំ ឆ្នាំ ២០០៤)



ការបង្ហាញស្នាដៃរបស់គរុនិស្សិតផ្នែកវិទ្យាសាស្ត្រនិងគណិតវិទ្យា (វិទ្យាស្ថានជាតិអប់រំ ឆ្នាំ ២០០៤)




គរុនិស្សិតថ្មីមកទទួលរង្វាន់លើកទឹកចិត្តពីថ្នាក់ដឹកនាំរបស់វិទ្យាស្ថានជាតិអប់រំ



រូបភាពតំណាងអោយបញ្ញត្តិការអោយតំលៃខ្លួន ( ដកស្រង់ពីសៀវភៅលោក R

ព្រះរាជាណាចក្រ
បណ្ណាល័យ
លេខ.054.07..
រាជបណ្ឌិតសភាកម្ពុជា



រូបភាពតំណាងអោយបញ្ញត្តិការអោយតំលៃខ្លួន ( ដកស្រង់ពី UNICEF 2004 )